ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការអភិវឌ្ឍន៍

## រយៈពេលប្រាំឆ្នាំ(២០១១-២០១៥)

## ខេត្តព្រះវិហារ



ខែ ឧសភា ឆ្នាំ ២០១១

# មាតិកាអត្ថបទ


មាតិកាអត្ថបទ........ I

សេចក្តីសម្រេចស្តីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ខេត្ត........ IV

អារម្ភកថា........ VI

សេចក្តីផ្តើម........ ១

ផែនទីខេត្ត........ ២

**ជំពូកទី១: ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច** ........ ៣

**១.១ សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច** ........ ៣

**១.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម**........ ៨

**១.២.១ ស្ថានភាពសេដ្ឋកិច្ច** ........ ៩

១.២.១.១ វិស័យកសិកម្ម ........ ៩

១.២.១.២ វិស័យជលផល ........ ១៤

១.២.១.៣ វិស័យធនធានទឹក និងឧតុនិយម ........ ១៥

១.២.១.៤ វិស័យទេសចរណ៍ ........ ១៦

១.២.១.៥ វិស័យសាធារណៈការ និងដឹកជញ្ជូន ........ ១៧

១.២.១.៦ វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ ........ ១៨

១.២.១.៧ វិស័យពាណិជ្ជកម្ម ........ ២០

១.២.១.៨ វិស័យឧស្សាហកម្មរ៉ែ និងថាមពល ........ ២១

១.២.១.៩ វិស័យអភិវឌ្ឍន៍ជនបទ ........ ២១

**១.២.២ ស្ថានភាពសង្គមកិច្ច** ........ ២២

១.២.២.១ វិស័យអប់រំយុវជន និងកីឡា ........ ២២

១.២.២.២ វិស័យសុខាភិបាល ........ ២៤

១.២.២.៣ វិស័យវប្បធម៌ និងសិល្បៈ........ ២៥

១.២.២.៤ វិស័យព័ត៌មាន ........ ២៦

១.២.២.៥ វិស័យយេនឌ័រ ........ ២៧

**១.២.៣ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន** ........ ២៩

១.២.៣.១ វិស័យគ្រប់គ្រងដីធ្លី សុរិយោដី ........ ២៩

១.២.៣.២ វិស័យបរិស្ថាន គ្រប់គ្រងធនធានធម្មជាតិ ........ ៣០

១.២.៣.៣ ការបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ........ ៣១

**១.២.៤ ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ** ........ ៣១

**១.២.៥ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**........ ៣២

**ជំពូក២: ក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត** ........ ៣៣
**២.១ ចក្ខុវិស័យអភិវឌ្ឍន៍** ........ ៣៣
**២.២ គោលដៅអភិវឌ្ឍន៍** ........ ៣៣
**២.៣ គោលបំណងអភិវឌ្ឍន៍** ........ ៣៣
តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ប្រាំឆ្នាំខេត្ត(២០១១-២០១៥) ........ ៣៤
**២.៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍** ........ ៩៣
**២.៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ច** ........ ៩៣
២.៤.១.១. កសិកម្ម ........ ៩៣
២.៤.១.២.ជលផល ........ ៩៤
២.៤.១.៣ ធនធានទឹក និងឧតុនិយម ........ ៩៤
២.៤.១.៤ ទេសចរណ៍ ........ ៩៥
២.៤.១.៥ ឧស្សាហកម្ម ........ ៩៦
២.៤.១.៦ សាធារណការ និងដឹកជញ្ជូន ........ ៩៧
២.៤.១.៧ ប្រៃសណីយ៍ និងទូរគមនាគមន៍ ........ ៩៧
២.៤.១.៨ ពាណិជ្ជកម្ម ........ ៩៨
២.៤.១.៩ អភិវឌ្ឍន៍ជនបទ ........ ៩៨
២.៤.១.១០ បរិស្ថាន ........ ៩៩
២.៤.១.១១ សាលាខេត្ត ........ ១០០
**២.៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច** ........ ១០១
២.៤.២.១ អប់រំយុវជន និងកីឡា ........ ១០១
២.៤.២.២ សុខាភិបាល ........ ១០១
២.៤.២.៣ កិច្ចការនារី ........ ១០១
២.៤.២.៤ វប្បធម៌ និងវិចិត្រសិល្បៈ ........ ១០២
២.៤.២.៥ ព័ត៌មាន ........ ១០៣
២.៤.២.៦ សង្គមកិច្ច និងយុវនិតិសម្បទា ........ ១០៣
២.៤.២.៧ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ........ ១០៣
២.៤.២.៨ ធម្មការ និងសាសនា ........ ១០៤
២.៤.២.៩ ក្រុមការងារផែនការ សកម្មភាពកំចាត់មីន ........ ១០៤
២.៤.២.១០ សាលាខេត្ត ........ ១០៤
**២.៤.៣ យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន** ........ ១០៤
**២.៤.៤ យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ** ........ ១០៥
២.៤.៤.១ ការគ្រប់គ្រង និងបង្ការគ្រោះមហន្តរាយ ........ ១០៥

២.៤.៤.១.១ ការងារគ្រប់គ្រងលើគ្រោះធម្មជាតិលើវិស័យកសិកម្ម ........................................ ១០៥

២.៤.៤.១.២ ការត្រៀមលក្ខណៈបង្ការគ្រោះធម្មជាតិដោយគ្រោះរាំងស្ងួត និងទឹកជំនន់ក្នុងវិស័យធនធានទឹក ........................................ ១០៦

២.៤.៤.១.៣ ការងារគ្រប់គ្រង និងត្រៀមបង្ការគ្រោះទឹកជំនន់ក្នុងវិស័យសុខាភិបាល ........................ ១០៦

២.៤.៤.១.៤ ការគ្រប់គ្រង និងត្រៀមបង្ការគ្រោះធម្មជាតិ ក្នុងវិស័យអភិវឌ្ឍន៍ជនបទ ........................ ១០៦

២.៤.៤.២ ការសម្របសម្រួលការប្រែប្រួលអាកាសធាតុ ........................................ ១០៦

**២.៤.៥ យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**........................ ១០៧

២.៤.៥.១ រដ្ឋបាលទូទៅ ........................................ ១០៧

២.៤.៥.១.១ រដ្ឋបាលខេត្ត ........................................ ១០៧

២.៤.៥.២ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ........................................ ១០៨

២.៤.៥.២.១ សន្តិសុខទូទៅ ........................................ ១០៨

២.៤.៥.២.២ ទំនាក់ទំនងសភា និងអធិការកិច្ច........................................ ១០៨

២.៤.៥.២.៣ កិច្ចការនារី ........................................ ១០៨

**២.៥ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម** ........................................ ១០៨

**ជំពូកទី៣: ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការអភិវឌ្ឍន៍**........................ ១០៩

៣.១ សូចនាករសំខាន់ៗសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តន៍ផែនការ........................ ១០៩

៣.២ វិធីសាស្ត្រតាមដាន និងវាយតម្លៃការអនុវត្តន៍ផែនការ........................................ ១០៩

៣.៣ ពេលវេលាសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការ ........................ ១១០

៣.៤ ប្រពន្ធ័រៀបចំរបាយការណ៍ ........................................ ១១០

តារាងក្របខ័ណ្ឌត្រួតពិនិត្យ តាមដាន........................................ ១១១

**ឧបសម្ព័ន្ធ :**........................................ ១៤៥

១-អនុក្រឹត្យស្តីពីផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ........................ ១៤៦

២-ប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ១៥៥

៣-សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តព្រះវិហារ..... ១៦៥

៤-សេចក្តីសម្រេចស្តីពីការទទួលស្គាល់ប្រធាន អនុប្រធាន និង សមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាខេត្តព្រះវិហារ........................................ ១៧០

៥-សេចក្តីសម្រេចស្តីពីការទទួលស្គាល់ប្រធាន អនុប្រធាន និង សមាជិកគណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ ក្រុមប្រឹក្សាខេត្តព្រះវិហារ........................................ ១៧៤

៦-ប្រតិទិនការងារកសាងផែនការអភិវឌ្ឍន៍ខេត្តប្រាំឆ្នាំ ........................................ ១៧៨

៧-សេចក្តីសម្រេចស្តីពីគោលការណ៍ណែនាំផ្ទៃកគោលនយោបាយសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ........................................ ១៨២

៨-លទ្ធផលវិភាគសំខាន់ៗនៃស្ថានភាពខេត្ត( តារាង២.១៣ និង២.១៤)........................................ ១៩០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រះវិហារ**

លេខ : ០១២.សសរ/១១

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ(២០១១_២០១៥)

## ខេត្តព្រះវិហារ

## ប្រធានក្រុមប្រឹក្សាខេត្ត

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៩/៧៥២ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៩ ស្តីពីការតែងតាំងជាអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៤ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីការទទួលស្គាល់ សមាសភាពក្រុមប្រឹក្សាខេត្តព្រះវិហារអាណត្តិទី ១ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី ២០ខែធ្នូឆ្នាំ១៩៩៣ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងារ របស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក ។
- យោងតាមប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យ ចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាក្រុង ការបង្កើតការិយាល័យចំណុះទីចាត់ការ នៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ។
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បកចុះថ្ងៃទី១៤ខែធ្នូឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្តក្រុងស្រុកខណ្ឌ។
- យោងអនុក្រឹត្យលេខ១៥២អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យស្តីពីការ កសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្តក្រុងស្រុក ខណ្ឌ។
- យោងប្រកាសអន្តរក្រសួងលេខ២៨១៧ប្រក ចុះថ្ងៃទី[illegible] ខែ[illegible] ឆ្នាំ២០១០ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធី វិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- យោងតាមស្មារតីនៃកិច្ចប្រជុំសាមញ្ញលើកទី២៥ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី១ នាថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១១។

- យោង លិខិតលេខ ៧៩៩/១១ សជណ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ ស្តីពីការផ្តល់អនុលោមភាពលើសេចក្តីព្រាងផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ របស់ក្រសួងមហាផ្ទៃ។

# សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវផែនការអភិវឌ្ឍន៍សម្រាប់ឆ្នាំ២០១១-២០១៥ របស់ខេត្តព្រះវិហារ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាខេត្តព្រះវិហារ នាកិច្ចប្រជុំលើកទី២៥ នាថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១១។

**ប្រការ ២.-**

គណៈអភិបាលខេត្តព្រះវិហារ ត្រូវចាត់ចែងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍នេះដល់ប្រជាពលរដ្ឋនិងអ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្តព្រះវិហារ។

គណៈអភិបាលខេត្តព្រះវិហារ ត្រូវចាត់ចែង សម្របសម្រួល និងកៀរគរធនធាននានាក្នុងការអនុវត្តផែនការអភិវឌ្ឍន៍នេះ ប្រកបដោយការចូលរួម តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់។

**ប្រការ ៣.-**

គណៈអភិបាលខេត្ត ត្រូវរៀបចំយន្តការ និងប្រព័ន្ធសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការអភិវឌ្ឍន៍នេះ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនានា ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តផែនការ។

គណៈអភិបាលខេត្ត ត្រូវរៀបចំរបាយណ៍ស្តីពីលទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការអភិវឌ្ឍន៍នេះ និងរាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាខេត្ត អំពីវឌ្ឍនភាពនៃការអនុវត្តផែនការនេះទៅតាមកាលកំណត់។

គណៈអភិបាលខេត្ត ត្រូវរៀបចំ និងដាក់ជូនក្រុមប្រឹក្សាខេត្ត អំពីរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍នេះ។

**ប្រការ ៤.-**

គណៈអភិបាលខេត្ត ត្រូវធ្វើការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះ នៅពាក់កណ្តាលអាណត្តិ និងចុងអាណត្តិរបស់ក្រុមប្រឹក្សាខេត្ត ដើម្បីវាយតម្លៃអំពីលទ្ធផលសម្រេចបានធៀបនឹង គោលដៅ និងគោលបំណង ដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត។

**ប្រការ ៥.-**

គណៈអភិបាលខេត្ត នាយករដ្ឋបាល នាយកទីចាត់ការទាំង៥ចំណុះរចនាសម្ព័ន្ធសាលាខេត្ត លោក លោកស្រីប្រធានមន្ទីរអង្គភាពជុំវិញខេត្ត រដ្ឋបាលក្រុង ស្រុកក្នុងខេត្តព្រះវិហារ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ព្រះវិហារ, ថ្ងៃទី ០៦ ខែឧសភា ឆ្នាំ២០១១

ជ.ក្រុមប្រឹក្សាខេត្ត

ប្រធាន

ឡុង_សុវណ្ណ

<u>ចម្លងជូន :</u>

- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន គ.ជ.អ.ប
  "ដើម្បីជ្រាប"
- ដូចប្រការ៥
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# អារម្ភកថា

ក្រុមប្រឹក្សាខេត្តព្រះវិហារ រៀបចំផែនការអភិវឌ្ឍន៍ខេត្តប្រាំឆ្នាំ(២០១១-២០១៥)ដោយផ្តល់ឱកាសឱ្យមានការចូលរួមដោយផ្ទាល់ពីមន្ទីរអង្គភាព ក្រុង ស្រុក អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ខេត្ត។ ផែនការអភិវឌ្ឍន៍ខេត្តប្រាំឆ្នាំដែលបានបង្កើតឡើងផ្តល់នូវគោលការណ៍ណែនាំផ្នែកគោលនយោបាយ និងក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត ដើម្បីតម្រង់ទិសរដ្ឋបាលខេត្ត ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន និងលើកកម្ពស់គុណភាពសេវាសំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងខេត្ត។ ផែនការអភិវឌ្ឍន៍នេះប្រើប្រាស់ជាមូលដ្ឋានដ៏សំខាន់សម្រាប់ធ្វើការសម្រេចក្នុងការអភិវឌ្ឍន៍ខេត្ត និងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលក្របខ័ណ្ឌចំណាយរយៈពេលមធ្យម(បីឆ្នាំ) និងថវិកាប្រចាំឆ្នាំរបស់ខេត្ត។

ក្នុងនាមក្រុមប្រឹក្សាខេត្តព្រះវិហារអាណត្តិទី១ ខ្ញុំសូមថ្លែងអំណរគុណដល់គណៈអភិបាលខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារខេត្ត គណៈកម្មាធិការនានាក្រុមការងារកសាងផែការអភិវឌ្ឍន៍ខេត្តរបស់ក្រុមប្រឹក្សាខេត្ត មន្ទីរ អង្គភាព ក្រុង ស្រុក អង្គការសង្គមស៊ីវិលវិស័យឯកជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាក្នុងខេត្តដែលបានជួយគាំទ្រដឹកនាំ សម្របសម្រួល និងចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ខេត្ត។ ខ្ញុំសង្ឃឹមថា ផែនការអភិវឌ្ឍន៍នឹងក្លាយជាផែនការស្នូលសម្រាប់អនុវត្តន៍នាពេលអនាគតប្រកបដោយប្រសិទ្ធភាព។

ក្នុងនាមក្រុមប្រឹក្សាខេត្ត ខ្ញុំសូមអំពាវនាវដល់វិស័យឯកជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍និងសប្បុរសជននានា ជួយគាំទ្រគម្រោងសកម្មភាព ឬសេវាជាអាទិភាពនានា ដែលឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្តដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត។

ព្រះវិហារ ថ្ងៃទ០៦ ខែឧសភា ឆ្នាំ២០១១

ជ.ក្រុមប្រឹក្សាខេត្ត

ប្រធាន

ឡុង_សុវណ្ណ

# សេចក្តីផ្តើម

នៅខែឧសភា ឆ្នាំ២០០៩ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានធ្វើឡើងប្រកបដោយជោគជ័យ ក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ក្រុមប្រឹក្សាខេត្តរួមជាមួយគណៈអភិបាលខេត្ត បានអនុវត្តនូវតួនាទី ភារកិច្ចរបស់ខ្លួនដើម្បីអភិបាលកិច្ច និងអភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋានស្របតាមច្បាប់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងលិខិតបទដ្ឋានគតិយុត្តិនានា។

ក្រុមប្រឹក្សាខេត្តព្រះវិហារអាណត្តិទី១ បានរៀបចំផែនការអភិវឌ្ឍន៍ខេត្តសម្រាប់ឆ្នាំ២០១១-២០១៥ ដោយយោងមាត្រា៣៨ និងមាត្រា៣៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យលេខ ២១៩អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យលេខ១៥២អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា ១២នៃ អនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ផែនការអភិវឌ្ឍន៍ខេត្តព្រះវិហារ បានរៀបចំឡើងស្របតាមសេចក្តីណែនាំដោយមានការចូលរួម និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ក្រុមតំណាងផលប្រយោជន៍ ពិសេសក្រុមយុវជន ស្ត្រី និងកុមារ រដ្ឋបាលក្រុង ស្រុក មន្ទីរជំនាញជុំវិញខេត្ត ទីចាត់ការចំណុះសាលាខេត្ត អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់ខេត្តក្នុងការវិភាគស្ថានភាព សក្តានុពល បញ្ហាប្រឈម និងតម្រូវការនានា។

ផែនការអភិវឌ្ឍន៍ខេត្តបានកំណត់អំពីចក្ខុវិស័យ គោលដៅ គោលបំណង សូចនាករជាក់លាក់ និងយុទ្ធសាស្ត្រដែលជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការប្រើប្រាស់ធនធាន និងសក្តានុពលនានា ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកកម្ពស់គុណភាពសេវាសំដៅឆ្លើយតបតាមតម្រូវការប្រជាពលរដ្ឋ និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។

ផែនការអភិវឌ្ឍន៍នេះមានបីជំពូកៈ ជំពូកទី១ បរិយាយអំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ជំពូកទី២ បរិយាយអំពីក្របខ័ណ្ឌអភិវឌ្ឍន៍ និងជំពូកទី៣ បរិយាយអំពីការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខេត្តសម្រាប់រយៈពេល៥ឆ្នាំខាងមុខ។


ផែនទីខេត្តព្រះវិហារ
N
0 10 20
kilometers
ឆែប
គូលែន
ព្រះវិហារ
អំណាស់សំគាល់
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ព្រំប្រទល់ឃុំ
ផ្លូវជាតិ
ផ្លូវខេត្ត
ផ្លូវរថភ្លើង
ទន្លេរ ស្ទឹង ព្រែក
ទីរួមស្រុក
សាលា
មណ្ឌលសុខភាពឃុំ
មន្ទីរពេទ្យបង្អែក

# ជំពូកទី១

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

# ជំពូកទី១

## ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

### ១.១ សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

**ព័ត៌មានសំខាន់ៗក្នុងខេត្ត**

| បរិយាយ | ឯកតា | 2007 | 2008 | 2009 | 2010 |
|---|---|---|---|---|---|
| **ទិន្នន័យទូទៅ** | | | | | |
| ផ្ទៃដីខេត្ត | គ.ម² | 14,031 | 14,031 | 14,031 | 14,031 |
| ចំនួនក្រុង | ក្រុង | 0 | 0 | 1 | 1 |
| ចំនួនស្រុក | ស្រុក | 7 | 7 | 7 | 7 |
| ចំនួនសង្កាត់ | សង្កាត់ | 0 | 0 | 2 | 2 |
| ចំនួនឃុំ | ឃុំ | 49 | 49 | 47 | 47 |
| ចំនួនភូមិ | ភូមិ | 208 | 208 | 209 | 209 |
| ចំនួនប្រជាជនសរុប | នាក់ | 149,402 | 157,132 | 167,798 | 175,500 |
| ចំនួនស្ត្រីសរុប | នាក់ | 76,253 | 79,594 | 84,553 | 88,746 |
| កំណើនប្រជាជនប្រចាំឆ្នាំ | % | គ្មាន | 5.17 | 6.79 | 4.59 |
| ចំនួនគ្រួសារសរុប | គ្រួសារ | 31,300 | 33,032 | 34,963 | 37,456 |
| ទំហំគ្រួសារជាមធ្យម | នាក់ | 4.77 | 4.76 | 4.8 | 4.69 |
| ភាគរយមេគ្រួសារជាស្ត្រី | % | 10.3 | 11.95 | 9.85 | 9.64 |
| ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រក្រឡា | នាក់ | 11 | 11 | 12 | 13 |
| **ទិន្នន័យផ្នែកសេដ្ឋកិច្ច** | | | | | |
| ភាគរយគ្រួសារមានមុខរបរកសិកម្មជាចម្បង: | % | 92.09 | 92.06 | 90.54 | 87.95 |
| ធ្វើស្រែ | % | 87.71 | 86.14 | 84.13 | 82.21 |
| ធ្វើចំការ | % | 3.96 | 5.54 | 5.97 | 5.35 |
| នេសាទ | % | 0.18 | 0.21 | 0.16 | 0.15 |
| ចិញ្ចឹមសត្វ | % | 0.20 | 0.09 | 0.06 | 0.05 |
| អនុផលព្រៃឈើ | % | 0.05 | 0.08 | 0.22 | 0.19 |
| គ្រួសារមានមុខរបរធ្វើសិប្បកម្មជាចំបង: | % | 0.18 | 0.21 | 0.12 | 0.13 |
| សិប្បកម្មផលិតគ្រឿងសង្ហារឹម | % | 0.15 | 0.13 | 0.07 | 0.07 |
| សិប្បកម្មផលិតពីដែក កញ្ចក់ អាលុយមីញ៉ូម | % | 0.01 | 0.02 | 0.01 | 0.02 |
| សិប្បកម្មត្បាញរវៃ ក្រមា ហូល... | % | 0 | 0.01 | 0.01 | 0.01 |
| គ្រួសារប្រកបមុខរបរសេវាកម្មជាចំបង: | % | 2.70 | 3.65 | 3.56 | 4.56 |
| មុខរបរជំនួញ | % | 1.23 | 1.89 | 2.06 | 2.17 |

| | | | | | |
|---|---|---|---|---|---|
| មុខរបរជាង | % | 0.35 | 0.36 | 0.42 | 0.43 |
| មុខរបរដឹកជញ្ជូន | % | 0.26 | 0.38 | 0.39 | 0.27 |
| **ទិន្នន័យផ្នែកសង្គមកិច្ច** | | | | | |
| ភាគរយកុមារអាយុពី៣-៥ឆ្នាំចូលរៀនក្នុងមត្តេយ្យសាលា | % | 5.80 | 7.37 | 8.69 | 10.81 |
| ភាគរយកុមារអាយុ៦-១១ឆ្នាំចូលរៀនក្នុងសាលាបឋមសិក្សា | % | 81.91 | 81.86 | 82.66 | 84.47 |
| ភាគរយកុមារអាយុ៦-១១ឆ្នាំមិនបានចូលរៀន | % | 18.09 | 18.14 | 17.34 | 15.53 |
| ភាគរយអ្នកមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | % | 31.54 | 30.70 | 28.49 | 27.85 |
| ភាគរយស្ត្រីមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | % | 17.31 | 16.84 | 14.86 | 14.43 |
| ចំនួនស្ត្រីសម្រាលកូនសរុប | នាក់ | 3,443 | 3,428 | 3,445 | 3,327 |
| ភាគរយស្ត្រីសម្រាលកូនដោយឆ្មបបុរាណ | % | 76.39 | 66.16 | 58.69 | 55.67 |
| អត្រាមរណភាពមាតាក្នុង១០ម៉ឺនកំណើតក្រោយពេលសម្រាលកូនពី 0-១ខែ | នាក់ | 1,162 | 1,079 | 610 | 992 |
| អត្រាមរណភាពទារកអាយុពី0-១ខែ ក្នុង១000 កំណើតរស់ | នាក់ | 84 | 61 | 50 | 60 |
| ភាគរយ កុមារអាយុ៩-១២ខែមិនបានចាក់ថ្នាំបង្ការគ្រប់ចំនួន | % | 8.68 | 4.81 | 6.47 | 9.51 |
| ភាគរយគ្រួសារប្រើប្រាស់ទឹកម៉ាស៊ីន | % | 0.09 | 2.05 | 2.13 | 3.22 |
| ភាគរយគ្រួសារប្រើប្រាស់អណ្តូងទឹកស្អាត | % | 67.02 | 63.59 | 62.5 | 57.52 |
| ភាគរយគ្រួសារគ្មានបង្គន់អនាម័យប្រើប្រាស់ | % | 95.55 | 93.82 | 91.91 | 91.11 |
| **ទិន្នន័យផ្នែកដីធ្លី ធនធានធម្មជាតិ និងបរិស្ថាន** | | | | | |
| ចំនួនគ្រួសាររងគ្រោះដោយគ្រោះធម្មជាតិ | គ្រួសារ | 1,352 | 2,573 | 1,558 | 4,300 |
| ចំនួនជនរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ | នាក់ | 116 | 47 | 61 | 54 |
| ភាគរយគ្រួសារមានសេវាប្រមូលសំរាម | % | 0 | 0 | 0.03 | 0.77 |
| ភាគរយគ្រួសារទទួលរងនូវការបំពុលបរិស្ថាន | % | 0.25 | 0 | 0.29 | 0.30 |
| ភាគរយគ្រួសារដាំដុះដោយប្រើជីគីមី | % | 0.55 | 0.62 | 0.84 | 1.15 |
| **ទិន្នន័យផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់** | | | | | |
| ភាគរយទារកមិនបានចុះសំបុត្រកំណើតក្នុងឆ្នាំ | % | 54.28 | 65.86 | 70.65 | 73.69 |
| ចំនួនគ្រួសារមានផ្ទះនៅលើដីសាធារណៈ | គ្រួសារ | 113 | 299 | 311 | 462 |
| ចំនួនមនុស្សចាស់ជរាគ្មានទីពឹង | នាក់ | 191 | 156 | 176 | 222 |
| ចំនួនជនរងគ្រោះដោយសារការរំលោភផ្លូវភេទ | នាក់ | 26 | 10 | 14 | 11 |
| ចំនួនជនរងគ្រោះដោយសារការជួញដូរមនុស្ស | នាក់ | 0 | 7 | 0 | 0 |
| ចំនួនករណីលួច | ករណី | 432 | 183 | 206 | 174 |
| ចំនួនករណីទំនាស់ដីធ្លី | ករណី | 466 | 493 | 671 | 508 |
| ភាគរយគ្រួសារមានអំពើហិង្សាក្នុងគ្រួសារ | % | 3.34 | 2.62 | 3.03 | 2.9 |

ប្រភពទិន្នន័យ: ទិន្នន័យមូលដ្ឋានឃុំ (CDB)

## វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ខេត្តព្រះវិហារ

គោលដៅទី១ (MDG 1) : លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន

គោលដៅទី២ (MDG 2) : សំរេចឱ្យបានជាទូទៅនូវការអប់រំមូលដ្ឋាន

គោលដៅទី៣ (MDG 3) : លើកកំពស់សមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី

គោលដៅទី៤ (MDG 4) : កាត់បន្ថយមរណភាពកុមារ

គោលដៅទី៥ (MDG 5) : លើកកំពស់សុខភាពមាតា

គោលដៅទី៦ (MDG 6) : ប្រយុទ្ធនឹងមេរោគអេដស៍ ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺដទៃទៀត

គោលដៅទី៧ (MDG 7) : ធានាចីរភាពបរិស្ថាន




| ឆ្នាំ | MDG1 | MDG2 | MDG3 | MDG4 | MDG5 | MDG6 | MDG7 | TOTAL |
|---|---|---|---|---|---|---|---|---|
| 2007 | 12 | 15 | 39 | 18 | 12 | 94 | 43 | 33 |
| 2008 | 16 | 18 | 28 | 24 | 19 | 88 | 43 | 34 |
| 2009 | 23 | 23 | 50 | 27 | 33 | 86 | 42 | 40 |
| 2010 | 25 | 29 | 49 | 19 | 26 | 83 | 45 | 39 |

























វឌ្ឍនភាពនៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍រយៈពេល៤ឆ្នាំចុងក្រោយ២០០៧-២០១០បាន បង្ហាញឱ្យឃើញថាមានការរីកចម្រើនជាវិជ្ជមាន ។ បើពិនិត្យលើពិន្ទុសរុបមានកំណើនពី៣៣ក្នុងឆ្នាំ២០០៧ ទៅ៣៩ ក្នុងឆ្នាំ២០១០ ។

ទោះបីជាមានការរីកចម្រើនដូចនេះក្តី បើពិនិត្យទៅលើពិន្ទុឆ្នាំចុងក្រោយបានត្រឹម៣៩ពិន្ទុ ជាកម្រិតមួយទាបដែលតម្រូវឱ្យខេត្តខិតខំប្រឹងប្រែងជំរុញឱ្យមានកំណើនក្នុងការអនុវត្តគោលដៅទាំងប្រាំពីរដូចខាងក្រោម:

គោលដៅទី១ លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន ពិន្ទុកើនពី១២(២០០៧)ទៅ២៥ (២០១០) ទោះបីជាមានកំណើនខ្ពស់ តែពិន្ទុនៅមានកម្រិតទាបនៅឡើយ ។ គោលដៅនេះ បង្ហាញពីបញ្ហានៅតែធ្ងន់ធ្ងរដែលត្រូវយកចិត្តទុកដាក់ដោះស្រាយ**ជាអាទិភាព ។**

គោលដៅទី២ សំរេចឱ្យបានជាទូទៅនូវការអប់រំមូលដ្ឋាន ពិន្ទុកើនពី១៥(២០០៧)ទៅ២៩ (២០១០) ទោះ

បីជាមានកំណើនខ្ពស់ តែពិន្ទុនៅមានកម្រិតទាបនៅឡើយ។ គោលដៅនេះ**ជាអាទិភាព**ដែលត្រូវយកចិត្តទុកដាក់ជំរុញបន្ថែមទៀត។

គោលដៅទី៣ លើកកំពស់សមភាពយេនឌ័រនិងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី ពិន្ទុកើនពី៣៣(២០០៧) ទៅ៣៩(២០១០)មានកំណើនខ្ពស់ តែពិន្ទុនៅមានកម្រិតទាបនៅឡើយ។ គោលដៅនេះបង្ហាញពីបញ្ហាដែលត្រូវយកចិត្តទុកដាក់ដោះស្រាយ**ជាអាទិភាព ។**

គោលដៅទី៤ កាត់បន្ថយមរណភាពកុមារ ពិន្ទុកើនពី១៨(២០០៧) ទៅ១៩(២០១០) មានកំណើនតិចតែពិន្ទុស្ថិតក្នុងកម្រិតទាប។ គោលដៅនេះ បង្ហាញពីបញ្ហាដែលត្រូវយកចិត្តទុកដាក់ដោះស្រាយ **ជាអាទិភាព។**

គោលដៅទី៥ លើកកំពស់សុខភាពមាតា ពិន្ទុកើនពី១២(២០០៧) ទៅ២៦(២០១០)មានកំណើនខ្ពស់ តែពិន្ទុនៅមានកម្រិតទាប។ គោលដៅនេះបង្ហាញពីបញ្ហាដែលត្រូវយកចិត្តទុកដាក់ដោះស្រាយ **ជាអាទិភាព។**

គោលដៅទី៦ ប្រយុទ្ធនឹងមេរោគអេដស៍ ជំងឺអេដស៍ គ្រុនចាញ់ និងជំងឺដទៃទៀត ពិន្ទុថយចុះពី៩៤(២០០៧)មក៨៣(២០១០)។ ការថយចុះពិន្ទុនេះបង្ហាញឱ្យឃើញពីប្រសិទ្ធភាពនៃការខំប្រឹងប្រែងក្នុងការផ្តល់សេវាសុខាភិបាល ពិសេសអំពីការពន្យាជីវិតអ្នកផ្ទុកមេរោគអេដស៍។ គោលដៅនេះនៅតែ**ជាអាទិភាព**ដែលត្រូវដោះស្រាយជាបន្តទៀត ។

គោលដៅទី៧ ធានាចីរភាពបរិស្ថាន ពិន្ទុកើនពី៤៣(២០០៧)ទៅ ៤៥(២០១០) មានកំណើនខ្ពស់ តែពិន្ទុនៅមានកម្រិតទាប។ គោលដៅនេះនៅតែ **ជាអាទិភាព** ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយជាបន្ត ។

## ១.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

ខេត្តព្រះវិហារស្ថិតនៅតំបន់ខ្ពង់រាប ព្រៃភ្នំ ដែលសំបូរទៅដោយព្រៃឈើ រ៉ែ ធនធានធម្មជាតិ ទន្លេ ស្ទឹង អូរ ដីមានជីជាតិ ដែលអំណោយផលយ៉ាងខ្លាំងដល់ប្រជាកសិករក្នុងការប្រកបមុខរបរកសិកម្ម ដើម្បីជីវភាពរស់នៅប្រចាំថ្ងៃ និងមានប្រាសាទបុរាណជាច្រើនដូចជាក្រុមប្រាសាទកោះកែរ ក្រុមប្រាសាទព្រះខ័ន្ធ ប្រាសាទព្រះវិហារ ដែលមានឈ្មោះល្បីល្បាញ។ ខេត្តព្រះវិហារស្ថិតនៅប៉ែកឧត្តរនៃព្រះរាជាណាចក្រកម្ពុជា ដែលមានចំងាយប្រមាណ ២៩៨គ.ម ពីរាជធានីភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ ឆ្លងកាត់ទីរួមខេត្តកំពង់ធំ តាមផ្លូវជាតិលេខ៦២ ពី ទីរួមខេត្តកំពង់ធំដែលមានចំងាយ១២៨គ.ម មកទីរួមខេត្តព្រះវិហារដែលស្ថិតនៅក្នុងក្រុងព្រះវិហារ។ ខេត្តមានព្រំប្រទល់ខាងជើងទល់នឹងប្រទេសថៃ និងប្រទេសឡាវ ខាងកើតទល់នឹងខេត្តស្ទឹងត្រែង ខាងត្បូងទល់នឹងខេត្តកំពង់ធំ និងខាងលិចទល់នឹងខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ។

ខេត្តព្រះវិហារមានផ្ទៃដីសរុបចំនួន១៤.០៣១គ.ម$^{២}$ ចែកចេញជា៧ស្រុក និង១ក្រុងមាន ៤៧ឃុំ ២សង្កាត់ ២០៩ភូមិ មាន៣៧.៤៥៦គ្រួសារ ដែលមានប្រជាជនសរុប១៧៥.៥០០នាក់(ស្ត្រី៨៨.៧៤៦នាក់ ស្មើ៥០,៥៦%) (CDB២០១០)។ ដង់ស៊ីតេប្រជាពលរដ្ឋជាមធ្យមចំនួន ១៣នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា។ ប្រជាពលរដ្ឋក្នុងខេត្តព្រះវិហារមានការកើនឡើងជាលំដាប់ដោយការចូលមកតាំងទីលំនៅរបស់ប្រជាពលរដ្ឋពីខេត្តផ្សេងៗ និងអត្រាកំណើនរបស់ប្រជាពលរដ្ឋផ្ទាល់ក្នុងខេត្ត។ កំណើនប្រជាពលរដ្ឋ និងលំហូរចូលរបស់ប្រជាពលរដ្ឋពីខេត្តដទៃទៀតធ្វើឱ្យមានការកាប់រានដីព្រៃសម្រាប់ធ្វើលំនៅដ្ឋាន ការដាំដុះ និងការប្រើប្រាស់ធនធានព្រៃឈើហួសកំរិតដែលធ្វើឱ្យមានការប៉ះពាល់ដល់បរិស្ថាន ធនធានធម្មជាតិ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

**តារាងៈ ស្ថិតិប្រជាជន** (យោងស្ថិតិភូមិ)

| | ឆ្នាំ2006 | ឆ្នាំ2007 | ឆ្នាំ2008 | ឆ្នាំ2009 |
|---|---|---|---|---|
| ចំនួនគ្រួសារសរុប | **31,300** គ្រួសារ | **33,032** គ្រួសារ | **34,963** គ្រួសារ | **37,456** គ្រួសារ |
| កើន/ថយ | | **6%** | **6%** | **7%** |
| ចំនួនប្រជាជនសរុប | **149,402** នាក់ | **157,132** នាក់ | **167,98** នាក់ | **175,500** នាក់ |
| កើន/ថយ | | **5%** | **7%** | **5%** |
| ចំនួនគ្រួសារដែលស្ត្រីជាមេគ្រួសារ | **3,224** គ្រួសារ | **3,948** គ្រួសារ | **3,445** គ្រួសារ | **3,612** គ្រួសារ |

***សំគាល់*** : ភាគរយកើន/ថយ ត្រូវបានគណនាតាមវិធីសាមញ្ញ ដោយយកតួលេខឆ្នាំនេះ ដកឆ្នាំមុន ចែកនិងឆ្នាំមុន រួចគុណនិង១០០ភាគរយ ។

**តារាងៈ ចំនួនប្រជាជន ទំហំគ្រួសារ និងចំនួនស្ត្រីជាមេគ្រួសារ** ( ប្រភព : ទិន្នន័យឃុំឆ្នាំ២០០៩ )

| ស្រុក | ចំនួនឃុំ | ចំនួនភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាជន | | ទំហំគ្រួសារ | ចំនួនស្ត្រីជាមេគ្រួសារ | |
|---|---|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | | សរុប | % |
| ជ័យសែន | 6 | 21 | 4,435 | 20,680 | 10,579 | 5 | 272 | 6.13 |
| ឆែប | 8 | 26 | 3,418 | 17,715 | 9,182 | 5 | 384 | 11.23 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ជាំក្សាន្ត | 6 | 27 | 6,853 | 28,403 | 14,331 | 4 | 664 | 9.69 |
| គូលែន | 6 | 22 | 5,627 | 26,497 | 13,193 | 5 | 506 | 8.99 |
| រវៀង | 12 | 57 | 7,472 | 37,253 | 18,989 | 5 | 761 | 10.18 |
| សង្គមថ្មី | 5 | 24 | 3,663 | 17,389 | 8,830 | 5 | 283 | 7.73 |
| ត្បែងមានជ័យ | 4 | 12 | 2,029 | 9,664 | 4,574 | 5 | 211 | 10.40 |
| ក្រុងព្រះវិហារ | 2 | 20 | 3,959 | 17,899 | 9,068 | 5 | 531 | 13.41 |
| **សរុប** | **49** | **209** | **37,456** | **175,500** | **88,746** | **5** | **3,612** | **9.64** |

## ១.២.១ ស្ថានភាពសេដ្ឋកិច្ច

### ១.២.១.១ វិស័យកសិកម្ម

បច្ចុប្បន្ននេះ ប្រជាពលរដ្ឋក្នុងខេត្តព្រះវិហារភាគច្រើន(៨៧.៩៥ភាគរយ) រស់នៅពឹងផ្អែកលើរបរកសិកម្ម ជាចម្បងក្នុងនោះ ៨២.២១ភាគរយ ធ្វើស្រែ, ៥.៣៥ភាគរយ ធ្វើចំការ, 0.១៥ភាគរយ នេសាទ, 0.0៥ភាគរយ ចិញ្ចឹមសត្វ ក្រៅពីនោះ ប្រកបរបរជំនួញ សិប្បកម្មលក្ខណៈគ្រួសារ ប្រើប្រាស់ផលអនុផលព្រៃឈើជាដើម។ ផ្ទៃដី ដែលអាចធ្វើការងារកសិកម្មបានមានចំនួន ៧៨.១00ហ.ត ប៉ុន្តែមកទល់បច្ចុប្បន្ន ការដាំដុះដំណាំស្រូវបានចំនួន ៤៥.៩៣0ហ.ត ស្មើ១១0,៨៣%នៃផ្ទៃដីផែនការ៤១.៤៤0ហ.ត និងដំណាំផ្សេងៗទៀតបានប្រមាន៦៨.៤៧៥ហ.ត ស្មើ១0៧,៥២%នៃផ្ទៃដីផែនការ ៦៣.៦៨៤ហ.ត(ចំពោះផ្ទៃដីដាំដំណាំកសិករដាំដុះបាន ២ដងក្នុង១ឆ្នាំ)។ ទិន្នផល ស្រូវសរុបនៅឆ្នាំ២0១0មានចំនួន ១១៦.៦៨0តោន លើផ្ទៃដីប្រមូលផលសរុប៤៤.៨៧៧ហ.ត ដោយឡែកនៅឆ្នាំ ដដែលនេះ ផ្ទៃដីរងផលប៉ះពាល់និងខូចខាតមានចំនួន៩៦៦,៥0ហ.ត។ ស្រូវសល់ជាចំណីមានចំនួន១0១.៥១៣តោន បើគិតលើទិន្នផលជាអង្ករក្នុងអត្រា ៦៤% ស្មើ ៦៤.៩៦៩តោន។ ចំពោះតម្រូវការអង្ករក្នុងខេត្តព្រះវិហារមានចំនួន ២៧.២២0តោន បើវិភាគលើតុល្យភាពស្បៀងគិតជាអង្ករគឺមានចំនួនលើស ៣៧.៧៤៨តោន ដែលតុល្យភាព ស្បៀងនេះគិតជាស្រូវគឺលើស ៥៨.៩៨១តោន។

ការដាំដុះដំណាំស្រូវ និងដំណាំផ្សេងៗទៀតក្នុងខេត្ត ប្រជាកសិករធ្វើការដាំដុះដោយពឹងផ្អែកទាំងស្រុងលើ ទឹកភ្លៀង និងធម្មជាតិ។ ជាទូទៅទិន្នផលទទួលបានជាមធ្យម ២.៦តោន/ហ.ត ដែលបរិមាណសរុប នៃផលស្រូវ មិនទាន់ជាការពេញចិត្តនៅឡើយទេ បើប្រៀបធៀបទិន្នផលទៅបណ្តាប្រទេសជិតខាង។

ដោយឡែកផលិតកម្ម និងបសុព្យាបាល ក៏ជាមុខរបរមួយដ៏សំខាន់បន្ទាប់ពីដំណាំស្រូវរបស់ប្រជាពលរដ្ឋក្នុង ខេត្តដែរ។ ជាទូទៅប្រជាពលរដ្ឋ មានប្រពៃណីចិញ្ចឹមសត្វសំរាប់លក់ដូរក្នុងការដោះស្រាយជីវភាពប្រចាំថ្ងៃ។ ដោយឡែក ប្រជាពលរដ្ឋ ៧២%ចិញ្ចឹមសត្វពាហនៈ(គោ-ក្របី) ជាលក្ខណៈគ្រួសារសំរាប់ជាកំលាំងអូសទាញ និង លក់ដូរបង្កើនប្រាក់ចំណូលគ្រួសារបន្ថែម។ ពាក់ព័ន្ធនឹងបញ្ហាផលិតកម្ម និងបសុព្យាបាល ប្រជាកសិករកំពុងជួប ប្រទះនូវបញ្ហាជាច្រើនដែលធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់វិស័យដូចជា: សត្វជាច្រើនមានជម្ងឺ ពុំមានពេទ្យសត្វភូមិ គ្រប់គ្រាន់សំរាប់ការថែទាំ និងព្យាបាល ពុំមានថ្នាំវ៉ាក់សាំងសំរាប់ចាក់ការពារ និងអំពើចោរកម្មលួចគោក្របីផងដែរ។

ដូច្នេះ ប្រសិនបើយើងយកចិត្តទុកដាក់ដោះស្រាយបញ្ហានេះជូនប្រជាពលរដ្ឋបាន យើងអាចធ្វើឱ្យវិស័យចិញ្ចឹមសត្វមានការរីកចំរើន និងពិតជាអាចធ្វើឱ្យជីវភាពរបស់ប្រជាពលរដ្ឋប្រសើរឡើង និងបានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ ជាពិសេសពិតជាបានរួមចំណែកសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាជាក់ជាពុំខាន។

**តារាង: ស្ថានភាពដាំដុះដំណាំស្រូវ និងទិន្នផលទទួលបានតាមបណ្តាស្រុកឆ្នាំ ២០១០**

| ល.រ | ឈ្មោះស្រុក | ផ្ទៃដីអនុវត្ត (ហ.ត) | ផ្ទៃដីប្រមូលផល (ហ.ត) | បរិមាណផល/ តោន | ទិន្នផល (តោន/ហ.ត) |
|---|---|---|---|---|---|
| ១ | ជ័យសែន | 5,195 | 5,195 | 13,507 | 2.6 |
| ២ | ឆែប | 4,583 | 4,548 | 11,825 | 2.6 |
| ៣ | ជាំក្សាន្ត | 8,204 | 7,273 | 18,910 | 2.6 |
| ៤ | គូលែន | 12,118 | 12,118 | 31,507 | 2.6 |
| ៥ | រវៀង | 6,478 | 6,478 | 16,843 | 2.6 |
| ៦ | សង្គមថ្មី | 4,398 | 4,398 | 11,435 | 2.6 |
| ៧ | ត្បែងមានជ័យ | 3,401 | 3,401 | 8,843 | 2.6 |
| ៨ | ក្រុងព្រះវិហារ | 1,466 | 1,466 | 3,812 | 2.6 |
| សរុប | | **45,843** | **44,877** | **116,680** | **2.6** |

**តារាង: ផ្ទៃដីដំណាំអនុផល(ហ.ត) និងការចិញ្ចឹមសត្វ**

| ល.រ | ឈ្មោះស្រុក | ពោត ស | ពោត ក្រហម | ដំឡូង មី | ដំឡូង ជ្វា | បន្លែ | សណ្តែក | | | អំពៅ | ល្ង | %គ្រួសារចិញ្ចឹមសត្វ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | បាយ | សៀង | ដី | | | គោ | ជ្រូក |
| ១ | ជ័យសែន | 1500 | 124 | 160 | 18 | 173 | 496 | 35 | 237 | 17 | 145 | 81 | 86 |
| ២ | ឆែប | 150 | 140 | 35 | 37 | 127 | 453 | 33 | 325 | 15 | 25 | 66 | 65 |
| ៣ | ជាំក្សាន្ត | 130 | 325 | 110 | 76 | 172 | 579 | 36 | 239 | 66 | 160 | 56 | 67 |
| ៤ | គូលែន | 2740 | 1280 | 3070 | 1020 | 540 | 3130 | 4680 | 3260 | 1270 | 1895 | 71 | 74 |
| ៥ | រវៀង | 230 | 172 | 89 | 59 | 152 | 679 | 1331 | 578 | 46 | 571 | 78 | 66 |
| ៦ | សង្គមថ្មី | 350 | 250 | 140 | 200 | 108 | 1085 | 5000 | 1280 | 50 | 686 | 89 | 77 |
| ៧ | ត្បែងមានជ័យ | 1470 | 1372 | 88 | 160 | 134 | 689 | 1517 | 974 | 123 | 205 | 54 | 43 |
| ៨ | ក្រុងព្រះវិហារ | 1960 | 264 | 1809 | 225 | 66 | 1870 | 3536 | 835 | 109 | 255 | | |
| **សរុប** | | **8,530** | **3,927** | **5,501** | **1,795** | **1,472** | **8,981** | **16,168** | **7,728** | **1,696** | **3,942** | **71** | **68** |

(ប្រភពទិន្នន័យ: ការិ.ក្សេត្រសាស្ត្រ និងកែលំអដីកសិកម្ម)

ចំពោះស្ថាប័នដែលពាក់ព័ន្ធក្នុងការងារកសិកម្ម ក្នុងខេត្តក៏មានស្ថាប័នរដ្ឋ អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានសហការ និងគាំទ្រក្នុងវិស័យនេះ ដើម្បីឱ្យប្រជាកសិករមានជីវភាពប្រសើរឡើង ដូចជាឆ្នាំ២០១០កន្លងមកនេះមានមន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនិតិសម្បទា ខណ្ឌរដ្ឋបាលព្រៃឈើ មន្ទីររៀបចំដែនដីនគរូនីយកម្មសំណង់ និងសុរិយោដី មន្ទីរធនធានទឹកនិងឧតុនិយម អង្គការទស្សនៈពិភពលោក អង្គការអាដ្រា អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ អង្គការការីតាស បានចុះចែកពូជដំណាំនិងចុះផ្សព្វផ្សាយអំពីបច្ចេកទេសដាំដំណាំបន្លែ ផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការប្រើប្រាស់ជីគីមី ផ្សព្វផ្សាយអំពីច្បាប់ព្រៃឈើ ផ្សព្វផ្សាយអំពីច្បាប់ភូមិបាលដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងបានចុះជួយចាក់វ៉ាក់សាំងដល់សត្វគោ ក្របី និងរៀបចំប្រព័ន្ធស្រោចស្រពនៅតាមមូលដ្ឋានទាំងនោះផងដែរ ។

**តារាងៈ តំលៃស្រូវ និងបរិមាណផលស្រូវធៀបនិងប្រជាជន**

| **បរិយាយ** | 2007 | 2008 | 2009 |
|---|---|---|---|
| តំលៃលក់ស្រូវចេញជាមធ្យមអតិបរមា | **729** រៀល/គ.ក្រ | **817** រៀល/គ.ក្រ | **1,159** រៀល/គ.ក្រ |
| តំលៃលក់ស្រូវចេញជាមធ្យមអប្បរមា | **578** រៀល/គ.ក្រ | **568** រៀល/គ.ក្រ | **861** រៀល/គ.ក្រ |
| តំលៃលក់ស្រូវចេញជាមធ្យម | **654** រៀល/គ.ក្រ | **692** រៀល/គ.ក្រ | **1,010** រៀល/គ.ក្រ |
| បរិមាណផលស្រូវជាមធ្យមក្នុង១នាក់ | **404** គ.ក្រ/នាក់ | **382** គ.ក្រ/នាក់ | **378** គ.ក្រ/នាក់ |

***សំគាល់*** : ១.តំលៃស្រូវមធ្យមខ្ពស់ និងទាប ជាផលបូកតំលៃស្រូវដែលមេភូមិរាយការណ៍ខ្ពស់ និងទាប ចែករកចំនួនមធ្យម ។

២.បរិមាណផលស្រូវមធ្យម គណនាដោយយកផលស្រូវសរុបក្នុងខេត្តក្រុងចែកនិងចំនួនប្រជាជនសរុបក្នុងខេត្តក្រុង ។ ផលចែកនេះគិតជាគ.ក្រ ក្នុងប្រជាជនម្នាក់ ដើម្បីអោយដឹងថាតើបរិមាណផលស្រូវប្រចាំឆ្នាំ អាចចិញ្ចឹមប្រជាជនក្នុងខេត្តក្រុងបានដែរឬទេ ។ អាចមានន័យម៉្យាងទៀតថា តើខេត្តក្រុងជាប្រភេទខេត្តក្រុងនាំស្រូវ-អង្ករ **ចេញ** ឬនាំស្រូវ-អង្ករ **ចូល**។

**ក្រាហ្វិកៈ តម្លៃស្រូវជាមធ្យមតាមបណ្តាស្រុក ក្រុង** (យោងស្ថិតិភូមិ ឆ្នាំ២០០៩)



**តារាង: ការចិញ្ចឹមគោ ក្របី (យោងស្ថិតិភូមិ ឆ្នាំ២០០៩)**

| បរិយាយ | 2007 | 2008 | 2009 | |
|---|---|---|---|---|
| | ភាគរយ | ភាគរយ | ភាគរយ | ចំនួន |
| គ្រួសារចិញ្ចឹមគោ-ក្របីសរុប | 66.47% | 66.40% | 65.32% | 24,465 គ្រួសារ |
| គ្រួសារចិញ្ចឹមគោ-ក្របីជាកំលាំងអូសទាញ | 53.94% | 52.34% | 47.19% | 17,676 គ្រួសារ |
| ចំនួនគោ-ក្របីសរុប | 94,527 ក្បាល | 98,645 ក្បាល | 99,158 ក្បាល | |
| ផលធៀបក្នុង១គ្រួសារ | 4.3 ក្បាល/ គ្រួសារ | 4 ក្បាល/ គ្រួសារ | 4 ក្បាល/ គ្រួសារ | |

***សំគាល់*** : ភាគរយគ្រួសារចិញ្ចឹមគោ-ក្របី គិតធៀបជាមួយគ្រួសារសរុប។ ដោយឡែកផលធៀបចំនួនគោក្របីជាមួយនិងគ្រួសារ គិតតែក្នុងរង្វង់គ្រួសារចិញ្ចឹមគោ-ក្របី ប៉ុណ្ណោះមិនគិតធៀបនិងគ្រួសារសរុបឡើយ ដើម្បីអោយដឹងថាការចិញ្ចឹមគោ-ក្របីរបស់ប្រជាជនក្នុងខេត្ត មានលក្ខណៈជាទ្រង់ទ្រាយតូចឬធំ ។

ក្រាហ្វិក:ផលធៀបគោក្របីក្នុងមួយគ្រួសារ(ក្បាល/ គ្រួសារ)តាមបណ្តាស្រុក ក្រុង(យោងស្ថិតិភូមិឆ្នាំ២០០៩)




***សំគាល់*** : ផលធៀបចំនួនគោក្របីជាមួយនិងគ្រួសារ គិតតែក្នុងរង្វង់គ្រួសារចិញ្ចឹមគោ-ក្របីប៉ុណ្ណោះ មិនគិតធៀបនិងគ្រួសារសរុបឡើយ។

ក្រាហ្វិក:គ្រួសារចិញ្ចឹមគោក្របីសរុបនិងចិញ្ចឹមសម្រាប់អូសទាញតាមបណ្តាស្រុកក្រុង(យោងស្ថិតិភូមិឆ្នាំ២០០៩)




***សំគាល់*** : ភាគរយគ្រួសារចិញ្ចឹមគោ-ក្របី គិតធៀបជាមួយគ្រួសារសរុប ។

## តារាង ៖ការចិញ្ចឹមជ្រូក ការចិញ្ចឹមសត្វផ្សេងទៀតជាលក្ខណៈគ្រួសារ (យោងស្ថិតិភូមិ ឆ្នាំ២០០៩)

| បរិយាយ | 2007 | 2008 | 2009 | |
|---|---|---|---|---|
| | ភាគរយ | ភាគរយ | ភាគរយ | ចំនួន |
| គ្រួសារចិញ្ចឹមជ្រូកសរុប | 55.68% | 59.86% | 58.00% | 21,725 គ្រួសារ |
| គ្រួសារចិញ្ចឹមជ្រូកលើសពី៣ក្បាល | 12.72% | 14.10% | 13.65% | 5,114 គ្រួសារ |
| គ្រួសារចិញ្ចឹមមាន់សរុប | 77.05% | 78.18% | 76.05% | 28,487 គ្រួសារ |
| គ្រួសារចិញ្ចឹមមាន់មេលើសពី៣ក្បាល | 54.50% | 59.94% | 59.80% | 22,400 គ្រួសារ |
| គ្រួសារចិញ្ចឹមទាសរុប | 10.33% | 11.18% | 10.56% | 3,954 គ្រួសារ |
| គ្រួសារចិញ្ចឹមទាមេលើសពី៥ក្បាល | 5.25% | 6.34% | 6.38% | 2,388 គ្រួសារ |
| គ្រួសារចិញ្ចឹមពពែ-ចៀម | 0.03% | 0.04% | 0.11% | 41 គ្រួសារ |
| គ្រួសារចិញ្ចឹមសេះ | 0.01% | 0.01% | 0.01% | 2 គ្រួសារ |

ក្រាហ្វិក: គ្រួសារចិញ្ចឹមជ្រូកតាមបណ្តាស្រុក ក្រុង (យោងស្ថិតិភូមិ ឆ្នាំ២០០៩)




***<u>សំគាល់</u>*** : ភាគរយគ្រួសារចិញ្ចឹមជ្រូកគិតធៀបជាមួយគ្រួសារសរុប ។

## តារាង៖ ស្ថានភាពមុខរបរចម្បងរបស់ប្រជាជនក្នុងខេត្ត (យោងស្ថិតិភូមិ ឆ្នាំ២០០៩)

| ប្រភេទមុខរបរ | 2007 | 2008 | 2009 | |
|---|---|---|---|---|
| | ភាគរយ | ភាគរយ | ភាគរយ | ចំនួន |
| **គ្រួសារមានមុខរបរធ្វើកសិកម្មជាចំបង** | **92.06%** | **90.55%** | **87.95%** | **32,944 គ្រួសារ** |
| គ្រួសារមានមុខរបរធ្វើស្រែជាចំបង | 86.14% | 84.13% | 82.21% | 30,791 គ្រួសារ |
| គ្រួសារមានមុខរបរដាំដំណាំរយៈពេលវែងជាចំបង | 0.63% | 0.94% | 1.06% | 398 គ្រួសារ |
| គ្រួសារមានមុខរបរដាំដំណាំរយៈពេលខ្លីជាចំបង | 4.57% | 4.65% | 3.91% | 1,465 គ្រួសារ |
| គ្រួសារមានមុខរបរដាំបន្លែជាចំបង | 0.34% | 0.38% | 0.38% | 143 គ្រួសារ |
| គ្រួសារមានមុខរបរនេសាទជាចំបង | 0.21% | 0.16% | 0.15% | 58 គ្រួសារ |
| គ្រួសារមានមុខរបរចិញ្ចឹមសត្វជាចំបង | 0.09% | 0.06% | 0.05% | 17 គ្រួសារ |
| គ្រួសារមានមុខរបរពីអនុផលព្រៃឈើជាចំបង | 0.08% | 0.22% | 0.19% | 72 គ្រួសារ |
| **គ្រួសារមានមុខរបរធ្វើសិប្បកម្មជាចំបង** | **0.21%** | **0.12%** | **0.13%** | **49 គ្រួសារ** |
| គ្រួសារមានមុខរបរសិប្បកម្មផលិតសង្ហារឹមពីឈើ ផ្តៅ ឫស្សី | 0.13% | 0.07% | 0.07% | 28 គ្រួសារ |

| | | | | |
|---|---|---|---|---|
| គ្រួសារមានមុខរបរសិប្បកម្មផលិតពីដែក កញ្ចក់ អាលុយមីញ៉ូម | 0.02% | 0.01% | 0.02% | 6 គ្រួសារ |
| គ្រួសារមានមុខរបរសិប្បកម្មផលិតគ្រឿងបរិភោគ | 0.01% | 0.01% | 0.00% | 0 គ្រួសារ |
| គ្រួសារមានមុខរបរសិប្បកម្មផលិតពោះវៀនកង់ ម៉ូតូ | 0.04% | 0.00% | 0.00% | 0 គ្រួសារ |
| គ្រួសារមានមុខរបរសិប្បកម្មត្បាញរវៃ ក្រមា ហូល... | 0.01% | 0.01% | 0.01% | 5 គ្រួសារ |
| គ្រួសារមានមុខរបរសិប្បកម្មផ្សេងៗ | 0.01% | 0.02% | 0.03% | 10 គ្រួសារ |
| **គ្រួសារប្រកបមុខរបរសេវាកម្មជាចំបង** | **3.65%** | **3.56%** | **4.56%** | **1,709 គ្រួសារ** |
| គ្រួសារប្រកបមុខរបរជំនួញ | 1.89% | 2.06% | 2.17% | 813 គ្រួសារ |
| គ្រួសារប្រកបមុខរបរជាង | 0.36% | 0.42% | 0.43% | 160 គ្រួសារ |
| គ្រួសារប្រកបមុខរបរដឹកជញ្ជូន | 0.38% | 0.39% | 0.27% | 103 គ្រួសារ |
| គ្រួសារប្រកបមុខរបរសេវាកម្មផ្សេងៗ | 1.04% | 0.69% | 1.69% | 633 គ្រួសារ |
| **គ្រួសារដែលប្រកបមុខរបរមិនច្បាស់លាស់(ចំរុះ)** | **4.07%** | **5.77%** | **7.35%** | **2,754 គ្រួសារ** |

### ១.២.១.២ វិស័យជលផល

វិស័យជលផលនៅក្នុងខេត្តព្រះវិហារ បានផ្តល់លទ្ធភាព និងធនធានជលផល(ត្រី)សម្រាប់ដោះស្រាយជាម្ហូបអាហារ(ត្រីសាច់ ត្រីប្រហុក ផ្អក...)របស់ប្រជាកសិករបានមួយរយៈកាលក្នុងរដូវបើកនេសាទកន្លងមកនេះ។ ទន្ទឹមនេះ ខណ្ឌរដ្ឋបាលជលផលបានខិតខំអនុវត្តការងារសកម្មភាពដូចជា ការគ្រប់គ្រងធនធានជលផលតាមរយៈការបង្កើតសហគមន៍ស្រះជម្រកត្រី ការអភិវឌ្ឍវារីវប្បកម្មជាលក្ខណៈគ្រួសារ(ចិញ្ចឹមត្រី និងការផលិតកូនត្រីពូជ)ដែលបានសហការ និងការជួយគាំទ្រគម្រោងពីរដ្ឋបាលជលផល អង្គការជាតិ និងអន្តរជាតិនានា(FAO/EUFF ,DFID/DANIDA, NCCD...)។ ដោយឡែកក្រៅពីការងារ ខាងលើ ខណ្ឌបានខិតខំទប់ស្កាត់នូវបញ្ហាមួយចំនួនទៀតដោយមានការចូលរួមសហការពីអាជ្ញាធរពាក់ព័ន្ធដូចជា ចុះផ្សព្វផ្សាយច្បាប់ស្តីពីជលផលចុះពិនិត្យសកម្មភាពធ្វើនេសាទហួសកំរិត និងសកម្មភាពនេសាទខុសច្បាប់ផ្សេងៗ។ ខណ្ឌរដ្ឋបាលជលផលមានការជួបប្រទះបញ្ហាមួយចំនួន :

-ខ្វះមន្ត្រី ដើម្បីបម្រើការងារនៅថ្នាក់ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលជលផល ។

-ពុំមានដីធ្លីសម្រាប់បង្កើតស្នាក់ការខណ្ឌ និងផ្នែក-សង្កាត់រដ្ឋបាលនៅថ្នាក់ក្រុង ស្រុក។

-ពុំមានកញ្ចប់ថវិកាដើម្បីដំណើរការសកម្មភាពការងារ និងអភិវឌ្ឍន៍ ដូចបណ្តាមន្ទីរជំនាញនានា ។

បញ្ហាដូចបានរាប់ខាងលើនេះ បណ្តាលមកពីការផ្តាច់ចេញរដ្ឋបាលគ្រប់គ្រងរយៈខ្សែបណ្តោយ និងពុំទាន់បានរៀបចំនូវថវិកា និងហេដ្ឋារចនាសម្ព័ន្ធអាគាររូបវន្តនានាសម្រាប់ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលជលផលឱ្យបានទាន់ពេលមុននឹងផ្តាច់ចេញពីមន្ទីរកសិកម្មខេត្ត ។

បច្ចុប្បន្នខណ្ឌ បានដោះស្រាយ និងសម្របសម្រួលឱ្យមានស្ថានភាពល្អខ្លះៗផងដែរ ដូចជា:

-បានជួលទីស្នាក់បណ្តោះអាសន្ន ដើម្បីមានទីតាំងច្បាស់លាស់មានកន្លែងធ្វើការ និងការស្នាក់អាស្រ័យការងាររបស់មន្ត្រីជំនាញ។

-បានស្នើសុំជំនួយពីរដ្ឋបាលជលផល និងបានរកដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយអភិវឌ្ឍន៍ការងារវិស័យជលផល និងជួយដល់ប្រជាពលរដ្ឋនៅក្នុងខេត្តព្រះវិហារ ។

-បានរៀបចំគម្រោង និងសំណើរផ្សេងៗដាក់បញ្ចូលទៅក្នុងផែនការថ្នាក់ជាតិ និងកំពុងបានដំណើរការសកម្មភាពគម្រោង ដើម្បីជួយទ្រទ្រង់ជីវភាពប្រជាកសិករនៅតាមភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ។

### ១.២.១.៣ វិស័យធនធានទឹក និងឧតុនិយម

ខេត្តព្រះវិហារ មានប្រព័ន្ធធារាសាស្ត្រចាស់ៗជាច្រើនដែលបានសាងសង់ក្នុងកំឡុងឆ្នាំ១៩៧៥-៧៩។ ប៉ុន្តែប្រព័ន្ធធារាសាស្ត្រទាំងនោះបានខូចខាតស្ទើរតែទាំងស្រុង ដោយសារខ្វះការថែទាំ និងសំណង់ដែលពុំមានគុណភាពល្អ។ ចាប់តាំងពីឆ្នាំ២០០១មក មន្ទីរធនធានទឹកបានរៀបចំធ្វើការសិក្សា និងស្វែងរកទុនក្នុងការជួសជុលស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រទាំងនោះជាបណ្តើរៗ ដើម្បីចូលរួមដោះស្រាយបញ្ហាទឹកក្នុងការងារកសិកម្មជូនប្រជាពលរដ្ឋតាមមូលដ្ឋាន។ ប្រព័ន្ធធារាសាស្ត្ររួមមាន ទំនប់អាងទឹកចំនួន២១៩ទំនប់(ប្រើប្រាស់បានចំនួន១៥ទំនប់) ស្រះទឹកចំនួន៦៩ស្រះ(ប្រើប្រាស់បានចំនួន១១ស្រះ) ប្រឡាយចំនួន៤១ខ្សែ(ប្រើប្រាស់បានចំនួន៨ខ្សែ) ទ្វារទឹកចំនួន១៤០កន្លែង(ប្រើប្រាស់បានចំនួន១៧ទ្វារទឹក) លូដោះទឹកចំនួន៨១កន្លែង(ខូចមិនអាចប្រើប្រាស់បាន) និងទំនប់បង្វៀរចំនួន១៤កន្លែង(ប្រើប្រាស់បានចំនួន៧ទំនប់បង្វៀរ) ។

**តារាង៖ ស្ថិតិប្រព័ន្ធធារាសាស្ត្រ**

| ល.រ | បរិយាយ | ទំនប់អាងទឹក | ស្រះទឹក | ប្រឡាយ | ទ្វាទឹក | លូដោះទឹក | ទំនប់បង្វៀរ |
|---|---|---|---|---|---|---|---|
| ១ | ក្រុងព្រះវិហារ | ០៥ ទំនប់ | ០ | ០៣ ខ្សែ | ០៥ កន្លែង | ០២ កន្លែង | ០១ កន្លែង |
| ២ | ស្រុកគូលែន | ៤២ ទំនប់ | ២៥ ស្រះ | ០៥ ខ្សែ | ៤០ កន្លែង | ២៣ កន្លែង | ០ |
| ៣ | ស្រុកសង្គមថ្មី | ៣៣ ទំនប់ | ១១ ស្រះ | ០៥ ខ្សែ | ២០ កន្លែង | ១៣ កន្លែង | ០២ កន្លែង |
| ៤ | ស្រុកជាំក្សាន្ត | ៣៩ ទំនប់ | ០៦ ស្រះ | ០៥ ខ្សែ | ១៩ កន្លែង | ០៩ កន្លែង | ០១ កន្លែង |
| ៥ | ស្រុកត្បែងមានជ័យ | ២០ ទំនប់ | ០៤ ស្រះ | ០៤ ខ្សែ | ០៨ កន្លែង | ០៧ កន្លែង | ០ |
| ៦ | ស្រុករវៀង | ៤២ ទំនប់ | ០២ ស្រះ | ០៥ ខ្សែ | ១៤ កន្លែង | ០៥ កន្លែង | ០២ កន្លែង |
| ៧ | ស្រុកឆែប | ២០ ទំនប់ | ០៨ ស្រះ | ០៩ ខ្សែ | ១៧ កន្លែង | ១៤ កន្លែង | ០១ កន្លែង |
| ៨ | ស្រុកជ័យសែន | ១៨ ទំនប់ | ១៣ ស្រះ | ០៨ ខ្សែ | ១៧ កន្លែង | ០៨ កន្លែង | ០៧ កន្លែង |
| សរុប | | ២១៩ ទំនប់ | ៦៩ ស្រះ | ៤១ ខ្សែ | ១៤០ កន្លែង | ៨១ កន្លែង | ១៤ កន្លែង |

ទន្ទឹមនឹងនេះ វិស័យធនធានទឹកនិងឧតុនិយមបានជួបបញ្ហាមួយចំនួនដូចជា៖

- ទិន្នន័យតាមដានកម្ពស់ទឹកភ្លៀងតាមបណ្តាស្រុក ពុំមានតួលេខច្បាស់លាស់ និងការតាមដានកម្ពស់ទឹកជំនន់នៅតាមដងស្ទឹងសែនពុំទាន់មានតួលេខគ្រប់គ្រាន់ ។

- កសិករទូទាំងខេត្ត ខ្វះលទ្ធភាពនាំទឹកសម្រាប់ស្រោចស្រពក្នុងការបង្កបង្កើនផល។ ម្យ៉ាងទៀតនៅតំបន់មួយចំនួនមានប្រព័ន្ធស្រោចស្រពហើយ ប៉ុន្តែប្រជាពលរដ្ឋខ្វះការគ្រប់គ្រងថែទាំ និងមួយចំនួនទៀតរស់នៅឆ្ងាយពីប្រភពទឹក ពេលជួបគ្រោះរាំងស្ងួតមិនអាចនាំទឹកទៅជួយសង្គ្រោះបានទាន់ពេលវេលា ។

- ទិន្នន័យកម្ពស់ទឹកភ្លៀងនៅតាមបណ្ដាស្រុកទាំង៧ ពុំទាន់មានភ្នាក់ងារតាមដាន។ម្យ៉ាងទៀត ប៉ុស្តិ៍សម្រាប់ពិនិត្យ និងយកទិន្នន័យត្រូវខូចខាតទាំងស្រុង។ រីឯការតាមដានកម្ពស់ទឹកជំនន់តាមដងស្ទឹងសែនវិញពុំទាន់មានប៉ុស្តិ៍ពិនិត្យកម្ពស់ទឹកឡើង ឬចុះគ្រប់គ្រាន់នៅឡើយ ។

### ១.២.១.៤ វិស័យទេសចរណ៍

វិស័យទេសចរណ៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកសាងសេដ្ឋកិច្ចសង្គម ផ្ដល់ឱកាសការងារធ្វើបង្កើនប្រាក់ចំណូល លើកកម្ពស់ជីវភាពរស់នៅ និងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ផ្អែកលើសក្ដានុពលដែលមានក្នុងខេត្ត វិស័យទេសចរណ៍ត្រូវបានចាត់ទុកជាវិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពផ្សេងៗទៀតក្នុងការជម្រុញកំណើនសេដ្ឋកិច្ចឱ្យរីកចម្រើន តាមរយៈការចូលរួមវិនិយោគលើសម្បទាសេវាកម្មទេសចរណ៍ពីដៃគូរអភិវឌ្ឍន៍នានា និងចងក្រងសហគមន៍ទេសចរណ៍មូលដ្ឋាន។ មកដល់បច្ចុប្បន្ននេះស្ថានភាពវិស័យទេសចរណ៍ក្នុងខេត្ត បើប្រៀបជាមួយគោលដៅទេសចរណ៍ផ្សេងៗទៀតក្នុងព្រះរាជាណាចក្រកម្ពុជាដោយឡែកបើប្រៀបជាមួយគោលដៅទេសចរណ៍នៅភូមិភាគពាយ័ព្យសាន ការរីកចម្រើនរបស់យើងនៅមានកំរិតនៅឡើយដែលចំនុចនេះទាមទារឱ្យមន្ទីរត្រូវបន្តរៀបចំតំរិយាបទការងារ និងខិតខំប្រឹងប្រែងទ្វេឡើងថែមទៀតក្នុងការដាក់ចេញនូវយុទ្ធសាស្ត្រជាគន្លឹះសម្រាប់ការកសាងផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ សំដៅស្វែងរកប្រភពធនធាន និងទាក់ទាញពីគ្រប់ភាគីពាក់ព័ន្ធ ពិសេសពីផ្នែកអង្គការសង្គមស៊ីវិល និងឯកជន ដើម្បីរួមចំណែកអភិវឌ្ឍន៍វិស័យនេះឱ្យទទួលបានលទ្ធផលល្អ។ ផ្ទុយទៅវិញ បើប្រៀបជាមួយនិងរយៈពេលប៉ុន្មានឆ្នាំកន្លងមក នៃការចាត់តាំងអនុវត្តតាមគោលការណ៍ដឹកនាំរបស់ក្រសួងទេសចរណ៍ និងការដឹកនាំរបស់ខេត្ត ពិសេសក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាលក្នុងការស្តារ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់បានរីកចម្រើនយ៉ាងឆាប់រហ័ស ធ្វើឱ្យវិស័យទេសចរណ៍នៅក្នុងខេត្តរីកចំរើនឡើងដែរ ថ្វីត្បិតជួបប្រទះនឹងបញ្ហាប្រឈមមួយចំនួនក៏ពិតមែន តែជារួមមានការវិវឌ្ឍន៍រីកចម្រើនជាបន្តបន្ទាប់គួរកត់សម្គាល់ទាំងស្ថានភាពភ្ញៀវទេសចរ និងមូលដ្ឋានសេវាកម្មបម្រើភ្ញៀវទេសចរ។ ជាក់ស្តែងដូចមានបង្ហាញក្នុងតារាងចំនួន ៣ដូចខាងក្រោម :

**តារាងៈ ស្ថិតិភ្ញៀវទេសចរទស្សនាខេត្តព្រះវិហាររយៈពេល៥ ឆ្នាំ ២០០៦-២០១០**

| ឆ្នាំ | ភ្ញៀវជាតិ | ភ្ញៀវអន្តរជាតិ | សរុប | ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|
| 2006 | 18.972 | 73.876 | **92.848** | + 4,55 % | +4.233 |
| 2007 | 37.530 | 90.693 | **128.223** | +27,58 % | +35.375 |
| 2008 | 65.182 | 62.258 | **127.440** | -0,61 % | -783 |
| 2009 | 53.391 | 8.512 | **61.903** | -51,42 % | -65.537 |
| 2010 | 124.408 | 11.249 | **135.657** | +54,36 % | +73.754 |
| **សរុប** | **299.483** | **246.588** | **546.071** | | |

### តារាងៈ បង្ហាញពីគោលដៅទេសចរណ៍ដែលភ្ញៀវអាចទៅទស្សនាក់សាន្តបាន

| ឈ្មោះរមណីយដ្ឋាន | ទីតាំង | | | ប្រភេទផ្លូវ | ចម្ងាយផ្លូវ | ការគ្រប់គ្រង | ការគាំទ្រថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | ភូមិ | ឃុំ | ស្រុក | | | | | |
| **១-រមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ** | | | | | | | | |
| -ក្រុមប្រាសាទព្រះវិហារ | ធម្មជាតិ | កន្ទួត | ជាំក្សាន្ត | កៅស៊ូ | ១១៦គម | អាជ្ញាធរជាតិ | យូណេស្កូ | |
| -ក្រុមប្រាសាទកោះកេរ | ស្រយង់ | ស្រយង់ | គូលែន | កៅស៊ូ | ៧៥គម | ក្រុមហ៊ុន | ខេង សុមេធ | |
| -ក្រុមប្រាសាទព្រះខ័ន | តាសែងជើង | រណៈសិរ្ស | សង្គមថ្មី | កៅស៊ូ+ដី | ១០៥ គម | ក្រុមការងារ | មិនមាន | |
| -ប្រាសាទនរាយណ៍ | ក្រឡាពាស | ព្រីងធំ | ជាំក្សាន្ត | ផ្លូវលំ | ៣០ គ.ម | | | ខែប្រាំង |
| -ក្រុមប្រាសាទនាគបួស | ឆ្អេះ | ទឹកក្រហម | ជាំក្សាន្ត | កៅស៊ូ+ដី | ១១៥ គម | | | ខែប្រាំង |
| -ក្រុមបាសាទព្រះលាន | ក្រាំងដូង | ព្រះឃ្លាំង | ត្បែង | កៅស៊ូ | ២៥ គម | | | |
| -ក្រុមប្រាសាទក្រពុំឈូក | ថ្នល់កោង | រំដោះ | រវៀង | កៅស៊ូ | ៤៥ គម | | | |
| -ក្រុមប្រាសាទក្អាក់ | ក្អាក់ | ត្បែងពីរ | គូលែន | គ្រួសក្រហម | ៥៥ គម | | | |
| **២-រមណីយដ្ឋានធម្មជាតិ** | | | | | | | | |
| -សហគមន៍អភិរក្សសត្វស្លាបត្មាតប៉ើយ | ត្មាតប៉ើយ | ព្រីងធំ | ជាំក្សាន្ត | កៅស៊ូ+ដី | ៤០គម | | WCS | |
| -ទឹកធ្លាក់ព្រះនិម្មិត | គំពង់សីមី | ស្រឡៅពីរ | ឆែប | គ្រួ.ក្រហម | ១៤៥ គម | សហគមន៍ | | |
| -ទឹកធ្លាក់តេជោបុះស្បូវ | តេជោបុះស្បូវ | កន្ទួត | ជាំក្សាន្ត | កៅស៊ូ.ផ្លូវដី | ១០០គម | | | ខែវស្សា |
| -ទឹកធ្លាក់ព្រៃរយោង | បេងកោង | ព្រះឃ្លាំង | ត្បែង. | កៅស៊ូ.ផ្លូវដី | ១៥គ.ម | | | ខែវស្សា |
| -រមណីយដ្ឋានវត្តពើងព្រះគោ | មហាផល | ឈានមុខ | ត្បែង | កៅស៊ូ+ផ្លូវដី | ៩គម | | | |

### តារាងៈ ស្ថិតិការគ្រប់គ្រងសេវាកម្មទេសចរណ៍ពីឆ្នាំ ២០០៦-២០១០

| | ២០០៦ | | ២០០៧ | | ២០០៨ | | ២០០៩ | | ២០១០ | | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|---|
| | កន្លែង | បន្ទប់.គ្រុ | កន្លែង | បន្ទប់ | កន្លែង | បន្ទប់ | កន្លែង | បន្ទប់ | កន្លែង | បន្ទប់ | |
| ១-សណ្ឋាគារ | ០ | ០ | ០ | ០ | ០ | ០ | ០ | ០ | ១ | ២០ | +១ |
| ២-ផ្ទះសំណាក់ | ០៩ | ១០៨ | ១០ | ១១៨ | ១០ | ១២៧ | ២០ | ២២០ | ២៣ | ២៤៨ | +៣ |
| ៣-ម៉ូតែល | | | | | ០ | | ០ | | ០១ | ០៨ | +១ |
| ៤-ភោជនីយដ្ឋានទេសចរណ៍ | | | | | ០៤ | | ០៦ | | ០៧ | | +១ |
| ៥- អាហារដ្ឋានក្នុងស្រុក | | | | | ១៨ | | ២១ | | ២៨ | | +៧ |
| ៦-ខារ៉ាអូខេ | | | | | ០២ | | ០២ | | ០៤ | | +២ |
| ៧-បៀហ្គាឌិន | | | | | ០២ | | ០២ | | ០១ | | -១ |

### ១.២.១.៥ វិស័យសាធារណៈការ និងដឹកជញ្ជូន

ខេត្តព្រះវិហារគឺជាខេត្តមួយដែលមានភូមិសាស្ត្រជាប់នឹងប្រទេសថៃនិងប្រទេសឡាវ ហើយមានចម្ងាយផ្លូវពីរាជធានីភ្នំពេញមកខេត្តប្រវែង២៩៨គ.មមានផ្លូវជាតិ និងផ្លូវខេត្តសំខាន់ៗដែលអាចតភ្ជាប់ពីទីក្រុងដល់ជនបទ ហើយបានធ្វើឱ្យវិស័យគមនាគមន៍ដឹកជញ្ជូនមានលទ្ធភាពច្រើនសំរាប់ការផ្លាស់ប្តូរផលិតផលកសិផលរបស់ប្រជាពល

រដ្ឋបានទៅដល់គោលដៅ។

លទ្ធផលដែលសម្រេចបានទាំងនេះ អាស្រ័យដោយរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ផ្តល់ថវិកាជារៀងរាល់ឆ្នាំនិងជាបន្តបន្ទាប់។ ដូចនេះបណ្តាញគមនាគមន៍ដែលបាននឹងកំពុងសាងសង់គិតទាំងផ្លូវជាតិ និងផ្លូវខេត្តរួមមានផ្លូវជាតិលេខ៦២ សំរាប់ភ្ជាប់ពីព្រំប្រទល់ខេត្តកំពង់ធំដល់ជើងភ្នំប្រាសាទព្រះវិហារមានប្រវែង ២០៣គ.ម សម្រេចបានប្រមាណ៨០% ផ្លូវជាតិលេខ ៦៤ ពីឃុំថ្មីស្រុកគូលែនដល់ព្រំប្រទល់ស្រុកស្វាយលើខេត្តសៀមរាបមានប្រវែង ៥១គ.មដោយចាក់កៅស៊ូសម្រេចបាន ៣៤គ.ម ផ្លូវខេត្តលេខ ១៧៥ ពីភូមិស្រអែមដល់ព្រំប្រទល់ស្រុកត្រពាំងប្រាសាទខេត្តឧត្តរមានជ័យប្រវែង១៧គ.ម ចាក់កៅស៊ូ១០០% ផ្លូវខេត្តលេខ២៦២៤ ពីភូមិភ្នំដែក ឃុំរមណីយ ស្រុករវៀង ដល់ស្ពង់ខេត្តស្ទឹងត្រែងប្រវែង ៧៨គ.មចាក់កៅស៊ូបាន ៣៧,៥គ.ម ផ្លូវខេត្តលេខ ២៦៤៦-២៦៤៧ ពីភូមិកំពង់ស្រឡៅ ស្រុកឆែប ប្រវែង ១០៦,៨គ.ម បាននឹងកំពុងធ្វើការ សាងសង់ផ្លូវក្រាលគ្រួសក្រហមសម្រេចបាន៨០% ផ្លូវខេត្តលេខ ២១៤ ពីមាត់ស្ទឹងសែនភូមិកំពង់ចម្លង សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ដល់ព្រំប្រទល់ខេត្តស្ទឹងត្រែងប្រវែង ៧៤,៥គ.ម ក្រាលគ្រួសក្រហមសម្រេចបាន ៩៥% ដោយឡែកផ្លូវជាច្រើនខ្សែទៀតនៅតាមបណ្តោយព្រំដែនប្រទេសថៃ និងប្រទេសឡាវ សុទ្ធតែបានសាងសង់រួចនឹងកំពុងសាងសង់ជាបន្តបន្ទាប់ដែលជា ប្រភេទផ្លូវក្រាលគ្រួសក្រហមជាផ្លូវយុទ្ធសាស្ត្រសំរាប់ការពារបូរណភាពទឹកដី។

នៅក្នុងឆ្នាំ២០១១ខាងមុខនេះ រាជរដ្ឋាភិបាលបានរៀបចំសាងសង់ផ្លូវមួយខ្សែទៀត ដោយចាក់កៅស៊ូពីស្រុកថាឡាបរិវ៉ាត់ខេត្តស្ទឹងត្រែងតមកភ្ជាប់ទីរួមខេត្តព្រះវិហារ ភ្ជាប់ជាមួយផ្លូវជាតិលេខ៦២ នៅចន្លោះភូមិស្អាតរសង្កាត់ប៉ាលហាលក្រុងព្រះវិហារ។ រីឯផ្លូវក្នុងទីរួមខេត្តក៏មានការអភិវឌ្ឍជាបណ្តើរៗ ដើម្បីកែលំអសោភ័ណភាពទីក្រុងឱ្យកាន់តែប្រសើរឡើង។

ទន្ទឹមនឹងសមិទ្ធផលដែលសម្រេចបានខាងលើ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តបានលើកផែនការយុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍន៍សំរាប់៥ឆ្នាំលើហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និងសាងសង់បន្ថែមទៀតឱ្យសមស្របតាមកំណើនសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ ព្រោះផ្លូវថ្នល់ ស្ពាន គឺជាសរសៃឈាមរបស់ប្រទេសជាតិសំរាប់កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ១.២.១.៦ វិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍

ផ្តើមចេញពីគោលនយោបាយយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលតំណាក់កាលទី២ ផែនការយុទ្ធ-សាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១១-២០១៥។ មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍បានលើកគម្រោងផែនការ និងសកម្មភាពការងារសំដៅរៀបចំប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍មួយស្របតាមបណ្តាខេត្តក្នុងប្រទេសឱ្យមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ សេវាកម្មទំនើប និងគ្របដណ្តប់ទូទាំងខេត្ត ដោយមានប្រព័ន្ធត្រួតពិនិត្យគុណភាពដើម្បីចូលរួមជម្រុញកំនើនសេដ្ឋកិច្ចនិងលើកកម្ពស់ជីវភាពរបស់ប្រជាជនកាត់បន្ថយភាពក្រីក្រ។ ពង្រីកសេវាប្រៃសណីយ៍នៅតំបន់ជនបទ បង្កលក្ខណៈឱ្យប្រជាជនបានទទួលព័ត៌មាន និងបញ្ជូនព័ត៌មានក្នុងការទំនាក់ទំនងបានឆាប់រហ័ស។

បង្កើនសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីសម្រេចនូវកម្មវិធីទំនើបកម្មក្នុងវិស័យនេះ។ យកចិត្តទុកដាក់ជម្រុញការបណ្តុះបណ្តាលធនធានមនុស្ស។

ប្រៃសណីយ៍ និងទូរគមនាគមន៍ជាវិស័យមួយដែលបម្រើឱ្យសកម្មភាពសង្គមលើគ្រប់វិស័យ ដើម្បីកាត់បន្ថយនូវការចំណាយពេលវេលានិងថវិកាដែលមិនអាចខ្វះបានឡើយហើយវិស័យនេះចែកចេញជាពីរគឺប្រៃសណីយ៍ និងទូរគមនាគមន៍។

ប្រៃសណីយ៍មានភារកិច្ចក្នុងការធ្វើ បម្រើសេវាកម្ម អាជីវកម្មសម្រាប់បម្រើឱ្យផលប្រយោជន៍សង្គមជាតិទាំងមូលដូចជាការបញ្ជូន និងទទួល លិខិតគ្រប់ប្រភេទ បញ្ញើឆាប់រហ័ស អាណត្តិប្រៃសណីយ៍(ផ្ញើប្រាក់) កញ្ចប់គ្រប់ប្រភេទនៅក្នុងនិងក្រៅប្រទេស និងបញ្ជូននិងទទួលបញ្ញើគ្រប់ប្រភេទទៅតាមបណ្តាស្រុក និងមូលដ្ឋានជនបទទូទាំងខេត្ត។

ទូរគមនាគមន៍ជាវិស័យមួយបម្រើសេវាកម្ម អាជីវកម្មនៅផ្ទៃប្រទេស និងនៅទូទាំងពិភពលោក។ ដោយឡែកនៅទូទាំងខេត្តព្រះវិហារ បច្ចុប្បន្ន ទូរគមនាគមន៍មានបណ្តាញសេវាគ្របដណ្តប់ទូទាំងខេត្តដែលមានក្រុមហ៊ុនចំនួន០៦ជាក្រុមហ៊ុនទូរស័ព្ទចល័ត និង០១ក្រុមហ៊ុនទូរស័ព្ទអចល័ត ហើយក្រុមហ៊ុននីមួយៗ មានស្ថានីយ៍នៅគ្រប់ក្រុង ស្រុក និងទីប្រជុំជនដូចមានក្នុងតារាងស្ថិតិស្ថានីយ៍ទូរស័ព្ទភ្ជាប់ខាងក្រោម:

**តារាង: ស្ថិតិស្ថានីយ៍ទូរស័ព្ទតាមបណ្តាក្រុង-ស្រុក**

| ឈ្មោះ ក្រុមហ៊ុន | ក្រុង ព្រះវិហារ | ស្រុកត្បែង មានជ័យ | ស្រុក រវៀង | ស្រុក ជ័យសែន | ស្រុក ឆែប | ស្រុក ជាំក្សាន្ត | ស្រុក គូលែន | ស្រុក សង្គមថ្មី | សរុបរួម |
|---|---|---|---|---|---|---|---|---|---|
| ក្រុមហ៊ុន Mobitel 012,092 | ០៥ | ០១ | ០៣ | ០១ | ០២ | ០២ | ០៣ | ០១ | **១៨** |
| ក្រុមហ៊ុន Metfont 097,088 | ០៧ | ០៣ | ១០ | ០៤ | ០២ | ០៩ | ០៧ | ០៣ | **៤៥** |
| ក្រុមហ៊ុន Mfont 011,099 | ០៤ | ០១ | ០៤ | ០២ | ០២ | ០២ | ០៣ | ០២ | **២០** |
| ក្រុមហ៊ុន Hello 015,016 | ០២ | ០១ | ០៤ | ០០ | ០០ | ០២ | ០៣ | ០០ | **១២** |
| ក្រុមហ៊ុន Star Cell 090,013 | ០៣ | ០២ | ០៨ | ០០ | ០០ | ០២ | ០២ | ០០ | **១៧** |
| ក្រុមហ៊ុន Camintel 023,064 | ០១ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | **០១** |
| សរុបស្ថានីយ៍ទូរស័ព្ទ | **២២** | **០៨** | **២៩** | **០៧** | **០៦** | **១៧** | **១៨** | **០៦** | **១១៣** |
| VSAT Internet | ១១ | ០០ | ០១ | ០០ | ០០ | ០០ | ០០ | ០០ | **១២** |
| ស្ថានីយ៍វិទ្យុ FM99 | ០០ | ០០ | ០០ | ០០ | ០០ | ០១ | ០០ | ០០ | **០១** |
| ស្ថានីយ៍វិទ្យុ និងទូរទស្សន៍ បាយ័ន FM95 | ០០ | ០០ | ០០ | ០០ | ០០ | ០១ | ០០ | ០០ | **០១** |
| វិទ្យុ ICOM 50W | - | - | - | - | - | - | - | - | **២០** |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| វិទ្យុ ICOM 5W | - | - | - | - | - | - | - | - | ៣២ |

លើសពីនេះ ខេត្តក៏មានបណ្តាញកាប្លិឌុបទិចរាយតាមបណ្តោយផ្លូវជាតិ និងចូលទៅទីប្រជុំជនមួយចំនួន នៅទូទាំងខេត្ត និងការគ្រប់គ្រងរលកអាកាសវិទ្យុ និងអាជ្ញាប័ណ្ណ។

យោងតាមស្ថានភាពជាក់ស្តែងនៃវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ជួបប្រទះនូវបញ្ហាដូចជាគ្មានទីតាំង និងការិយាល័យសម្រាប់បម្រើការងារវិស័យតាមប្រៃសណីយ៍នៅបណ្តាក្រុង ស្រុក ខ្វះមន្ត្រីជំនាញសម្រាប់បំពេញការងារនៅតាមបណ្តាក្រុង ស្រុក។ ការបញ្ជូន និងទទួលលិខិតគ្រប់ប្រភេទទៅក្នុង និងក្រៅប្រទេសមិនអាចបម្រើឱ្យតម្រូវការអ្នកប្រើប្រាស់បានទាន់ពេលវេលា ព្រោះមានការយឺតយ៉ាវមិនឆ្លើយតបទៅនឹងពាក្យមួយឃ្លាថា "រហ័សទាន់ ចិត្តឥតបែកការ "។ បញ្ហាអាណត្តិប្រៃសណីយ៍ជាក់ស្តែងកន្លងមក ពុំមានអតិថិជនបញ្ជូន និងទទួលទេ ដោយសេវាថ្លៃទម្រង់បែបបទច្រើន ធ្វើឱ្យអតិថិជនធុញទ្រាន់ ហើយទៅប្រើសេវាផ្សេងៗខាងក្រៅវិញ។ ខ្វះការទំនាក់ទំនង និងផ្សព្វផ្សាយសេវាមិនបានជ្រួតជ្រាបដល់អតិថិជន។ សមត្ថភាពមន្ត្រីបម្រើការងារជំនាញបច្ចេកទេសមានកម្រិត ការផ្សព្វផ្សាយច្បាប់ដល់អ្នកគោរព និងអនុវត្តច្បាប់មិនទាន់បានជ្រួតជ្រាបឡើយ។ បណ្តាក្រុមហ៊ុនទូរស័ព្ទចល័តមួយចំនួនដែលបោះទីតាំងនៅលើទឹកដីខេត្ត ពុំទាន់មានច្បាប់សាងសង់អង់តែននៅឡើយ។ ឧបករណ៍បំពាក់ដែលក្រុមហ៊ុននីមួយៗ បានបំពាក់នៅតាមអង់តែនមួយចំនួន មិនបានរាយការណ៍ឱ្យអង្គភាពពាក់ព័ន្ធបានដឹងឡើយ។ អ្នកប្រើប្រាស់វិទ្យុរលកអាកាសមួយចំនួនមិនទាន់មានច្បាប់ឱ្យប្រើប្រាស់ទេ ។

### ១.២.១.៧ វិស័យពាណិជ្ជកម្ម

មន្ទីរពាណិជ្ជកម្មមានមន្ត្រីក្របខ័ណ្ឌចំនួន១២នាក់ស្រី៤នាក់ មានមន្ត្រីចំនួន៨នាក់(ស្រី៣នាក់)ក្នុងមន្ទីរ និងតាមបណ្តាស្រុកមានមន្ត្រីចំនួន៤នាក់(ស្រី១នាក់)។ មន្ទីរមាន០៣ការិយាល័យ:១-ការិយាល័យរដ្ឋបាលហិរញ្ញវត្ថុមាន៤ផ្នែក ២-ការិយាល័យគ្រប់គ្រងអាជីវកម្ម និងតម្លៃមាន៥ផ្នែក និង៣-ការិយាល័យជំរុញពាណិជ្ជកម្មមាន៥ផ្នែក។

ខេត្តព្រះវិហារមាន ផ្សារសំខាន់ៗចំនួន០៩កន្លែង គឺផ្សារធំ០១កន្លែងនៅទីរួមខេត្ត(ផ្សារកំពង់ប្រណាក)កំពុងដំណើរការជាធម្មតា ផ្សារ តូចៗមាន០៦កន្លែង នៅទីរួមស្រុករវៀង ជាំក្សាន្ត គូលែន ឆែប សង្គមថ្មី ជ័យសែន និងផ្សារ០២កន្លែង ផ្សេងទៀតផ្សារស្រយ៉ង់ នៅក្នុងឃុំស្រយ៉ង់ ស្រុកគូលែន និងផ្សារស្រអែម នៅក្នុងឃុំកន្ទួត ស្រុកជាំក្សាន្ត។

ផលិតផលក្នុងស្រុកមួយចំនួនមិនអាចជ្រៀតចូលទីផ្សារបាន ឬមិនអាចប្រកួតប្រជែងក្នុងទីផ្សារ និងពុំទាន់មានទីផ្សារត្រឹមត្រូវ តម្លៃផលិតផលឡើងចុះតាមឈ្មួញជាអ្នកកំណត់។ ម្យ៉ាងទៀត ផលិតផលពុំទាន់មានការកែច្នៃវេចខ្ចប់ត្រឹមត្រូវតាមស្តង់ដាបច្ចេកទេសនៅឡើយ។

ដើម្បីដោះស្រាយបញ្ហានេះ យើងត្រូវផ្តល់ព័ត៌មានទីផ្សារ សាងសង់មណ្ឌលពិព័រណ៍ដាក់តាំងផលិតផល លើកកំពស់ការផ្តល់សេវាកម្ម និងបណ្តុះបណ្តាលធនធានមនុស្ស រៀបចំកម្មវិធីតាំងពិព័រណ៍ផលិតផលពាណិជ្ជកម្មខេត្ត បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេសថ្នាក់ខេត្ត ថ្នាក់ស្រុក ភ្នាក់ងារផ្សព្វផ្សាយផលិតផល និងព័ត៌មានទីផ្សារ ជំរុញផលិតផលនាំចេញ កែលំអធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានភាព

ប្រសើរឡើង ពង្រីកសកម្មភាពទីផ្សារ ព័ត៌មានទីផ្សារ និងបង្កើនបរិមាណ គុណភាពផលិតផលកសិកម្ម សិប្បកម្ម ដើម្បីប្រកួតប្រជែងក្នុងទីផ្សារ។

### ១.២.១.៨ វិស័យឧស្សាហកម្មរ៉ែ និង ថាមពល

ខេត្តមានធនធានរ៉ែជាច្រើនប្រភេទដូចជារ៉ែមាស រ៉ែដែក ត្បូងថ្ម...បច្ចុប្បន្នមានក្រុមហ៊ុនឯកជនបាននឹងកំពុងចូលសិក្សាស្រាវជ្រាវជាច្រើនកន្លែង។ ខេត្តមានក្រុមហ៊ុនឯកជនបានចូលមកផលិតថាមពលអគ្គិសនីនៅទីរួមខេត្ត ១កន្លែង និងនៅទីរួមស្រុកចំនួន៣កន្លែងទៀត( ស្រុករវៀង ជាំក្សាន្ត គូលែន) ។

ទន្ទឹមនឹងនេះ ទីរួមខេត្តមានបណ្តាញប្រព័ន្ធទឹកស្អាត ១កន្លែង ដែលផលិតដោយក្រុមហ៊ុនទឹកស្អាត។ ប៉ុន្តែបណ្តាញទុយោចែកចាយទឹក មិនធានានឹងសម្ពាធទឹក ឧស្សាហ៍បែកធ្លាយ សម្ពាធទឹកខ្សោយ។ លើសពីនេះ ខេត្តមានសហគ្រាសសំណង់ សហគ្រាសផលិតទឹកបរិសុទ្ធ សិប្បកម្មធុនតូច និងមធ្យម( ផលិតទឹកស៊ីអ៊ីវ ទឹកត្រី សិប្បកម្មកែច្នៃអនុផលព្រៃឈើ សិប្បកម្មតំបាញ...) ។

### ១.២.១.៩ វិស័យអភិវឌ្ឍន៍ជនបទ

#### ក. ការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

ទឹកស្អាតជាតម្រូវការចាំបាច់បំផុត សម្រាប់ប្រជាពលរដ្ឋនៅតាមជនបទក្នុងខេត្តព្រះវិហារ។ ជាទូទៅ ក្នុងរដូវប្រាំងប្រជាពលរដ្ឋតែងជួបការខ្វះខាតទឹកយ៉ាងខ្លាំង ដោយត្រូវចំណាយពេលយ៉ាងច្រើនក្នុងការស្វែងរកទឹកសម្រាប់ប្រើប្រាស់ និងបរិភោគ ហើយនេះគឺជាបន្ទុកយ៉ាងធ្ងន់ធ្ងរសម្រាប់ស្ត្រី និងកុមារ ដែលជាហេតុធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពរបស់ស្ត្រី និងការរៀនសូត្ររបស់កុមារ។ យោងតាមទិន្នន័យដែលប្រមូលបានពីថ្នាក់ភូមិ និងឃុំ បង្ហាញឱ្យឃើញថាចំនួនគ្រួសារមានទឹកអណ្តូងជិតផ្ទះប្រើមានតែ ៣៤.០៩% ប៉ុណ្ណោះ ដោយឡែកនៅស្រុកជ័យសែន ស្រុកឆែប និងស្រុកសង្គមថ្មីមានតែ១៥ ទៅ២៧% ប៉ុណ្ណោះ គ្រួសារដែលមានទឹកអណ្តូងនៅជិតផ្ទះប្រើ។ ជារួមនៅក្នុងខេត្ត គ្រួសារដែលមានទឹកអណ្តូងប្រើប្រាស់ឆ្ងាយពីផ្ទះលើសពី១៥០ម៉ែត្រមាន១៦.៤៧% និង៤៩.៤៤% ទៀតគឺប្រើប្រាស់ទឹកពីប្រភពផ្សេងៗ។

#### ខ.ការងារផ្លូវជនបទ

ផ្លូវជនបទ គឺជាប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនដ៏សំខាន់ សម្រាប់តភ្ជាប់ពីជនបទ មកកាន់ផ្លូវជាតិ ផ្លូវខេត្ត ទីផ្សារ សាលារៀន មណ្ឌលសុខភាព វត្តអារាម តំបន់ទេសចរណ៍ និងកសិកម្ម។ល។ ផ្លូវជនបទបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងកាត់បន្ថយភាពក្រីក្រ។ ក្នុងការងារកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ ដោយប្រើប្រាស់ថវិកាជាតិ មន្ទីរបានអនុវត្តគម្រោងថែទាំផ្លូវលំជាលក្ខណៈខួប១ខ្សែប្រវែង ២៦ គ.ម លូ៥កន្លែង ថែទាំជាលក្ខណៈប្រចាំ១ខ្សែប្រវែង ២៧ គ.ម ជួលជុលនិងសាងសង់ផ្លូវ អនុវត្តដោយកងវិស្វកម្ម និងក្រសួងអភិវឌ្ឍន៍ជនបទ ប្រវែង ៩២ គ.ម ផ្លូវប្រភេទ DBST ប្រវែង ៨ គ.ម ស្ពាន១៨ កន្លែង និងលូ១៣២កន្លែង។

**ប្រភេទផ្លូវជនបទ:** ផ្លូវជនបទប្រភេទទី១ : ផ្លូវជាតិ-ផ្លូវខេត្ត ទៅក្រុង ស្រុក ខណ្ឌ និងពីក្រុង ស្រុក ខណ្ឌ

ទៅ ក្រុង ស្រុក ខណ្ឌ។ ផ្លូវជនបទប្រភេទទី២ : ក្រុង ស្រុក ខណ្ឌ ទៅឃុំ សង្កាត់។ ផ្លូវជនបទប្រភេទទី៣ : ឃុំ សង្កាត់ ទៅ ឃុំ សង្កាត់។ ផ្លូវជនបទប្រភេទទី៤ : ឃុំ សង្កាត់ ទៅភូមិ ពីភូមិ ទៅភូមិ និងផ្លូវក្នុងភូមិ។ មន្ទីរបានជួបប្រទះបញ្ហាដូចជាការដឹកទំនិញលើសទម្ងន់លើផ្លូវជនបទ ការចូលរួមរបស់សហគមន៍ និងអាជ្ញាធរក្នុងការថែទាំផ្លូវជនបទនៅមានកម្រិត កង្វះថវិកាសម្រាប់ជួសជុល និងថែទាំផ្លូវជនបទ មានបម្រែបម្រួលអាកាសធាតុដែលបណ្តាលឱ្យមានការខូចខាតផ្លូវ កង្វះធនធានមនុស្ស ឧបករណ៍ និងសម្ភារៈសម្រាប់ការងារគ្រប់គ្រង និងថែទាំផ្លូវជនបទ កង្វះឯកសារ និងលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការគ្រប់គ្រង និងថែទាំផ្លូវជនបទ។

## ១.២.២ ស្ថានភាពសង្គមកិច្ច

### ១.២.២.១ វិស័យអប់រំ

វិស័យអប់រំយុវជន និងកីឡាខេត្ត បានខិតខំអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំខេត្តឆ្នាំ២០០៧-២០០៩ ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០របស់ក្រសួងអប់រំយុវជននិងកីឡាខេត្ត ដើម្បីឈានទៅសម្រេចផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០១១-២០១៥ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ជាពិសេសដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងនិតិកាលទី៤របស់សភាជាតិគឺជំរុញកំណើនការងារ ធានាសមធម៌ និងប្រសិទ្ធភាពឱ្យសមស្របតាមនិន្នាការរីកចម្រើនរបស់ពិភពលោក ។

សម្រាប់ឆ្នាំសិក្សា២០១០-២០១១នេះ ខេត្តមានសាលារៀនគ្រប់ភូមិសិក្សាចំនួន២៦៨សាលា កើនជាងឆ្នាំសិក្សា២០០៩-២០១០ ចំនួន២៥សាលា និងមានសិស្សានុសិស្សសរុបចំនួន៤៨.៣៤៦នាក់ ស្រី២៣.០៧០នាក់ កើនចំនួន ២.២៩៣នាក់ ស្រី១.២៣៧នាក់ ស្មើនឹង៥% ។

មត្តេយ្យសិក្សាមានចំនួន១៩សាលា សិស្សសរុប៩១២នាក់ ស្រី៥៤៧នាក់។ បឋមសិក្សាមាន ២០៥សាលា សិស្សសរុប៣៧.៦០៦នាក់ស្រី១៨.៣៤៦នាក់ ហើយមានអត្រាពិតចូលរៀនថ្មី៩០,០៧% និងអត្រារួមនៃការសិក្សានៅបឋមសិក្សា៩២,៧២%។ មធ្យមសិក្សាបឋមភូមិមាន ៣៦សាលា(នៅសល់១២ឃុំទៀត ពុំទាន់មានអនុវិទ្យាល័យ) មានសិស្សសរុប៦.៤៦៣នាក់ ស្រី៣.៣២៨នាក់ និងមធ្យមសិក្សាទុតិយភូមិមាន ៨សាលា(ស្រុកត្បែងមានជ័យពុំទាន់មានវិទ្យាល័យ)សិស្សសរុបចំនួន៣.៣៦៥នាក់ ស្រី១.៥០៧នាក់។ ខេត្តមានសាលាគរុកោសល្យនិងវិក្រិត្យការចំនួន ១កន្លែង ដែលមានគរុសិស្សឆ្នាំទី២ជំនាន់ទី២៩ ចំនួន៧៣នាក់ ស្រី៤៦នាក់ និងគរុសិស្សឆ្នាំទី១ ជំនាន់ទី៣០ ចំនួន៨៤នាក់ ស្រី៤៧នាក់ ។

ទោះបីមានការរីកចម្រើនក៏ដោយ មន្ទីរបានជួបប្រទះនូវបញ្ហាលំបាកជាច្រើនដូចជា: ខ្វះបន្ទប់រៀន អគារសិក្សា និងគ្រូមត្តេយ្យសិក្សាដែលមានលក្ខណៈសមស្របតាមបច្ចេកទេសគរុកោសល្យមត្តេយ្យ។ ខ្វះគ្រូបង្រៀននៅតាមសាលារៀននៅតំបន់ដាច់ស្រយាល និងខ្វះសៀវភៅសិក្សាគោលសម្រាប់គ្រូ និងសិស្ស។ សាលារៀននៅឆ្ងាយពីភូមិតូចៗដែលកើតថ្មី ឃុំមួយចំនួនពុំទាន់មានអនុវិទ្យាល័យ និងពុំទាន់មានគ្រូ សមស្របទៅតាមមុខវិជ្ជាឯកទេសនៅមធ្យមសិក្សា។ ការអនុវត្តម៉ោងសិក្សាទៅតាមប្រតិទិនសិក្សាពុំទាន់បានសមស្របតាមការណែនាំរបស់ក្រសួងអប់រំយុវជន និងកីឡា។ ប្រជាពលរដ្ឋនៅរាយប៉ាយតាមភូមិកើតថ្មី ផ្លាស់ប្តូរទីលំនៅញឹកញាប់ និងយកកូនទៅស្រែចំការ

នៅរដូវធ្វើស្រែចំការ ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ មន្ទីរអប់រំយុវជន និងកីឡាខេត្ត មានការសហការល្អជាមួយអង្គការជាតិ អន្តរជាតិ សប្បុរសជនជាតិ អន្តរជាតិ និងសហគមន៍នៅក្នុងមូលដ្ឋានបានបង្កើតជាសាលារោងដោលដែលជាសាលាឆ្លងកាត់ និងជាសាលាដែលស្ថិតនៅក្បែរផ្ទះប្រជាជនបំផុតសម្រាប់ឱ្យកុមារដែលទើបនឹងគ្រប់អាយុបានចូលរៀននៅថ្នាក់ទី១ ទី២ និងបានរៀបចំឱ្យមានថ្នាក់សម្រាប់មធ្យមសិក្សាបឋមភូមិនៅក្នុងបឋមសិក្សា។ ដោយមានកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយដៃគូអភិវឌ្ឍន៍នានាជាច្រើនដែលមានក្នុងខេត្ត បាននាំគ្នាពុះពារជួយសង់ជាសាលាឆ្លងកាត់ បណ្តុះបណ្តាលកែលម្អវិធីសាស្ត្របង្រៀនថ្មីៗ និងកែលម្អបរិស្ថានសាលាឱ្យទៅជាបរិស្ថានសិក្សាកុមារមេត្រី។ ម្យ៉ាងវិញទៀត មន្ទីរបានរៀបចំឱ្យមានការប្រើប្រាស់គ្រូជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប ពីរពេល និងគ្រូបឋមសិក្សាជួយបង្រៀននៅបឋមភូមិ គ្រូមធ្យមសិក្សាបឋមភូមិជួយបង្រៀននៅមធ្យមសិក្សាទុតិយភូមិទៅតាមចំណេះដឹងមូលដ្ឋានដែលពួកគេមាន។

អត្រាអនក្ខរជនមានចំនួន៣០,៧០% ក្នុងនោះអនក្ខរជនជាស្ត្រីមានចំនួន១៦,៨៤% បញ្ហានេះជាឧបស័គ្គយ៉ាងធំសម្រាប់ការងារអភិវឌ្ឍន៍ក្នុងមូលដ្ឋានក៏ដូចជាការផ្តល់ចំណេះដឹងទូទៅសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

**តារាង: ស្ថានភាពអ្នកមិនចេះអក្សរ (យោងស្ថិតិភូមិ ឆ្នាំ២០០៩)**

| ស្ថានភាពអនក្ខរជន | 2007 | 2008 | 2009 | |
|---|---|---|---|---|
| | ភាគរយ | ភាគរយ | ភាគរយ | ចំនួន |
| អ្នកមិនចេះអក្សរសរុបអាយុពី១៥-៦០ឆ្នាំ | 30.70% | 28.49% | 27.85% | 26,511 នាក់ |
| ស្ត្រីមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | 16.84% | 14.86% | 14.43% | 13,736 នាក់ |
| អ្នកមិនចេះអក្សរសរុបអាយុពី១៥-១៧ឆ្នាំ | 17.47% | 15.55% | 15.19% | 2,100 នាក់ |
| ស្ត្រីមិនចេះអក្សរអាយុពី១៥-១៧ឆ្នាំ | 8.33% | 7.01% | 7.27% | 1,005 នាក់ |
| អ្នកមិនចេះអក្សរសរុបអាយុពី១៨-២៤ឆ្នាំ | 28.74% | 25.62% | 23.67% | 5,028 នាក់ |
| ស្ត្រីមិនចេះអក្សរអាយុពី១៨-២៤ឆ្នាំ | 14.99% | 13.18% | 11.38% | 2,418 នាក់ |
| អ្នកមិនចេះអក្សរសរុបអាយុពី២៥-៦០ឆ្នាំ | 34.36% | 32.45% | 32.23% | 19,383 នាក់ |
| ស្ត្រីមិនចេះអក្សរអាយុពី២៥-៦០ឆ្នាំ | 19.41% | 17.24% | 17.15% | 10,313 នាក់ |

***សំគាល់*** : ភាគរយធៀបជាមួយចំនួនមនុស្សតាមក្រុមអាយុនិមួយៗ (មិនមែនធៀបជាមួយប្រជាជនសរុបឡើយ) ។ ដោយឡែកភាគរយស្ត្រីមិនចេះ អក្សរ គិតធៀបចំនួនបុរស-ស្ត្រី ក្នុងចន្លោះអាយុនោះ ដើម្បីដឹងថា ក្នុងចំនួនភាគរយសរុបមានស្ត្រីមិនចេះអក្សរប៉ុន្មានភាគរយ ។

ក្រាហ្វិកទី: អ្នកមិនចេះអក្សរសរុបអាយុពី១៥-៦០ឆ្នាំ និងស្ត្រីមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំតាមបណ្តាស្រុកខណ្ឌ




***សំគាល់*** : ភាគរយអនក្ខរជនស្ត្រី ធៀបជាមួយចំនួនបុរស-ស្ត្រី ស្ថិតក្នុងចន្លោះអាយុ១៥-៦០ឆ្នាំ ដើម្បីដឹងថា ក្នុងភាគរយសរុបនោះមានស្ត្រីប៉ុន្មានភាគរយ ។

### ១.២.២.២ វិស័យសុខាភិបាល

មន្ទីរសុខាភិបាលមានស្រុកប្រតិបត្តិ០១ មន្ទីរពេទ្យបង្អែកខេត្ត០១ មណ្ឌលសុខភាព១៨ និងប៉ុស្តិ៍សុខភាព ១៣កន្លែង មានបុគ្គលិកសរុប២៦៣នាក់ ក្នុងនោះមានវេជ្ជបណ្ឌិត១៥នាក់ គ្រូពេទ្យ៥នាក់ ឱសថការី៣នាក់ ឆ្មបមធ្យម ២៣នាក់ ឆ្មបបឋម៦៨នាក់ គិលានុបដ្ឋាកមធ្យម២៣នាក់ និងគិលានុបដ្ឋាកបឋម៦៣នាក់ ។

ទោះបីវិស័យសុខាភិបាលបានរីកចំរើនពីមួយឆ្នាំទៅមួយឆ្នាំក៏ដោយក៏នៅពុំទាន់ឆ្លើយតបតាមតំរូវការរបស់ប្រជាជន ដោយយើងនៅមានការលំបាកដូចជាស្ថានភាពភូមិសាស្ត្រ ការរស់នៅរបស់ប្រជាជននៅរាយប៉ាយធ្វើឱ្យមានការលំបាកខ្លាំងសំរាប់អ្នកទទួលយកសេវា និងការផ្តល់សេវា។ ការខ្វះធនធានមនុស្សនៅជាអាទិភាពធ្វើឱ្យមានការលំបាកយ៉ាងខ្លាំងក្នុងការពង្រីកបន្ថែមនូវមណ្ឌលសុខភាព។ ដូច្នេះមន្ទីរមានការផែនការពង្រីកបន្ថែមនូវមូលដ្ឋានសុខាភិបាលដែលមានកំរិតប៉ុស្តិ៍សុខភាព។

មន្ទីរសុខាភិបាលខេត្តសំរេចលទ្ធផលបានអាស្រ័យលើ ការចូលរួមពីគ្រប់មជ្ឈដ្ឋានទូទាំងខេត្តដូចជា: សហគមន៍ មន្ទីរពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមួយចំនួនដូចជាអង្គការសុខភាពគ្មានព្រំដែន អង្គការរ៉ាឆា អង្គការទស្សនៈពិភពលោក អង្គការការីតាស អង្គការម្តាយរីករាយកូនរីករាយ អង្គការCWPD ពិសេសអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់។

**តារាង: ស្ថានភាពសេវាសុខភាពតាមបណ្តាស្រុក ក្រុង ក្នុងខេត្តព្រះវិហារ ឆ្នាំ២០០៩**

| ប្រភេទស្ថិតិ | | សរុបខេត្ត | ជ័យសែន | ឆែប | ជាំក្សាន្ត | គូលែន | រវៀង | សង្គមថ្មី | ត្បែងមានជ័យ | ក្រុងព្រះវិហារ |
|---|---|---|---|---|---|---|---|---|---|---|
| ចំនួនមន្ទីរពេទ្យបង្អែកខេត្ត | កន្លែង | **1** | 0 | 0 | 0 | 0 | 0 | 0 | | 1 |
| ចំនួនមណ្ឌលសុខភាពស្រុក | កន្លែង | **18** | 1 | 1 | 8 | 3 | 3 | 1 | 0 | 1 |
| ចំនួនប៉ុស្តិ៍សុខភាពឃុំ | កន្លែង | **13** | 1 | 2 | 2 | 2 | 3 | 1 | 2 | 0 |
| ចំនួនឆ្មបបុរាណឬឆ្មបទទួលបានការបណ្តុះ បណ្តាលតិចតួច | នាក់ | **715** | 78 | 94 | 70 | 95 | 223 | 72 | 44 | 39 |
| ចំនួនពេទ្យឆ្មប | នាក់ | **172** | 27 | 23 | 17 | 20 | 51 | 16 | 4 | 14 |
| ចំនួនស្ត្រីដែលបានឆ្លងទន្លេ | ឆ្មបបុរាណ | **1,852** | 283 | 366 | 177 | 278 | 400 | 207 | 105 | 36 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ឆ្លបពេទ្យ | **1,475** | 121 | 105 | 202 | 222 | 414 | 95 | 76 | 240 |
| | សរុប | **3,327** | 404 | 471 | 379 | 500 | 814 | 302 | 181 | 276 |
| ចំនួនមរណៈភាពមាតាបន្ទាប់ពីសំរាលកូនក្នុង ចន្លោះ ០-១ខែ | ឆ្មបបុរាណ | **22** | 3 | 3 | 4 | 1 | 1 | 6 | 4 | 0 |
| | ឆ្មបពេទ្យ | **11** | 2 | 1 | 3 | 0 | 2 | 3 | 0 | 0 |
| | សរុប | **33** | 5 | 4 | 7 | 1 | 3 | 9 | 4 | 0 |
| ចំនួនទារកដែលបានកើតរស់ | ឆ្មបបុរាណ | **1,859** | 283 | 366 | 177 | 278 | 405 | 207 | 107 | 36 |
| | ឆ្មបពេទ្យ | **1,477** | 121 | 105 | 202 | 223 | 415 | 95 | 76 | 240 |
| | សរុប | **3,336** | 404 | 471 | 379 | 501 | 820 | 302 | 183 | 276 |
| ចំនួនមរណៈភាពទារកក្នុងចន្លោះអាយុ ០-១ខែ | ឆ្មបបុរាណ | **158** | 17 | 23 | 16 | 23 | 42 | 21 | 15 | 1 |
| | ឆ្មបពេទ្យ | **42** | 6 | 4 | 10 | 4 | 10 | 6 | 1 | 1 |
| | សរុប | **200** | 23 | 27 | 26 | 27 | 52 | 27 | 16 | 2 |
| ចំនួនមរណៈភាពកុមារអាយុក្រោម៥ឆ្នាំ (គិតពីអាយុ១ខែឡើងទៅ) | | **214** | 214 | 22 | 25 | 17 | 8 | 41 | 82 | 9 |
| ចំនួនទារកដែលបានចុះសំបុត្រកំណើត | | **825** | 825 | 108 | 94 | 169 | 80 | 145 | 15 | 76 |
| ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែ ក្នុងឆ្នាំ២០០៦ | | **2,239** | 2,239 | 285 | 365 | 262 | 336 | 476 | 195 | 130 |
| ចំនួនកុមារដែលមានអាយុចន្លោះពី៩-១២ខែបានចាក់ថ្នាំបង្ការគ្រប់ចំនួន | | **2,026** | 2,026 | 268 | 269 | 248 | 326 | 428 | 185 | 130 |

ប្រភព : ទិន្នន័យឃុំឆ្នាំ២០០៩

### ១.២.២.៣ វិស័យវប្បធម៌ និងសិល្បៈ

ខេត្តព្រះវិហារជាខេត្តមួយសម្បូរទៅដោយបេតិកភ័ណ្ឌវប្បធម៌រូបីយរួមមាន ប្រាង្គប្រាសាទជាច្រើនកន្លែង និងស្រះបុរាណ ស្ពានបុរាណ រមណីយដ្ឋានធម្មជាតិ និងបុរេប្រវត្តិសាស្ត្រម្លូព្រៃ។ មិនតែប៉ុណ្ណោះ នៅមានបេតិកភ័ណ្ឌអរូបីយជាច្រើនប្រភេទ ច្រើនទម្រង់ទៀតដូចជាចម្រៀង របាំ ល្ខោន ក្បាច់គុណបុរាណ និងទំនៀមទំលាប់ប្រពៃណីរបស់ជនជាតិដើមភាគតិច។ ទាំងនេះជាស្នាដៃដែលបុព្វបុរសដូនតាយើងបានបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយ។

កេរ្តិ៍មរតកដ៏សម្បូរបែបនៃសម្បត្តិវប្បធម៌ទាំងអស់នេះ បច្ចុប្បន្នបានក្លាយជាកម្លាំងចលករប្រកបដោយប្រសិទ្ធភាពបំផុតក្នុងការអភិវឌ្ឍនសេដ្ឋកិច្ចសង្គម តាមរយៈការបង្កើតការងារ បង្កើនចំណូលស្របតាមទស្សនទាន **(វប្បធម៌គឺជាសេដ្ឋកិច្ចជាតិ)** ដែលជាចំណែកមួយដ៏ចាំបាច់ក្នុងការចូលរួមកាត់បន្ថយភាពក្រីក្រ របស់ប្រជាជនស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ដោយបានដាក់ចេញនូវកម្មវិធីនយោបាយៈ ថែរក្សាការពារលើកតម្កើងកេរ្តិ៍ដំណែលវប្បធម៌ជាតិនិងអភិវឌ្ឍន៍សកម្មភាពវប្បធម៌គ្រប់ជំនាញនៅតាមមូលដ្ឋាន។ ជំរុញផលិតកម្មសិប្បកម្មវប្បធម៌ដោយលើកទឹកចិត្តឱ្យមានការបង្កើតស្នាដៃថ្មី និងផ្សព្វផ្សាយអំពីផលិតផលវប្បធម៌ខ្មែរដ៏សម្បូរបែប។ អប់រំអំពីវប្បធម៌ និងសីលធម៌ដ៏ល្អថ្លៃថ្លារបស់ជាតិ ទប់ស្កាត់ការហូរចូលឥតឈប់ឈរនៃវប្បធម៌

អវិជ្ជមានពីបរទេស កាត់បន្ថយសកម្មភាពមិនល្អក្នុងស្រទាប់យុវជន និងកុមារដែលធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ប្រពៃណីទំនៀមទម្លាប់ដ៏ល្អផូរផង់របស់ជាតិ ។

បន្តថែរក្សា និងអភិវឌ្ឍន៍វប្បធម៌ប្រពៃណី ទំនៀមទម្លាប់ ភាសារបស់បងប្អូនជនជាតិដើមភាគតិច និងជំរុញការអភិវឌ្ឍតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅឱ្យមានការរីកចម្រើនខាងសង្គមសេដ្ឋកិច្ច និងជីវភាពរស់នៅឈានឡើងស្របតាមកម្រិតរីកចម្រើនរួមរបស់ជាតិ ។

កន្លងមកក៏ដូចជាបច្ចុប្បន្ន មន្ទីរបានជួបប្រទះបញ្ហាប្រឈមដូចជាការងារថែរក្សានិងគ្រប់គ្រងនៅមានកំរិតដោយបណ្តាលមកពីកង្វះក្របខ័ណ្ឌ និង ធនធានមនុស្ស ។ ប្រជាពលរដ្ឋខ្វះការយល់ដឹងពីតម្លៃបេតិកភ័ណ្ឌជាតិ និងអត្តសញ្ញាណជាតិដោយមូលហេតុភាពក្រីក្រ លំហូរចូលវប្បធម៌អវិជ្ជមានពីបរទេស ការបណ្តុះបណ្តាល និងផ្សព្វផ្សាយពីច្បាប់ពាក់ព័ន្ធនិងវិស័យវប្បធម៌មិនបានទូលំទូលាយដល់មូលដ្ឋាន ។

ដោយសារបញ្ហា និងមូលហេតុទាំងនេះ មន្ទីរបានរៀបចំជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឱ្យប្រសើរឡើងទាំងផ្នែកធនធានមនុស្ស និងការចូលរួមគាំទ្រពីមហាជននៅក្នុងខេត្តទាំងមូលដើម្បីថែរក្សា និងលើកតម្កើងមរតកវប្បធម៌ឱ្យបានគង់វង្ស ។

វិស័យវប្បធម៌ និងវិចិត្រសិល្បៈនៅក្នុងខេត្តព្រះវិហារ នៅពុំទាន់ទទួលបានការចូលរួមគាំទ្រ និងអនុវត្តន៍លើគំរោងសំរាប់អភិវឌ្ឍន៍ក្នុងខេត្ត ពីអង្គការសង្គមស៊ីវិលនានានៅឡើយទេ ។

### ១.២.២.៤ វិស័យព័ត៌មាន

មន្ទីរព័ត៌មាន មានអគាររដ្ឋបាល២ដែលស្ថិតក្នុងទីតាំងនៃបរិវេណមន្ទីរ១អគាររដ្ឋបាលធ្វើអំពីឈើមានភាពចាស់ទ្រុឌទ្រោមនិង១ទៀតជាអគារស្ទូឌីយូវិទ្យុដែលកំពុងសាងសង់ពុំទាន់បំពាក់ឧបករណ៍ ។ មានមន្ត្រីក្នុងក្របខ័ណ្ឌសរុប១៦នាក់ ស្រី៣នាក់ និងបុគ្គលិកជាប់កិច្ចសន្យា១៥នាក់ ។ ខេត្តមានស្ថានីយ៍វិទ្យុឯកជន២កន្លែង និងស្ថានីយ៍ទូរទស្សន៍១កន្លែងដែលស្ថិតក្នុងភូមិស្រអែម ឃុំកន្ទួត ស្រុកជាំក្សាន្ត និងមានស្ថានីយ៍ទូរទស្សន៍ខ្សែកាប២កន្លែង ១កន្លែងនៅក្រុងព្រះវិហារ ១កន្លែងទៀតនៅទីរួមស្រុករវៀងដែលកំពុងដំណើរការ ។

មន្ទីរព័ត៌មានមានអគារទ្រុឌទ្រោម ពុំទាន់មានស្ថានីយ៍វិទ្យុ ឬទូរទស្សន៍នៅឡើយ សមត្ថភាពមន្ត្រីនៅមានកំរិត ពុំទាន់មានឧបករណ៍បញ្ជូនព័ត៌មានទំនើបដែលអាចបញ្ជូនព័ត៌មានទាន់ពេលវេលា ។ ស្ថានីយ៍ទូរទស្សន៍ឬស្ថានីយ៍វិទ្យុជារបស់ឯកជនដែលមាននៅក្នុងខេត្ត កម្លាំងផ្សាយពុំបានគ្របដណ្តប់១០០%នៅឡើយ ។

មន្ទីរគ្រោងធ្វើការសាងសង់អគាររដ្ឋបាល និងស្ថានីយ៍វិទ្យុ ឬទូរទស្សន៍ព្រមទាំងបំពាក់ឧបករណ៍វិទ្យុ ឬទូរទស្សន៍ និងឧបករណ៍បញ្ជូនព័ត៌មានឱ្យឆ្លើយតបនឹងតម្រូវការ ។ បង្កើនសមត្ថភាពមន្ត្រី បង្កើនកិច្ចសហប្រតិបត្តិការ និងដាក់មន្ត្រីព័ត៌មានអចិន្ត្រៃយ៍គ្រប់ស្រុក ដើម្បីមានមូលដ្ឋានក្នុងការបញ្ជូនព័ត៌មានមកមន្ទីរ ។

វិស័យព័ត៌មានដែលកំពុងដំណើរការបានដោយមានការចង្អុលបង្ហាញពីក្រសួង និងអាជ្ញាធរខេត្ត ព្រមទាំងមានការសហការយ៉ាងល្អពីបណ្តាញសារព័ត៌មានក្នុងខេត្ត ស្ថានីយ៍ទូរទស្សន៍ ឬវិទ្យុឯកជន និងការរួមចំណែកពីស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីដោះស្រាយបញ្ហានានាក្នុងខេត្ត ។

### ១.២.២.៥ វិស័យយេនឌ័រ

ការជំរុញលើកតម្កើងសមភាពយេនឌ័រនិងការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារជាទិសដៅមួយដ៏សំខាន់របស់ខេត្តក៏ដូចជាគោលដៅរាជរដ្ឋាភិបាល ។ បច្ចុប្បន្នក្នុងខេត្តព្រះវិហារ ទាំងស្ថាប័នរាជរដ្ឋាភិបាលក៏ដូចជាអង្គការមិន-មែនរដ្ឋាភិបាលកំពុងខិតខំផ្សព្វផ្សាយ និង ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសមភាពយេនឌ័រ ដោយបានអនុវត្តការបញ្ជ្រាប យេនឌ័រ ការស្វែងរកមតិគាំទ្រ និងផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ ទប់ស្កាត់ការជួញដូរស្ត្រី និងកុមារដល់ថ្នាក់មូលដ្ឋានភូមិ ឃុំ។ ម្យ៉ាងវិញទៀតក៏មានការជំរុញលើកទឹកចិត្តដល់ស្ត្រីឱ្យមានការចូលរួមក្នុងសកម្មភាពការងារសង្គមឱ្យកាន់តែច្រើនថែមទៀតតាមរយៈគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

**តារាង: ស្ថានភាពការងារស្ត្រីនៅមូលដ្ឋាន** (យោងស្ថិតិភូមិ ឆ្នាំ២០០៩)

| បរិយាយ | 2007 | 2008 | 2009 | |
|---|---|---|---|---|
| | ភាគរយ | ភាគរយ | ភាគរយ | ចំនួន |
| ចំនួនមនុស្សចូលរួមក្នុងការងារសង្គមស៊ីវិល | 3.17% | 2.17% | 1.49% | 2,620 នាក់ |
| ចំនួនមនុស្សស្រីចូលរួមក្នុងការងារសង្គមស៊ីវិល | 1.59% | 1.04% | 0.69% | 1,207 នាក់ |
| ចំនួនមនុស្សអាយុ១៨-៦០ដែលគ្មានការងារធ្វើពិតប្រាកដ និងទៀងទាត់ | 2.58% | 2.44% | 2.92% | 2,375 នាក់ |
| ចំនួនមនុស្សស្រីអាយុ១៨-៦០ដែលគ្មានការងារធ្វើពិតប្រាកដ និងទៀងទាត់ | 1.37% | 1.21% | 1.48% | 1,205 នាក់ |

***សំគាល់*** : ក្រុមមនុស្សអាយុ១៨-៦០ ដែលគ្មានការងារធ្វើពិតប្រាកដភាគរយ ត្រូវគិតធៀបជាមួយក្រុមអាយុ១៨-៦០ឆ្នាំ មិនមែនធៀបជាមួយមនុស្សសរុប គ្រប់ក្រុមអាយុឡើយ ។

ក្រាហ្វិក: អត្រាស្ត្រីចូលរួមក្នុងការងារសង្គមស៊ីវិលនិងគ្មានការងារច្បាស់លាស់តាមបណ្តាស្រុក ក្រុង




**តារាង: ស្ថានភាពស្ត្រីជាមេគ្រួសារ** (យោងស្ថិតិភូមិឆ្នាំ២០០៩)

| ប្រភេទគ្រួសារដែលមាន : | 2007 | 2008 | 2009 | |
|---|---|---|---|---|
| | ភាគរយ | ភាគរយ | ភាគរយ | ចំនួន |
| ស្ត្រីជាមេគ្រួសារ | 11.95% | 9.85% | 9.64% | 3,612 គ្រួសារ |
| ស្ត្រីជាមេគ្រួសារមានកូនតូចអាយុតិចជាង៥ឆ្នាំ | 2.47% | 1.81% | 1.74% | 653 គ្រួសារ |

## ក្រាហ្វិក: អត្រាគ្រួសារដែលស្ត្រីជាមេគ្រួសារនិងមានកូនតូចអាយុតិចជាង៥ឆ្នាំ តាមបណ្តាស្រុក ក្រុង




## តារាង: កំណត់ហេតុថ្នាក់ឃុំសង្កាត់អំពីអំពើហឹង្សាក្នុងគ្រួសារ ឆ្នាំ ២០០៩ (យោងទិន្នន័យឃុំឆ្នាំ២០០៩)

| បរិយាយ | | 2007 | 2008 | 2009 |
|---|---|---|---|---|
| ចំនួនគ្រួសារដែលមានអំពើហឹង្សាក្នុងគ្រួសារ | | 865 គ្រួសារ | 1,061 គ្រួសារ | 1,085 គ្រួសារ |
| % គ្រួសារដែលមានអំពើហឹង្សាក្នុងគ្រួសារ | | 2.62% | 3.03% | 2.90% |
| ចំនួនករណី(ដង)អំពើហឹង្សាក្នុងគ្រួសារដែលមេភូមិរាយការណ៍ | | 624 ករណី | 670 ករណី | 835 ករណី |
| ក្នុងនោះ | 288 ករណី | 293 ករណី | 357 ករណី | 357 ករណី |
| | 21 ករណី | 41 ករណី | 22 ករណី | 22 ករណី |
| | 173 ករណី | 220 ករណី | 264 ករណី | 264 ករណី |
| | 142 ករណី | 116 ករណី | 192 ករណី | 192 ករណី |
| សរុបចំនួនសេចក្តីសំរេចរដ្ឋបាលផ្នែកអំពើហឹង្សាក្នុងគ្រួសារ | | 246 ករណី | 340 ករណី | 522 ករណី |
| % សេចក្តីសំរេចរដ្ឋបាលផ្នែកអំពើហឹង្សាក្នុងគ្រួសារ | | 39.42% | 50.75% | 62.51% |

## ក្រាហ្វិក: ភាគរយគ្រួសារមានអំពើហឹង្សាក្នុងគ្រួសារតាមបណ្តាស្រុក ក្រុង



### ១.២.៣ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន

ខេត្តព្រះវិហារសម្បូរទៅដោយព្រៃភ្នំ ស្ទឹង បឹង អូរ ធនធានរ៉ែ និងសត្វព្រៃ។ ខេត្តមានតំបន់ការពារធនធានធម្មជាតិចំនួន៣កន្លែង គឺដែនជំរកសត្វព្រៃគូលែនព្រហ្មទេព ដែនជំរកសត្វព្រៃបឹងពែរ និងដែនការពារទេសភាពប្រាសាទព្រះវិហារ ដែលមានផ្ទៃដីសរុបទាំងអស់ប្រមាណជាង៣០០.០០០ហិចតា។ បច្ចុប្បន្ន ដោយមានសន្តិភាពប្រជាពលរដ្ឋអាចប្រកបមុខរបរកសិកម្ម និងពិសេសដោយការបន្លាស់ទី នៃប្រជាពលរដ្ឋពីខេត្តផ្សេងៗ និងកំណើនប្រជាជនផ្ទាល់ក្នុងស្រុកបានធ្វើឱ្យមានបញ្ហាជាច្រើនដូចជាទំនាស់ដីធ្លី ការបំផ្លិចបំផ្លាញព្រៃឈើ និងការបំពុលបរិស្ថានដែលគួរឱ្យព្រួយបារម្ភក្នុងពេលបច្ចុប្បន្ន និងអនាគត។ ដើម្បីជៀសវាងបញ្ហាទាំងនេះ អាជ្ញាធរខេត្តក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបាននិងកំពុងធ្វើការទប់ស្កាត់តាមរយៈការចុះផ្សព្វផ្សាយច្បាប់ភូមិបាលច្បាប់ព្រៃឈើនិងកិច្ចការពារបរិស្ថានដល់ប្រជាពលរដ្ឋ។ កន្លងមក ខេត្តបានរៀបចំកំណត់ព្រំប្រទល់តំបន់អភិរក្សសត្វព្រៃ និងរៀបចំឱ្យមានសហគមន៍ព្រៃឈើដើម្បីឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានចូលរួមក្នុងការគ្រប់គ្រង ការពារព្រៃឈើ និងសម្បត្តិធម្មជាតិផ្សេងៗទៀត។ ការអនុវត្តន៍ការងារនេះ បានជួបប្រទះនូវការលំបាកខ្លាំងគួរសមដែរដោយសារតម្រូវការជាក់ស្តែងខ្ពស់ ធនធានមនុស្សតិច និងថវិកានៅមានកំរិតទាប។

#### ១.២.៣.១ វិស័យគ្រប់គ្រងដីធ្លី សុរិយោដី

ដើម្បីឱ្យផែនការអភិវឌ្ឍន៍ដំណើរការចំគោលដៅ និងមានប្រសិទ្ធិភាព មន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដីខេត្ត ខិតខំប្រឹងប្រែងរិះរកមធ្យោបាយទាំងផ្នែកជំនាញ និងឯកសារសំខាន់ៗដែលតម្រូវដល់ការអនុវត្ត និងរកដៃគូរសម្រាប់គាំទ្រ។ មន្ទីរមានមន្ត្រីបម្រើការងារសរុបចំនួន ២២នាក់ មានការិយាល័យចំណុះចំនួន៣ និងការិយាល័យក្រុង ស្រុកចំនួន៨ ក្នុងនោះមន្ទីរបានបំពេញបេសកម្មមានដូចជា ចុះធ្វើអត្តសញ្ញាណកម្មដីសម្បទានសេដ្ឋកិច្ចចំនួន២១កន្លែងស្មើ១០៣.២០៦ហិកតា ចុះធ្វើអត្តសញ្ញាណកម្មដីសម្បទានសង្គមកិច្ចចំនួន១១កន្លែងស្មើ១៨.០៧៤ហិកតា ទទួលពាក្យបណ្តឹងចំនួន៤២ករណី ដោះស្រាយទំនាស់ដីធ្លីបានចំនួន៤២ករណី ដោះស្រាយបញ្ចប់ចំនួន២១ករណី ច្រានចោលចំនួន១៥ករណី កំពុងដោះស្រាចំនួន០៦ករណី។ ចុះបញ្ជីដីធ្លីជាក់ស្តែងបានចំនួន៤៦៩ប័ណ្ណ ចុះរៀបចំភូមិធម្មជាតិតេជោហ៊ុន សែនចំនួន០១ភូមិ ស្មើផ្ទៃដីចំនួន៤.៥២៥ហិកតា។

ទន្ទឹមនឹងមោទនភាពនេះ មន្ទីរក៏ត្រូវជួបបញ្ហាប្រឈមដូចជា ភាពអនាធិបតេយ្យកាប់ព្រៃឈើយកដី ការសាងសង់សំណង់លើដីចំណីផ្លូវ ប្រជាជនមិនទាន់យល់ច្បាស់អំពីសិទ្ធិក្នុងការកាន់កាប់ដីធ្លីរបស់ខ្លួនបង្កឱ្យមានទំនាស់ព្រោះពួកគាត់មិនបានធ្វើប័ណ្ណសំគាល់សិទ្ធដីរបស់ខ្លួន។ ក្រុមហ៊ុនដែលសុំដីសម្បទានសេដ្ឋកិច្ចមួយចំនួនមិនទាន់បានចុះបញ្ជីដីធ្លី។ ការផ្ទេរ ការលក់ដូរដីធ្លីភាគច្រើនធ្វើលិខិតត្រឹមមេឃុំ សង្កាត់ និងមន្ត្រីពន្ធដារប៉ុណ្ណោះ នាំឱ្យមានបញ្ហាទំនាស់ដីធ្លីកាន់តែកើនឡើងនៅពេលខាងមុខ។ សមត្ថភាពមន្ត្រីមានការយល់ដឹងនៅមានកំរិត។

ដើម្បីឱ្យដំណើរការការកសាងផែនការ៥ឆ្នាំបានជោគជ័យ មន្ទីរសម្រេចយកអនុក្រឹត្យ សារាចរណែនាំសេចក្តីណែនាំប្រកាសលេខ៧៦ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិង

សំណង់ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រុង និងតួនាទីរបស់ការិយាល័យក្រោមឱវាទមកអនុវត្ត និងមានការសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងក្នុងរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលដូចជា អង្គភាពរដ្ឋបាលព្រៃឈើ មន្ទីរបរិស្ថាន មន្ទីរកសិកម្ម កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអង្គភាពពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ។

## ១.២.៣.២ វិស័យបរិស្ថាន គ្រប់គ្រងធនធានធម្មជាតិ

ពាក់ព័ន្ធនឹងការប្រើប្រាស់ថ្នាំពុលកសិកម្មសំរាប់សំលាប់សត្វល្អិត និងការប្រើប្រាស់ជីគីមីក្នុងខេត្តព្រះវិហារ ពុំទាន់មានបញ្ហាអ្វីដែលគួរឱ្យកត់សំគាល់នៅឡើយទេ ដោយសារប្រជាកសិករនៅមានទំលាប់ប្រពៃណី បុរាណក្នុងការប្រកបការងារកសិកម្ម និងគុណភាពដីនៅមានជីជាតិល្អ។ ដើម្បីរក្សាលំនឹងបរិស្ថានឱ្យបានល្អបន្តទៀតនោះ ទាំងមន្ទីរកសិកម្ម មន្ទីរបរិស្ថាន រដ្ឋបាលព្រៃឈើ និងគ្រប់ស្ថាប័នទាំងអស់ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល បានធ្វើការផ្សព្វផ្សាយអំពីផលប៉ះពាល់ និងវិធានការការពារបរិស្ថានដល់ប្រជាពលរដ្ឋ ដើម្បីធ្វើយ៉ាងណាឱ្យពួកគាត់បានយល់ច្បាស់ពីតម្លៃបរិស្ថាន និងការការពារសុខភាព។

**តារាង: គ្រួសារនិងបញ្ហាធនធានធម្មជាតិនិងបរិស្ថាននៅក្នុងខេត្ត** (យោងស្ថិតិភូមិ ឆ្នាំ២០០៩)

| ប្រភេទ | 2007 | 2008 | 2009 | |
|---|---|---|---|---|
| | ភាគរយ | ភាគរយ | ភាគរយ | ចំនួន |
| គ្រួសាររស់នៅដោយសារអនុផលព្រៃឈើ | 0.08 % | 0.22 % | 0.19 % | 72 គ្រួសារ |
| គ្រួសាររស់នៅក្នុងតំបន់អភិរក្ស/ការពារ | 8.72 % | 6.93 % | 6.39 % | 2,394 គ្រួសារ |
| គ្រួសារដែលមានសេវាប្រមូលសំរាម | 0.00 % | 0.03 % | 0.77 % | 287 គ្រួសារ |
| គ្រួសារដែលទទួលរងនូវការបំពុលបរិស្ថាន | 0.00 % | 0.29 % | 0.30 % | 114 គ្រួសារ |
| គ្រួសារដាំដុះដែលប្រើជីរគីមី | 0.62 % | 0.84 % | 1.15 % | 431 គ្រួសារ |
| គ្រួសារដាំដុះដែលប្រើថ្នាំគីមីសំលាប់សត្វល្អិត | 0.84 % | 1.09 % | 1.11 % | 414 គ្រួសារ |

***សំគាល់*** : ភាគរយ គណនាដោយយកចំនួនគ្រួសារតាមប្រភេទនិមួយៗ ចែកនិងចំនួនគ្រួសារសរុប។

ក្រាហ្វិក: គ្រួសារប្រើជីរគីមីនិងគ្រួសារថ្នាំគីមីសំលាប់សត្វល្អិតតាមបណ្តាស្រុក ក្រុង(យោងស្ថិតិភូមិ ឆ្នាំ២០០៩)



### ១.២.៣.៣ ការបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

វិស័យសកម្មភាពមីនមានលក្ខណៈជាប្រព័ន្ធ និងជាវិស័យអាទិភាពមួយត្រូវបានកំណត់ដោយរាជរដ្ឋាភិបាល ក្នុងគោលដៅទី៩ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ វិស័យនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ច សង្គម លើកកំពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងរួមចំណែកយ៉ាងសកម្ម ដល់កិច្ចអភិវឌ្ឍន៍ នៅតាមមូលដ្ឋានភូមិ ឃុំ ដែលមានតំបន់មីន។ វិស័យសកម្មភាពមីនរួមចំណែក យ៉ាងសំខាន់មួយទៀតគឺកាត់បន្ថយ ការគ្រោះថ្នាក់របស់ប្រជាពលរដ្ឋ ដែលស្ថិតនៅលើតំបន់មានមីន និងគ្រាប់មិនទាន់ផ្ទុះ។

ស្ទើរៀងរាល់ឆ្នាំកន្លងមកទោះបី យើងមានផែនការបោសសំអាតមីនជាបន្តបន្ទាប់យ៉ាងណាក៏ដោយផ្ទៃដីមានមីនក្នុងខេត្តព្រះវិហារនៅមានសល់ច្រើន សំខាន់គឺស្រុកជាំក្សាន្ត។ ជាក់ស្តែងក្នុងឆ្នាំ២០១០កន្លងទៅនេះ មានតំបន់មានមីន និងគ្រាប់មិនទាន់ផ្ទុះដែលបង្កឱ្យមានគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋចំនួន១៤នាក់ ក្នុងនោះស្លាប់០១នាក់ និងរបួស ១៣នាក់ នៅក្នុងស្រុកជាំក្សាន្ត និងស្រុកត្បែងមានជ័យ។

បច្ចុប្បន្ន តំបន់ដែលមានមីន និងគ្រាប់មិនទាន់ផ្ទុះដែលប្រតិបត្តិករបោសសំអាតរួចដូចជា ជុំវិញតំបន់ប្រាសាទព្រះវិហារនៅគ១ ស្វាយជ្រុំ និងភូមិសែនជ័យ ដែលជាភូមិបង្កើតថ្មីត្រូវបានទ័ពសៀមវាយប្រហារដោយប្រើអាវុធទំនើបបាញ់កាំភ្លើងធុនធ្ងន់ ពង្រាយគ្រាប់ចង្កោមទៅលើតំបន់ទាំងនោះ។

## ១.២.៤ ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ខេត្តព្រះវិហារ ជាខេត្តដែលងាយរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិផ្សេងៗ ពិសេស គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ព្រោះខេត្តមានភូមិសាស្ត្រស្ថិតនៅតំបន់ខ្ពង់រាប មានជួរភ្នំ ទន្លេ ស្ទឹង អូរដែលអាចទទួលឥទ្ធិពលពីទឹកជំនន់ដោយសារទឹកភ្លៀង ខ្យល់ព្យុះដែលបង្កឱ្យមានការខូចខាតផ្ទះសំបែង ទ្រព្យសម្បត្តិ សត្វពាហនៈ ផលដំណាំ ស្រែ ចំការ...។ល។ ខេត្តក៏ទទួលរងនូវគ្រោះរាំងស្ងួតជាញឹកញាប់ផងដែរ ព្រោះប្រព័ន្ធធារាសាស្ត្រនៅ មានកំរិត ដែលមិនមានលទ្ធភាពផ្គត់ផ្គង់ទឹកគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ក្នុងការស្រោចស្រព។

ឥទ្ធិពលនៃគ្រោះមហន្តរាយ និងការប្រែប្រួលធាតុអាកាសធាតុបានធ្វើឱ្យផលិតផលកសិកម្មទទួលបានទិន្នផលទាប និងប៉ះពាល់ដល់ជីវិតសត្វ មនុស្ស និងទ្រព្យសម្បត្តិផ្សេងៗយ៉ាងដំណំ ជាហេតុធ្វើមានការចំណាយធនធាន (ថវិកា សម្ភារៈ មនុស្ស) និងខាតបង់ពេលវេលាជាច្រើន ក្នុងការដោះស្រាយ។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត អាជ្ញាធរខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ មន្ទីរធនធានទឹកនិងឧតុនិយម មន្ទីរកសិកម្ម និងមន្ទីរអង្គភាពពាក់ព័ន្ធនានាគ្រប់លំដាប់ថ្នាក់ បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដល់គ្រប់មូលដ្ឋានដើម្បីត្រៀមខ្លួនទប់ទល់ និងដោះស្រាយពេលមានបញ្ហាកើតឡើង។ ក្នុងន័យនេះ ប្រជាពលរដ្ឋត្រូវត្រៀមជាមុននូវសំលៀកបំពាក់ សម្ភារៈ ស្បៀងអាហារ ការសាងសង់លំនៅដ្ឋានឱ្យ សមស្របនឹងស្ថានភាពជាក់ស្តែង។ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រៀមសំភារៈបរិក្ខារ ស្បៀងអាហារសម្រាប់ផ្គត់ផ្គង់ និងទីតាំងសុវត្ថិភាពសម្រាប់ជំលៀសប្រជាពលរដ្ឋផងដែរ។

### ១.២.៥ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

ខេត្តបានលើកកំពស់ការគ្រប់គ្រងរដ្ឋបាលតាមរយៈអភិបាលកិច្ចល្អនៅគ្រប់ថ្នាក់រដ្ឋបាលខេត្ត ដើម្បីកាត់បន្ថយពេលវេលា ពិនិត្យឯកសារ និងចំណាយរត់ការក្រៅផ្លូវច្បាប់ ។ បង្កើនការគ្រប់គ្រងកំណត់ព្រំប្រទល់រដ្ឋបាលឱ្យបានច្បាស់កំណត់បង្កើតភូមិថ្មីស្របតាមផ្លូវច្បាប់ ធ្វើការរៀបចំប្លង់គោលឱ្យបានត្រឹមត្រូវ និងជំរុញការចុះបញ្ជីអត្រានុកូលដ្ឋាន ធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋប្រើប្រាស់បានគ្រប់ៗគ្នា ។

លើកកំពស់ការអនុវត្តន៍គោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ដើម្បីលុបបំបាត់ការជួញដូរគ្រឿងញៀន អំពើចោរកម្ម អំពើហឹង្សា ការជួញដូរមនុស្ស ការចាប់រំលោភផ្លូវភេទ ល្បែងស៊ីសង ក្មេងទំនើង បទល្មើសផ្សេងៗ និងជំរុញការគោរពការអនុវត្តន៍ច្បាប់ចរាចរ ។

# ជំពូក២
# ក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត

# ជំពូក២

## ក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត

ខេត្តព្រះវិហារបានកំណត់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ខេត្តសម្រាប់រយៈពេលប្រាំឆ្នាំ២០១១-២០១៥ដែលស្របតាមយុទ្ធសាស្ត្រចតុកោណ និងមានសង្គតិភាពជាមួយគោលនយោបាយជាតិ ក៏ដូចជាគោលនយោបាយរបស់ខេត្តដែរ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឈានទៅកសាងសង្គមមួយដែលមានសុខសន្តិភាព ស្ថេរភាព សណ្តាប់ធ្នាប់សង្គម មានការគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍ប្រជាធិបតេយ្យ ព្រមទាំងសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ដើម្បីសម្រេចនូវគោលដៅយុទ្ធសាស្ត្រនេះខេត្តបានកំណត់នូវ ចក្ខុវិស័យ គោលដៅ គោលបំណង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ ដូចខាងក្រោម៖

### ២.១ ចក្ខុវិស័យអភិវឌ្ឍន៍

ជំរុញការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន កសាងសាមគ្គីភាពរឹងមាំពីគ្រប់មជ្ឈដ្ឋានទាំងអស់ដោយមិនប្រកាន់និន្នាការនយោបាយ សាសនា ជនជាតិ កសាងបាននូវសុខសន្តិភាព សេរីភាព ជីវភាពសំបូររុងរឿង សមធម៌ យុត្តិធម៌ និងសេចក្តីថ្លៃថ្នូរ។

### ២.២ គោលដៅអភិវឌ្ឍន៍

ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យអភិវឌ្ឍន៍ខាងលើនេះ ខេត្តបានដាក់ចេញនូវគោលដៅចំនួនបួនដូចខាងក្រោម :

**គោលដៅទី ១** : កែលំអធានាសន្តិសុខស្បៀង បង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ និងរៀបចំកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត-អរូបវ័ន្តឱ្យមានភាពប្រសើរឡើង។

**គោលដៅទី ២** : លើកកំពស់ការផ្តល់សេវាកម្មសង្គម ការថែទាំសុខមាលភាពនិងបណ្តុះបណ្តាលធនធានមនុស្ស។

**គោលដៅទី ៣** : ប្រើប្រាស់ គ្រប់គ្រង សក្តានុពលសេដ្ឋកិច្ច ធនធានធម្មជាតិ ដើម្បីអភិវឌ្ឍន៍ខេត្ត ទទួលបានលទ្ធផលខ្ពស់ ហើយមិនប៉ះពាល់ដល់បរិស្ថាន និងជួយការពារបរិស្ថានឱ្យមាននិរន្តរភាព។

**គោលដៅទី៤** : ពង្រឹងសេវារដ្ឋបាលធានាសន្តិសុខសណ្តាប់ធ្នាប់សង្គមឱ្យកាន់តែមានភាពល្អប្រសើរឡើង។

### ២.៣ គោលបំណងអភិវឌ្ឍន៍

ដើម្បីសម្រេចបានចក្ខុវិស័យ និងគោលដៅអភិវឌ្ឍន៍ខាងលើនេះខេត្តត្រូវមានវិធានការណ៍រៀបចំទិសដៅទៅតាមវិស័យអាទិភាព ដូចមាននៅក្នុងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍ខាងក្រោមនេះ :

## តារាងក្របខ័ណ្ឌអភិវឌ្ឍន៍ប្រាំឆ្នាំខេត្ត(២០១១_២០១៥)

| | | | | |
|---|---|---|---|---|
| **ចក្ខុវិស័យ : ជំរុញការអនុវត្តន៍គោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូល ដ្ឋាន កសាងសាមគ្គីភាពរឹងមាំពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដោយមិនប្រកាន់និន្នាការនយោបាយ សាសនា ជនជាតិ កសាងបាននូវសុខសន្តិភាព សេរីភាព ជីវភាពសំបូររុងរឿង សមធម៌ យុត្តិធម៌ និងសេចក្តីថ្លៃថ្នូរ ។** | | | | |
| **គោលដៅ និងគោលបំណង** | **សូចនាករ** | | | **យុទ្ធសាស្ត្រអភិវឌ្ឍន៍** |
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| **១_ផ្នែកសេដ្ឋកិច្ច** | | | | |
| **គោលដៅទី១ : កែលំអធានាសន្តិសុខស្បៀង បង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ និងរៀបចំកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត-អរូបវ័ន្តឱ្យមានភាពប្រសើរឡើង ។** | | | | |
| **កសិកម្ម** | | | | |
| **១.១.១ គោលបំណងៈធ្វើឱ្យប្រសើរឡើងនូវផលិតកម្មដំណាំស្រូវតាមរយៈការផ្តល់បច្ចេកទេសកសិកម្មសំរាប់ ស្រុកគោលដៅទាំង ០៧** | | | | |
| ទិន្នផលស្រូវជាមធ្យមក្នុង១ហិកតា | តោន | ២,៦ | ៣,២ | -បណ្តុះបណ្តាលបច្ចេកទេសដាំដុះដំណាំស្រូវ |
| ផ្តល់ពូជស្រូវទិន្នផលខ្ពស់ | តោន | ១៨ | ២៥ | -រៀបចំកន្លែងផលិតពូជនៅតាម មូលដ្ឋាន<br>-រៀបចំបង្ហាញពូជ |
| សាលារៀនស្រែកសិករ | សាលា | ៤៨ | ៩៨ | -រៀបចំស្រែបង្ហាញ |
| ផ្ទៃដីដាំដុះដំណាំស្រូវកើនឡើង | ហ.ត | ៤៥.៨៤៣ | ៩.៥០០០ | -ពង្រីកផ្ទៃដីកសិកម្ម |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| សហគមន៍ស្រូវសិរីរាង្គ | សហគមន៍ | ១ | ៥ | -ចងក្រងសហគមន៍ |
| **១.១.២ គោលបំណងៈធ្វើឱ្យប្រសើរឡើងនូវផលិតកម្មដំណាំបន្លែ** | | | | |
| ផ្ទៃដីដំណាំបន្លែកើនឡើង | ហ.ត | ៩២៧ | ១៥០០ | -រៀបចំប្រព័ន្ធស្រោចស្រព ខ្នាតតូច |
| កសិករទទួលបានចំនេះដឹងពីបច្ចេកទេសដាំដុះដំណាំបន្លែ | នាក់ | ១២០០ | ៣៦០០ | -បណ្តុះបណ្តាលបច្ចេកទេសដាំដុះ ដំណាំបន្លែ |
| ទទួលបានការបង្ហាញដំណាំបន្លែ | បង្ហាញ | ៤៨ | ៧៨ | -រៀបចំបង្ហាញបន្លែ |
| **១.១.៣ គោលបំណងៈ ធ្វើឱ្យប្រសើរឡើងផលិតផល-កសិផលមានគុណភាព និងតម្លៃលើទីផ្សារ** | | | | |
| ចងក្រងក្រុមកសិករ | ក្រុម | ៤៨ | ១៩២ | ចងក្រងសហគមន៍អភិវឌ្ឍន៍កសិកម្ម |
| កសិករទទួលបានចំណេះដឹងទំនាក់ទំនង ទីផ្សារ | នាក់ | ១២០០ | ៣៦០០ | -បណ្តុះបណ្តាលជំនាញទំនាក់ទំនង ទីផ្សារ<br>-បណ្តុះបណ្តាលជំនាញការកសាង ក្រុម |
| កសិករទទួលបានប្រព័ន្ធព័តមានទីផ្សារតំលៃកសិផល | លើក | ៣៦៥ | ១៨២៥ | -ផ្សព្វផ្សាយតំលៃកសិផលតាម រយៈវិទ្យុក្នុងតំបន់<br>-បិទផ្សាយតំលៃកសិផលតាមភូមិ |
| **១.១.៤ គោលបំណងៈ បង្កើនផលិតកម្មសត្វ** | | | | |
| សត្វមាន់-ទាកើនឡើង និងមាន សុខភាពល្អ | ក្បាល | ២៤០២៦៨ | ៥១០០០០ | -ផ្សព្វផ្សាយពីវិធីសាស្ត្រការពារ-យុទ្ធនាការចាក់វ៉ាក់សាំង |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| សត្វគោ-ក្របីកើនឡើង និងមានសុខភាពល្អ | ក្បាល | ១០៦២១៨ | ២៥០០០០ | -ផ្សព្វផ្សាយពីវិធីសាស្ត្រការពារ<br>-យុទ្ធនាការចាក់វ៉ាក់សាំង |
| កសិករទទួលបានចំណេះដឹងបច្ចេកទេស ចិញ្ចឹមសត្វ | នាក់ | ១២០០ | ៥៦០០ | -បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹម សត្វ |
| **១.១.៥ គោលបំណងៈ កាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល** | | | | |
| កសិករទទួលបានចំណេះដឹងពីការបាត់បងក្រោយប្រមូលផល | ភូមិ | ២០ | ១០២ | -បណ្តុះបណ្តាលបច្ចេកទេសកាត់បន្ថយការបាត់បង់ក្រោយប្រមូលផល |
| កសិករទទួលបានតង់សំរាប់ហាលស្រូវ | គ្រួសារ | ៦៦០ | ១២០០ | -ផ្សព្វផ្សាយនិងចែករំលែកបទពិសោធន៍ពីបច្ចេកទេសក្រោយប្រមូលផល |
| ឧបករណ៏ត្រួតពិនិត្យការបាត់បង់ក្រោយប្រមូលផល ត្រូវបានបំពាក់ | កំប្លេ | ២ | ៧ | -បណ្តុះបណ្តាលពីរបៀបប្រើប្រាស់ឧបករណ៏ដល់មន្ត្រីថ្នាក់ខេត្តស្រុក |
| **ជលផល** | | | | |
| **១.២.៦ គោលបំណងៈ បង្កើនវារីវប្បកម្មជាលក្ខណៈគ្រួសារ** | | | | |
| កសិករចិញ្ចឹមត្រី | គ្រួសារ | ១០០ | ៣៥០ | - បណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមត្រី |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| ចំនួនស្រះ | ស្រះ | ១០០ | ៣៤០ | - ស្តារស្រះ |
| **១.២.៧ គោលបំណងៈ លើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋដោយផ្សព្វផ្សាយច្បាប់ជលផល** | | | | |
| ប្រជាពលរដ្ឋតាមស្រុក | % | ២៥ | ៧០ | -ជម្រុញការគាំទ្រផ្នែកច្បាប់ |
| **ធនធានទឹក និងឧតុនិយម** | | | | |
| **១.៣.៨ គោលបំណងៈ ការងារធារាសាស្ត្រ កសិកម្ម** | | | | |
| ការសិក្សាគ្រោងប្លង់ | កន្លែង | ១៨ | ៥០ | -មន្ត្រីបច្ចេកទេសចុះសិក្សា |
| ជួសជុលទំនប់អាងទឹក | កន្លែង | ០៦ | ៣០ | -ជួសជុលទំនប់អាងទឹកឡើងវិញ |
| ស្តារប្រឡាយមេ ប្រឡាយរង និងប្រឡាយស្រោចស្រព | ខ្សែ | ០៤ | ២៥ | -ស្តារ និងជួសជុលឡើងវិញ |
| ស្តារប្រឡាយដោះទឹកជំនន់ | ខ្សែ | ០១ | ០៣ | -ស្តារ និងជួសជុលឡើងវិញ |
| ជួសជុល និងសាងសង់សំណង់សិល្បការ | កន្លែង | ២២ | ៤៥ | -សាងសង់ និងជួសជុលឡើងវិញ |
| ជីកស្រះ និងស្តារប្រព័ន្ធស្រោចស្រព | ស្រះ | ២០ | ៨០ | -ជីក និងស្តារឡើងវិញ |
| **១.៣.៩ គោលបំណងៈ បង្កើនការប្រើប្រាស់ទឹកស្អាត និងអនាម័យ** | | | | |
| អត្រាប្រើប្រាស់ទឹកស្អាតនៅទីប្រជុំជន | % | ០៥ | ១៦ | -ជម្រុញការវិនិយោគទឹកស្អាត |

| គោលដៅ  និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| អត្រាគ្រួសារប្រើប្រាស់អណ្តូងលូ ឬ ស្នប់ដោយដៃ | % | ៣០ | ៥០ | -ជីក ឬ ខួងអណ្តូងស្នប់ |
| អត្រាគ្រួសារប្រើប្រាស់អណ្តូងស្នប់ដោយម៉ូទ័រ | % | ០៦ | ៣០ | -ជីក ឬ ខួងអណ្តូងស្នប់ |
| កែលំអប្រព័ន្ធដោះទឹកកខ្វក់នៅទីប្រជុំជន | ខ្សែ | ០ | ០៥ | -សាងសង់ថ្មី |
| **១.៣.១០ គោលបំណងៈ ពង្រឹងការគ្រប់គ្រង និងអភិរក្សធនធានទឹក** | | | | |
| រៀបចំសហគមន៏កសិករប្រើប្រាស់ទឹក | សហគមន៏ | ១៩ | ៥០ | -ចុះពង្រឹង និងរៀបចំសហគមន៏ |
| ផ្សព្វផ្សាយលក្ខន្តិកៈប្រើប្រាស់ទឹក | លើក | ១៩ | ៥០ | -ចុះផ្សព្វផ្សាយលក្ខន្តិកៈប្រើប្រាស់ទឹក |
| ពង្រឹងសមត្ថភាព និងបណ្តុះបណ្តាលដល់មន្ត្រីជំនាញ | វគ្គ | ១០ | ៦០ | -បណ្តុះបណ្តាលបច្ចេកទេស |
| ផ្តួចផ្តើមគម្រោងស្វែងរកជំនួយថវិកាពីដៃគូរអភិវឌ្ឍន៍ | លើក | ១២ | ៥០ | -ស្វែងរកម្ចាស់ជំនួយ |
| **ទេសចរណ៏** | | | | |
| **១.៤.១១ គោលបំណងៈពង្រីកការអភិវឌ្ឍន៍ផលិតផលទេសចរណ៏** | | | | |
| បន្តពង្រីកគោលដៅទេសចរណ៏ និផលិតផលទេសចរណ៏ | កន្លែង | ៣ | ៧ | - ស្វែងរកដៃគូអភិវឌ្ឍន៏<br>-អនុវត្តច្បាប់ទេសចរណ៏ |
| ពង្រីកសម្បទា សេវាកម្មទេសចរណ៏តាមបទដ្ឋានកំណត់ | កន្លែង | ២៣ | ២៦ | |
| បង្កើតទីភ្នាក់ងារទេសចរណ៏នៅក្នុងខេត្ត | កន្លែង | ០ | ៣ | |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| **១.៤.១២ គោលបំណងៈ បន្តពង្រឹងគុណភាពសេវាកម្មទេសចរណ៍ប្រកបដោយប្រសិទ្ធភាព** | | | | |
| ពង្រឹងការគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មស្នាក់នៅ | កន្លែង | ២៣ | ៤៣ | -ជម្រុញអនុវត្តច្បាប់ទេសចរណ៍ និងលិខិតបទដ្ឋានក្រោមច្បាប់ |
| ពង្រឹងការគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋាន អាហារដ្ឋាន | កន្លែង | ៧ | ២៧ | -ជម្រុញចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត |
| លើកកម្ពស់សេវាកម្មសេវាកំសាន្ត | កន្លែង | ៦ | ២៦ | សេវាល្អ |
| **១.៤.១៣ គោលបំណងៈកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍** | | | | |
| ទាក់ទាញភ្ញៀវទេសចរអោយមានកំណើនរៀងរាល់ឆ្នាំ | នាក់ | ១៣៥៦៥៧ | ៣០៥២២០ | -បង្កើនការផ្សព្វផ្សាយ<br>-ពង្រឹងគុណភាពផលិតផល |
| លើកកម្ពស់សមត្ថភាពក្នុងវិស័យទេចរណ៍លើគ្រប់ផ្នែក | % | ៣៧ | ៨៥ | -បង្កើនការបណ្តុះបណ្តាល |
| **ពាណិជ្ជកម្ម** | | | | |
| **១.៥.១៤ គោលបំណងៈ បង្កើនផលិតផលនាំចេញ** | | | | |
| ផលិតផលច្រើតចូលក្នុងទីផ្សារ | % | ៤៥ | ៦៨ | -ផ្តល់ពត័មានទីផ្សារ<br>-បណ្តុះបណ្តាលបច្ចេកទេស |
| ការវិនិយោគលើផលិតផល | % | ៤០ | ៦០ | -រៀបចំកម្មវិធីពិព័រណ៍ផលិតផលប្រចាំឆ្នាំ |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| **១.៥.១៥ គោលបំណងៈ ពង្រឹងការគ្រប់គ្រងទីផ្សារ** | | | | |
| ផ្តល់ប័ណ្ណអនុញ្ញាតអាជីវកម្ម | ច្បាប់ | ៤៧០ | ៧៩៩ | |
| **១.៥.១៦ គោលបំណងៈ ផលិតផលនាំចេញទៅកាន់ទីផ្សារ** | | | | |
| ស្រូវ | តោន | ៧១,៨៨១ | ១០៧,៨២២ | -ជំរុញការដាំដុះ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល |
| ពោតស | តោន | ២៣,០៣១ | ២៨,៧៨៩ | |
| ពោតក្រហម | តោន | ១៧,១១៤ | ២១,៣៩៣ | |
| ល្ង | តោន | ២,៣៦៥ | ២,៩៥៦ | |
| គ្រាប់ស្វាយចន្ទី | តោន | ១,៤៩៦ | ១,៨៧០ | -ផ្តល់បច្ចេកទេសក្នុងការដាំដុះ |
| សណ្តែកបាយ | តោន | ១០,៧៧៧ | ១៣,៤៧១ | |
| សណ្តែកដី | តោន | ៦,១៨២ | ៧,៧២៨ | |
| សណ្តែកសៀង | តោន | ៣៥,៦៨៨ | ៤៤,៦១០ | |
| ចេក | តោន | ៣,១៤៥ | ៣,៩៣១ | |
| ដំឡូងមី | តោន | ៥៤,២៥២ | ៦៧,៨១៥ | |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| **ឧស្សាហកម្ម រ៉ែ និង ថាមពល** | | | | |
| **១.៦.១៧ គោលបំណង: ពង្រីកការវិនិយោគផ្នែកឧស្សាហកម្មតូច-សិប្បកម្ម** | | | | |
| សិប្បកម្មផលិតទឹកកក | មូលដ្ឋាន | ៥ | ៧ | -បង្កើតថ្មី |
| សិប្បកម្មផលិតទឹកពិសារដប | មូលដ្ឋាន | ៣ | ៥ | -បង្កើតថ្មី |
| សិប្បកម្មតម្រូវសុំចុះបញ្ជី | មូលដ្ឋាន | ២៥ | ៤០ | -បង្កើតថ្មី |
| សិប្បកម្មសុំចុះបញ្ជីស្ថិតិ | មូលដ្ឋាន | ៩៤០ | ១២០០ | -បង្កើតថ្មី |
| បណ្តាញផ្គត់ផ្គង់ទឹកស្អាត | មូលដ្ឋាន | ១ | ៥ | -ជម្រុញការអភិវឌ្ឍន៍តាមទីប្រជុំជនស្រុក |
| -បរិមាណទឹកស្អាតផ្គត់ផ្គង់ | $ម^{៣}$ | ១២៥០០០ | ៥០០០០០ | |
| **១.៦.១៨ គោលបំណង: លើកកម្ពស់ការវិនិយោគធនធានរ៉ែ** | | | | |
| ក្រុមហ៊ុន IRON | តោន | ០ | ៣០០០០ | -ផលិតដែកគ្រប់ប្រភេទ |
| **១.៦.១៩ គោលបំណង: បង្កើនការវិនិយោគ និង ផ្គត់ផ្គង់ថាមពលដល់ មូលដ្ឋាន** | | | | |
| បណ្តាញផ្គត់ផ្គង់អគ្គិសនី | កន្លែង | ៤ | ១៣ | -ជម្រុញការវិនិយោគ |
| -ថាមពលបណ្តាញ | គ្រួសារ | ៤០០០ | ១៥០០០ | |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| -ថាមពលពន្លឺព្រះអាទិត្យ | គ្រួសារ | ៤០ | ៣២០០ | -អប់រំផ្សព្វផ្សាយពីការប្រើប្រាស់ |
| -អាគុយ | គ្រួសារ | ១៥០០ | ១២០០០ | |
| **អភិវឌ្ឍន៍ជនបទ** | | | | |
| **១.៧.២០ គោលបំណង: ស្តារនិងជួសជុលឡើងវិញផ្លូវក្រាលគ្រួសក្រហម** | | | | |
| ជួសជុលនិងថែទាំផ្លូវក្រាលគ្រួសក្រហមប្រភេទលេខ១ | ខ្សែ/គ.ម | ២/៥៨,៥ | ៣/៨៣,៥ | -ធ្វើផែនការសុំថវិកាសំរាប់សាងសង់,ជួសជុល,ថែទាំប្រចាំឆ្នាំ គៀងគរប្រភពទុនពីគ្រប់រូបភាព |
| ជួសជុលនិងថែទាំផ្លូវក្រាលគ្រួសក្រហមប្រភេទលេខ២ | ខ្សែ/គ.ម | ៩/១៤៩,៥ | ១១/២២៧,៤ | -ធ្វើផែនការសុំថវិកាសំរាប់សាងសង់,ជួសជុល,ថែទាំប្រចាំឆ្នាំ គៀងគរប្រភពទុនពីគ្រប់រូបភាព |
| **១.៧.២១ គោលបំណង: បង្កើនការផ្គត់ផ្គង់ទឹកជនបទ** | | | | |
| អត្រាគ្របដណ្តប់ប្រជាជនមានទឹកស្អាតប្រើប្រាស់ | % | ៤៦,០២ | ៥០ | -ធ្វើផែនការសុំថវិកាសំរាប់សាងសង់,ជួសជុល,ថែទាំអណ្តូងប្រចាំឆ្នាំ គៀងគរប្រភពទុនពីគ្រប់រូបភាព |
| **១.៧.២២ គោលបំណង: លើកកម្ពស់អនាម័យជនបទ** | | | | |
| អត្រាគ្របដណ្តប់ប្រជាជនមានបង្គន់អនាម័យប្រើប្រាស់ | % | ១១ | ៣០ | -ធ្វើផែនការសុំថវិកាសំរាប់សាងសង់បង្គន់ និងសំរាប់អប់រំ |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| | | | | ផ្សព្វផ្សាយ ប្រចាំឆ្នាំ គៀងគរប្រភពទុនពីគ្រប់រូបភាព |
| **សាធារណការ និងដឹកជញ្ជូន** | | | | |
| **១.៨.២៣ គោលបំណង: ការងារជួសជុលប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ** | | | | |
| ក-ការងារជួសជុលផ្លូវចាក់កៅស៊ូ | | | | |
| -ផ្លូវជាតិ | គម | ០ | ១៧ | -ស្ពានហេដ្ឋារចនាសម្ព័ន្ធ |
| -ផ្លូវខេត្ត | គម | ០ | ២៦ | |
| -ផ្លូវក្នុងទីរួមខេត្ត | គម | ០ | ៥ | |
| ខ-ការងារជួសជុលផ្លូវក្រាលគ្រួសក្រហម | | | | |
| -ផ្លូវខេត្ត | គម | ២៨ | ៤១ | -ស្ពានហេដ្ឋារចនាសម្ព័ន្ធ |
| -ផ្លូវក្នុងទីរួមខេត្ត | គម | ០ | ៣,២ | |
| **១.៨.២៤ គោលបំណង: ការងារថែទាំប្រចាំនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ** | | | | |
| ក-ការងារថែទាំប្រចាំផ្លូវចាក់កៅស៊ូ | | | | |
| -ផ្លូវជាតិ | គម | ០ | ២០៣ | -ស្ពានហេដ្ឋារចនាសម្ព័ន្ធ |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្តដើមគ្រា | ២០១៥ | |
| -ផ្លូវខេត្ត | គម | ១៨,៥ | ៣៦,៥ | |
| -ផ្លូវក្នុងទីរួមខេត្ត | គម | 0 | ១៨ | |
| ខ-ការងារថែទាំប្រចាំផ្លូវក្រាលគ្រួសក្រហម | | | | |
| -ផ្លូវខេត្ត | គម | 0 | ៥0 | -ស្ពារហេដ្ឋារចនាសម្ព័ន្ធ |
| -ផ្លូវក្នុងទីរួមខេត្ត | គម | 0 | ១៥ | |
| **១.៨.២៥ គោលបំណងៈ ការងារថែទាំប្រចាំផ្លូវចាក់បេតុង** | | | | |
| -ផ្លូវឡើងមុំ៣ | គម | 0 | ២,១ | -ស្ពារហេដ្ឋារចនាសម្ព័ន្ធ |
| -ផ្លូវឡើងភ្នំប្រាសាទព្រះវិហារ | គម | 0 | ៦,២ | |
| **១.៨.២៦ គោលបំណងៈ ការងារថែទាំប្រចាំប្រព័ន្ធបង្ហូរទឹកស្អុយ** | | | | |
| -រៀបចំប្រព័ន្ធលូក្នុងទីរួមខេត្ត | ម | ៥.000 | ៥.000 | -ស្ពារហេដ្ឋារចនាសម្ព័ន្ធ |
| **ប្រៃសណីយ៍ និង ទូរគមនាគមន៍** | | | | |
| **១.៩.២៧ គោលបំណងៈ ពង្រីកការអភិវឌ្ឍន៍ វិស័យទូរគមនាគមន៍** | | | | |
| ចំនួនស្ថានីយ៍ទូរស័ព្ទ | បង្គោល | ១១៣ | ២២៦ | -ក្រុមហ៊ុនសាងសង់បន្ថែម |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| ចំនួនវិទ្យុ ICOM | គ្រឿង | ៥២ | ៦០ | -ជំរុញអោយអតិថិជន ស្នើសុំច្បាប់អនុញ្ញាតប្រើប្រាស់ |
| វីសាត INTERNET | ស្ថានីយ៍ | ១៣ | ១៥ | -ក្រុមហ៊ុនពង្រីកបណ្តាញ បន្ថែម |
| លើកកម្ពស់សមត្ថភាពបច្ចេកទេសក្នុងវិស័យប្រៃសណីយ៍និង ទូរគមនាគមន៏ | ភាគរយ | ៣៥ | ៦០ | -បណ្តុះបណ្តាលបច្ចេកទេសមន្ត្រីជំនាញ |
| **១.៩.២៨ គោលបំណងៈ បន្តពង្រីកនិង ពង្រឹងគុណភាពសេវាកម្ម វិស័យប្រៃសណីយ៍** | | | | |
| បញ្ជូនបញ្ញើគ្រប់ប្រភេទ | បាវ/កញ្ចប់ | ៨៩ | ៤៥៤ | ជម្រុញឱ្យសហគ្រាសពង្រីកបន្ថែម |
| ទទួលបញ្ញើគ្រប់ប្រភេទ | បាវ/កញ្ចប់ | ៩៧ | ៤៩៥ | ជម្រុញឱ្យសហគ្រាសពង្រីកបន្ថែម |
| **១.៩.២៩ គោលបំណងៈ កាត់បន្ថយភាពក្រីក្រតាមរយៈវិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍** | | | | |
| ទាក់ទាញក្រុមហ៊ុនទូរស័ព្ទចល័តឱ្យវិនិយោគ | ស្ថានីយ៍ | ១១៣ | ២២៦ | -បង្កើនការសាងសង់ស្ថានីយ៍<br>-ពង្រឹងគុណភាពបច្ចេកទេស |
| ផ្តល់អត្រាតម្លៃសមរម្យសម្រាប់ក្រុមហ៊ុនវិនិយោគ | រៀល/ដុល្លា | - | - | -ជម្រុញឱ្យក្រុមហ៊ុនគោរពតាមប្រកាសកំណត់តម្លៃ |
| **ផែនការ** | | | | |
| **១.១០.៣០ គោលបំណងៈ បង្កើនសមត្ថភាពមន្ត្រីតាមរយៈការបណ្តុះបណ្តាលជំនាញ** | | | | |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| -មន្ត្រីប្រកបដោយសមត្ថភាពគុណភាពទាំងនៅថ្នាក់ខេត្ត និងថ្នាក់ ស្រុក-ក្រុង | នាក់ | ១៣ | ៤២ | -ជ្រើសរើសក្របខ័ណ្ឌថ្មីបន្ថែម ។<br>-បើកវគ្គរយៈពេលខ្លី មធ្យមឬ វែងដើម្បីពង្រឹង គុណភាពសមត្ថភាព ។<br>-បង្កើនប្រាក់បៀវត្សឱ្យបានសមរម្យ ។ |
| -មានអាគារសំរាប់បំរើការងារមានលក្ខណៈសមរម្យទាំងនៅថ្នាក់ខេត្តនិងនៅថ្នាក់ស្រុក-ក្រុង ។ | ខ្នង | ០ | ៩ | -សាងសង់អាគារមន្ទីរនៅថ្នាក់ខេត្តនិងការិយាល័យនៅថ្នាក់ ស្រុក-ក្រុង ។<br>-បំពាក់សំភារៈប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ |
| -សមត្ថភាព គុណភាព មន្ត្រីថ្នាក់ មូលដ្ឋានភូមិ ឃុំ-សង្កាត់ | % | ៦០ | ៨០ | -ណែនាំ និង បើកវគ្គ ដើម្បីពង្រឹងគុណភាព សមត្ថភាព ឱ្យបានញឹកញាប់ ។<br>-បង្កើនប្រាក់ឧបត្ថម្ភឱ្យបានសមរម្យ ។ |
| **សាលាខេត្ត** | | | | |
| **ទីចាត់ការផែនការ និងវិនយោគ** | | | | |
| **១.១១.៣១ គោលបំណងៈ បង្កើន និងពង្រឹងការគាំទ្រការអនុវត្តការងារដល់ឃុំ សង្កាត់ ក្រុង ស្រុកឱ្យបានកាន់តែប្រសើរឡើងស្របតាមគោល នយោបាយវិមជ្ឈការ និងវិសហមជ្ឈការ** | | | | |
| ការវិនិយោគឃុំសង្កាត់ | | | | - បណ្តុះបណ្តាលពង្រឹងសមត្ថភាពឃុំ សង្កាត់ |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| | ឃុំសង្កាត់ | ៤៩ | ៤៩ | - បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីទីចាត់ការ<br>-សហការរៀបចំការសិក្សាលទ្ធភាពគម្រោង រៀបចំការដេញ ថ្លៃគម្រោង,តាមដានវាយតម្លៃការអនុវត្តគម្រោងឃុំ សង្កាត់នានា.<br>- បន្តសហការ និងគាំទ្រការរៀបចំផែនការ អភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់<br>- បន្តសហការ និងគាំទ្រការរៀបចំ ផែនការថវិកាឃុំ សង្កាត់<br>- បន្តសហការ និងគាំទ្រការបង្កើត ការបំបែក ការបង្រួម ការកំណត់ព្រំប្រទល់ភូមិ ឃុំ ស្រុក ក្រុងតាមការចាំបាច់ |
| គាំទ្រការអនុវត្តការងាររបស់ក្រុង ស្រុក | ក្រុងស្រុក | ៨ | ៨ | - បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីក្រុងស្រុក<br>- បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីទីចាត់ការ |
| **១.១១.៣២ គោលបំណង: ជំរុញ និងលើកកំពស់ការផ្តល់សេវាដល់វិនិយោគិនឯកជន** | | | | |
| ផ្តល់សេវាដល់វិនិយោគិនឯកជន | ទូទាំងខេត្ត | ១ | ១ | - បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីទីចាត់ការ ពាក់ព័ន្ធការវិនិយោគថ្នាក់ខេត្ត ក្រុង ស្រុក<br>- ជំរុញក្បៀតវិនិយោគិនឯកជន |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| | | | | - ធ្វើទស្សនៈកិច្ចសិក្សាដកស្រង់បទពិសោធន៍លើ វិស័យវិនិយោគនេះ ទាំងក្នុងប្រទេស និងក្រៅប្រទេស<br>- ផ្សព្វផ្សាយលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធ ការវិនិយោគដល់អ្នកពាក់ព័ន្ធ |
| **១.១១.៣៣ គោលបំណង៖ ជំរុញ និងវាយតម្លៃការអនុវត្តផែនការខេត្តឱ្យមានប្រសិទ្ធភាព** | | | | |
| កិច្ចសហការរៀបចំ និងតាមដានវាយតម្លៃការអនុវត្តផែនការ | ទូទាំងខេត្ត | ១ | ១ | - បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធការរៀបចំ ផែនការ<br>-បណ្តុះបណ្តាលពង្រឹងសមត្ថភាពលើការ តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត ផែនការនានា |
| **ទីចាត់ការហិរញ្ញវត្ថុ** | | | | |
| **១.១១.៣៤ គោលបំណង៖ កែលម្អសោភណ្ឌភាពខេត្ត និង ស្រុក** | | | | |
| **ថែទាំសាងសង់ផ្សារកំពង់ប្រណាក** | | | | |
| -ជួសជុលចាក់កំរាលបេតុង | ម២ | ១.១៥៥ | ១.៦០០ | -ដើម្បីអោយមានសោភ័ណ្ឌភាព និងអនាម័យស្វែងរកថវិកាសំរាប់សាងសង់ |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| -ជួសជុលលូ | ម | ១៧៨ | ៤៥០ | -អប់រំអាជីវករឱ្យជួយសំអាត និងថែទាំ |
| **សាងសង់សួនច្បារ** | | | | |
| -សាងសង់សួនច្បារផ្លូវភ្លោះ | ម២ | ២.០០០ | ៤.២០០ | -ស្វែងសប្បុរសជនដើម្បីជួយ |
| -សាងសង់សួនច្បារបរិវេណសាលាខេត្ត | ម២ | ៣.០០០ | ៩.០០០ | -ស្វែងសប្បុរសជនដើម្បីជួយ |
| -រៀបចំប្រព័ន្ធទឹកស្រោចផ្កា | ម | ៩៥០ | ៩៥០ | -ស្វែងសប្បុរសជនដើម្បីជួយ |
| -រៀបចំបង្គោលភ្លើងបំភ្លឺសាធារណៈផ្លូវភ្លោះ | ដើម | ២៥ | ១០០ | -ស្វែងសប្បុរសជនដើម្បីជួយ |
| -រៀបចំប្រព័ន្ធភ្លើងរង្វង់មូលព្រះនរាយ ដល់នាគបាញ់ទឹក | ដើម | ១៥ | ១៥ | -កែសម្រួលពីគោមទោលទៅគោមភ្លោះ |
| -រៀបចំសួនច្បារនៅដំណាក់ស្តេចតាមបណ្តោយមាត់ស្ទឹងសែន | ម | ១.៥០០ | ៣.០០០ | -ទំនាក់ទំនងសុំថវិការដ្ឋ |
| **ការកែលម្អអគារ** | | | | |
| **+ជួសជុលរបងសាលាស្រុក៧ +ក្រុង ១** | | | | |
| -ក្រុងព្រះវិហារ | ម | ៣០០ | ៣០០ | -អភិវឌ្ឍទៅជារបងបេតុង |
| -សាលាស្រុកត្បែងមានជ័យ | ម | ៣០០ | ៣០០ | -អភិវឌ្ឍទៅជារបងបេតុង |
| -សាលាស្រុកគូលែន | ម | ៣០០ | ៣០០ | -អភិវឌ្ឍទៅជារបងបេតុង |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| -សាលាស្រុករវៀង | ម | ៣០០ | ៣០០ | -អភិវឌ្ឍទៅជារបងបេតុង |
| -សាលាស្រុកសង្គមថ្មី | ម | ៣០០ | ៣០០ | -អភិវឌ្ឍទៅជារបងបេតុង |
| -សាលាស្រុកជ័យសែន | ម | ៣០០ | ៣០០ | -អភិវឌ្ឍទៅជារបងបេតុង |
| -សាលាស្រុកឆែប | ម | ៣០០ | ៣០០ | -អភិវឌ្ឍទៅជារបងបេតុង |
| -សាលាស្រុកជាំក្សាន្ត | ម | ៣០០ | ៣០០ | -អភិវឌ្ឍទៅជារបងបេតុង |
| -ធ្វើការសាងសង់អគារសាលាក្រុងបន្ត | ម២ | ៣០៦ | ៣០៦ | -ទំនាក់ទំនងសុំថវិការដ្ឋដើម្បីសាងសង់ |
| -ជួសជុលអគារសាលាស្រុកគូលែន | ម២ | ១២៦ | ១២៦ | -ទំនាក់ទំនងសុំថវិការដ្ឋដើម្បីសាងសង់ |
| -ជួសជុលអគារសាលាស្រុកត្បែងមានជ័យ | ម២ | ១៥៣ | ១៥៣ | -ទំនាក់ទំនងសុំថវិការដ្ឋដើម្បីសាងសង់ |
| -ជួសជុលអគារសាលាស្រុកជាំក្សាន្ត | ម២ | ១២៣ | ១២៣ | -ទំនាក់ទំនងសុំថវិការដ្ឋដើម្បីសាងសង់ |
| -ជួសជុលអគារសាលាស្រុកជ័យសែន | ម២ | ១២៣ | ១២៣ | -ទំនាក់ទំនងសុំថវិការដ្ឋដើម្បីសាងសង់ |
| -ជួសជុលអគារសាលាស្រុកឆែប | ម២ | ១២៣ | ១២៣ | -ទំនាក់ទំនងសុំថវិការដ្ឋដើម្បីសាងសង់ |
| -ជួសជុលអគារសាលាស្រុកសង្គមថ្មី | ម២ | ១២៦ | ១២៦ | -ទំនាក់ទំនងសុំថវិការដ្ឋដើម្បីសាងសង់ |
| -ជួសជុលអគារសាលាស្រុករវៀង | ម២ | ១២៦ | ១២៦ | -ទំនាក់ទំនងសុំថវិការដ្ឋដើម្បីសាងសង់ |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | |
| -ស្ថាបនាផ្លូវភ្លោះក្រាលកៅស៊ូ | ម២ | ៧.៥៦០ | ២០.០០០ | -ស្នើសុំថវិការដ្ឋ |
| -ជួសជុលផ្លូវក្រាលគ្រួសក្រហម | ម | ៣.៩៣៤ | ២០.០០០ | -ស្នើសុំថវិការដ្ឋ |
| -ជួសជុលផ្លូវក្រាលគ្រួសក្រហមស្រុក ៧ និងក្រុង ១ | ម | ១៦.០០០ | ២០.០០០ | -ស្នើសុំថវិការដ្ឋ |
| -ស្ថាបនាលូបង្ហូរទឹកស្រុក ក្រុង និងខេត្ត | ខ្សែ | ៣០ | ១០០ | -ស្នើសុំថវិការដ្ឋ |
| **សាងសង់របងបេតុងសត្តឃាតដ្ឋាន** | | | | |
| -ក្រុងព្រះវិហារ | ម | ៣០០ | ៣០០ | -ស្នើសុំថវិកាដើម្បីសាងសង់ទៅជារបងបេតុង |
| -ស្រុកគូលែន | ម | ១៥០ | ១៥០ | -ស្នើសុំថវិកាដើម្បីសាងសង់ទៅជារបងបេតុង |
| -ស្រុកជាំក្សាន្ត | ម | ១៥០ | ១៥ | -ស្នើសុំថវិកាដើម្បីសាងសង់ទៅជារបងបេតុង |
| **ទីចាត់ការអន្តរវិស័យ** | | | | |
| **១.១១.៣៥ គោលបំណងៈពង្រឹងការរៀបចំច្បាប់ធ្វើអាជីវកម្ម** | | | | |
| -រៀបចំការគ្រប់គ្រង ឱ្យបានដាច់ស្រឡះ ជៀសវាងការជាន់ ភារកិច្ចគ្នា | ភាគរយ | ១០ | ៣០ | .គោរពតួនាទី និងអនុវត្តភារកិច្ច ឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ |
| -ពង្រឹងការអនុវត្តច្បាប់ឱ្យបាន តឹងរឹង | ភាគរយ | ៣០ | ៨០ | -ផ្សព្វផ្សាយអំពីច្បាប់ និងមានវិធាន ការតឹងរឹង |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| -ពង្រីកទីតាំង និងសាងសង់តូប លក់ដូរបន្ថែម, រៀបចំជួសជុលនិងសាង សង់ផ្សារថ្មី បន្ថែម និងរៀបចំសាងសង់ ទីតាំងសត្តឃាតឱ្យបានល្អ | ភាគរយ | ៣០ | ៩០ | -ស្វែងរកដៃគូវិនិយោគ |
| -ធ្វើការផ្សព្វផ្សាយ អំពីសក្តានុពល ដែលខេត្តមានដើម្បីទាក់ទាញការ វិនិយោគ | ភាគរយ | ៣០ | ៩០ | -ស្វែងរកដៃគូវិនិយោគ |
| **សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** | | | | |
| **១.១២.៣៦ គោលបំណងៈពង្រឹងការគ្រប់គ្រងថវិកាថ្នាក់ខេត្ត** | | | | |
| -ថវិកាទីចាត់ការហិរញ្ញវត្ថុ សាលាខេត្ត | | | | |
| ចំណូលចរន្តៈ | | | | |
| ចំណូលៈ សារពើពន្ធ | លានរៀល | 357 | 1,787 | -ជំរុញការងារប្រមូលចំណូលអោយបានតាមផែនការពិសេស ចំណូលក្រៅសារពើពន្ធ អោយមានកំណើនពី៥%-៧% ក្នុង ១ ឆ្នាំ ជៀសវាងអង្គភាពទុកចំណូលក្នុងបេឡារបស់ខ្លួន |
| ចំណូលៈ មិនមែនសារពើពន្ធ | លានរៀល | 13,757 | 68,786 | |
| ចំណាយចរន្តៈ | | | | |
| ចំណាយៈ មធ្យោបាយសេវា | លានរៀល | 9,303 | 46,517 | -ពិនិត្យ និងតាមដានការចំណាយថវិការដ្ឋ និងតំរង់ ទិសដៅការងារ |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្ត្រអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| ចំណាយ: អន្តរាគមន៍សាធារណៈ | លានរៀល | 171 | 855 | ប្រតិបត្តិថវិកា អោយបានត្រឹមត្រូវចំគោលដៅ ជឿទុកចិត្តបាន និង ប្រកប ដោយប្រសិទ្ធិភាព |
| ចំណាយ: ជាមូលធន | លានរៀល | 4,639 | 23,193 | |
| -ថវិកាតាមបណ្តាមន្ទីរជំនាញ | | | | |
| ចំណូលចរន្ត: | | | | |
| ចំណូល: សារពើពន្ធ | លានរៀល | - | - | -គ្រប់គ្រង និងសំរបសំរួលកែទំរង់រចនាសម្ព័ន្ធ និងការគ្រប់គ្រង សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈសហការជាមួយក្រសួងស្ថាប័ន ពាក់ព័ន្ធ ដើម្បីដឹកនាំនិងចូលរួមរៀបចំអនុវត្តគោលនយោបាយ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល -រៀបចំ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ |
| ចំណូល: មិនមែនសារពើពន្ធ | លានរៀល | 28 | 137 | |
| ចំណាយចរន្ត: | | | | |
| ចំណាយ: មធ្យោបាយសេវា | លានរៀល | 21,962 | 109,810 | |
| ចំណាយ: អន្តរាគមន៍សាធារណៈ | លានរៀល | 2,385 | 11,923 | |
| **ពន្ធដារ** | | | | |
| **១.១៣.៣៧ គោលបំណង: បង្កើនចំណូលសារពើពន្ធ** | | | | |
| ចំណូលថវិការដ្ឋ ( ផ្នែកគ្រប់គ្រងអ្នកជាប់ពន្ធមធ្យម , របបម៉ៅការ ) | លានរៀល | 826.209 | 1,345 | -ផ្សព្វផ្សាយច្បាប់ពន្ធ |
| ចំណូលថវិកាខេត្ត ( ពន្ធប្រថាប់ត្រា , ពន្ធប្រថាប់ត្រាក្រុមហ៊ុន , អាករបំភ្លឺ | | | | -ជំរឿនមូលដ្ឋានជាប់ពន្ធ |

| គោលដៅ និងគោលបំណង | សូចនាករ | | | យុទ្ធសាស្រ្តអភិវឌ្ឍន៍ |
|---|---|---|---|---|
| | ឯកតា | ២០១០ អនុវត្ត ដើមគ្រា | ២០១៥ | |
| សាធារណៈ , អាករស្នាក់នៅ , ពន្ធសត្តឃាត , ពន្ធប៉ាតង់ , ពន្ធមធ្យោបាយដឹកជញ្ជូន ) | លានរៀល | 357.333 | 400 | |
| **រតនាគារ** | | | | |
| **១.១៤.៣៨ គោលបំណងៈបើកផ្តល់ថវិកាឱ្យទាន់ពេលវេលា** | | | | |
| បើកផ្តល់ថវិការដ្ឋ-ខេត្ត ( បៀវត្សមន្ត្រីជុំវិញខេត្ត ស្រុក ក្រុង ឃុំ) | លានរៀល | 10,222 | 20,576 | |
| បើកប្រាក់ឧបត្ថម្ភមន្ត្រីមានជម្ងឺ-កូនកំព្រា និវត្តជន ជនក្រីក្រ | លានរៀល | 4,297 | 7,879 | |
| **អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍** | | | | |
| **១.១៥.៣៩ គោលបំណងៈ បង្កើនសន្តិសុខស្បៀងសំរាប់កសិករដែលទទួលរងឥទ្ធិពលដោយសារការឡើងថ្លៃស្បៀងអាហារ(ស្រុកគូលែន និងជ័យសែន)** | | | | |
| ផ្តល់ស្រូវពូជនិងជី | គ្រួសារ | ៤២៨៥ | | -ជ្រើសរើសតាមលក្ខណៈវិនិច្ឆ័យដែលផ្តល់ដោយ FAO<br>-ប្រជុំណែនាំគំរោងដល់អាជ្ញាធរពាក់ព័ន្ធ<br>-សហការជាមួយមន្ទីរកសិកម្មខេត្តក្នុងការជ្រើសរើសនិងចែកចាយ<br>-តាមដានការប្រើប្រាស់ពូជនិងជី |
| ផ្តល់ពូជបន្លែនិងជី | គ្រួសារ | ២០០០ | | |
- ពង្រឹងការគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ដោយផ្អែកលើមូលដ្ឋានច្បាប់ លិខិតបទដ្ឋានគោលការណ៍ណែនាំនានារបស់ក្រសួងទេសចរណ៍ រដ្ឋបាលខេត្ត និងយន្តការនៃគណៈកម្មការគ្រប់គ្រងអភិវឌ្ឍន៍ទេសចរណ៍ខេត្តឱ្យមានប្រសិទ្ធភាព ។
- លើកកម្ពស់យេនឌ័រ សីលធម៌ សុជីវធម៌ នៅក្នុងវិស័យទេសចរណ៍ ស្របតាមគោលការណ៍ដឹកនាំរបស់ក្រសួង និងខេត្ត ។
- កែលំអ និងពង្រឹងការគ្រប់គ្រងមណ្ឌលព័ត៌មានទេសចរណ៍ទាំងពីរកន្លែង និងរចនាសម្ព័ន្ធការងារឱ្យកាន់តែមានប្រសិទ្ធភាពស្របតាមតួនាទី ភារកិច្ច ដែលក្រសួងបានកំណត់ ។

### ២.៤.១.៥ ឧស្សាហកម្ម

- ខិតខំបង្កើនថាមពលអគ្គិសនី ជូនដល់ប្រជាពលរដ្ឋសម្រាប់ធ្វើការផលិត និងប្រើប្រាស់ឱ្យបានប្រសើរមួយកំរិតថែមទៀត ។
- ស្វែងរកដៃគូដើម្បីធ្វើវារីអគ្គិសនីធុនតូចស្មើ ១០មេកាវ៉ាត់ នៅស្ទឹងសែន(ចំនុចតាកឹង) ស្រុកគូលែន ។
- ទំនាក់ទំនងតភ្ជាប់បណ្តាញអគ្គិសនីពីប្រទេសឡាវ ។
- ធានាឱ្យមានការទុកចិត្ត និងមានស្ថេរភាពក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនី ដើម្បីសម្រួលដល់ការវិនិយោគនិងការអភិវឌ្ឍសេដ្ឋកិច្ចខេត្ត ។

- ជំរុញ និងលើកទឹកចិត្តប្រជាពលរដ្ឋ សមាគមឬផ្នែកឯកជនផ្សេងៗក្នុងការសាងសង់សហគ្រាស និងសិប្បកម្មខ្នាតតូចនៅជនបទ។

## ២.៤.១.៦ សាធារណការ និងដឹកជញ្ជូន

- សិក្សាស្រាវជ្រាវលើកគម្រោងសាងសង់ ជួសជុល និងធ្វើការថែទាំ ប្រព័ន្ធគមនាគមន៍ក្នុងខេត្ត ។
- ពង្រីកកិច្ចសហការជាមួយស្ថាប័នដែលជាដៃគូ ដើម្បីសម្រេចគោលដៅលើវិស័យគមនាគមន៍ ។
- បង្កើនល្បឿនការងារគម្រោងសាងសង់ផ្លូវ ស្ពាននានា ដែលអាចតភ្ជាប់ពីទីរួមខេត្ត ទៅកាន់បណ្តាស្រុកនិងភូមិ ឃុំដាច់ស្រយាល ដែលមិនទាន់មានផ្លូវ ស្ពាន។
- បង្កើនភាពជាដៃគូក្នុងការអនុវត្តគំរោងជួសជុល និងថែទាំផ្លូវ ស្ពានក្នុងខេត្ត ដោយការប្រើថវិកាជំនួយរបស់អង្គការជាតិ និងអន្តរជាតិនានា។
- រៀបចំថែទាំផ្លូវស្ពានជាប្រចាំ ដែលមានស្រាប់ ពិសេសផ្លូវចាក់កៅស៊ូ និងផ្លូវក្រាលគ្រួសក្រហមក្នុងទីរួមខេត្ត។
- សម្រួលសកម្មភាពក្នុងការផ្តល់សេវាកម្ម អាជីវកម្ម និងលើកទឹកចិត្តផ្នែកឯកជនដែលមានយានយន្តឱ្យមកធ្វើច្បាប់សុំធ្វើអាជីវកម្មដឹកជញ្ជូនក្នុងស្រុក។
- ពង្រឹងបន្ថែមការផ្តល់សេវាផ្សព្វផ្សាយស្តីពីច្បាប់ចរាចរ និងស្លាកចរាចរដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋឱ្យយល់ដឹងពីច្បាប់ចរាចរ ឬស្លាកសញ្ញាចរាចរ។
- អនុវត្តផែនការសកម្មភាព ស្តីពីសុវត្ថិភាពចរាចរផ្លូវគោកឱ្យបានហ្មត់ចត់។
- សម្រួលសកម្មភាពសេវាកម្មអាជីវកម្មដឹកជញ្ជូននិងលើកទឹកចិត្តផ្នែកឯកជនឱ្យចូលរួមវិនិយោគលើការងារដឹកជញ្ជូនទំនិញផ្សេងៗឱ្យបានច្រើន។
- សហការជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដើម្បីរៀបចំសណ្តាប់ធ្នាប់នៅលើដងផ្លូវសាធារណៈឱ្យបានល្អដោយអនុវត្តតាមអនុក្រឹត្យលេខ១៧៩អនក្រនិងប្រកាសលេខ០៦ របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងដីចំណីផ្លូវទាំងផ្លូវជាតិ និងផ្លូវខេត្តតាមការកំណត់។ ទប់ស្កាត់ឱ្យបាននូវរថយន្តគ្រប់ប្រភេទដែលធ្វើចរាចរលើផ្លូវសាធារណៈដោយដឹកជញ្ជូនលើសទម្ងន់កំណត់។

## ២.៤.១.៧ ប្រៃសណីយ៍ និងទូរគមនាគមន៍

- ផ្សព្វផ្សាយច្បាប់នៃការប្រើប្រាស់បណ្តាញទូរគមនាគមន៍ក្នុង និងក្រៅប្រទេស។
- ជំរុញការគ្រប់គ្រងសេវាប្រៃសណីយ៍ និងគមនាគមន៍ឱ្យមានប្រសិទ្ធិភាពខ្ពស់ពីក្រសួងដល់មូលដ្ឋាន។
- បន្តផ្សព្វផ្សាយច្បាប់ប្រើប្រាស់រលកធាតុអាកាស(វិទ្យុគមនាគមន៍(ម៉ៃក្រូវ៉េវ) ប្រព័ន្ធអ៊ីនធើណែត វិទ្យុទូរទស្សន៍ ប្រព័ន្ធផ្កាយរណប) និងពង្រីកបណ្តាញទូរគមនាគមន៍ដល់មូលដ្ឋាន។
- ជំរុញការផ្សព្វផ្សាយឱ្យអតិថិជនចេះប្រើប្រាស់វិស័យប្រៃណីយ៍និងពង្រីកបណ្តាញប្រៃសណីយ៍ដល់មូលដ្ឋាន ។
- សហការជាមួយក្រុមហ៊ុនឯកជន និងក្រុមហ៊ុនចំរុះរដ្ឋ ឱ្យមកវិនិយោគទុន ពង្រីកបណ្តាញទូរស័ព្ទអចល័ត

និងចល័តឱ្យបាននៅទូទាំងខេត្ត ។

## ២.៤.១.៨.ពាណិជ្ជកម្ម

- ពង្រីកទីផ្សារលក់រាយ ដែលមានស្រាប់ក្នុងខេត្ត ស្រុក ឃុំ និងតាមច្រកព្រំដែន ។
- ទំនាក់ទំនងរកវិនិយោគិន ដើម្បីសាងសង់ផ្សារនៅស្រុក ឃុំ ។
- បង្កើតផ្សារលក់ដុំកសិផល ។
- បង្កើនបរិមាណគុណភាពនាំចេញ ។
- រៀបចំពិព័រណ៍ពាណិជ្ជកម្មប្រចាំឆ្នាំនៅថ្នាក់ខេត្ត និងចូលរួមក្នុងពិព័រណ៍ប្រចាំឆ្នាំនៅថ្នាក់ជាតិ និងតំបន់ ។
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្ត្រីរាជការក្នុងការងារពាណិជ្ជកម្ម ។
- ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋាននានា លើវិស័យពាណិជ្ជកម្ម ។
- ផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម និងតម្លៃតម្រូវការលើទីផ្សារ ។
- ចងក្រងសមាគមដោយអាចទាញយកផលប្រយោជន៍ ពីសក្តានុពល ពីស្ថានភាពភូមិសាស្ត្ររបស់ខ្លួន ពីវិនិយោគិន និងមីក្រូហិរញ្ញវត្ថុ ។
- ជំរុញការអភិវឌ្ឍការកែច្នៃផលិតផលនៅនឹងកន្លែង បង្កើតការងារពលកម្មនៅនឹងកន្លែង ។
- កែលំអបច្ចេកទេសផលិតផល ដើម្បីចំណាយទុនតិច ផលិតផលទទួលបានបរិមាណច្រើន គុណភាពខ្ពស់ លក់ចេញតាមតម្លៃសមស្របបានច្រើន និងមានការទាក់ទាញពីអ្នកទិញ ។
- ទំនាក់ទំនងសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្មជាមួយប្រទេសជិតខាង និងបើកច្រកព្រំដែនជំរុញការនាំចេញ-នាំចូល ។

## ២.៤.១.៩. អភិវឌ្ឍន៍ជនបទ

- បើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ។
- បន្តរៀបចំដាក់លេខផ្លូវ និងជំរុញអ្នកប្រើប្រាស់ផ្លូវឱ្យគោរពច្បាប់(ពិសេសអ្នកដឹកលើសទម្ងន់)
- ជំរុញបន្ថែមការសហការជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋានបានល្អ ។
- បង្កើនថវិកាសម្រាប់ការងារថែទាំផ្លូវ និងមធ្យោបាយប្រើប្រាស់ ។
- បន្តការសហការល្អជាមួយសហគន៏ អាជ្ញាធរមូលដ្ឋាន ដើម្បីបន្តដាំឈើតាមដងផ្លូវ ។
- បង្កើនការផ្គត់ផ្គង់សេវាទឹកស្អាតដើម្បីឱ្យទទួលបានការគ្របដណ្តប់នៅទូទាំងខេត្ត ។
- ពង្រឹងការគ្រប់គ្រង និងប្រើប្រាស់ទិន្នន័យអណ្តូងគ្រប់ប្រភេទ ។
- ធ្វើផែនទីបង្ហាញទីតាំងដល់ភ្នាក់ងារ និងដៃគូរអភិវឌ្ឍន៍ដែលកំពុងអនុវត្តកម្មវិធីទឹកស្អាត ។
- ពង្រឹងការត្រួតពិនិត្យ និងវាយតម្លៃលើរាល់ការអនុវត្តកម្មវិធីទឹកស្អាតឱ្យមានប្រសិទ្ធភាពខ្ពស់ ។
- រៀបចំលិខិតបទដ្ឋានស្តីពីការគ្រប់គ្រងក្រុមហ៊ុនជីកអណ្តូងឯកជន ។

- បណ្ដុះបណ្ដាលពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេស ។
- ពង្រឹងការគ្រប់គ្រងគុនភាពទឹកតាមតំបន់ដែលការប៉ះពាល់សុខភាព ។
- បន្តបង្កើត និងពង្រឹងសមត្ថភាពក្រុមប្រើប្រាស់ទឹកស្អាត និងអនាម័យ ។
- គួរមានគោលនយោបាយថ្នាក់ជាតិ ស្ដីពីការគ្រប់គ្រងនិងថែទាំផ្លូវ ។

## ២.៤.១.១០. បរិស្ថាន

- ពង្រឹងភាពជាដៃគូ និងរកដៃគូជំនួយសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។
- ពង្រឹងសមត្ថភាពនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយមានការចូលរួម ។
- លើកទឹកចិត្តដល់អ្នកមានស្នាដៃក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ទន្ទឹមនោះក៏យកចិត្តទុកដាក់ប្រើប្រាស់វិធានការច្បាប់ ដើម្បីទប់ស្កាត់នូវរាល់អំពើបំផ្លិចបំផ្លាញធនធានធម្មជាតិ និងបរិស្ថាន ។
- ជំរុញការបង្កើត និងបន្តពង្រឹងសហគមន៍ព្រៃឈើដែលមានស្រាប់ ។
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយម្ចាស់ជំនួយដើម្បីកៀរគរជំនួយថវិកា និងបច្ចេកទេសដើម្បីអភិរក្សធនធានធម្មជាតិ និងបរិស្ថានឱ្យកាន់តែប្រសើរឡើង ។
- បង្កើត និងពង្រឹងសហគមន៍តំបន់ការពារធម្មជាតិ ។
- សហការជាមួយមន្ទីរជំនាញ និងអាជ្ញាធរពាក់ព័ន្ធដើម្បីចុះបោះបង្គោលកំណត់ទីតាំងអភិវឌ្ឍន៍រម្មណីយដ្ឋានឱ្យបានត្រឹមត្រូវច្បាស់លាស់ ។
- រៀបចំប្លង់មេឱ្យបានត្រឹមត្រូវដើម្បីអភិវឌ្ឍន៍ទៅតាមគោលដៅដែលបានកំណត់ និងស្របទៅតាមគោលការណ៍ច្បាប់ ។
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋមូលដ្ឋានដើម្បីបង្កើនមនសិការស្រឡាញ់វប្បធម៌ និងធនធានធម្មជាតិតាមរយៈគោលការណ៍ និងសេចក្ដីណែនាំផ្សេងៗ ។
- ត្រួតពិនិត្យតាមដានការអនុវត្តន៍របស់ដៃគូអភិវឌ្ឍន៍ដើម្បីសម្របសម្រួលលើការគ្រប់គ្រង និងប្រើប្រាស់ធនធានឱ្យមាននិរន្តរភាព ។
- ពង្រឹងយន្តការ នៃការគ្រប់គ្រងធនធាននៅតាមសហគមន៍អេកូទេសចរណ៍គណៈកម្មការគ្រប់គ្រងសហគមន៍ និងការពង្រីកបន្ថែមនូវសហគមន៍នេះ ។
- ផ្ដល់ចំណេះដឹងដល់មន្ត្រីខេត្ត ក្រុង ស្រុក ជនបង្គោលឃុំ និងសហគមន៍ឱ្យមានសមត្ថភាពជំនាញលើការគ្រប់គ្រង និងត្រួតពិនិត្យការបំពុលបរិស្ថាន និងការងារអប់រំផ្សព្វផ្សាយបរិស្ថាន ។
- ផ្សព្វផ្សាយព័ត៌មានបរិស្ថានតាមគ្រប់រូបភាព ដើម្បីឱ្យមានការចូលរួមគាំទ្រកិច្ចការពារបរិស្ថាន និងអភិរក្សធនធានធម្មជាតិ ។
- រួមចំណែកផ្ដល់យោបល់ក្នុងការកែលំអរាល់គម្រោងអភិវឌ្ឍន៍នានា សំដៅកាត់បន្ថយហេតុប៉ះពាល់បរិស្ថាននៅកំរិតអប្បបរមា ។

## ២.៤.១.១១.សាលាខេត្ត

- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ និងជួយថែរក្សាសំអាតទីផ្សារ ពង្រឹងការអនុវត្តច្បាប់ឱ្យបានតឹងរឹង ពង្រីកទីតាំង និងសាងសង់តូបលក់ដូរបន្ថែម និងរៀបចំជួសជុល និងសាងសង់ផ្សារថ្មីបន្ថែម ។
- សាងសង់ ជួសជុល កែលំអរបងទីធ្លាសាធារណៈនានាដូចជាទីតាំងសត្តឃាត របងផ្សារ របងសាលាក្រុង ស្រុក របងសាលាខេត្ត ។
- កែលំអសោភ័ណ្ឌភាពសួនច្បារសាធារណៈដូចជា សួនច្បារផ្លូវភ្លោះ សួនច្បារក្នុងបរិវេណសាលាខេត្ត សួនច្បារដំណាក់ស្តេច សួនច្បារកន្លែងផ្សេងៗតាមការចាំបាច់ ក្រាលការ៉ូឡាផ្លូវភ្លោះ រៀបចំប្រព័ន្ធទឹក ប្រព័ន្ធភ្លើងបំភ្លឺផ្លូវ បង្គោលភ្លើងតាមដងផ្លូវរង្វង់មូលព្រះនរាយណ៍-នាគបាញ់ទឹក-ផ្លូវភ្លោះ ។
- បន្តសាងសង់ ជួសជុល កែលំអអគាររដ្ឋបាលខេត្ត ក្រុង ស្រុក ។
- ការរៀបចំទីធ្លាប្រណាំងទូក និងកន្លែងប្រារព្ធពិធីសាធារណៈ ។
- សាងសង់ ជួសជុល កែលំអផ្លូវក្រួសក្រហម ប្រព័ន្ធលូដោះទឹកដូចជា ផ្លូវកៅស៊ូនៅផ្លូវភ្លោះ ផ្លូវក្រួសក្រហម ក្នុងខេត្តនិងតាមបណ្តាស្រុក ប្រព័ន្ធលូដោះទឹកជុំវិញផ្សារកំពង់ប្រណាកនិងតាមផ្លូវសាធារណៈក្នុងខេត្ត និងស្រុក ។
- ធ្វើការផ្សព្វផ្សាយអំពីសក្តានុពលដែលខេត្តមាន ដើម្បីទាក់ទាញការវិនិយោគ ។
- បន្តផ្សព្វផ្សាយ និងជំរុញឱ្យភាគីបុរសចូលរួមក្នុងសកម្មភាពជំរុញឱ្យមានការផ្សព្វផ្សាយការគោរពច្បាប់ របស់រដ្ឋ ។
- បន្តពង្រឹងសមត្ថភាពភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ។
- ធ្វើការរៀបចំការសិក្សាលទ្ធភាពគម្រោងរៀបចំការដេញថ្លៃគម្រោង តាមដានវាយតម្លៃការអនុវត្ត គម្រោងក្រុង ស្រុក ឃុំ សង្កាត់នានា. ។
- ជំរុញ និងវាយតម្លៃការអនុវត្តផែនការខេត្តឱ្យមានប្រសិទ្ធភាព ។
- បន្តសហការ និងគាំទ្រការរៀបចំផែនការ អភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។
- បន្តសហការ និងគាំទ្រការរៀបចំ ផែនការថវិកាឃុំ សង្កាត់ ។
- បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីទីចាត់ការពាក់ព័ន្ធការវិនិយោគថ្នាក់ខេត្ត ក្រុង ស្រុក ។
- ជំរុញកៀគវិនិយោគិនឯកជននិងធ្វើទស្សនៈកិច្ចសិក្សាដកស្រង់បទពិសោធន៍លើវិស័យវិនិយោគនេះ ទាំងក្នុង និងក្រៅប្រទេស ។
- ផ្សព្វផ្សាយលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធ ការវិនិយោគដល់អ្នកពាក់ព័ន្ធ ។
- បន្តសហការ និងគាំទ្រការបង្កើត ការបំបែក ការបង្រួម និងការកំណត់ព្រំប្រទល់ភូមិ ឃុំ សង្កាត់ ក្រុង ស្រុកតាមការចាំបាច់ ។

## ២.៤.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

### ២.៤.២.១ អប់រំយុវជន និងកីឡា

- ធ្វើឱ្យប្រសើរឡើងប្រសិទ្ធភាពសេវាអប់រំ ។
- ពង្រីកការអប់រំកុមារតូច ។
- ជំរុញការចូលរៀន ពង្រឹងគុណភាព និងប្រសិទ្ធភាពការអប់រំកំរិតបឋមសិក្សា ។
- ជំរុញការចូលរៀន ពង្រឹងគុណភាព និងប្រសិទ្ធភាពការអប់រំកំរិតមធ្យមសិក្សាបឋមភូមិ ។
- ជំរុញការចូលរៀន និងសមធម៌នៃការអប់រំនៅកំរិតមធ្យមសិក្សាទុតិយភូមិ ។
- ជំរុញការអភិវឌ្ឍន៍សមត្ថភាព និងពង្រឹងគុណភាពគ្រូបង្រៀន ។
- ការផ្គត់ផ្គង់សៀវភៅគោលដល់គ្រូ និងសិស្ស ។
- ជំរុញពង្រីកការអប់រំក្រៅប្រព័ន្ធ ។
- ជំរុញការអភិវឌ្ឍន៍ការងារយុវជន និង កីឡា ។
- ចុះបណ្តុះបណ្តាលវគ្គមិត្តអប់រំមិត្តដល់ក្រុមកុមារនៅតាមបណ្តាមូលដ្ឋាន ។

### ២.៤.២.២. សុខាភិបាល

- បង្កើនសុខភាពមាតា កុមារ និងទារក ។
- ផ្តល់ការអប់រំសុខភាពបន្តពូជ ដល់ប្រជាពលរដ្ឋទូទៅនៅមូលដ្ឋាន ។
- ផ្តល់ការចាក់ថ្នាំបង្ការ និងផ្តល់អាហារូបត្ថម្ភដល់ប្រជាពលរដ្ឋនៅតាមជនបទ ។
- ពង្រឹងធនធានមនុស្ស និងស្ថាប័នលើវិស័យសុខាភិបាល និងអប់រំសុខភាព នៅថ្នាក់ខេត្ត និង ស្រុក ។
- រៀបចំធ្វើឱ្យប្រសើរឡើង នូវហេដ្ឋារចនាសម្ព័ន្ធជនបទលើវិស័យសុខាភិបាល ។

### ២.៤.២.៣. កិច្ចការនារី

- បំប៉ន និងពង្រឹងសមត្ថភាពគ្រូ និងជនបង្គោលស្ត្រី និងកុមារថ្នាក់ខេត្ត ដល់ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ។
- បញ្ជ្រាបយេនឌ័រឱ្យបានទូលំទូលាយលើគ្រប់វិស័យដល់ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ។
- រៀបចំវេទិកាផ្សេងៗ ដើម្បីបង្កើនការយល់ដឹងឱ្យកាន់តែល្អប្រសើរដល់ស្ត្រីនៅតាមភូមិ ឃុំ សង្កាត់ ក្រុង ស្រុក ។
- បើកវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយពីច្បាប់ផ្សេងៗដូចជា ច្បាប់ទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងសុខភាពបន្តពូជឱ្យបានទូលំទូលាយ ។ ការទប់ស្កាត់ការជួញដូរស្ត្រីនិងកុមារ ការជួញដូរផ្លូវភេទ ការរំលោភសេពសន្ថវៈ និងការធ្វើចំណាកស្រុក ។ល ។ ដើម្បីបង្កើនការយល់ដឹងដល់ស្ត្រី និងប្រជាពលរដ្ឋទូទៅ ។
- បណ្តុះបណ្តាលវគ្គមិត្តអប់រំមិត្តដល់ក្រុមកុមារនៅតាមបណ្តាមូលដ្ឋាន ។
- បណ្តុះបណ្តាលជំនាញអធិការកិច្ចការងារដល់មន្ត្រី ។

- ពង្រឹងភាពអង់អាចដល់ស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុង ស្រុក និងរដ្ឋបាលភូមិក្នុងការសម្តែងមតិ ។
- ពង្រឹងសមត្ថភាពដល់មន្ត្រីជំនាញ ។
- រៀបចំបើកវេទិកាស្ត្រី(នារីរតនៈ)និងវេទិកាសាធារណៈ ដើម្បីបង្កើនការយល់ដឹងដល់ស្ត្រីឱ្យកាន់តែប្រសើរឡើង ។
- រៀបចំវេទិកា និងផ្សព្វផ្សាយលើកកំពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ។
- ផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារ និងលើកកំពស់ជនពិការ ។
- ផ្សព្វផ្សាយការអនុវត្តច្បាប់ ស្តីពីការគោរពសិទ្ធកុមារ និងកិច្ចការពារកុមាររងគ្រោះ និងងាយរងគ្រោះ នៅតាមសហគមន៍តាមបណ្តាមណ្ឌលថែទាំកុមាររដ្ឋ និងអង្គការនានា ។
- អនុវត្តកម្មវិធីចុះផ្សព្វផ្សាយទប់ស្កាត់ការជួញដូរស្ត្រីនិងកុមារនៅតាមមណ្ឌលរដ្ឋអង្គការនិងនៅតាមសហគមន៍ ។ យកចិត្តទុកដាក់ដល់សន្តិសុខចំពោះមុខសញ្ញាដែលរងគ្រោះ ពិសេសកុមារកំព្រា ស្ត្រីមេម៉ាយក្រីក្រ កូនច្រើន ពេស្យាចារ ស្ត្រីនិងកុមាររងគ្រោះដោយសារ ការជួញដូរ ការកេងប្រវ័ញ្ចកំលាំងពលកម្មទម្រង់ ធ្ងន់ធ្ងរ ។
- ផ្សព្វផ្សាយច្បាប់ ។
- រៀបចំអន្តេវាសិកដ្ឋានសម្រាប់សិស្សស្ត្រី ។
- ជំរុញឱ្យមានបង្គន់អានាម័យតាមសាលាសម្រាប់សិស្សស្រី ។
- រៀបចំក្រុមប្រឹក្សាកុមារនៅគ្រប់សាលារៀន ។
- ជម្រុញសិស្សស្រី ឱ្យរៀនចប់ការអប់រំកំរិតមូលដ្ឋាន ។
- ផ្សព្វផ្សាយឱ្យមានលក្ខណៈទូលំទូលាយ និងស៊ីជម្រៅក្នុងឱកាសទិវាសិទ្ធិនារី៨មីនា ។
- រៀបចំទម្រង់បទដ្ឋាននីមួយៗ និងបញ្ចូលទិន្នន័យកុមារក្នុងផែនការអភិវឌ្ឍន៍ឃុំសង្កាត់ ។
- ផ្សព្វផ្សាយ និងជម្រុញការគ្រប់គ្រងរបស់មេដោះនៅតាមផ្ទះ ។
- ចុះដល់សហគ្រាសសិប្បកម្ម ស្នើសុំផ្តល់ព័ត៌មានឱ្យបានជាក់លាក់អំពីការប្រែប្រួលកម្មករ ។
- សិក្សាពីតម្រូវការវិជ្ជាជីវៈដល់មូលដ្ឋាន ។

### ២.៤.២.៤. វប្បធម៌ និងវិចិត្រសិល្បៈ

- រៀបចំភ្នាក់ងារ ទីកន្លែង មធ្យោបាយផ្សេងៗឱ្យបានសមស្របសម្រាប់ការងារថែរក្សា គ្រប់គ្រង និងលើកតម្កើង មរតកវប្បធម៌ឱ្យបានគង់វង្ស ។
- រៀបចំកម្មវិធីបណ្តុះបណ្តាលផ្សព្វផ្សាយច្បាប់ដល់មហាជនស្តីពីការលើកកំពស់ការងារអភិរក្សនិងអភិវឌ្ឍន៍ វិស័យវប្បធម៌ជាតិ ។
- ចុះប្រមូលដីកវត្ថុបុរាណ ដែលបាក់បែករាយប៉ាយក្នុងព្រៃ និងនៅតាមបណ្តាប្រាសាទ ដើម្បីយកមករក្សាទុកក្នុងមន្ទីរ ។
- ចុះសិក្សាស្រាវជ្រាវពីបេតិកភ័ណ្ឌរូបី និងអរូបី ។
- ចុះពង្រីក និងពង្រឹងសកម្មភាពថែរក្សាប្រាសាទបុរាណ ។

- ផ្សព្វផ្សាយបំផុសស្មារតីមហាជនឱ្យចេះស្រឡាញ់ និងថែរក្សាទំនៀមទំលាប់ប្រពៃណី សម្បត្តិវប្បធម ។
- គ្រប់គ្រងត្រួតពិនិត្យផ្ទាំងស្លាកសញ្ញា យីហោ អាជីវកម្មភាពយន្ត សិល្បៈសូន្យរូប និងសិប្បកម្ម ។
- ចុះសិក្សាស្រាវជ្រាវទំនៀមទំលាប់ប្រពៃណី និងជនជាតិភាគតិច ។
- ចុះត្រួតពិនិត្យ អាជីវកម្ម សំអាងការ ភ្លេងបុរាណ និងសម័យ ។

## ២.៤.២.៥. ព័ត៌មាន

- សាងសង់អភិរក្សដ្ឋានសំរាប់ចុះសិក្សាស្រាវជ្រាវ ។
- សាងសង់អាគារ និងស្ថានីយ៍វិទ្យុ ។
- សិក្សាអំពីទីតាំងសាងសង់ស្ថានីយ៍ និងដាក់ទូរទស្សន៍ខ្សែកាប ។
- ធ្វើការទំនាក់ទំនង និងសហការជាមួយក្រសួងព័ត៌មានដើម្បីសម្រេចឱ្យបានការសាងសង់អគារ និងស្ថានីយ៍វិទ្យុ ។
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពមន្ត្រីជំនាញបច្ចេកទេស និងព័ត៌មាន ។
- ជំរុញការផ្សព្វផ្សាយព័ត៌មានក្នុងខេត្ត ដោយយកចិត្តទុកដាក់លើព័ត៌មានឆ្លុះបញ្ចាំងជូនរាជរដ្ឋាភិបាលអំពីការរីកចំរើនលើគ្រប់វិស័យរបស់ខេត្ត ព័ត៌មានស្តីពីច្បាប់ជាមួយវប្បធមិប្រពៃណីក្នុងខេត្ត ។
- ផ្គត់ផ្គង់មធ្យោបាយឧបករណ៍ចាំបាច់សម្រាប់ការផ្សព្វផ្សាយព័ត៌មាន និងបង្កើតភ្នាក់ងារសារព័ត៌មាននៅថ្នាក់ឃុំ សង្កាត់ ។
- ជំរុញការចុះយកព័ត៌មាន និងពង្រីកការផ្សព្វផ្សាយព័ត៌មាន ។
- បណ្តុះបណ្តាលមន្ត្រីព័ត៌មាន និងមន្ត្រីបច្ចេកទេស ។
- ផ្សព្វផ្សាយការអនុវត្តអនុក្រិត្យស្តីពីទិវាអន្តរជាតិគ្រួសារ១៥ ឧសភា ។

## ២.៤.២.៦. សង្គមកិច្ច និងយុវនិតិសម្បទា

- បន្តការផ្តល់គ្រឿងអវៈយវៈសិប្បនិម្មិត ដើម្បីសំរួលរាងកាយជូនជនពិការទាំង២ភេទ ដោយសហការជាមួយអង្គការជាដៃគូរជាតិ អន្តរជាតិ ដែលមានកម្មវិធីលើផ្នែកស្តារលទ្ធភាពពលកម្ម ។
- សាងសង់ផ្ទះកុមារឱ្យរស់នៅជាលក្ខណៈគ្រួសារក្រោមការឧបត្ថម្ភពីអង្គការអាស៊ីអាស្តេកា ។
- រៀបចំទិវា ០១ តុលា រៀងរាល់ឆ្នាំ សំរាប់រំលឹកគុណដល់គុណូបការៈរបស់មនុស្សចាស់ ។
- អនុវត្តការផ្តល់ដីសម្បទានសង្គមកិច្ច ជូនប្រជាពលរដ្ឋ ដែលខ្វះដីពិតប្រាកដ ដោយអនុវត្តទៅតាម ប្រកាសស្តីពីលក្ខណៈវិនិច្ឆ័យខាងហិរញ្ញវត្ថុរបស់អ្នកសុំដីសម្បទានសង្គមកិច្ច ។

## ២.៤.២.៧. ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- ផ្សព្វផ្សាយស្តីពីច្បាប់ការងារដល់ កម្មករ និយោជិត និយោជក និងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិ និងកម្មវិធីជួយដល់ក្រុមជនងាយទទួលរងគ្រោះ ។
- សិក្សាស្រាវជ្រាវទីផ្សារការងារ ដើម្បីធ្វើការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ។

- ខិតខំស្វែងរកជំនួយ និងសហការជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជំរុញការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**២.៤.២.៨. ធម្មការ និងសាសនា**

- ពង្រឹងរចនាសម្ព័ន្ធសម្រាប់អនុគណក្រុង ស្រុកឱ្យមាន វិន័យធម៌ ធម្មធម៌ សមុហ៍ និង អនុលេខាធិការ ។
- បង្កើតអនុគណៈកម្មការសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃលើព្រះសង្ឃខុសវិន័យ និងខុសពីច្បាប់រដ្ឋ។
- រៀបចំការប្រជុំអន្តរសាសនាគ្រឹះ និង សាសនាឥស្លាមជារៀងរាល់មួយឆ្នាំម្តង។
- ពង្រឹងការគ្រប់គ្រង ការចុះបញ្ជីលើពាហិរសាសនាផ្សេងៗ និងបន្តចុះស្រាវជ្រាវសមាគមន៍អង្គការ ដែលមានចរិតជាសាសនា ដើម្បីឱ្យសុំច្បាប់អនុញ្ញាតពីក្រសួងធម្មការ និងសាសនា។

**២.៤.២.៩.ក្រុមការងារផែនការ សកម្មភាពកំចាត់មីន Mine Action Provincial Unit**

- រៀបចំការកសាងផែនការផ្ទេរ ប្រគល់ដីដោះមីនរួច ។
- ការប្រជុំឃុំរៀបចំផែនការទិន្នន័យដីមានដោះមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។
- ពង្រឹងការគ្រប់គ្រងសកម្មភាពពិនិត្យមើលដំណើរការអនុវត្តផែនការដោះមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។
- ពង្រឹងការតាមដានអនុវត្តផែនការដោះមីន និង ការត្រួតពិនិត្យការគ្រប់គ្រងដីដោះមីនរួច ។

**២.៤.២.១០.សាលាខេត្ត**

- ជំរុញការអនុវត្តតួនាទី ភារកិច្ចរបស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ ។
- លើកកំពស់ និងជំរុញការអនុវត្តសកម្មភាពវិនិយោគសេវាកម្មនៅថ្នាក់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ។
- អប់រំផ្តល់ចំណេះដឹងអំពីការការពារសុវត្ថិភាព និងសង្គ្រោះប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិតាមរយៈផ្តល់ស្បៀង និងដោះស្រាយគោលនយោបាយជូនប្រជាពលរដ្ឋ។

## ២.៤.៣ យុទ្ធសាស្ត្រប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

- កែលំអការសំអាតបរិស្ថានទីប្រជុំជនខេត្ត ដោយការដាក់ធុងសំរាមតាមទីធ្លាសាធារណៈ និងធ្វើការណែនាំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីការថែទាំបរិស្ថាន។
- ជំរុញការរៀបចំផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី និងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋចូលរួមចុះបញ្ជីដីធ្លី ។
- ជំរុញឱ្យមានការគោរព និងអនុវត្ត ច្បាប់ដែលមានជាធរមាន។
- ណែនាំឱ្យប្រជាពលរដ្ឋយល់ដឹងអំពី គោលការណ៍អភិវឌ្ឍន៍ ការងាររៀបចំដែនដី ការងារនគរូបនីយកម្ម សំណង់ សុរិយោដី និងការងារភូមិសាស្ត្រ ដើម្បីធានានូវ តុល្យភាព និងស្ថេរភាពនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចសំដៅការពារផលប្រយោជន៍ និងសណ្តាប់ធ្នាប់សាធារណៈ លើកកំពស់សោភ័ណ្ឌភាពសង្គម ការពារ សម្បត្តិធម្មជាតិ និងវប្បធម៌ធម្មជាតិ។
- ចងក្រងឯកសារទិន្នន័យទាក់ទងការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ សុរិយោដី និងភូមិសាស្ត្រ

ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ។

- អនុវត្តន៍បទបញ្ញត្តិ លិខិតបទដ្ឋានបច្ចេកទេសនានា របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។
- ផ្តល់មតិយោបល់ និងពិនិត្យលើការស្នើសុំទីតាំងសាងសង់ដោយផ្អែកលើលិខិតអនុញ្ញាតិរបស់ក្រសួងឬខេត្ត ។
- គ្រប់គ្រងតាមដាន និងត្រួតពិនិត្យការសិក្សាស្រាវជ្រាវគម្រោងប្លង់ និងសំណង់ដល់រូបវ័ន្តបុគ្គល និងក្រុមជាងសំណង់ និងតាមដានសមត្ថភាពបច្ចេកទេសអាជីវកម្ម។
- វាស់វែង និងគណនាឋានលេខា ស្ថានភាពដី និងក្បាលដីក្នុងក្របខ័ណ្ឌសមត្ថកិច្ច និងភូមិសាស្រ្តរដ្ឋបាលដែលខ្លួនទទួលខុសត្រូវ។
- កសាងប្លង់ដីគ្រប់ប្រភេទ ប្លង់ស្ថានភាពដីទូទៅ ប្លង់សុរិយោដី និងប្លង់ក្បាលដី ។
- ជំរុញការបោះបង្គោល ព្រំដីសម្បទានសេដ្ឋកិច្ចឱ្យក្រុមហ៊ុនវិនិយោគ និង ព្រំដីសម្បទានសង្គមកិច្ច សំរាប់សាងសង់លំនៅដ្ឋានកសិកម្ម និងធ្វើការបែងចែកដីដល់អ្នកខ្វះដីពិតប្រាកដ ។
- អនុវត្តគោលនយោបាយដីធ្លី ជូនប្រជាពលរដ្ឋប្រកបដោយយុត្តិធម៌ និងសមភាពទាំងដីលំនៅដ្ឋាន និង ដីសម្បទាន សង្គមកិច្ច។
- បណ្តុះបណ្តាល និងពង្រឹងសមត្ថភាពដល់មន្រ្តីសុរិយោដី និងភូមិបាលខេត្ត ក្រុង ស្រុក ។
- ចេញលិខិតអនុញ្ញាតិសាងសង់ និងគ្រប់គ្រងដីធ្លីគ្រប់ប្រភេទ ។
- តាមដានអនុវត្តបទបញ្ញត្តិសេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្នុងការជួសជុលថែទាំ ប្រើប្រាស់អាគារសំណង់សិល្បការ្យ និងបេតិកភ័ណ្ឌក្នុងខេត្ត។
- ចូលរួមសិក្សា កសាងឯកសារពន្ធអាករដី និងលើកគម្រោងចំណូលពន្ធអាករដីប្រចាំឆ្នាំក្នុងទូទាំងខេត្តក្នុងសមត្ថកិច្ចរបស់ខ្លួន។
- ផ្សព្វផ្សាយពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ដល់ប្រជាជនគ្រប់រូប នៅតាមទីប្រជុំជន និងជនបទ។

## ២.៤.៤ យុទ្ធសាស្រ្តគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

### ២.៤.៤.១.ការគ្រប់គ្រង និងបង្ការគ្រោះមហន្តរាយ

#### ២.៤.៤.១. ១ការងារគ្រប់គ្រងលើគ្រោះធម្មជាតិលើវិស័យកសិកម្មៈ

- បណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់មន្រ្តី និងបុគ្គលិកក្រោមឱវាទលើការងារត្រៀមឆ្លើយតប និងគ្រប់គ្រងគ្រោះមហន្តរាយផ្សេងៗ ពិសេសលើបញ្ហាទឹកជំនន់។
- ផ្តល់ការណែនាំដល់កសិករឱ្យយល់ដឹងអំពីការប្រើប្រាស់ពូជដំណាំ ពូជស្រូវដែលមានអាយុកាលខ្លីៗសម្រាប់ការដាំដុះក៏ដូចជាការចិញ្ចឹមត្រី សត្វពាហនៈ ជាលក្ខណៈគ្រួសារ និងជាក្រុមដើម្បីរក្សាបាននូវសន្តិសុខស្បៀងរបស់ពួកគេ។
- ផ្តល់ការណែនាំដល់កសិករពីរបៀបបន្ថយទឹក និងការស្តុកទឹកសម្រាប់បំរើឱ្យការងារកសិកម្មដែលទទួល

បានទិន្នផលខ្ពស់ និងជួយស្វែងរកទីផ្សារលក់កសិផល ។

- ត្រៀមសំភារៈផ្សេងៗ ស្រូវ អង្ករ ស្បៀងអាហារ ស្រូវពូជ ពូជដំណាំផ្សេងៗបំរុងទុកសម្រាប់ប្រើប្រាស់ និងដាំដុះដើម្បីប្រើប្រាស់ និងដាំដុះឡើងវិញក្រោយពីរដូវទឹកជំនន់ និងភាពរាំងស្ងួត ។

### ២.៤.៤.១.២ ការត្រៀមលក្ខណៈបង្ការគ្រោះធម្មជាតិដោយគ្រោះរាំងស្ងួត និងទឹកជំនន់ក្នុងវិស័យធនធានទឹកៈ

- កំណត់ទីតាំងដែលតែងតែរងនូវគ្រោះរាំងស្ងួតដើម្បីរៀបចំស្តាប្រព័ន្ធប្រឡាយ ម៉ាស៊ីបូមទឹក និងត្រៀម ប្រេងឥន្ធនៈ សម្រាប់បូមបាចសង្គ្រោះ ដើម្បីអនុវត្តសកម្មភាពភ្លាមៗនៅពេលមានភាពរាំងស្ងួត ។
- រៀបចំ និងបន្តស្តារប្រឡាយ បឹង ទំនប់ដែលជាប្រភពទប់ទឹក សម្រាប់រំដោះទឹកជំនន់ដោយទឹកភ្លៀង និង ប្រើប្រាស់ពេលរាំងស្ងួត និងប្រើប្រាស់ស្រោចស្រពកសិផលទាំងឡាយ ។
- រៀបចំផែនការសិក្សា ជួសជុលប្រព័ន្ធធារាសាស្ត្រ និងសាងសង់ថ្មីបន្ថែមទៀត ។
- រៀបចំលើកផែនការស្តារ និងអភិវឌ្ឍន៏ប្រព័ន្ធស្រោចស្រពខ្នាតតូចក្នុងគ្រួសារតាមភូមិ ឃុំ ប្រព័ន្ធឋាមពល តូចៗព្រមទាំងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងទឹកប្រើប្រាស់រយៈពេលខ្លី មធ្យម និងយូរអង្វែង ។
- ផ្តល់ការគាំទ្រម៉ាស៊ីនបូមទឹកសម្រាប់ការងារអន្តរាគមន៏បានទាន់ពេលវេលានៅពេលជួបគ្រោះរាំងស្ងួត ។

### ២.៤.៤.១.៣ ការងារគ្រប់គ្រង និងត្រៀមបង្ការគ្រោះទឹកជំនន់ក្នុងវិស័យសុខាភិបាលៈ

- បង្កើន និងពង្រឹងសមត្ថភាពជំនាញដល់បុគ្គលិកគ្រប់លំដាប់ថ្នាក់ ពិសេសដល់ក្រុមទ្រទ្រង់សុខភាពភូមិទាក់ទិន នឹងជំនាញសង្គ្រោះបន្ទាន់ វិធីសាស្ត្រអនាម័យក្នុងគ្រួសារដល់ប្រជាពលរដ្ឋ និងសត្វពាហនៈតែងប្រឈមនា រដូវទឹកជំនន់ មានដូចជាវិធីសង្គ្រោះពេលមានសត្វពស់ចឹកនិងការលង់ទឹក រាករូសជាដើម ក៏ដូចជាត្រៀម ជាស្រេចនូវថ្នាំពេទ្យ បរិក្ខាសង្គ្រោះ និងមធ្យោបាយ ។
- ជំរុញលើកទឹកចិត្តដល់បុគ្គលិកគ្រប់លំដាប់ថ្នាក់ ក៏ដូចជាក្រុមទ្រទ្រង់សុខភាពភូមិ ឱ្យយកចិត្តទុកដាក់ ណែនាំពីអនាម័យ សុខភាព និងផ្តល់សេវាព្យាបាលជម្ងឺជាប្រចាំនៅតាមតំបន់លិចទឹកនានានៅមូលដ្ឋាន ។

### ២.៤.៤.១.៤. ការគ្រប់គ្រង និងត្រៀមបង្ការគ្រោះធម្មជាតិ ក្នុងវិស័យអភិវឌ្ឍន៏ជនបទៈ

- បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រី សម្រាប់ត្រៀមខ្លួន ជួយដោះស្រាយគ្រោះមហន្តរាយផ្សេងៗដែលនឹងកើត មានឡើង ។
- ជួយផ្សព្វផ្សាយបំផុសប្រជាពលរដ្ឋ អាជ្ញាធរភូមិ ឃុំឱ្យត្រៀមរកទីតាំងសុវត្ថិភាព ស្បៀងអាហារ ។
- ត្រៀមសម្ភារៈឧបករណ៏ផ្សេងៗពាក់ព័ន្ធការដោះស្រាយគ្រោះមហន្តរាយដូចជាការជួសជុលផ្លូវថ្នល់ ធុងចំរោះ ទឹក បង្គន់អនាម័យ អណ្តូងទឹកស្អាត និងវិធីថែរក្សា ។

### ២.៤.៤.២.ការសម្របសម្រួលការប្រែប្រួលអាកាសធាតុ

ជីវិតមនុស្ស សត្វ និងរុក្ខជាតិត្រូវត្រៀមបន្សាំខ្លួនទៅនិងការប្រែប្រួលអាកាសធាតុ ព្រោះយើងមិនអាច

ទប់ស្កាត់ឬទប់ទល់និងការប្រែប្រួលនេះបានទេ ដូចនេះប្រជាពលរដ្ឋត្រូវចេះបន្សាំខ្លួន។ មន្ទីរកិច្ចការនារី នឹងរៀបចំការផ្សព្វផ្សាយពីការបញ្រ្ជាបយេឌ័រក្នុងវិស័យប្រែប្រួលអាកាសធាតុដល់ប្រជាជនគ្រប់រូបនៅតាមទីប្រជុំជន និងជនបទ ពិសេសជនងាយរងគ្រោះ( ស្រ្តី និងកុមារ) ។

## ២.៤.៥ យុទ្ធសាស្រ្តគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

### ២.៤.៥.១ រដ្ឋបាលទូទៅ:

#### ២.៤.៥.១.១ រដ្ឋបាលខេត្ត

- ជំរុញ និងពន្លឿនដំណើរការចរាចរឯកសារ។
- បង្កើនធនធានមនុស្សផ្នែកភាសាបរទេស និងព័ត៌មានវិទ្យា។
- លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋដោយផ្សព្វផ្សាយការចុះបញ្ជីអត្រានុកូលដ្ឋាន។
- លើកកម្ពស់ និងជម្រុញការងារផ្តល់របាយការណ៍ និងការប្រមូលព័ត៌មាន។
- ពិនិត្យ និងកែលម្អអំពីនិតិវិធីរដ្ឋបាលដោយសហការជាមួយក្រសួងថ្នាក់កណ្តាល។
- សហការជាមួយស្ថាប័ននានា ដើម្បីជ្រើសរើសមន្រ្តីផ្នែកភាសាបរទេស។
- ពង្រឹង និងជំរុញដល់បណ្តាមន្ទីរ អង្គភាពជុំវិញខេត្តឱ្យផ្តល់របាយការណ៍តាមពេលវេលាកំណត់។
- បណ្តុះបណ្តាលមន្រ្តីបន្ថែមលើផ្នែកព័ត៌មានវិទ្យា។
- ជំរុញ និងវាយតម្លៃពីស្ថានភាពចំណូល និងចំណាកស្រុក។
- សហការជាមួយទីចាត់ការនិងការិយាល័យពាក់ព័ន្ធដើម្បីផ្តល់ព័ត៌មានឱ្យទាន់ពេលសម្រាប់រៀបចំកិច្ចប្រជុំឱ្យបានទៅតាមការកំណត់ ។
- សហការ និងជំរុញស្ថាប័នពាក់ព័ន្ធ ឱ្យរៀបចំចុះបញ្ជី និងធ្វើប័ណ្ណកម្មសិទ្ធ។
- សហការ និងជំរុញការអប់រំផ្សព្វផ្សាយអំពីច្បាប់ឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ ។
- ណែនាំដល់អ្នកប្រើប្រាស់ឱ្យបានយល់ពីការប្រើប្រាស់ដីចំណីផ្លូវ។
- ត្រូវរកវិធីទប់ស្កាត់ការហូរចូលវប្បធម៌ពាលាអាវ៉ាសែ។
- រៀបចំការផ្សព្វផ្សាយអប់រំ ឱ្យយល់ដឹងអំពីផលវិបាកនៃការប្រើប្រាស់គ្រឿងញៀន។
- អប់រំផ្សព្វផ្សាយអំពីច្បាប់ចរាចរណ៍ដល់ប្រជាពលរដ្ឋ និងរៀបចំស្លាកសញ្ញាចរាចរណ៍តាមដងផ្លូវឱ្យបានគ្រប់គ្រាន់។
- រៀបចំ និងគ្រប់គ្រងធនធានមនុស្សក្នុងរចនាសម្ព័ន្ធរដ្ឋបាលថ្មី សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយនិរន្តរភាព។
- ជ្រើសរើស បុគ្គលិក ទីប្រឹក្សា អ្នកបច្ចេកទេស មន្រ្តីជាប់កិច្ចសន្យា។
- រៀបចំបណ្តុះបណ្តាលដល់មន្រ្តីរាជការ នៃរដ្ឋបាលខេត្ត ក្រុង ស្រុក។

- រៀបចំគោលនយោបាយជូនមន្ត្រីចូលនិវត្តន៍ និងពលីមរណៈ ។
- បញ្ជូនមន្ត្រីរាជការទៅបណ្តុះបណ្តាល ទៅទស្សនកិច្ចសិក្សាជំនាញផ្សេងៗនៅក្នុង និងក្រៅប្រទេស ។
- ណែនាំអំពីរបៀបបំពេញការងារតាមតួនាទីភារកិច្ចនៃរចនាសម្ព័ន្ធថ្មីនៅថ្នាក់ក្រោមជាតិ ។
- លើកសរសើរ ជូនរង្វាន់ និងផ្តល់ជូនគ្រឿងឥស្សរិយយសតម្លើងថ្នាក់ជូនមន្ត្រីដែលមានស្នាដៃការងារល្អ ។
- អប់រំផ្សព្វផ្សាយអំពីវិន័យច្បាប់ដល់មន្ត្រីបុគ្គលិក រៀបចំឯកសណ្ឋាន សញ្ញាសក្តិជូនមន្ត្រីរាជការតាមឋានានុក្រម ។

### ២.៤.៥.២ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

#### ២.៤.៥.២.១. សន្តិសុខទូទៅ

- ជំរុញ និងលើកកំពស់ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពឱ្យបានកាន់តែមានប្រសិទ្ធភាព ។
- ជំរុញដល់អាជ្ញាធរមូលដ្ឋានយកចិត្តទុកដាក់រៀបចំសណ្តាប់ធ្នាប់សាធារណៈឱ្យបានប្រសើរ ។
- ជំរុញការងារចុះតាមដាន អង្កេតស្រាវជ្រាវបទល្មើសគ្រប់ប្រភេទ ព្រមទាំងទប់ស្កាត់បទល្មើសឆ្លងដែន និងរុករកវត្ថុតាងដើម្បីរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ។
- បើកវគ្គបណ្តុះបណ្តាល និងផ្សព្វផ្សាយអត្ថបទច្បាប់ដល់មន្ត្រីនគរបាលយុត្តិធម៌ថ្នាក់ខេត្ត ក្រុង និងស្រុកទាំង៧ ។

#### ២.៤.៥.២.២. ទំនាក់ទំនងសភា និងអធិការកិច្ច

- រៀបចំផែនការសកម្មភាព ដើម្បីចុះធ្វើអធិការកិច្ចលើវិស័យ និងស្ថាប័នទាំងឡាយណាដែលក្រសួង និងអាជ្ញាធរខេត្តយល់ឃើញថាមានភាពមិនប្រក្រតីក្នុងការអនុវត្តន៍ការងាររបស់វិស័យ ឬស្ថាប័ននោះ ។
- ជំរុញការចុះតាមដាន អង្កេតស្រាវជ្រាវពាក្យបណ្តឹង និងការអនុវត្តច្បាប់ទាំងឡាយដែលចូលជាធរមាន ។
- រៀបចំផ្សព្វផ្សាយច្បាប់ទាំងឡាយជូនប្រជាពលរដ្ឋ អាជ្ញាធរមានសមត្ថកិច្ចគ្រប់ប្រភេទ ដើម្បីលើកកំពស់ការយល់ដឹងឱ្យកាន់តែច្បាស់ក្នុងការអនុវត្ត និងគោរពច្បាប់ ។

#### ២.៤.៥.២.៣.កិច្ចការនារី

- ធ្វើការផ្សព្វផ្សាយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធនានាឱ្យបានទូលំទូលាយជាសាធារណៈឱ្យបានដល់ប្រជាពលរដ្ឋ និងអាជ្ញាធរមូលដ្ឋានភូមិ ឃុំ សង្កាត់ ក្រុងស្រុកក្នុងខេត្ត ។

### ២.៥~ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

ពុំទាន់មានរបាយការណ៍ (រងចាំការណែនាំ)

# ជំពូកទី៣

# ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ ផែនការអភិវឌ្ឍន

# ជំពូកទី៣

## ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍ផែនការអភិវឌ្ឍន៍

ស្ថិតក្នុងអាណត្តិ៥ឆ្នាំរបស់ក្រុមប្រឹក្សាខេត្ត យន្តការត្រួតពិនិត្យនិងវាយតម្លៃយ៉ាងទៀងទាត់លើការអនុវត្ត សកម្មភាព កម្មវិធីគម្រោងទាំងឡាយបានធ្វើឡើងនៅក្នុងផែនការអភិវឌ្ឍន៍ខេត្ត និងកម្មវិធីវិនិយោគខេត្ត មាន ស្ថាប័នក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗទៀត មន្ទីរ អង្គភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា មានអង្គការ សង្គមស៊ីវិល ស្ថាប័នឯកជនដែលមានសកម្មភាពអភិវឌ្ឍន៍ក្នុងដែនសមត្ថកិច្ច របស់ក្រុមប្រឹក្សាខេត្ត ដើម្បីធ្វើការត្រួតពិនិត្យការអនុវត្តន៍សកម្មភាពនានាឱ្យបានទាន់ពេលវេលា ជួយជម្រុញដល់ ការអនុវត្តប្រកបដោយប្រសិទ្ធភាព និងតម្លាភាព ផ្តល់អនុសាសន៍នានាទៅលើប្រសិទ្ធភាព ប្រសិទ្ធផល និង ឥទ្ធិពលនៃគម្រោងឱ្យទទួលបានលទ្ធផលល្អដល់ ប្រជាពលរដ្ឋដែលជាអ្នកទទួលផលប្រយោជន៍ពីគម្រោង ធ្វើការ ត្រួតពិនិត្យបន្ថែមទៀតទៅលើសូចនាករនានាទាំងឡាយ ដើម្បីឈានទៅសម្រេចចក្ខុវិស័យគោលបំណង និង គោលដៅដែលបានដាក់ចុះក្នុងក្របខ័ណ្ឌអនុវត្តរយៈពេលមធ្យម ។ ក្រុមប្រឹក្សាខេត្តមានទស្សនៈគោលនយោបាយ ធ្វើការអភិវឌ្ឍន៍ខេត្ត បន្តឈានទៅលប់បំបាត់ភាពក្រីក្ររបស់ប្រជាពលរដ្ឋ ឱ្យបានឆាប់រហ័សទៅតាមទិសដៅរបស់ រាជរដ្ឋាភិបាល ដែលមានគោលនយោបាយនានាដូចជាយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល អាណត្តិទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សន៍ កម្ពុជាដែលនឹងត្រូវសម្រេចឱ្យបាននៅឆ្នាំ២០១៥។ ដើម្បីសម្រេចឱ្យបាននូវលទ្ធផលដ៏សំខាន់នេះ ត្រូវមានការ ចូលរួមតាមបែបប្រជាធិបតេយ្យពីប្រជា ពលរដ្ឋប្រកបដោយសមភាព សមធម៌ និងមានតម្លាភាព។

### ៣.១. សូចនាករសំខាន់ៗសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តន៍ផែនការ

ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តន៍ផែនការអភិវឌ្ឍន៍ខេត្ត ត្រូវផ្អែកទៅលើតារាងសូចនាករ ដែលបានរៀបចំរួចជាស្រេចទៅតាមវិស័យសំខាន់ៗមួយចំនួន ដើម្បីវាយតម្លៃពីវឌ្ឍនភាពនៃការរីកចំរើនដោយ ប្រៀបធៀបទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៥ឆ្នាំ និងគោលដៅសហស្សវត្សន៍កម្ពុជាដែលត្រូវសម្រេចឱ្យ បាននៅដំណាច់ឆ្នាំ២០១៥ ធ្វើឱ្យមានសង្គតិភាព សុខដុមនីយកម្មរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ។

### ៣. ២. វិធីសាស្ត្រតាមដាន និងវាយតម្លៃការអនុវត្តន៍ផែនការ

វិធីសាស្ត្រតាមដាន និងវាយតម្លៃការអនុវត្តផែនការត្រូវផ្អែកលើរចនាសម្ព័ន្ធដែលមានស្រាប់ពីថ្នាក់ឃុំ និងស្ថាប័ន ដែលមានស្រាប់បានចាត់តាំងមន្ត្រីជំនាញត្រួតពិនិត្យវាយតម្លៃ និងបំពេញបន្ថែមចំណុចខ្វះខាតចន្លោះ និងធ្វើការបណ្តុះ បណ្តាលបន្ថែមនូវជំនាញត្រួតពិនិត្យវាយតម្លៃឆ្លើយតបទៅនឹងតម្រូវការ និងទំហំការងារចាំបាច់ ក្នុងពេលបច្ចុប្បន្ន សម្រាប់ផ្តល់របាយការណ៍មកការិយាល័យជំនាញត្រួតពិនិត្យ និងវាយតំលៃរបស់គណៈអភិបាល ខេត្តដើម្បីធ្វើការបូកសរុបជូនក្រុមប្រឹក្សាខេត្ត ។

## ៣. ៣. ពេលវេលាសម្រាប់តាមដាន និងវាយតម្លៃការអនុវត្តផែនការ

ផ្អែកទៅលើរបាយការណ៍ត្រួតពិនិត្យប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំដែលបញ្ជូនមកពីគ្រប់ប្រព័ន្ធត្រួតពិនិត្យ វាយតម្លៃពីគ្រប់អង្គភាពក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាខេត្តដោយធ្វើការបូកសរុប និងផ្តល់យោបល់នានា ទៅលើសកម្មភាពនៃការអនុវត្តគម្រោងជូនគណៈអភិបាលខេត្តដើម្បីដាក់ជូនក្រុមប្រឹក្សាខេត្តពិនិត្យមើលពីវឌ្ឍនភាពអភិវឌ្ឍន៍ ប្រៀបធៀបទៅនឹងសូចនាកររបស់ផែនការអភិវឌ្ឍន៍ខេត្ត និងផ្តល់អនុសាសន៍កែលម្អឱ្យបានទាន់ពេលវេលាទៅតាមតម្រូវការចាំបាច់។

## ៣.៤. ប្រពន្ធ័រៀបចំរបាយការណ៍

ប្រព័ន្ធរៀបចំរបាយការណ៍ត្រូវចាប់ផ្តើមរៀបចំចេញពីមន្ត្រីជំនាញត្រួតពិនិត្យវាយតម្លៃមកពីគ្រប់អង្គភាពអភិវឌ្ឍន៍នានាក្នុងខេត្ត បញ្ជូនរបាយការណ៍ឱ្យបានទាន់ពេលវេលាប្រចាំខែ ប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំមកឱ្យការិយាល័យកណ្តាលផ្នែកត្រួតពិនិត្យនិងវាយតម្លៃរបស់គណៈអភិបាលខេត្តសម្រាប់រៀបចំរបាយការណ៍ជូនអភិបាលខេត្ត ។ នៅក្នុងអាណត្តិទី៥របស់ក្រុមប្រឹក្សាខេត្តត្រូវរៀបចំរបាយកាណ៍វាយតម្លៃពាក់កណ្តាលអាណត្តិ និងបញ្ចប់អាណត្តិជូនក្រសួងមហាផ្ទៃសម្រាប់ឆ្លុះបញ្ចាំងពីវឌ្ឍនភាពក្នុងការដឹកនាំការងារអភិវឌ្ឍខេត្តរបស់ក្រុមប្រឹក្សាខេត្ត។

# តារាងក្របខ័ណ្ឌត្រួតពិនិត្យ តាមដាន

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាព ទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **១_ផ្នែកសេដ្ឋកិច្ច** | | | | | | | | | |
| **គោលដៅទី១ : កែលំអធានាសន្តិសុខស្បៀង បង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ និងរៀបចំកែលំអហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត-អរូបវ័ន្តឱ្យមានភាពប្រសើរឡើង ។** | | | | | | | | | |
| **កសិកម្ម** | | | | | | | | | |
| **១.១.១ គោលបំណងៈធ្វើឱ្យប្រសើរឡើងនូវផលិតកម្មដំណាំស្រូវតាមរយៈការផ្តល់បច្ចេកទេសកសិកម្មសំរាប់ ស្រុកគោលដៅទាំង ០៧** | | | | | | | | | |
| ទិន្នផលស្រូវជាមធ្យមក្នុង១ហិកតា | តោន | ២,៦ | ២.៧២ | ២.៨៤ | ២.៩៦ | ៣.០៨ | ៣,២ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ផ្តល់ពូជស្រូវទិន្នផលខ្ពស់ | តោន | ១៨ | ១៩,៤ | ២០,៨ | ២២,២ | ២៣,៦ | ២៥ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| សាលារៀនស្រែកសិករ | សាលា | ៤៨ | ៥៨ | ៦៨ | ៧៨ | ៨៨ | ៩៨ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ផ្ទៃដីដាំដុះដំណាំស្រូវកើនឡើង | ហ.ត | ៤៥៨៤៣ | ៥៥៦៧៤ | ៦៥៥០៦ | ៧៥៣៣៧ | ៨៥១៦៩ | ៩៥០០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| សហគមន៍ស្រូវសរីរាង្គ | សហគមន៍ | ១ | ២ | ៣ | ៣ | ៤ | ៥ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ផ្ទៃដីដំណាំបន្លែកើនឡើង | ហ.ត | ៩២៧ | ១.០៤២ | ១១៥៨ | ១២៧៣ | ១៣៨៩ | ១៥០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| កសិករទទួលបានចំនេះដឹងពីបច្ចេកទេសដាំដុះដំណាំបន្លែ | នាក់ | ១២០០ | ១៦៨០ | ២១៦០ | ២៦៤០ | ៣១២០ | ៣៦០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ទទួលបានការបង្ហាញដំណាំបន្លែ | បង្ហាញ | ៤៨ | ៥៤ | ៦០ | ៦៦ | ៧២ | ៧៨ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ចងក្រងក្រុមកសិករ | ក្រុម | ៤៨ | ៧៧ | ១០៦ | ១៣៤ | ១៦៣ | ១៩២ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| កសិករទទួលបានចំណេះដឹងទំនាក់ទំនង ទីផ្សារ | នាក់ | ១២០០ | ១៦៨០ | ២១៦០ | ២៦៤០ | ៣១២០ | ៣៦០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| កសិករទទួលបានប្រព័ន្ធព័តមានទីផ្សារតំលៃកសិផល | លើក | ៣៦៥ | ៦៥៧ | ៩៤៩ | ១២៤១ | ១៥៣៣ | ១៨២៥ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| សត្វមាន់-ទាកើនឡើង និងមាន សុខភាពល្អ | ក្បាល | ២៤០២៦៨ | ២៩៤២១៤ | ៣៤៨១៦១ | ៤០២១០៧ | ៤៥៦០៥៤ | ៥១០០០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| សត្វគោ-ក្របីកើនឡើង និងមានសុខភាពល្អ | ក្បាល | ១០៦២១៨ | ១៣៤៩៧៤ | ១៦៣៧៣១ | ១៩២៤៨៧ | ២២១២៤៤ | ២៥០០០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាព ទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| កសិករទទួលបានចំណេះដឹងបច្ចេកទេស ចិញ្ចឹមសត្វ | នាក់ | ១២០០ | ២០៨០ | ២៩៦០ | ៣៨៤០ | ៤៧២០ | ៥៦០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| កសិករទទួលបានចំណេះដឹងពីការបាត់បងក្រោយប្រមូលផល | ភូមិ | ២០ | ៣៦ | ៥៣ | ៦៩ | ៨៦ | ១០២ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| កសិករទទួលបានតង់សំរាប់ហាលស្រូវ | គ្រួសារ | ៦៦០ | ៧៦៨ | ៨៧៦ | ៩៨៤ | ១០៩២ | ១២០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ឧបករណ៍ត្រួតពិនិត្យការបាត់បង់ក្រោយប្រមូលផល ត្រូវបានបំពាក់ | កំប្លេ | ២ | ៣ | ៤ | ៥ | ៦ | ៧ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| **ជលផល** | | | | | | | | | |
| **១.២.៦ គោលបំណងៈ បង្កើនវារីវប្បកម្មជាលក្ខណៈគ្រួសារ** | | | | | | | | | |
| កសិករចិញ្ចឹមត្រី | គ្រួសារ | ១០០ | ១៥០ | ២០០ | ២៥០ | ៣០០ | ៣៥០ | រដ្ឋបាលជលផល | រដ្ឋបាលជលផល |
| ចំនួនស្រះ | ស្រះ | ១០០ | ១៤៨ | ១៩៦ | ២៤៤ | ២៩២ | ៣៤០ | រដ្ឋបាលជលផល | រដ្ឋបាលជលផល |
| **១.២.៧ គោលបំណងៈ លើកកំពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋដោយផ្សព្វផ្សាយច្បាប់ជលផល** | | | | | | | | | |
| ប្រជាពលរដ្ឋតាមស្រុក | % | ២៥ | ៣៤ | ៤៣ | ៥២ | ៦១ | ៧០ | រដ្ឋបាលជលផល | រដ្ឋបាលជលផល |
| **ធនធានទឹក និងឧតុនិយម** | | | | | | | | | |
| **១.៣.៨ គោលបំណងៈ ការងារធារាសាស្ត្រ កសិកម្ម** | | | | | | | | | |
| ការសិក្សាគ្រោងប្លង់ | កន្លែង | ១៨ | ២៤ | ៣១ | ៣៧ | ៤៤ | ៥០ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| ជួសជុលទំនប់អាងទឹក | កន្លែង | ០៦ | ១១ | ១៦ | ២០ | ២៥ | ៣០ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| ស្តារប្រឡាយមេ ប្រឡាយរង និងប្រឡាយស្រោចស្រព | ខ្សែ | ០៤ | ៨ | ១២ | ១៧ | ២១ | ២៥ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| ស្តារប្រឡាយដោះទឹកជំនន់ | ខ្សែ | ០១ | ១ | ២ | ២ | ៣ | ៣ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| ជួសជុល និងសាងសង់សំណង់សិល្បការ | កន្លែង | ២២ | ២៧ | ៣១ | ៣៦ | ៤០ | ៤៥ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| ជីកស្រះ និងស្តារប្រព័ន្ធស្រោចស្រព | ស្រះ | ២០ | ៣២ | ៤៤ | ៥៦ | ៦៨ | ៨០ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **១.៣.៩ គោលបំណង: បង្កើនការប្រើប្រាស់ទឹកស្អាត និងអនាម័យ** | | | | | | | | | |
| អត្រាប្រើប្រាស់ទឹកស្អាតនៅទីប្រជុំជន | % | ៥ | ៧,២ | ៩,៤ | ១១,៦ | ១៣,៨ | ១៦ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| អត្រាគ្រួសារប្រើប្រាស់អណ្តូងលូ ឬ ស្នប់ដោយដៃ | % | ៣០ | ៣៤ | ៣៨ | ៤២ | ៤៦ | ៥០ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| អត្រាគ្រួសារប្រើប្រាស់អណ្តូងស្នប់ដោយម៉ូទ័រ | % | ០៦ | ១០,៨ | ១៥,៦ | ២០,៤ | ២៥,២ | ៣០ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| កែលំអប្រព័ន្ធដោះទឹកកខ្វក់នៅទីប្រជុំជន | ខ្សែ | ០ | ១ | ២ | ៣ | ៤ | ៥ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| **១.៣.១០ គោលបំណង: ពង្រឹងការគ្រប់គ្រង និងអភិរក្សធនធានទឹក** | | | | | | | | | |
| រៀបចំសហគមន៍កសិករប្រើប្រាស់ទឹក | សហគមន៍ | ១៥ | ២៥ | ៣១ | ៣៨ | ៤៤ | ៥០ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| ផ្សព្វផ្សាយលក្ខន្តិកៈប្រើប្រាស់ទឹក | លើក | ១៥ | ២៥ | ៣១ | ៣៨ | ៤៤ | ៥០ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| ពង្រឹងសមត្ថភាព និងបណ្តុះបណ្តាលដល់មន្ត្រីជំនាញ | វគ្គ | ១០ | ២០ | ៣០ | ៤០ | ៥០ | ៦០ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| ផ្តួចផ្តើមគម្រោងស្វែងរកជំនួយថវិកាពីដៃគូរអភិវឌ្ឍន៍ | លើក | ១២ | ២០ | ២៧ | ៣៥ | ៤២ | ៥០ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| **ទេសចរណ៍** | | | | | | | | | |
| **១.៤.១១ គោលបំណង:ពង្រីកការអភិវឌ្ឍន៍ផលិតផលទេសចរណ៍** | | | | | | | | | |
| បន្តពង្រីកគោលដៅទេសចរណ៍ និងផលិតផលទេសចរណ៍ | កន្លែង | ៣ | ៤ | ៥ | ៥ | ៦ | ៧ | មន្ទីរទេសចរណ៍ | មន្ទីរទេសចរណ៍ |
| ពង្រីកសម្បទា សេវាកម្មទេសចរណ៍តាមបទដ្ឋានកំណត់ | កន្លែង | ២៣ | ២៤ | ២៤ | ២៥ | ២៥ | ២៦ | មន្ទីរទេសចរណ៍ | មន្ទីរទេសចរណ៍ |
| បង្កើតទីភ្នាក់ងារទេសចរណ៍នៅក្នុងខេត្ត | កន្លែង | ០ | ១ | ១ | ២ | ២ | ៣ | មន្ទីរទេសចរណ៍ | មន្ទីរទេសចរណ៍ |
| **១.៤.១២ គោលបំណង: បន្តពង្រឹងគុណភាពសេវាកម្មទេសចរណ៍ប្រកបដោយប្រសិទ្ធភាព** | | | | | | | | | |
| ពង្រឹងការគ្រប់គ្រងមូលដ្ឋានអាជីវកម្មសេវាកម្មស្នាក់នៅ | កន្លែង | ២៣ | ២៧ | ៣១ | ៣៥ | ៣៩ | ៤៣ | មន្ទីរទេសចរណ៍ | មន្ទីរទេសចរណ៍ |
| ពង្រឹងការគ្រប់គ្រងអាជីវកម្មភោជនីយដ្ឋាន អាហារដ្ឋាន | កន្លែង | ៧ | ១១ | ១៥ | ១៩ | ២៣ | ២៧ | មន្ទីរទេសចរណ៍ | មន្ទីរទេសចរណ៍ |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| លើកកម្ពស់សេវាកម្មសេវាកំសាន្ត | កន្លែង | ៦ | ១០ | ១៤ | ១៨ | ២២ | ២៦ | មន្ទីរទេសចរណ៏ | មន្ទីរទេសចរណ៏ |
| **១.៤.១៣ គោលបំណងៈកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៏** | | | | | | | | | |
| ទាក់ទាញភ្ញៀវទេសចរអោយមានកំណើនរៀងរាល់ឆ្នាំ | នាក់ | ១៣៥៦៥៧ | ១៦៩៥៦៩ | ២០៣៤៨២ | ២៣៧៣៩៥ | ២៧១៣០៧ | ៣០៥២២០ | មន្ទីរទេសចរណ៏ | មន្ទីរទេសចរណ៏ |
| លើកកម្ពស់សមត្ថភាពក្នុងវិស័យទេចរណ៏លើគ្រប់ផ្នែក | % | ៣៧ | ៤៦,៦ | ៥៦,២ | ៦៥,៨ | ៧៥,៤ | ៨៥ | មន្ទីរទេសចរណ៏ | មន្ទីរទេសចរណ៏ |
| **ពាណិជ្ជកម្ម** | | | | | | | | | |
| **១.៥.១៤ គោលបំណងៈ បង្កើនផលិតផលនាំចេញ** | | | | | | | | | |
| ផលិតផលច្រៀតចូលក្នុងទីផ្សារ | % | ៤៥ | ៥០ | ៥៤ | ៥៩ | ៦៣ | ៦៨ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| ការវិនិយោគលើផលិតផល | % | ៤០ | ៤៤ | ៤៨ | ៥២ | ៥៦ | ៦០ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| **១.៥.១៥ គោលបំណងៈ ពង្រឹងការគ្រប់គ្រងទីផ្សារ** | | | | | | | | | |
| ផ្តល់ប័ណ្ណអនុញ្ញាតអាជីវកម្ម | ច្បាប់ | ៤៧០ | ៥៣៦ | ៦០២ | ៦៦៧ | ៧៣៣ | ៧៩៩ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| **១.៥.១៦ គោលបំណងៈ ផលិតផលនាំចេញទៅកាន់ទីផ្សារ** | | | | | | | | | |
| ស្រូវ | តោន | ៧១៨៨១ | ៧៩០៦៩ | ៨៦២៥៧ | ៩៣៤៤៦ | ១០០៦៣៤ | ១០៧៨២២ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| ពោតស | តោន | ២៣០៣១ | ២៤១៨៣ | ២៥៣៣៤ | ២៦៤៨៦ | ២៧៦៣៧ | ២៨៧៨៩ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| ពោតក្រហម | តោន | ១៧១១៤ | ១៧៩៦៩ | ១៨៨២៥ | ១៩៦៨១ | ២០៥៣៧ | ២១៣៩៣ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| ល្ង | តោន | ២៣៦៥ | ២៤៨៣ | ២៦០១ | ២៧១៩ | ២៨៣៨ | ២៩៥៦ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| គ្រាប់ស្វាយចន្ទី | តោន | ១៤៩៦ | ១៥៧១ | ១៦៤៦ | ១៧២០ | ១៧៩៥ | ១៨៧០ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| សណ្តែកបាយ | តោន | ១០៧៧៧ | ១១៣១៦ | ១១៨៥៥ | ១២៣៩៣ | ១២៩៣២ | ១៣៤៧១ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| សណ្តែកដី | តោន | ៦១៨២ | ៦៤៩១ | ៦៨០០ | ៧១០៩ | ៧៤១៩ | ៧៧២៨ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| សណ្តែកសៀង | តោន | ៣៩៦៨៨ | ៣៧៤៧២ | ៣៩២៩៧ | ៤១០៤១ | ៤២៨២៦ | ៤៤៦១០ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| ចេក | តោន | ៣១៤៥ | ៣៣០២ | ៣៤៥៩ | ៣៦១៧ | ៣៧៧៤ | ៣៩៣១ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| ដំឡូងមី | តោន | ៥៤២៥២ | ៥៦៩៦៥ | ៥៩៦៧៧ | ៦២៣៨៩ | ៦៥១០២ | ៦៧៨១៥ | មន្ទីរពាណិជ្ជកម្ម | មន្ទីរពាណិជ្ជកម្ម |
| **ឧស្សាហកម្ម រ៉ែ និង ថាមពល** | | | | | | | | | |
| **១.៦.១៧ គោលបំណងៈ ពង្រីកការវិនិយោគផ្នែកឧស្សាហកម្មតូច-សិប្បកម្ម** | | | | | | | | | |
| សិប្បកម្មផលិតទឹកកក | មូលដ្ឋាន | ៥ | ៥ | ៦ | ៦ | ៧ | ៧ | មន្ទីរឧស្សាហកម្ម | មន្ទីរឧស្សាហកម្ម |
| សិប្បកម្មផលិតទឹកពិសារដប | មូលដ្ឋាន | ៣ | ៣ | ៤ | ៤ | ៥ | ៥ | មន្ទីរឧស្សាហកម្ម | មន្ទីរឧស្សាហកម្ម |
| សិប្បកម្មតម្រូវសុំចុះបញ្ជី | មូលដ្ឋាន | ២៥ | ២៨ | ៣១ | ៣៤ | ៣៧ | ៤០ | មន្ទីរឧស្សាហកម្ម | មន្ទីរឧស្សាហកម្ម |
| សិប្បកម្មសុំចុះបញ្ជីស្ថិតិ | មូលដ្ឋាន | ៩៤០ | ៩៩២ | ១០៤៤ | ១០៩៦ | ១១៤៨ | ១២០០ | មន្ទីរឧស្សាហកម្ម | មន្ទីរឧស្សាហកម្ម |
| បណ្តាញផ្គត់ផ្គង់ទឹកស្អាត | មូលដ្ឋាន | ១ | ២ | ៣ | ៣ | ៤ | ៥ | មន្ទីរឧស្សាហកម្ម | មន្ទីរឧស្សាហកម្ម |
| -បរិមាណទឹកស្អាតផ្គត់ផ្គង់ | ម$^{៣}$ | ១២៥០០០ | ២០០០០០ | ២៧៥០០០ | ៣៥០០០០ | ៤២៥០០០ | ៥០០០០០ | មន្ទីរឧស្សាហកម្ម | មន្ទីរឧស្សាហកម្ម |
| **១.៦.១៨ គោលបំណងៈ លើកកម្ពស់ការវិនិយោគធនធានរ៉ែ** | | | | | | | | | |
| ក្រុមហ៊ុន IRON | តោន | ០ | ៦០០០ | ១២០០០ | ១៨០០០ | ២៤០០០ | ៣០០០០ | មន្ទីរឧស្សាហកម្ម | មន្ទីរឧស្សាហកម្ម |
| **១.៦.១៩ គោលបំណងៈ បង្កើនការវិនិយោគ និង ផ្គត់ផ្គង់ថាមពលដល់ មូលដ្ឋាន** | | | | | | | | | |
| បណ្តាញផ្គត់ផ្គង់អគ្គិសនី | កន្លែង | ៤ | ៦ | ៨ | ៩ | ១១ | ១៣ | មន្ទីរឧស្សាហកម្ម | មន្ទីរឧស្សាហកម្ម |
| -ថាមពលបណ្តាញ | គ្រួសារ | ៤០០០ | ៦២០០ | ៨៤០០ | ១០៦០០ | ១២៨០០ | ១៥០០០ | មន្ទីរឧស្សាហកម្ម | មន្ទីរឧស្សាហកម្ម |
| -ថាមពលពន្លឺព្រះអាទិត្យ | គ្រួសារ | ៤០ | ៦៧២ | ១៣០៤ | ១៩៣៦ | ២៥៦៨ | ៣២០០ | មន្ទីរឧស្សាហកម្ម | មន្ទីរឧស្សាហកម្ម |
| -អាគុយ | គ្រួសារ | ១៥០០ | ៣៦០០ | ៥៧០០ | ៧៨០០ | ៩៩០០ | ១២០០០ | មន្ទីរឧស្សាហកម្ម | មន្ទីរឧស្សាហកម្ម |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **អភិវឌ្ឍន៍ជនបទ** | | | | | | | | | |
| **១.៧.២០ គោលបំណងៈ ស្តារនិងជួសជុលឡើងវិញផ្លូវក្រាលគ្រួសក្រហម** | | | | | | | | | |
| ជួសជុលនិងថែទាំផ្លូវក្រាលគ្រួសក្រហមប្រភេទលេខ១ | គ.ម | ៥៨.៥ | ៦៤ | ៦៩ | ៧៤ | ៧៩ | ៨៤.៥ | មន្ទីរអភិវឌ្ឍន៍ជនបទ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| ជួសជុលនិងថែទាំផ្លូវក្រាលគ្រួសក្រហមប្រភេទលេខ២ | គ.ម | ១៤៩.៥ | ១៦៥ | ១៨១ | ១៩៦ | ២១២ | ២២៧.៤ | មន្ទីរអភិវឌ្ឍន៍ជនបទ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| **១.៧.២១ គោលបំណងៈ បង្កើនការផ្គត់ផ្គង់ទឹក** | | | | | | | | | |
| អត្រាគ្របដណ្តប់ប្រជាជនមានទឹកស្អាតប្រើប្រាស់ | % | ៤៦.០២ | ៤៦.៨ | ៤៧.៦ | ៤៨.៤ | ៤៩.២ | ៥០ | មន្ទីរអភិវឌ្ឍន៍ជនបទ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| **១.៧.២២ គោលបំណង ៖ លើកកម្ពស់អនាម័យជនបទ** | | | | | | | | | |
| អត្រាគ្របដណ្តប់ប្រជាជនមានបង្គន់អនាម័យប្រើប្រាស់ | % | ១១ | ១៥ | ១៩ | ២២ | ២៦ | ៣០ | មន្ទីរអភិវឌ្ឍន៍ជនបទ | មន្ទីរអភិវឌ្ឍន៍ជនបទ |
| **សាធារណការ និងដឹកជញ្ជូន** | | | | | | | | | |
| **១.៨.២៣ គោលបំណងៈ ការងារជួសជុលប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | |
| ក-ការងារជួសជុលផ្លូវចាក់កៅស៊ូ | | | | | | | | | |
| -ផ្លូវជាតិ | គ.ម | ០ | ៣ | ៧ | ១០ | ១៤ | ១៧ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| -ផ្លូវខេត្ត | គ.ម | ០ | ៥,២ | ១០ | ១៦ | ២១ | ២៦ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| -ផ្លូវក្នុងទីរួមខេត្ត | គ.ម | ០ | ១ | ២ | ៣ | ៤ | ៥ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| ខ-ការងារជួសជុលផ្លូវក្រាលគ្រួសក្រហម | | | | | | | | | |
| -ផ្លូវខេត្ត | គ.ម | ២៨ | ៣១ | ៣៣ | ៣៦ | ៣៨ | ៤១ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| -ផ្លូវក្នុងទីរួមខេត្ត | គ.ម | ០ | ០,៦៤ | ១,២៨ | ១,៩២ | ២,៥៦ | ៣,២ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **១.៨.២៤ គោលបំណង: ការងារថែទាំប្រចាំនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | |
| ក-ការងារថែទាំប្រចាំផ្លូវចាក់កៅស៊ូ | | | | | | | | | |
| -ផ្លូវជាតិ | គ.ម | ០ | ៤១ | ៨១ | ១២២ | ១៦២ | ២០៣ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| -ផ្លូវខេត្ត | គ.ម | ១៨,៥ | ២២ | ២៦ | ២៩ | ៣៣ | ៣៦,៥ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| -ផ្លូវក្នុងទីរួមខេត្ត | គ.ម | ០ | ៤ | ៧ | ១១ | ១៤ | ១៨ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| ខ-ការងារថែទាំប្រចាំផ្លូវក្រាលគ្រួសក្រហម | | | | | | | | | |
| -ផ្លូវខេត្ត | គ.ម | ០ | ១០ | ២០ | ៣០ | ៤០ | ៥០ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| -ផ្លូវក្នុងទីរួមខេត្ត | គ.ម | ០ | ៣ | ៦ | ៩ | ១២ | ១៥ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| **១.៨.២៥ គោលបំណង: ការងារថែទាំប្រចាំផ្លូវចាក់បេតុង** | | | | | | | | | |
| -ផ្លូវឡើងមុំ៣ | គ.ម | ០ | ០,៤២ | ០,៨៤ | ១,២៦ | ១,៦៨ | ២,១ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| -ផ្លូវឡើងភ្នំប្រាសាទព្រះវិហារ | គ.ម | ០ | ១,២៤ | ២,៤៨ | ៣,៧២ | ៤,៩៦ | ៦,២ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| **១.៨.២៦ គោលបំណង: ការងារថែទាំប្រចាំប្រព័ន្ធបង្ហូរទឹកស្អុយ** | | | | | | | | | |
| -រៀបចំប្រព័ន្ធលូក្នុងទីរួមខេត្ត | ម | ៥០០០ | ៥០០០ | ៥០០០ | ៥០០០ | ៥០០០ | ៥០០០ | មន្ទីរសាធារណការ | មន្ទីរសាធារណការ |
| **ប្រៃសណីយ៍ និង ទូរគមនាគមន៍** | | | | | | | | | |
| **១.៩.២៧ គោលបំណង: ពង្រីកការអភិវឌ្ឍន៍ វិស័យទូរគមនាគមន៍** | | | | | | | | | |
| ចំនួនស្ថានីយ៍ទូរស័ព្ទ | បង្គោល | ១១៣ | ១៥១ | ១៨៩ | ២២៦ | ២៦៤ | ២២៦ | មន្ទីរប្រៃសណីយ៍ | មន្ទីរប្រៃសណីយ៍ |
| ចំនួនវិទ្យុ ICOM | គ្រឿង | ៥២ | ៥៤ | ៥៥ | ៥៧ | ៥៨ | ៦០ | មន្ទីរប្រៃសណីយ៍ | មន្ទីរប្រៃសណីយ៍ |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| វីសាត INTERNET | ស្ថានីយ៍ | ១៣ | ១៣ | ១៤ | ១៤ | ១៥ | ១៥ | មន្ទីរប្រៃសណីយ៍ | មន្ទីរប្រៃសណីយ៍ |
| លើកកម្ពស់សមត្ថភាពបច្ចេកទេសក្នុងវិស័យប្រៃសណីយ៍និងទូរគមនាគមន៍ | ភាគរយ | ៣៥ | ៤០ | ៤៥ | ៥០ | ៥៥ | ៦០ | មន្ទីរប្រៃសណីយ៍ | មន្ទីរប្រៃសណីយ៍ |
| **១.៩.២៨ គោលបំណងៈ បន្តពង្រីកនិង ពង្រឹងគុណភាពសេវាកម្ម វិស័យប្រៃសណីយ៍** | | | | | | | | | |
| បញ្ជូនបញ្ញើគ្រប់ប្រភេទ | បាវ/កញ្ចប់ | ៨៩ | ១៦២ | ២៣៥ | ៣០៨ | ៣៨១ | ៤៥៤ | មន្ទីរប្រៃសណីយ៍ | មន្ទីរប្រៃសណីយ៍ |
| ទទួលបញ្ញើគ្រប់ប្រភេទ | បាវ/កញ្ចប់ | ៩៧ | ១៧៧ | ២៥៦ | ៣៣៦ | ៤១៥ | ៤៩៥ | មន្ទីរប្រៃសណីយ៍ | មន្ទីរប្រៃសណីយ៍ |
| **១.៩.២៩ គោលបំណងៈ កាត់បន្ថយភាពក្រីក្រតាមរយៈវិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍** | | | | | | | | | |
| ទាក់ទាញក្រុមហ៊ុនទូរស័ព្ទចល័តឱ្យវិនិយោគ | ស្ថានីយ៍ | ១១៣ | ១៥១ | ១៨៩ | ២២៦ | ២៦៤ | ២២៦ | មន្ទីរប្រៃសណីយ៍ | មន្ទីរប្រៃសណីយ៍ |
| ផ្តល់អត្រាតម្លៃសមរម្យសម្រាប់ក្រុមហ៊ុនវិនិយោគ | រៀល/ដុល្លា | - | - | | | | | មន្ទីរប្រៃសណីយ៍ | មន្ទីរប្រៃសណីយ៍ |
| **ផែនការ** | | | | | | | | | |
| **១.១០.៣០ គោលបំណងៈ បង្កើនសមត្ថភាពមន្ត្រីតាមរយៈការបណ្តុះបណ្តាលជំនាញ** | | | | | | | | | |
| -មន្ត្រីប្រកបដោយសមត្ថភាពគុណភាពទាំងនៅថ្នាក់ខេត្ត និងថ្នាក់ ស្រុក-ក្រុង | នាក់ | ១៣ | ១៩ | ២៥ | ៣០ | ៣៦ | ៤២ | មន្ទីរផែនការ | មន្ទីរផែនការ |
| -មានអាគារសំរាប់បំរើការងារមានលក្ខណៈសមរម្យទាំងនៅថ្នាក់ខេត្ត និង នៅថ្នាក់ស្រុក-ក្រុង ។ | ខ្នង | ០ | ២ | ៤ | ៥ | ៧ | ៩ | មន្ទីរផែនការ | មន្ទីរផែនការ |
| -សមត្ថភាព គុណភាព មន្ត្រីថ្នាក់ មូលដ្ឋានភូមិ ឃុំ-សង្កាត់ | % | ៦០ | ៦៤ | ៦៨ | ៧២ | ៧៦ | ៨០ | មន្ទីរផែនការ | មន្ទីរផែនការ |
| **សាលាខេត្ត** | | | | | | | | | |
| **ទីចាត់ការផែនការ និងវិនិយោគ** | | | | | | | | | |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **១.១១.៣១ គោលបំណង: បង្កើន និងពង្រឹងការគាំទ្រការអនុវត្តការងារដល់ឃុំ សង្កាត់ ក្រុង ស្រុកឱ្យបានកាន់តែប្រសើរឡើងស្របតាមគោល នយោបាយវិមជ្ឈការ និងវិសហមជ្ឈការ** | | | | | | | | | |
| ការវិនិយោគឃុំសង្កាត់ | ឃុំសង្កាត់ | ៤៩ | ៤៩ | ៤៩ | ៤៩ | ៤៩ | ៤៩ | សាលាខេត្ត | សាលាខេត្ត |
| គាំទ្រការអនុវត្តការងាររបស់ក្រុង ស្រុក | ក្រុងស្រុក | ៨ | ៨ | ៨ | ៨ | ៨ | ៨ | សាលាខេត្ត | សាលាខេត្ត |
| **១.១១.៣២ គោលបំណង: ជំរុញ និងលើកកំពស់ការផ្តល់សេវាដល់វិនិយោគិនឯកជន** | | | | | | | | | |
| ផ្តល់សេវាដល់វិនិយោគិនឯកជន | ទូទាំងខេត្ត | ១ | ១ | ១ | ១ | ១ | ១ | សាលាខេត្ត | សាលាខេត្ត |
| **១.១១.៣៣ គោលបំណង: ជំរុញ និងវាយតម្លៃការអនុវត្តផែនការខេត្តឱ្យមានប្រសិទ្ធភាព** | | | | | | | | | |
| កិច្ចសហការរៀបចំ និងតាមដានវាយតម្លៃការអនុវត្តផែនការ | ទូទាំងខេត្ត | ១ | ១ | ១ | ១ | ១ | ១ | សាលាខេត្ត | សាលាខេត្ត |
| **ទីចាត់ការហិរញ្ញវត្ថុ** | | | | | | | | | |
| **១.១១.៣៤ គោលបំណង: កែលម្អសោភណ្ឌភាពខេត្ត និង ស្រុក** | | | | | | | | | |
| **ថែទាំសាងសង់ផ្សារកំពង់ប្រណាក** | | | | | | | | | |
| -ជួសជុលចាក់កំរាលបេតុង | ម២ | ១១៥៥ | ១២៤៤ | ១៣៣៣ | ១៤២២ | ១៥១១ | ១៦០០ | សាលាខេត្ត | សាលាខេត្ត |
| -ជួសជុលលូ | ម | ១៧៨ | ២៣២ | ២៨៧ | ៣៤១ | ៣៩៦ | ៤៥០ | សាលាខេត្ត | សាលាខេត្ត |
| **សាងសង់សួនច្បារ** | | | | | | | | | |
| -សាងសង់សួនច្បារផ្លូវភ្លោះ | ម២ | ២០០០ | ២៤៤០ | ២៨៨០ | ៣៣២០ | ៣៧៦០ | ៤២០០ | សាលាខេត្ត | សាលាខេត្ត |
| -សាងសង់សួនច្បារបរិវេណសាលាខេត្ត | ម២ | ៣០០០ | ៤២០០ | ៥៤០០ | ៦៦០០ | ៧៨០០ | ៩០០០ | សាលាខេត្ត | សាលាខេត្ត |
| -រៀបចំប្រព័ន្ធទឹកស្រោចផ្កា | ម | ៩៥០ | ៩៥០ | ៩៥០ | ៩៥០ | ៩៥០ | ៩៥០ | សាលាខេត្ត | សាលាខេត្ត |
| -រៀបចំបង្គោលភ្លើងបំភ្លឺសាធារណៈផ្លូវភ្លោះ | ដើម | ២៥ | ៤០ | ៥៥ | ៧០ | ៨៥ | ១០០ | សាលាខេត្ត | សាលាខេត្ត |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| -រៀបចំប្រព័ន្ធភ្លើងរង្វង់មូលព្រះនរាយ ដល់នាគបាញ់ទឹក | ដើម | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | សាលាខេត្ត | សាលាខេត្ត |
| -រៀបចំសួនច្បារនៅដំណាក់ស្ដេចតាមបណ្ដោយមាត់ស្ទឹងសែន | ម | ១៥០០ | ១៨០០ | ២១០០ | ២៤០០ | ២៧០០ | ៣០០០ | សាលាខេត្ត | សាលាខេត្ត |
| **ការកែលម្អអគារ** | | | | | | | | | |
| **+ជួសជុលរបងសាលាស្រុក៧ +ក្រុង ១** | | | | | | | | | |
| -ក្រុងព្រះវិហារ | ម | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | សាលាខេត្ត | សាលាខេត្ត |
| -សាលាស្រុកត្បែងមានជ័យ | ម | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | សាលាខេត្ត | សាលាខេត្ត |
| -សាលាស្រុកគូលែន | ម | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | សាលាខេត្ត | សាលាខេត្ត |
| -សាលាស្រុករវៀង | ម | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | សាលាខេត្ត | សាលាខេត្ត |
| -សាលាស្រុកសង្គមថ្មី | ម | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | សាលាខេត្ត | សាលាខេត្ត |
| -សាលាស្រុកជ័យសែន | ម | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | សាលាខេត្ត | សាលាខេត្ត |
| -សាលាស្រុកឆែប | ម | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | សាលាខេត្ត | សាលាខេត្ត |
| -សាលាស្រុកជាំក្សាន្ត | ម | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | សាលាខេត្ត | សាលាខេត្ត |
| -ធ្វើការសាងសង់អគារសាលាក្រុងបន្ត | ម២ | ៣០៦ | ៣០៦ | ៣០៦ | ៣០៦ | ៣០៦ | ៣០៦ | សាលាខេត្ត | សាលាខេត្ត |
| -ជួសជុលអគារសាលាស្រុកគូលែន | ម២ | ១២៦ | ១២៦ | ១២៦ | ១២៦ | ១២៦ | ១២៦ | សាលាខេត្ត | សាលាខេត្ត |
| -ជួសជុលអគារសាលាស្រុកត្បែងមានជ័យ | ម២ | ១៥៣ | ១៥៣ | ១៥៣ | ១៥៣ | ១៥៣ | ១៥៣ | សាលាខេត្ត | សាលាខេត្ត |
| -ជួសជុលអគារសាលាស្រុកជាំក្សាន្ត | ម២ | ១២៣ | ១២៣ | ១២៣ | ១២៣ | ១២៣ | ១២៣ | សាលាខេត្ត | សាលាខេត្ត |
| -ជួសជុលអគារសាលាស្រុកជ័យសែន | ម២ | ១២៣ | ១២៣ | ១២៣ | ១២៣ | ១២៣ | ១២៣ | សាលាខេត្ត | សាលាខេត្ត |
| -ជួសជុលអគារសាលាស្រុកឆែប | ម២ | ១២៣ | ១២៣ | ១២៣ | ១២៣ | ១២៣ | ១២៣ | សាលាខេត្ត | សាលាខេត្ត |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| -ជួសជុលអគារសាលាស្រុកសង្គមថ្មី | ម២ | ១២៦ | ១២៦ | ១២៦ | ១២៦ | ១២៦ | ១២៦ | សាលាខេត្ត | សាលាខេត្ត |
| -ជួសជុលអគារសាលាស្រុករវៀង | ម២ | ១២៦ | ១២៦ | ១២៦ | ១២៦ | ១២៦ | ១២៦ | សាលាខេត្ត | សាលាខេត្ត |
| **ហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | |
| -ស្ថាបនាផ្លូវភ្លោះក្រាលកៅស៊ូ | ម២ | ៧៥៦០ | ១០០៤៨ | ១២៥៣៦ | ១៥០២៤ | ១៧៥១២ | ២០០០០ | សាលាខេត្ត | សាលាខេត្ត |
| -ជួសជុលផ្លូវក្រាលគ្រួសក្រហម | ម | ៣៩៣៤ | ៧១៤៧ | ១០៣៦០ | ១៣៥៧៣ | ១៦៧៨៧ | ២០០០០ | សាលាខេត្ត | សាលាខេត្ត |
| -ជួសជុលផ្លូវក្រាលគ្រួសក្រហមស្រុក ៧ និងក្រុង ១ | ម | ១៦០០០ | ១៦៨០០ | ១៧៦០០ | ១៨៤០០ | ១៩២០០ | ២០០០០ | សាលាខេត្ត | សាលាខេត្ត |
| -ស្ថាបនាលូបង្ហូរទឹកស្រុក ក្រុង និងខេត្ត | ខ្សែ | ៣០ | ៤៤ | ៥៨ | ៧២ | ៨៦ | ១០០ | សាលាខេត្ត | សាលាខេត្ត |
| **សាងសង់របងបេតុងសត្តឃាតដ្ឋាន** | | | | | | | | | |
| -ក្រុងព្រះវិហារ | ម | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | ៣០០ | សាលាខេត្ត | សាលាខេត្ត |
| -ស្រុកគូលែន | ម | ១៥០ | ១៥០ | ១៥០ | ១៥០ | ១៥០ | ១៥០ | សាលាខេត្ត | សាលាខេត្ត |
| -ស្រុកជាំក្សាន្ត | ម | ១៥០ | ១៥០ | ១៥០ | ១៥០ | ១៥០ | ១៥០ | សាលាខេត្ត | សាលាខេត្ត |
| **ទីចាត់ការអន្តរវិស័យ** | | | | | | | | | |
| **១.១១.៣៥ គោលបំណងៈពង្រឹងការរៀបចំច្បាប់ធ្វើអាជីវកម្ម** | | | | | | | | | |
| -រៀបចំការគ្រប់គ្រង ឱ្យបានដាច់ស្រឡះ ជៀសវាងការជាន់ ភារកិច្ចគ្នា | ភាគរយ | ១០ | ១៤ | ១៨ | ២២ | ២៦ | ៣០ | សាលាខេត្ត | សាលាខេត្ត |
| -ពង្រឹងការអនុវត្តច្បាប់ឱ្យបាន តឹងរឹង | ភាគរយ | ៣០ | ៤០ | ៥០ | ៦០ | ៧០ | ៨០ | សាលាខេត្ត | សាលាខេត្ត |
| -ពង្រីកទីតាំង និងសាងសង់តូប លក់ដូរបន្ថែម, រៀបចំជួសជុលនិងសាងសង់ផ្សារថ្មី បន្ថែម និងរៀបចំសាងសង់ ទីតាំងសត្តឃាតឱ្យបានល្អ | ភាគរយ | ៣០ | ៤២ | ៥៤ | ៦៦ | ៧៨ | ៩០ | សាលាខេត្ត | សាលាខេត្ត |
| -ធ្វើការផ្សព្វផ្សាយ អំពីសក្តានុពល ដែលខេត្តមានដើម្បីទាក់ទាញការ | ភាគរយ | ៣០ | ៤២ | ៥៤ | ៦៦ | ៧៨ | ៩០ | សាលាខេត្ត | សាលាខេត្ត |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| វិនិយោគ | | | | | | | | | |
| **សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** | | | | | | | | | |
| **១.១២.៣៦ គោលបំណងៈពង្រឹងការគ្រប់គ្រងថវិកាថ្នាក់ខេត្ត** | | | | | | | | | |
| -ថវិកាទីចាត់ការហិរញ្ញវត្ថុ សាលាខេត្ត | | | | | | | | | |
| ចំណូលចរន្តៈ | | | | | | | | | |
| ចំណូលៈ សារពើពន្ធ | លានរៀល | ៣៩៧ | ៦៤៣ | ៩២៩ | ១២១៥ | ១៥០១ | ១៧៨៧ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ |
| ចំណូលៈ មិនមែនសារពើពន្ធ | លានរៀល | ១៣៧៩៧ | ២៤៧៦៣ | ៣៥៧៦៩ | ៤៦៧៧៤ | ៥៧៧៨០ | ៦៨៧៨៦ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ |
| ចំណាយចរន្តៈ | | | | | | | | | |
| ចំណាយៈ មធ្យោបាយសេវា | លានរៀល | ៩៣០៣ | ១៦៧៤៦ | ២៤១៨៩ | ៣១៦៣១ | ៣៩០៧៤ | ៤៦៥១៧ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ |
| ចំណាយៈ អន្តរាគមន៍សាធារណៈ | លានរៀល | ១៧១ | ៣០៨ | ៤៤៥ | ៥៨១ | ៧១៨ | ៨៥៥ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ |
| ចំណាយៈ ជាមូលធន | លានរៀល | ៤៦៣៩ | ៨៣៥០ | ១២០៦១ | ១៥៧៧១ | ១៩៤៨២ | ២៣១៩៣ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ |
| -ថវិកាតាមបណ្តាមន្ទីរជំនាញ | | | | | | | | | |
| ចំណូលចរន្តៈ | | | | | | | | | |
| ចំណូលៈ សារពើពន្ធ | លានរៀល | | | | | | | | |
| ចំណូលៈ មិនមែនសារពើពន្ធ | លានរៀល | ២៨ | ៥០ | ៧២ | ៩៣ | ១១៥ | ១៣៧ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ |
| ចំណាយចរន្តៈ | | | | | | | | | |
| ចំណាយៈ មធ្យោបាយសេវា | លានរៀល | ២១៩៦២ | ៣៩៥៣២ | ៥៧១០១ | ៧៤៦៧១ | ៩២២៤០ | ១០៩៨១០ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ |
| ចំណាយៈ អន្តរាគមន៍សាធារណៈ | លានរៀល | ២៣៨៥ | ៤២៩៣ | ៦២០០ | ៨១០៨ | ១០០១៥ | ១១៩២៣ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ | មន្ទីរសេដ្ឋកិច្ច/ហិរញ្ញវត្ថុ |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **ពន្ធដារ** | | | | | | | | | |
| **១.១៣.៣៧ គោលបំណងៈ បង្កើនចំណូលសារពើពន្ធ** | | | | | | | | | |
| ចំណូលថវិការដ្ឋ (ផ្នែកគ្រប់គ្រងអ្នកជាប់ពន្ធមធ្យម , របបម៉ៅការ ) | លានរៀល | ៨២៦,២០៩ | ៩២៩,៩៦៧ | ១០៣៤ | ១១៣៧ | ១២៤១ | ១៣៤៥ | សាខាពន្ធដារ | សាខាពន្ធដារ |
| ចំណូលថវិកាខេត្ត (ពន្ធប្រថាប់ត្រា , ពន្ធប្រថាប់ត្រាក្រុមហ៊ុន , អាករបំភ្លឺ សាធារណៈ , អាករស្នាក់នៅ , ពន្ធសត្តឃាត , ពន្ធប៉ាតង់ , ពន្ធមធ្យោបាយ ដឹកជញ្ជូន ) | លានរៀល | ៣៥៧,៣៣៣ | ៣៦៩,៨៦៦ | ៣៧៤,៤ | ៣៨២,៩៣៣ | ៣៩១,៤៦៧ | ៤០០ | សាខាពន្ធដារ | សាខាពន្ធដារ |
| **រតនាគារ** | | | | | | | | | |
| **១.១៤.៣៨ គោលបំណងៈបើកផ្តល់ថវិកាឱ្យទាន់ពេលវេលា** | | | | | | | | | |
| បើកផ្តល់ថវិការដ្ឋ-ខេត្ត (បៀវត្សមន្ត្រីជុំវិញខេត្ត ស្រុក ក្រុង ឃុំ) | លានរៀល | ១០២២២ | ១២២៩៣ | ១៤៣៦៤ | ១៦៤៣៤ | ១៨៥០៥ | ២០៥៧៦ | រតនាគារ | រតនាគារ |
| បើកប្រាក់ឧបត្ថម្ភមន្ត្រីមានជម្ងឺ-កូនកំព្រា និវត្តជន ជនក្រីក្រ | លានរៀល | ៤២៩៧ | ៥០១៣ | ៥៧៣០ | ៦៤៤៦ | ៧១៦៣ | ៧៨៧៩ | រតនាគារ | រតនាគារ |
| **អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (BFD)** | | | | | | | | | |
| **១.១៥.៣៩ គោលបំណងៈ បង្កើនសន្តិសុខស្បៀងសំរាប់កសិករដែលទទួលរងឥទ្ធិពលដោយសារការឡើងថ្លៃស្បៀងអាហារ( ស្រុកគូលែននិងជ័យសែន)** | | | | | | | | | |
| ផ្តល់ស្រូវពូជនិងជី | គ្រួសារ | ៤២៨៥ | | | | | | **BFD** | **BFD** |
| ផ្តល់ពូជបន្លែនិងជី | គ្រួសារ | ២០០០ | | | | | | **BFD** | **BFD** |
| ផ្តល់តង់កៅស៊ូ និងធុងរក្សាពូជស្រូវ | គ្រួសារ | ៦៦០ | | | | | | **BFD** | **BFD** |
| ផ្តល់ចង្រ្កាន | គ្រួសារ | ១០០០ | | | | | | **BFD** | **BFD** |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **២.ផ្នែកសង្គមកិច្ច** | | | | | | | | | |
| **គោលដៅទី២ : លើកកំពស់ការផ្តល់សេវាកម្មសង្គម ការថែទាំសុខមាលភាព និងបណ្តុះបណ្តាលធនធានមនុស្ស ។** | | | | | | | | | |
| **អប់រំ** | | | | | | | | | |
| **២.១.១ គោលបំណង:** ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ | | | | | | | | | |
| ❖ ពង្រីកកម្មវិធីអប់រំកុមារតូចសម្រាប់កុមារអាយុពី៣ ទៅក្រោម ៦ឆ្នាំ ដោយផ្តោតមុខសញ្ញា ទៅលើ ឃុំដែលមានអត្រាពិត ចូលរៀនថ្មី ទាបនិងមានអត្រាត្រួតថ្នាក់ខ្ពស់នៅបឋមសិក្សា | % | ៤៣,១៧ | ៤៦,៥៤ | ៤៩,៩០ | ៥៣,២៧ | ៥៦,៦៣ | ៦០ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ ធានាឲ្យកុមារអាយុ ៦ឆ្នាំបានចូលរៀននៅបឋមសិក្សា រួមបញ្ចូល ទាំងក្រុមបាត់បង់ឱកាសដូចជា កុមារពិការ កុមារជនជាតិភាគតិច ពលករកុមារ ជាដើម។ | % | ៩០,០៧ | ៩២,០៦ | ៩៤,០៤ | ៩៦,០៣ | ៩៨,០១ | ១០០ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ កាត់បន្ថយបន្ទុកចំណាយរបស់មាតាបិតាសិស្សគ្រប់ទិដ្ឋភាពដូចជាចំណាយក្រៅផ្លូវការ | សាលា | ១៨៥ | ២០២ | ២១៨ | ២៣៥ | ២៥១ | ២៦៨ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ បង្កើនចំនួនអាហារូបករណ៍ (ថវិកាឬស្បៀង) ដល់សិស្សមកពីគ្រួសារក្រីក្រសិស្សក្រីក្ររៀនពូកែ ជាពិសេសសិស្សស្រី ដើម្បីធានា បានការចូលរៀននៅសាលា បឋមសិក្សា និងមធ្យមសិក្សា។ ធានា កំណត់ឲ្យបានលើមុខសញ្ញាសិស្សបឋមសិក្សាក្រីក្រ ឫសុវត្ថិភាព ស្បៀង | សិស្ស | ២៥៦០ | ២៦៤៨ | ២៧៣៦ | ២៨២៤ | ២៩១២ | ៣០០០ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាព ទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| សម្រាប់កម្មវិធីផ្តល់អាហារូបត្ថម្ភ និង កម្មវិធី អាហារូបករណ៍ សម្រាប់សិស្សថ្នាក់ទី ៧-៩ ។ | | | | | | | | | |
| ❖ ធានាសនិទានកម្មបុគ្គលិកអប់រំសម្រាប់តំបន់ដាច់ស្រយាល និងជួប ការលំបាក ។ | បុគ្គលិក | ១៥៤៧ | ១៥៨៨ | ១៦២៨ | ១៦៦៩ | ១៧០៩ | ១៧៥០ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ បន្តសាងសង់សាលារៀនថ្មី និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឬ ផ្តល់សម្ភារូបវ័ន្តបន្ថែមចំពោះ សាលារៀនបឋម សិក្សាមិនគ្រប់ កម្រិតថ្នាក់។ | អគារ | ៥៦ | ៦០ | ៦៤ | ៦៧ | ៧១ | ៧៥ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ ពង្រឹងនិងពង្រីកហេដ្ឋារចនាសម្ព័ន្ធកីឡាគ្រប់ប្រភេទនៅគ្រប់កម្រិត។ | សាលា | ២៥ | ៤៥ | ៦៥ | ៨៥ | ១០៥ | ១២៥ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| **២.១.២ គោលបំណង:** លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ | | | | | | | | | |
| ❖ កាត់បន្ថយអត្រាត្រួតថ្នាក់និងបោះបង់ការសិក្សានៅគ្រប់កម្រិតថ្នាក់ | % | ៨,៥ | ៧,៨ | ៧,១ | ៦,៤ | ៥,៧ | ៥ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ បង្កើតស្តង់ដានៃការសិក្សារបស់សិស្សនៅថ្នាក់ទី ៣ ទី ៦ និងទី ៩ ទូទាំងប្រទេស ។ | % | ៧៥ | ៧៨ | ៨១ | ៨៤ | ៨៧ | ៩០ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ បង្កើនរង្វាន់លើកទឹកចិត្ត និងប្រាក់លាភការជូនគ្រូបង្រៀនផ្អែកលើ លទ្ធផលបំពេញ ការងារ និង ស្តង់ដា។ | គ្រូ | ២១៥ | ២៤១ | ២៦៧ | ២៩៣ | ៣១៩ | ៣៤៥ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ បង្កើនគណនេយ្យភាពហិរញ្ញវត្ថុសាធារណៈ និងការទទួលខុសត្រូវ របស់គ្រឹះស្ថានសិក្សាក្នុងការប្រើប្រាស់ថវិកា | សាលា | ២៦៨ | ២៧០ | ២៧៣ | ២៧៥ | ២៧៨ | ២៨០ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| និងការសម្រេច ចិត្តលើ កម្មវិធីនានា ។ | | | | | | | | | |
| ❖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពកម្មវិធីអប់រំកាយ និងកីឡា។ | សាលា | ១៨៧ | ១៨៩ | ១៩១ | ១៩២ | ១៩៤ | ១៩៦ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| **២.១.៣ គោលបំណង: អភិវឌ្ឍស្ថាប័ននិងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ ធ្វើវិមជ្ឈការ** | | | | | | | | | |
| ❖ បង្កើនគុណភាព និងប្រសិទ្ធភាពនៃការកសាងផែនការ ពិនិត្យតាម ដាន ពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្ត ផែនការ នៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុក។ | សាលា | ១២០ | ១២១ | ១២២ | ១២៤ | ១២៥ | ១២៦ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ ធានាថាគ្រប់អង្គភាព និងគ្រឹះស្ថានសិក្សាជាអង្គភាព ប្រតិបត្តិ ប្រកបដោយប្រសិទ្ធភាព ក្នុងការគ្រប់គ្រង និងប្រើប្រាស់ថវិកា។ | សាលា | ២១៤ | ២១៦ | ២១៨ | ២២០ | ២២២ | ២២៤ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រង រដ្ឋបាល។ | សាលា | ២១៤ | ២១៦ | ២១៨ | ២២០ | ២២២ | ២២៤ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ ពង្រឹងប្រព័ន្ធពិនិត្យតាមដាន ការបំពេញការងារវិស័យ អប់រំ និងផល ប៉ះពាល់ ។ | សាលា | ២១៤ | ២១៦ | ២១៨ | ២២០ | ២២២ | ២២៤ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| ❖ កាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងតំណែងអ្នកគ្រប់ គ្រងនៅថ្នាក់ស្រុក ក្រុង សាលា។ | % | ១៥ | ១៩ | ២៣ | ២៧ | ៣១ | ៣៥ | មន្ទីរអប់រំយុវជននិងកីឡា | មន្ទីរអប់រំយុវជននិងកីឡា |
| **សុខាភិបាល** | | | | | | | | | |
| **២.២.៤ គោលបំណង: លើកកំពស់សុខមាលភាពនិង សុវត្ថភាពមាតា ទារក និង កុមារ** | | | | | | | | | |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| អត្រាស្ត្រីសំរាលកូនដោយឆ្មបពេទ្យ | % | ៣៧ | ៣៨,៦ | ៤០,២ | ៤១,៨ | ៤៣,៤ | ៤៥ | មន្ទីរសុខាភិបាល | មន្ទីរសុខាភិបាល |
| អត្រាស្ត្រីវិយបន្តពូជទទួលសេវាពន្យាកំណើតទំនើប | % | ៤២ | ៤២,៦ | ៤៣,២ | ៤៣,៨ | ៤៤,៤ | ៤៥ | មន្ទីរសុខាភិបាល | មន្ទីរសុខាភិបាល |
| %កុមារអាយុក្រោម១ឆ្នាំទទួលថ្នាំបង្ការគ្រប់ | % | ៦៨ | ៧០,៤ | ៧២,៨ | ៧៥,២ | ៧៧,៦ | ៨០ | មន្ទីរសុខាភិបាល | មន្ទីរសុខាភិបាល |
| %ស្ត្រីសំរាលកូនដោយវះកាត់ | % | ១ | ១,២ | ១,៤ | ១,៦ | ១,៨ | ២ | មន្ទីរសុខាភិបាល | មន្ទីរសុខាភិបាល |
| %ស្ត្រីមកពិនិត្យផ្ទៃពោះលើកទី២ | % | ៧៣ | ៧៣,៦ | ៧៤,២ | ៧៤,៨ | ៧៥,៤ | ៧៦ | មន្ទីរសុខាភិបាល | មន្ទីរសុខាភិបាល |
| %កុមារអាយុ៦-៥៩ខែទទួលវីតាមីនអា២ដូស | % | ៩៨ | ៩៨,៤ | ៩៨,៨ | ៩៩,២ | ៩៩,៦ | ១០០ | មន្ទីរសុខាភិបាល | មន្ទីរសុខាភិបាល |
| **២.២.៥ គោលបំណងៈ ប្រយុទ្ធនឹងជំងឺឆ្លង** | | | | | | | | | |
| %អាត្រាស្លាប់ដោយជំងឺគ្រុនចាញ់ធ្ងន់ធ្ងរ | % | ១.៧ | ១.៥៦ | ១.៤២ | ១.២៨ | ១.១៤ | ១ | មន្ទីរសុខាភិបាល | មន្ទីរសុខាភិបាល |
| អាត្រាស្រាវជាវរកអ្នកជំងឺរបេង | % | ៥១ | ៥២,៨ | ៥៤,៦ | ៥៦,៤ | ៥៨,២ | ៦០ | មន្ទីរសុខាភិបាល | មន្ទីរសុខាភិបាល |
| អាត្រាស្លាប់ដោយជំងឺគ្រុនឈាម | % | ១.៧ | ១.៥៦ | ១.៤២ | ១.២៨ | ១.១៤ | ១ | មន្ទីរសុខាភិបាល | មន្ទីរសុខាភិបាល |
| **វប្បធម៌** | | | | | | | | | |
| **២.៣.៦ គោលបំណងៈ លើកកំពស់ការងារថែរក្សា និង គ្រប់គ្រង បេតិកភ័ណ្ឌ រូបីយ** | | | | | | | | | |
| ថែរក្សាគ្រប់គ្រងប្រាសាទបុរាណ ចំនួន ២៤១ កន្លែង | ប្រាសាទ | ៩ | ១០ | ១១ | ១៣ | ១៤ | ១៥ | មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ | មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ |
| **២.៣.៧ គោលបំណងៈ លើកកំពស់វិស័យសិល្បៈ របាំ** | | | | | | | | | |
| សិក្សាស្រាវជ្រាវចងក្រងពីទម្រង់ សិល្បៈ របាំ ទំនៀមទំលាប់ប្រពៃណី | ក្រុម | ១ | ២ | ២ | ២ | ២ | ២ | មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ | មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ |
| **ព័ត៌មាន** | | | | | | | | | |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **២.៤.៨ គោលបំណង:** សម្រេចអោយបាននូវការផ្សព្វផ្សាយព័ត៌មានអោយទូលំទូលាយ និងគ្របដណ្តប់ទូទាំងខេត្ត | | | | | | | | | |
| សាងសង់ស្ថានីយ៍វិទ្យុ | ស្ថានីយ៍ | ១ | ១ | ១ | ១ | ១ | ១ | មន្ទីរព័ត៌មាន | មន្ទីរព័ត៌មាន |
| ពង្រីកស្ថានីយ៍វិទ្យុ ទូរទស្សន៍ឯកជន ខ្សែកាប | ស្ថានីយ៍ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | មន្ទីរព័ត៌មាន | មន្ទីរព័ត៌មាន |
| សាងសង់ស្ថានីយ៍ទូរទស្សន៍ខេត្ត | ស្ថានីយ៍ | ០ | ១ | ១ | ១ | ១ | ១ | មន្ទីរព័ត៌មាន | មន្ទីរព័ត៌មាន |
| រៀបចំអត្ថបទព័ត៌មានវិទ្យុ និង ទូរទស្សន៍ | អត្ថបទ | ១២ | ១៩ | ២៥ | ៣២ | ៣៨ | ៤៥ | មន្ទីរព័ត៌មាន | មន្ទីរព័ត៌មាន |
| ជ្រើសរើសនិងបង្កើនសមត្ថភាពក្នុងក្របខ័ណ្ឌមន្ទីរព័ត៌មាន | នាក់ | ១៦ | ១៨ | ២១ | ២៣ | ២៦ | ២៨ | មន្ទីរព័ត៌មាន | មន្ទីរព័ត៌មាន |
| សាងសង់អាគាររដ្ឋបាលមន្ទីរព័ត៌មាន | ខ្នង | ០ | ១ | ១ | ១ | ១ | ១ | មន្ទីរព័ត៌មាន | មន្ទីរព័ត៌មាន |
| **ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | | | | | | | |
| **២.៥.៩ គោលបំណង: បង្កើតការងារ និងធានាលក្ខខណ្ឌល្អប្រសើរ** | | | | | | | | | |
| ការអភិវឌ្ឍន៍មុខរបរសមរម្យនៅក្នុងសេដ្ឋកិច្ច ក្នុង និងក្រៅប្រព័ន្ធ | % | ៥០ | ៦០ | ៧០ | ៨០ | ៩០ | ១០០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ធានានូវសុខដុមរមនីយកម្មរវាងកម្មករ និយោជិត និងនិយោជក ស្របតាម ច្បាប់ស្តីពីការងារ | % | ៥៦ | ៦៤,៨ | ៧៣,៦ | ៨២,៤ | ៩១,២ | ១០០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ពង្រឹងការអនុវត្តន៍ប្រព័ន្ធសុខភាព | % | ៤៧ | ៥៧,៦ | ៦៨,២ | ៧៨,៨ | ៨៩,៤ | ១០០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| បង្កើតការិយាល័យបេឡាជាតិសន្តិ សុខសង្គម | % | ២២ | ៣៧,៦ | ៥៣,២ | ៦៨,៨ | ៨៤,៤ | ១០០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| អនុវត្តន៍ច្បាប់ និងចូលរួមអនុវត្តគម្រោង លប់បំបាត់ទម្រង់ ធ្ងន់ធ្ងរនៃពលកម្មកុមារនិងគម្រោងបង្ការមេរោគអេដស៍ជំងឺអេដស៍នៅតាម | % | ៦៤ | ៧១,២ | ៧៨,៤ | ៨៥,៦ | ៩២,៨ | ១០០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| សហគ្រាស គ្រឹះស្ថាន | | | | | | | | | |
| **២.៥.១០ គោលបំណង: ជម្រុញឲ្យការសាងសង់មជ្ឈមណ្ឌលបណ្តុះបណ្តាល វិជ្ជាជីវៈ និងផ្តល់ការអប់រំបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈជូនប្រជាពលរដ្ឋ** | | | | | | | | | |
| អភិវឌ្ឍន៍មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ | % | ៥៦ | ៦៤,៨ | ៧៣,៦ | ៨២,៤ | ៩១,២ | ១០០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ជំនាញផ្នែកសេវាកម្ម និងសិប្បកម្ម | វគ្គ | ១៤ | ២១ | ២៨ | ៣៥ | ៤២ | ៤៩ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ជំនាញផ្នែកកសិកម្ម | វគ្គ | ៣៣ | ៤៩ | ៦៥ | ៨០ | ៩៦ | ១១២ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| ហ្វឹកហ្វឺនកូនជាង | % | ៥២ | ៦១,៦ | ៧១,២ | ៨០,៨ | ៩០,៤ | ១០០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| | វគ្គ | ០ | ១ | ២ | ៣ | ៤ | ៥ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **២.៥.១១ គោលបំណង: ពង្រឹងការធ្វើឲ្យប្រសើរឡើងនៃយន្តការរដ្ឋបាលមន្ទីរនិងពង្រីកសមធម៌ យេនឌ័រ** | | | | | | | | | |
| ការគ្រប់គ្រងអង្គភាព | % | ៦៧ | ៧៣,៦ | ៨០,២ | ៨៦,៨ | ៩៣,៤ | ១០០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **២.៥.១២ គោលបំណង: ពង្រីកសមធម៌យេនឌ័រ** | | | | | | | | | |
| បញ្ជ្រាបយេនឌ័រក្នុងការគ្រប់គ្រងអង្គភាព | % | ៧៦ | ៨០,៨ | ៨៥,៦ | ៩០,៤ | ៩៥,២ | ១០០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| បញ្ជ្រាបយេនឌ័រក្នុងវិស័យការងារ | % | ៦០ | ៦៨ | ៧៦ | ៨៤ | ៩២ | ១០០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| បញ្ជ្រាបយេនឌ័រក្នុងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ | % | ៨៥ | ៨៨ | ៩១ | ៩៤ | ៩៧ | ១០០ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **សង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា** | | | | | | | | | |
| **២.៦.១៣ គោលបំណង: ពង្រឹងពង្រីកសេវាសុខុមាលភាព** | | | | | | | | | |
| ផ្តល់ជំនួយសង្គ្រោះ ដល់ជន រងគ្រោះ និងជនងាយរងគ្រោះ | គ្រួសារ | ៤៤១០ | ៤១២៨ | ៣៨៤៦ | ៣៥៦៤ | ៣២៨២ | ៣០០០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| ថែទាំកុមារក្នុងមណ្ឌលរដ្ឋ | នាក់ | ៩៧ | ១០២ | ១០៦ | ១១១ | ១១៥ | ១២០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| កូនកំព្រាមន្ត្រីរាជការតាមសហគមន៍ | នាក់ | ៩៣ | ១០៤ | ១១៦ | ១២៧ | ១៣៩ | ១៥០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| **២.៦.១៤ គោលបំណង: ពង្រឹងសេវាសុខុមាលភាពជនពិការនិងស្តារលទ្ធភាពពលកម្ម** | | | | | | | | | |
| បន្តនិរន្តរភាពពោងជាងស្តារលទ្ធភាពកាយសម្បទា និងសេវាព្យាបាល ដោយចលនា | នាក់ | ១៨៨ | ១៩៦ | ២០៥ | ២១៣ | ២២២ | ២៣០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| **២.៦.១៥ គោលបំណង: ពង្រឹងរបបសន្តិសុខសង្គមនិងសុខុមាលភាពមនុស្សចាស់និងប្រជាជនទូទៅ** | | | | | | | | | |
| និវត្តរាជការ | គ្រួសារ | ២១៣ | ២៥០ | ២៨៨ | ៣២៥ | ៣៦៣ | ៤០០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| និវត្តយោធិន | គ្រួសារ | ២១៨ | ២៥៤ | ២៩១ | ៣២៧ | ៣៦៤ | ៤០០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| បាត់បង់រាជការ | គ្រួសារ | ៤៣ | ៥៤ | ៦៦ | ៧៧ | ៨៩ | ១០០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| បាត់បង់យោធិន | គ្រួសារ | ៥៩ | ៦៧ | ៧៥ | ៨៤ | ៩២ | ១០០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| **២.៦.១៦ គោលបំណង: ពង្រឹងរបបសន្តិសុខសង្គមនិងសុខុមាលភាពអតីតយុទ្ធជន** | | | | | | | | | |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| ជនមរណៈ | គ្រួសារ | ៦៦ | ៧៣ | ៧៩ | ៨៦ | ៩៣ | ១០០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| ជនពលី | គ្រួសារ | ១០៣៨ | ១០៧០ | ១១០៣ | ១១៣៥ | ១១៦៨ | ១២០០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| ជនពិការ | គ្រួសារ | ៨០៦ | ៨៣៥ | ៨៦៤ | ៨៩២ | ៩២១ | ៩៥០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| **២.៦.១៧ គោលបំណងៈ ពង្រឹងសមត្ថភាពមន្ត្រីរាជការដើម្បីបង្កើនប្រសិទ្ធិភាពសេវាសង្គម** | | | | | | | | | |
| មន្ត្រីក្របខ័ណ្ឌ | នាក់ | ២៦ | ២៩ | ៣២ | ៣៤ | ៣៧ | ៤០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| បុគ្គលិកអណ្តែត | នាក់ | ៩ | ១១ | ១៣ | ១៦ | ១៨ | ២០ | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា | មន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា |
| **ធម្មការនិងសាសនា** | | | | | | | | | |
| **២.៧.១៨ គោលបំណងៈ** លទ្ធផលសំរេចជាទូទៅជាមូលដ្ឋានរយពេល៥ឆ្នាំ | | | | | | | | | |
| អនុសំវច្ឆរមហាសន្និបាទមន្ត្រីសង្ឃទូទាំងខេត្ត។ | នាក់អង្គ | ២១៨ | ៣៧៤ | ៥៣១ | ៦៨៧ | ៨៤៤ | ១០០០ | មន្ទីរធម្មការ និងសាសនា | មន្ទីរធម្មការ និងសាសនា |
| អប់រំផ្សព្វផ្សាយធម្មទេសនា តាមវិទ្យុ ទូទស្សន៍ ពិធីបុណ្យផ្សេងៗ ។ | % | ៧០ | ៧៦ | ៨២ | ៨៨ | ៩៤ | ១០០ | មន្ទីរធម្មការ និងសាសនា | មន្ទីរធម្មការ និងសាសនា |
| ជីវប្រវត្តិអាចារ្យ | % | ៥០ | ៥២ | ៦៤ | ៧៦ | ៨៨ | ១០០ | មន្ទីរធម្មការ និងសាសនា | មន្ទីរធម្មការ និងសាសនា |
| ប្រជុំអន្តរសាសនា | % | ៥០ | ៦០ | ៧០ | ៨០ | ៩០ | ១០០ | មន្ទីរធម្មការ និងសាសនា | មន្ទីរធម្មការ និងសាសនា |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| វត្តអារ៉ាម | អង្គ | ៥៦១ | ៥៩៩ | ៦៣៧ | ៦៧៤ | ៧១២ | ៧៥០ | មន្ទីរធម្មការ និងសាសនា | មន្ទីរធម្មការ និងសាសនា |
| សាលាធម្មវិន័យ | អង្គ | ៤៣ | ៨៤ | ១២៦ | ១៦៧ | ២០៩ | ២៥០ | មន្ទីរធម្មការ និងសាសនា | មន្ទីរធម្មការ និងសាសនា |
| សាលាពុទ្ធិកសិក្សា | អង្គ | ៦០ | ១១៨ | ១៧៦ | ២៣៤ | ២៩២ | ៣៥០ | មន្ទីរធម្មការ និងសាសនា | មន្ទីរធម្មការ និងសាសនា |
| **ក្រុមការងារផែនការកំចាត់មីន** | | | | | | | | | |
| **២.៨.១៩ គោលបំណង: កាត់បន្ថយគ្រោះថ្នាក់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ឱ្យក្លាយទៅជាតំបន់ស្ថេរភាព ផ្តល់ជូនប្រជាពលរដ្ឋ ប្រកបមុខរបរចិញ្ចឹមជីវិត ឈានឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ ។** | | | | | | | | | |
| ប្រជុំឃុំរៀបចំការដោះមីន | លើក | ៦ | ១១ | ១៦ | ២០ | ២៥ | ៣០ | ក្រុមការងារផែនការកំចាត់មីន | ក្រុមការងារផែនការកំចាត់មីន |
| ចុះអង្កេតចំកាមីន និងធ្វើបញ្ជីអ្នកទទួលផល | កន្លែង | ២០៨ | ៣៧៤ | ៥៤១ | ៧០៧ | ៨៧៤ | ១០៤០ | ក្រុមការងារផែនការកំចាត់មីន | ក្រុមការងារផែនការកំចាត់មីន |
| សិក្ខាសាលាចំការមីនអនុម័តថ្នាក់ស្រុក | លើក | ៤ | ៧ | ១០ | ១៤ | ១៧ | ២០ | ក្រុមការងារផែនការកំចាត់មីន | ក្រុមការងារផែនការកំចាត់មីន |
| សិក្ខាសាលាអនុម័តថ្នាក់ខេត្ត | លើក | ១ | ២ | ៣ | ៣ | ៤ | ៥ | ក្រុមការងារផែនការកំចាត់មីន | ក្រុមការងារផែនការកំចាត់មីន |
| ចុះអង្កេតចំការមីន ដោះមីន | កន្លែង | ៣០ | ៥៤ | ៧៨ | ១០២ | ១២៦ | ១៥០ | ក្រុមការងារផែនការ | ក្រុមការងារផែនការ |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| | | | | | | | | កំចាត់មីន | ការកំចាត់មីន |
| **២.៨.២០ គោលបំណងៈ បង្កើនសកម្មភាពពិនិត្យមើលដំណើរការអនុវត្តផែនការដោះមីន** | | | | | | | | | |
| ប្រជុំ ភីម៉ាក់ប្រចាំត្រីមាស | លើក | ៣ | ៥ | ៨ | ១០ | ១៣ | ១៥ | ក្រុមការងារផែនការកំចាត់មីន | ក្រុមការងារផែនការកំចាត់មីន |
| តាមដានការអនុវត្តផែនការដោះមីន | លើក | ១៨ | ៣២ | ៤៧ | ៦១ | ៧៦ | ៩០ | ក្រុមការងារផែនការកំចាត់មីន | ក្រុមការងារផែនការកំចាត់មីន |
| ការផ្ទេរប្រគល់ដីដោះមីនរួច | លើក | ២៤ | ៤៣ | ៦២ | ៨២ | ១០១ | ១២០ | ក្រុមការងារផែនការកំចាត់មីន | ក្រុមការងារផែនការកំចាត់មីន |
| ត្រួតពិនិត្យការគ្រប់គ្រង-ប្រើប្រាស់ដីដោះមីនរួច | កន្លែង | ៤៦ | ៨៣ | ១២០ | ១៥៦ | ១៩៣ | ២៣០ | ក្រុមការងារផែនការកំចាត់មីន | ក្រុមការងារផែនការកំចាត់មីន |
| សន្និបាតបូកសរុបការងារប្រចាំឆ្នាំ | លើក | ១ | ២ | ៣ | ៣ | ៤ | ៥ | ក្រុមការងារផែនការកំចាត់មីន | ក្រុមការងារផែនការកំចាត់មីន |
| **សាលាខេត្ត** | | | | | | | | | |
| **ទីចាត់ការហិរញ្ញវត្ថុ** | | | | | | | | | |
| **២.៩.២១ គោលបំណងៈ ជំរុញការសង្គ្រោះប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិ** | | | | | | | | | |
| +សង្គ្រោះប្រជាជនរងគ្រោះដោយធម្មជាតិ | | | | | | | | | |
| -ជ័យសែន | គ្រួសារ | ៨៣០ | ៧៦៤ | ៦៩៨ | ៦៣២ | ៥៦៦ | ៥០០ | សាលាខេត្ត | សាលាខេត្ត |
| -រវៀង | គ្រួសារ | ៥០០ | ៤៦០ | ៤២០ | ៣៨០ | ៣៤០ | ៣០០ | សាលាខេត្ត | សាលាខេត្ត |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| -ក្រុងព្រះវិហារ | គ្រួសារ | ៣៥០ | ៣២០ | ២៩០ | ២៦០ | ២៣០ | ២០០ | សាលាខេត្ត | សាលាខេត្ត |
| **ទីចាត់ការគ្រប់គ្រងធនធានមនុស្ស** | | | | | | | | | |
| **២.៩.២២ គោលបំណង: ពង្រឹងការគ្រប់គ្រងធនធានមនុស្សទៅតាមរចនាសម្ព័ន្ធថ្មីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយនីរន្តរភាព** | | | | | | | | | |
| -រៀបចំការគ្រប់គ្រងធនធានមនុស្សទៅតាមរចនាសម្ព័ន្ធថ្មីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ | ភាគរយ | ៤០ | ៤៤ | ៤៨ | ៥២ | ៥៦ | ៦០ | សាលាខេត្ត | សាលាខេត្ត |
| -ជ្រើសរើស បុគ្គលិក ទីប្រឹក្សា អ្នកបច្ចេកទេស មន្ត្រីជាប់កិច្ចសន្យា។ | ភាគរយ | ៣ | ៦,៤ | ៩,៨ | ១៣,២ | ១៦,៦ | ២០ | សាលាខេត្ត | សាលាខេត្ត |
| -រៀបចំបណ្តុះបណ្តាលដល់មន្ត្រីរាជការ នៃរដ្ឋបាលខេត្ត ក្រុង ស្រុក។ | ភាគរយ | ១០ | ២៨ | ៤៦ | ៦៤ | ៨២ | ១០០ | សាលាខេត្ត | សាលាខេត្ត |
| -រៀបចំគោលនយោបាយក្នុងការដាក់ឱ្យចូលនិវត្តន៍ចំពោះមន្ត្រីដែលដល់អាយុ មន្ត្រីបាត់បង់សមត្ថភាពពលកម្ម និងពលី មរណៈ។ | ភាគរយ | ៣ | ៦,៤ | ៩,៨ | ១៣,២ | ១៦,៦ | ២០ | សាលាខេត្ត | សាលាខេត្ត |
| -បញ្ជូនមន្ត្រីរាជការទៅបណ្តុះបណ្តាល ទៅទស្សនកិច្ចសិក្សាជំនាញផ្សេងៗ នៅក្នុងនិងក្រៅប្រទេស ឬតំបន់នានា ។ | ភាគរយ | ៥ | ១៤ | ២៣ | ៣២ | ៤១ | ៥០ | សាលាខេត្ត | សាលាខេត្ត |
| **ទីចាត់ការអន្តរវិស័យ** | | | | | | | | | |
| -រកដៃគូដើម្បី គាំទ្រ | ភាគរយ | ៧០ | ៧៦ | ៨២ | ៨៨ | ៩៤ | ១០០ | សាលាខេត្ត | សាលាខេត្ត |
| -ជ្រើសរើសបុគ្គលិក បន្ថែម ស្របតាមតម្រូវ ការ មូលដ្ឋាន | ភាគរយ | ៧០ | ៧៦ | ៨២ | ៨៨ | ៩៤ | ១០០ | សាលាខេត្ត | សាលាខេត្ត |
| -ឱ្យមានតម្លាភាព និង ការត្រួតពិនិត្យឱ្យបាន ច្បាស់លាស់ | ភាគរយ | ៥០ | ៦០ | ៧០ | ៨០ | ៩០ | ១០០ | សាលាខេត្ត | សាលាខេត្ត |
| -បន្តផ្សព្វផ្សាយ និង ជំរុញឱ្យភាគីបុរស ចូលរួមក្នុងសកម្មភាព | ភាគរយ | ៥០ | ៦០ | ៧០ | ៨០ | ៩០ | ១០០ | សាលាខេត្ត | សាលាខេត្ត |
| -ជំរុញឱ្យមានការផ្សព្វ ផ្សាយ ការគោរពច្បាប់ របស់រដ្ឋ | ភាគរយ | ៨០ | ៨៤ | ៨៨ | ៩២ | ៩៦ | ១០០ | សាលាខេត្ត | សាលាខេត្ត |
| **អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍** | | | | | | | | | |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **២.១០.២៣ គោលបំណង: លើកស្ទួយការគោរពសិទ្ធិមនុស្សមូលដ្ឋាន** | | | | | | | | | |
| បង្កើតអ្នកស្ម័គ្រចិត្តដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ (PDV) | នាក់ | ១៣២ | ១១៦ | ៩៩ | ៨៣ | ៦៦ | ៥០ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| បង្កើតគណៈកម្មាធិការការពារ និងដោះស្រាយការរំលោភសិទ្ធិមនុស្សនៅថ្នាក់ឃុំ (CPMHRV) | នាក់ | ១៥០ | ១៣៣ | ១១៦ | ៩៩ | ៨២ | ៦៥ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| បង្កើតអ្នកស្ម័គ្រចិត្តដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ថ្នាក់ឃុំ (CNHR) | នាក់ | ៣០ | ២៧ | ២៣ | ២០ | ១៦ | ១៣ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| បង្កើតគណៈកម្មាធិការការពារ និងដោះស្រាយការរំលោភសិទ្ធិមនុស្សថ្នាក់ស្រុក(DNHR) | នាក់ | ២៣ | ២០ | ១៧ | ១៥ | ១៣ | ១០ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| ផ្តល់ចំណេះដឹងដល់អ្នកស្ម័គ្រចិត្តដើម្បីសន្តិភាព និងការអភិវឌ្ឍន៍ថ្នាក់ភូមិនិងថ្នាក់ឃុំ | នាក់ | ១៣២ | ១១៤ | ៩៦ | ៧៩ | ៦១ | ៤៣ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| ផ្តល់ចំណេះដឹងដល់គណៈកម្មាធិការការពារ និង ដោះស្រាយការរំលោភសិទ្ធិមនុស្សថ្នាក់ឃុំ និងថ្នាក់ស្រុក | នាក់ | ១៥០ | ១៣៣ | ១១៦ | ៩៩ | ៨២ | ៦៥ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| ផ្តល់ថវិកាដល់ឃុំគោលដៅចំនួន ៣០ឃុំ (ឃុំចាស់) និង១៣ឃុំ (ថ្មី) ដើម្បីអនុវត្តគំរោងសិទ្ធិមនុស្សមូលដ្ឋាន | ដុល្លារ | ៤០០ | ៤០០ | ៤០០ | ៤០០ | ៤០០ | ៤០០ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| ផ្តល់ថវិកាដល់ស្រុកគោលដៅចំនួន ៥ស្រុក ដើម្បីអនុវត្តគំរោងសិទ្ធមនុស្សមូលដ្ឋាន | ដុល្លារ | ០ | ២០០ | ៤០០ | ៦០០ | ៨០០ | ១០០០ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| **២.១០.២៤ គោលបំណង:** *បង្កើនសេដ្ឋកិច្ចគ្រួសាររបស់កុមារក្រីក្រគ្រួសារផ្ទុកមេរោគអេដស៏និងគ្រួសារជនជាតិភាគតិចដើម្បីពួកគេមានជីវភាពធូរធាជាពិសេសលើវិស័យអប់រំរបស់កូនៗពួកគេ* | | | | | | | | | |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| ផ្នែកកុមារចិញ្ចឹមៈ | | | | | | | | | |
| ជួយឧបត្ថម្ភដល់កុមារចិញ្ចឹម ឲ្យពួកគេបានបន្តការសិក្សា និងចៀសវាង នូវការបោះបង់ការសិក្សា | នាក់ | ៣១១ | ៣១៩ | ៣២៧ | ៣៣៤ | ៣៤២ | ៣៥០ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| បង្កើនប្រាក់ចំណូលដល់គ្រួសារកុមារចិញ្ចឹមនីមួយៗអាចមានលទ្ធភាពឧបត្ថម្ភកូនដោយខ្លួនឯង | នាក់ | ៣១១ | ៣១៩ | ៣២៧ | ៣៣៤ | ៣៤២ | ៣៥០ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| បង្កើននូវការយល់ដឹងអំពីសង្គមនិងខ្លួនឯងព្រមទាំងការទទួលខុសត្រូវរបស់កុមារនិងក្រុមគ្រួសារដើម្បីឲ្យពួកគេតាំងចិត្តក្នុងការសិក្សានិងកាត់បន្ថយគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន កាត់បន្ថយការរំលោភសិទ្ធិមនុស្ស និងអំពើហឹង្សាក្នុងគ្រួសារ ។ | នាក់ | ៣១១ | ៣១៩ | ៣២៧ | ៣៣៤ | ៣៤២ | ៣៥០ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| សាងសង់សាលារៀននៅព្រះឃ្លាំងមួយខ្នង មាន០៥បន្ទប់ដែលស្ថិតនៅក្នុងសាលាបឋមសិក្សាព្រះឃ្លាំង | ខ្នង | ១ខ្នង ៥បន្ទប់ | | | | | | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| **២.១០.២៥ គោលបំណងៈ** ***ផ្តោតទៅលើការអប់រំអនាម័យខ្លួនប្រាណ និងអនាម័យទូទៅដល់ប្រជាពលរដ្ឋក្នុងសហគមន៍ និងសិស្សានុសិស្សបឋមសិក្សា ដើម្បីអោយពួកគេយល់ដឹងអំពីការថែរក្សាខ្លួនប្រាណ បរិស្ថាន ចំណីអាហារ ការបន្ទោរបង់តាមបង្គន់ ការប្រើប្រាស់ទឹកស្អាត*** | | | | | | | | | |
| ផ្នែកអប់រំសុខភាព | | | | | | | | | |
| បង្កើនការយល់ដឹងអំពីសុខភាពអនាម័យតាមសហគមន៍ (ស្រុកគោលដៅមានៈជាំក្សាន្ត គូលែន ជ័យសែន រវៀង សង្គមថ្មី ត្បែងមានជ័យ និងក្រុងព្រះវិហារ) | ភូមិ | ០ | ១២ | ២៤ | ៣៥ | ៤៧ | ៥៩ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |
| បង្កើនការយល់ដឹងអំពីសុខភាពអនាម័យតាមសាលាបឋមសិក្សាចំនួន២០ (ក្នុងស្រុកគោលដៅមានៈជាំក្សាន្ត គូលែន ជ័យសែន រវៀង ត្បែងមានជ័យ និងក្រុងព្រះវិហារ) | សាលា | ០ | ៤ | ៨ | ១២ | ១៦ | ២០ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ | ពុទសាសនាដើម្បីអភិវឌ្ឍន៍ |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **៣ ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | | | | | | |
| **គោលដៅទី៣ : ប្រើប្រាស់ គ្រប់គ្រង សក្តានុពលសេដ្ឋកិច្ច ធនធានធម្មជាតិ ដើម្បីអភិវឌ្ឍន៍ខេត្ត ទទួលបានលទ្ធផលខ្ពស់ ហើយមិនប៉ះពាល់ដល់បរិស្ថាន និងជួយការពារបរិស្ថានឱ្យមាននិរន្តរភាព។** | | | | | | | | | |
| **រៀបចំដែនដីនគរូបនីយកម្ម និង សំណង់** | | | | | | | | | |
| **៣.១.១ គោលបំណង: បង្កើនការគ្រប់គ្រងដីធ្លី និងដោះស្រាយករណីទំនាស់ដីធ្លី** | | | | | | | | | |
| ធ្វើអត្តសញ្ញាណកម្មដីសម្បទានសេដ្ឋកិច្ច | ហិកតា | ១០៣២០៦ | ១០៥៦៦៥ | ១០៨១២៤ | ១១០៥៨២ | ១១៣០៤១ | ១១៥៥០០ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ |
| ធ្វើអត្តសញ្ញាណកម្មសម្បទានដីសង្គមកិច្ច | ហិកតា | ១៨០៧៦ | ១៨៣៦១ | ១៨៦៤៦ | ១៨៩៣០ | ១៩២១៥ | ១៩៥០០ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ |
| ដោះស្រាយករណីទំនាស់ដីធ្លី | ករណី | ១០០ | ៨៨ | ៧៦ | ៦៥ | ៥៤ | ៤២ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ |
| ការចុះបញ្ជីដីធ្លី | ប័ណ្ណ | ៤៦៩ | ៤៨៥ | ៥០១ | ៥១៨ | ៥៣៤ | ៥៥០ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម និង សំណង់ |
| **ទេសចរណ៍** | | | | | | | | | |
| **៣.២.២ គោលបំណង: រៀបចំសហគមន៍ទេសចរណ៍** | | | | | | | | | |
| អភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព | កន្លែង | ១ | ២ | ៣ | ៣ | ៤ | ៥ | មន្ទីរទេសចរណ៍ | មន្ទីរទេសចរណ៍ |
| **បរិស្ថាន** | | | | | | | | | |
| **៣.៣.៣ គោលបំណង: បង្កើតសហគមន៍តំបន់ការពារធម្មជាតិ** | | | | | | | | | |
| ចងក្រងបង្កើតជាសហគមន៍ | សហគមន៍ | ៨ | ១១ | ១៥ | ១៨ | ២២ | ២៥ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| ជ្រើសរើសគណៈកម្មការ | គណៈកម្មការ | ៨ | ១១ | ១៥ | ១៨ | ២២ | ២៥ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| កំណត់ព្រៃសំរាប់ប្រគល់ជូនសហគមន៍ | ច្បាប់ | ៨ | ១១ | ១៥ | ១៨ | ២២ | ២៥ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| រៀបចំចងក្រងលក្ខន្តិកៈសហគមន៍ | ច្បាប់ | ៤ | ៨ | ១២ | ១៧ | ២១ | ២៥ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| រៀបចំផែនការគ្រប់គ្រង | ច្បាប់ | ១ | ២ | ២ | ៣ | ៣ | ៤ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| ចុះកិច្ចព្រមព្រៀងរវាងអគ្គនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិជាមួយ គណៈកម្មការ សហគមន៍តំបន់ការពារធម្មជាតិ | ច្បាប់ | ១ | ២ | ២ | ៣ | ៣ | ៤ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| **៣.៣.៤ គោលបំណង: អភិរក្សធនធានធម្មជាតិ និងជីវចំរុះ** | | | | | | | | | |
| ស្ទាក់ការស្ទាក់ការរង សំរាប់ទទួលខុសត្រូវល្បាតការពារភូមិសាស្ត្រដែលមានតំលៃខ្ពស់លើការងារអភិរក្ស ។ | កន្លែង | ០៧ | ៨ | ៩ | ១០ | ១១ | ១២ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| កំណត់ និង បែងចែកតំបន់គ្រប់គ្រង | តំបន់ | ០ | ១ | ១ | ១ | ១ | ១ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| សិក្សាស្រាវជ្រាវប្រភេទសត្វកម្រ | តំបន់ | ១ | ១ | ២ | ២ | ៣ | ៣ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| សួនបណ្តុះកូនឈើ | កន្លែង | ០ | ១ | ២ | ២ | ២ | ២ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| ដាំដើមឈើហូបផ្លែ | ដើម | ៣០០០ | ៥៤០០ | ៧៨០០ | ១០២០០ | ១២៦០០ | ១៥០០០ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| ស្តារដីព្រៃឈើ | ហិកតា | ០ | ២ | ៤ | ៦ | ៨ | ១០ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| កាត់បន្ថយប្រើប្រាស់ធនធានធម្មជាតិដើម្បីបង្កើនជីវភាពរស់នៅ | សហគមន៍ | ០ | ១ | ២ | ២ | ៣ | ៤ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| លើកកំពស់ការធ្វើអាជីវកម្មច្បោះជ័រ | សហគមន៍ | ១ | ២ | ២ | ៣ | ៣ | ៤ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| **៣.៣.៥ គោលបំណង: កំណត់ព្រំប្រទល់តំបន់សហគមន៍** | | | | | | | | | |
| សម្រង់ទិន្នន័យដីធ្លីកំពុងប្រើប្រាស់ | សហគមន៍ | ៧ | ៨ | ៨ | ៩ | ៩ | ១០ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| ផលិតផែនទីព្រំប្រទល់តំបន់សហគមន៍ដោយមានការយល់ព្រមពីសហគមន៍មូលដ្ឋាន | សហគមន៍ | ៧ | ៨ | ៨ | ៩ | ៩ | ១០ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| សុំការទទួលស្គាល់ជាផ្លូវការពីរាជរដ្ឋាភិបាល | សហគមន៍ | ០ | ២ | ៤ | ៦ | ៨ | ១០ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| ការបោះបង្គោលជាផ្លូវការ | សហគមន៍ | ០ | ១ | ១ | ២ | ២ | ២ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| **៣.៣.៦ គោលបំណង: ការបែងចែកដីធ្លីដោយសមធម៌** | | | | | | | | | |
| កំណត់ព្រំអំពីដីឯកជន-ឯកជនរបស់រដ្ឋនិងដីសាធារណៈរបស់រដ្ឋ | សហគមន៍ | ០ | ១ | ១ | ២ | ២ | ២ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| បែងចែកដោយសមធម៌នូវដីធ្លី(ដីលំនៅដ្ឋានដីស្រែនិងចំការ)និងស្នើសុំចុះបញ្ជី | សហគមន៍ | ០ | ១ | ១ | ២ | ២ | ៣ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| **៣.៣.៧ គោលបំណង: ការគ្រប់គ្រងសំណល់រឹង** | | | | | | | | | |
| ទីលានស្តុកសំណល់ | កន្លែង | ២ | ២ | ២ | ៣ | ៣ | ៣ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| សេវាប្រមូលសំណល់ | ក្រុមហ៊ុន | ១ | ២ | ២ | ២ | ៣ | ៣ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| ការគ្រប់គ្រងឡដុតសំណល់គ្លីនិក | ឡ | ០៧ | ១០ | ១២ | ១៥ | ១៧ | ២០ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| **៣.៣.៨ គោលបំណង: ការគ្រប់គ្រងសំណល់រាវ** | | | | | | | | | |
| ប្លង់គោលប្រព័ន្ធលូបង្ហូរសំណល់រាវ | ប្លង់ | ០ | ១ | ១ | ១ | ១ | ១ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| ប្រព័ន្ធលូមេបង្ហូរសំណល់រាវក្នុងទីរួមខេត្ត | គ.ម | ០ | ១ | ២ | ៣ | ៤ | ៥ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| អាងប្រព្រឹត្តកម្មសំណល់រាវបែបធម្មជាតិ | កន្លែង | ០ | ១ | ១ | ១ | ១ | ១ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| **៣.៣.៩ គោលបំណង: ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់** | | | | | | | | | |
| ការដាំដើមឈើលើតំបន់ព្រៃរិចរិល | ហ.ត | ០០ | ២០០ | ៤០០ | ៦០០ | ៨០០ | ១០០០ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| វាយតំលៃហេតុប៉ះពាល់បរិស្ថានលើគ្រប់គំរោងអភិវឌ្ឍន៍ | ភាគរយ | ៣០ | ៤៤ | ៥៨ | ៧២ | ៨៦ | ១០០ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| **៣.៣.១០ គោលបំណង: ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ** | | | | | | | | | |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| ការចូលរួមជាមួយស្ថាប័ន និងអ្នកពាក់ព័ន្ធ | ភាគរយ | ១៥ | ៣២ | ៤៩ | ៦៦ | ៨៣ | ១០០ | មន្ទីរបរិស្ថាន | មន្ទីរបរិស្ថាន |
| **ខណ្ឌរដ្ឋបាលព្រៃឈើ** | | | | | | | | | |
| **៣.៤.១១ គោលបំណងៈ ពង្រឹងការគ្រប់គ្រងព្រៃឈើ និងការអនុវត្តច្បាប់ព្រៃឈើ** | | | | | | | | | |
| ការធ្វើនិយ័តកម្មសហគមន៍ | សហគមន៍ | ១៨ | ១៩ | ១៩ | ២០ | ២០ | ២១ | រដ្ឋបាលព្រៃឈើ | រដ្ឋបាលព្រៃឈើ |
| ការងារបណ្ដុះនិងដាំកូនឈើ | ដើម | ១២០០០ | ២១៦០០ | ៣១២០០ | ៤០៨០០ | ៥០៤០០ | ៦០០០០ | រដ្ឋបាលព្រៃឈើ | រដ្ឋបាលព្រៃឈើ |
| ផ្សព្វផ្សាយច្បាប់ស្ដីពីព្រៃឈើ បទបញ្ជា០១,០២ បប.សារាចរ០២ | ភូមិ | ៦០ | ១០៨ | ១៥៦ | ២០៤ | ២៥២ | ៣០០ | រដ្ឋបាលព្រៃឈើ | រដ្ឋបាលព្រៃឈើ |
| ក្រុមការងារចុះស្រង់ស្ថិតិនិងផ្ទៀងផ្ទាត់ផ្ទៃដីព្រៃទទួលការរងកាប់រាន | កន្លែង | ១២ | ២២ | ៣១ | ៤១ | ៥០ | ៦០ | រដ្ឋបាលព្រៃឈើ | រដ្ឋបាលព្រៃឈើ |
| ក្រុមការងារអនុគណៈកម្មការទប់ស្កាត់និងបង្ក្រាបចុះត្រួតពិនិត្យនិងផ្ទៀងផ្ទាត់ធ្វើផែនទី,ដីកាដកហូតដីព្រៃយកមកទុកជាសម្បត្តិរដ្ឋវិញ | កន្លែង | ១២ | ២២ | ៣១ | ៤១ | ៥០ | ៦០ | រដ្ឋបាលព្រៃឈើ | រដ្ឋបាលព្រៃឈើ |
| ការងារបោះបង្គោលព្រំ | ដើម | ៥០ | ១៦០ | ២៧០ | ៣៨០ | ៤៩០ | ៦០០ | រដ្ឋបាលព្រៃឈើ | រដ្ឋបាលព្រៃឈើ |
| **ធនធានទឹក និងឧតុនិយម** | | | | | | | | | |
| **៣.៥.១២ គោលបំណងៈ ការងារឧតុនិយម និងជលសាស្ត្រ** | | | | | | | | | |
| រៀបចំ និងកែលំអប៉ុស្តិ៍តំរង់ទឹកភ្លៀងតាមស្រុកឡើងវិញ | ប៉ុស្តិ៍ | ១ | ២ | ៤ | ៥ | ៧ | ៨ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| រៀបចំប៉ុស្តិ៍វាស់កម្ពស់ទឹកជំនន់តាមដងស្ទឹងសែន | ប៉ុស្ត | ២ | ២ | ៣ | ៣ | ៣ | ៤ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| ផ្តល់ព័ត៌មានជាមុនអំពីគ្រោះមហន្តរាយដោយការប្រែប្រួលអាកាសធាតុ ( ទឹកជំនន់ គ្រោះរាំងស្ងួត និងព្យុះ ) | លើក | ៣ | ៥ | ៨ | ១០ | ១៣ | ១៥ | មន្ទីរធនធានទឹក | មន្ទីរធនធានទឹក |
| **កសិកម្ម** | | | | | | | | | |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| ៣.៦.១៣ គោលបំណងៈ វិធីសាស្ត្រធ្វើឱ្យប្រសើរឡើងនូវប្រពន្ធ័កសិកម្មដែលកាត់បន្ថយនូវហានីភ័យនៃការប្រែប្រួលអាកាសធាតុតាមរយៈរៀបចំស្តុកទុកទឹកភ្លៀង ដើម្បីចែកចាយសម្រាប់ធ្វើបង្ហាញ និងការធ្វើបង្ហាញពីបច្ចេកទេសកសិកម្មដែលបន្សុំាទៅនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | |
| ផ្តល់ពូជស្រូវទិន្នផលខ្ពស់ ដែលធន់នឹងអាកាសធាតុ | តោន | ០,៣ | ១.២៤ | ២.១៨ | ៣.១២ | ៤.០៦ | ៥ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| សាលារៀនស្រែកសិករ | សាលា | ៤ | ៨ | ១២ | ១៦ | ២០ | ២៤ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ផ្ទៃដីដំណាំបន្លែកើនឡើង | ហ.ត | ៥.២៥ | ៦.២ | ៧.១៥ | ៨.១ | ៩.០៥ | ១០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| កសិករទទួលបានចំនេះដឹងពីបច្ចេកទេស ដាំដុះដំណាំបន្លែ | នាក់ | ១៣៤ | ២៨៧ | ៤៤០ | ៥៩៤ | ៧៤៧ | ៩០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ទទួលបានការបង្ហាញដំណាំបន្លែ | បង្ហាញ | ៦ | ១២ | ១៨ | ២៤ | ៣០ | ៣៦ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ចងក្រងក្រុមកសិករផលិតចំណីសត្វជ្រូក | ក្រុម | ១ | ៤ | ៨ | ១១ | ១៥ | ១៨ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| កសិករទទួលបានចំណេះដឹងទំនាក់ទំនង ទីផ្សារ | នាក់ | ២៥ | ១០០ | ១៧៥ | ២៥០ | ៣២៥ | ៤០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| សត្វគោ-ក្របីកើនឡើង និងមានសុខភាពល្អ | ក្បាល | ១៦៧៥ | ២៣៤០ | ៣០០៥ | ៣៦៧០ | ៤៣៣៥ | ៥០០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ពូជគោដែលមានការលូតលាស់លឿន ធន់នឹងអាកាសធាតុ | ក្បាល | ៣ | ២០២ | ៤០២ | ៦០១ | ៨០១ | ១០០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ឡជីវឧស្ម័ន ដែលកាត់បន្ថយការប្រែប្រួលអាកាសធាតុ | គ្រួសារ | ១២ | ២៣ | ៣៥ | ៤៧ | ៥៨ | ៧០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| កសិករទទួលបានចំណេះដឹងពីការបាត់បងក្រោយប្រមូលផល | ភូមិ | ៦ | ១២ | ១៨ | ២៤ | ៣០ | ៣៦ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| កសិករទទួលបានពូជស្រូវធន់ទៅនឹងអាកាសធាតុ និង សម្ភារៈ សម្រាប់ធ្វើបង្ហាញ | គ្រួសារ | ១៣៤ | ២៦៨ | ៤០២ | ៥៣៦ | ៦៧០ | ៨០៤ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ផែនការ និងថវិកាឃុំត្រូវចាប់អារម្មណ៍លើហានីភ័យអំពីការបំប្រែបម្រួល អាកាសធាតុនៅក្នុងឃុំគោលដៅរបស់ខ្លួន | ឃុំ | ១ | ២ | ៣ | ៤ | ៥ | ៦ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| ប្រពន្ធ័ពតិមានស្តីពីព្រឹត្តិការនៃគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតត្រូវបានបង្កើតឡើងនៅក្នុងសហគមន៍ | នាក់ | ៤៨២៧ | ៥០៦២ | ៥២៩៦ | ៥៥៣១ | ៥៧៦៥ | ៦០០០ | មន្ទីរកសិកម្ម | មន្ទីរកសិកម្ម |
| **សាលាខេត្ត** | | | | | | | | | |
| **ទីចាត់ការហិរញ្ញវត្ថុ** | | | | | | | | | |
| **៣.៧.១៤ គោលបំណងៈ ពង្រឹងការគ្រប់គ្រងអនាម័យ** | | | | | | | | | |
| -ទិញធុងសំរាមដាក់តាមទីធ្លាសាធារណៈ | ធុង | ៥០០ | ៩០០ | ១៣០០ | ១៧០០ | ២១០០ | ២.៥០០ | សាលាខេត្ត | សាលាខេត្ត |
| -ទិញរថយន្តសំរាប់ដឹកសំរាម | គ្រឿង | ១ | ១ | ២ | ២ | ៣ | ៣ | សាលាខេត្ត | សាលាខេត្ត |
| **ទីចាត់ការអន្តរវិស័យ** | | | | | | | | | |
| **៣.៧.១៥ គោលបំណងៈ ពង្រឹងច្បាប់គ្រប់គ្រងដីធ្លី** | | | | | | | | | |
| ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋចូលរួមចុះបញ្ជីដីធ្លីនិងខិតខំរៀបចំផ្តល់ប័ណ្ណកម្មសិទ្ធិ | ភាគរយ | ២០ | ៣២ | ៤៤ | ៥៦ | ៦៨ | ៨០ | សាលាខេត្ត | សាលាខេត្ត |
| ជំរុញឱ្យមានការ គោរព និងអនុវត្ត ច្បាប់ដែលមាន ហើយ | ភាគរយ | ៣០ | ៤០ | ៥០ | ៦០ | ៧០ | ៨០ | សាលាខេត្ត | សាលាខេត្ត |
| ណែនាំឱ្យប្រជាពលរដ្ឋយល់ដឹងអំពី គោលការណ៍អភិវឌ្ឍន៍ | ភាគរយ | ៣០ | ៤០ | ៥០ | ៦០ | ៧០ | ៨០ | សាលាខេត្ត | សាលាខេត្ត |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| **៤-ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ** | | | | | | | | | |
| **គោលដៅទី៤ :ពង្រឹងសេវារដ្ឋបាល ធានាសន្តិសុខសណ្តាប់ធ្នាប់សង្គមឱ្យកាន់តែមានភាពល្អប្រសើរឡើង ។** | | | | | | | | | |
| **សាលាខេត្ត** | | | | | | | | | |
| **ទីចាត់ការគ្រប់គ្រងធនធានមនុស្ស** | | | | | | | | | |
| **៤.១.១ គោលបំណងៈ ពង្រឹងអំពីរបៀបរបបបំពេញការងារតាមតួនាទីភារកិច្ចនៃរចនាសម្ព័ន្ធថ្មីនៅថ្នាក់ក្រោមជាតិ និងបង្កើនប្រសិទ្ធភាពលើការងារ** | | | | | | | | | |
| -លើកសរសើរ ជូនរង្វាន់ និងផ្តល់ជូនគ្រឿងឥស្សរិយយស តម្លើងថ្នាក់ជូនមន្ត្រី បុគ្គលិក ដែលមានស្នាដៃក្នុងការបំពេញភារកិច្ចបានល្អ ។ | ភាគរយ | ១០ | ២០ | ៣០ | ៤០ | ៥០ | ៦០ | សាលាខេត្ត | សាលាខេត្ត |
| -អប់រំផ្សព្វផ្សាយអំពីវិន័យច្បាប់ដល់មន្ត្រីបុគ្គលិក | ភាគរយ | ១០ | ២០ | ៣០ | ៤០ | ៥០ | ៦០ | សាលាខេត្ត | សាលាខេត្ត |
| -រៀបចំឯកសណ្ឋាន សញ្ញាស័ក្តជូនមន្ត្រី បុគ្គលិកតាមឋានានុក្រម ។ | ភាគរយ | ០ | ១៤ | ២៨ | ៤២ | ៥៦ | ៧០ | សាលាខេត្ត | សាលាខេត្ត |
| **ទីចាត់ការអន្តរវិស័យ** | | | | | | | | សាលាខេត្ត | សាលាខេត្ត |
| **៤.១.២ គោលបំណងៈ បង្កើនការផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ** | | | | | | | | | |
| -អប់រំផ្សព្វផ្សាយ ដល់ ប្រជាពលរដ្ឋ អំពីច្បាប់ចរាចរ | ភាគរយ | ៤០ | ៤៨ | ៥៦ | ៦៤ | ៧២ | ៨០ | សាលាខេត្ត | សាលាខេត្ត |
| -រៀបចំ ស្លាកសញ្ញាចរាចរតាម ដងផ្លូវ ឱ្យបានគ្រប់គ្រាន់ | ភាគរយ | ២០ | ៣០ | ៤០ | ៥០ | ៦០ | ៧០ | សាលាខេត្ត | សាលាខេត្ត |
| -រៀបចំការផ្សព្វផ្សាយ អប់រំ ឱ្យយល់ដឹងអំពីផលវិបាកនៃការប្រើប្រាស់ គ្រឿងញៀន | ភាគរយ | ៥០ | ៥៨ | ៦៦ | ៧៤ | ៨២ | ៩០ | សាលាខេត្ត | សាលាខេត្ត |
| -ត្រូវរកវិធីទប់ស្កាត់ការហូរ ចូលវប្បធម៌ពាលាអាវ៉ាសែ | ភាគរយ | ៥០ | ៥៦ | ៦២ | ៦៨ | ៧៤ | ៨០ | សាលាខេត្ត | សាលាខេត្ត |
| -ណែនាំដល់អ្នកប្រើប្រាស់ ឱ្យបានយល់ពីការប្រើប្រាស់ដីចំណីផ្លូវ | ភាគរយ | ២០ | ២៨ | ៣៦ | ៤៤ | ៥២ | ៦០ | សាលាខេត្ត | សាលាខេត្ត |

| គោលដៅ និងគោលបំណង | សូចនាករ | | | | | | | ប្រភពទិន្នន័យ | អង្គភាពទទួលខុសត្រូវ |
|---|---|---|---|---|---|---|---|---|---|
| | ឯកតា | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | | |
| -ជំរុញដល់អាជ្ញាធរមូល ដ្ឋានយកចិត្តទុកដាក់រៀបចំ ស្តាប់ឱ្យបានប្រសើរ | | | | | | | | | |
| -ជំរុញការអប់រំផ្សព្វផ្សាយអំពីច្បាប់ឱ្យបានទូលំទូ លាយដល់ប្រជាពលរដ្ឋ | ភាគរយ | ៥០ | ៥៤ | ៥៨ | ៦២ | ៦៦ | ៧០ | សាលាខេត្ត | សាលាខេត្ត |
| -ជំរុញស្ថាប័នពាក់ព័ន្ធ ឱ្យរៀបចំចុះបញ្ជី និងធ្វើ ប័ណ្ណកម្មសិទ្ធ | ភាគរយ | ៥០ | ៥៤ | ៥៨ | ៦២ | ៦៦ | ៧០ | សាលាខេត្ត | សាលាខេត្ត |
| **ទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច** | | | | | | | | | |
| ៤.២.៣ គោលបំណង: បង្កើនសកម្មភាពចុះតាមដានអង្កេតស្រាវជ្រាវបទល្មើស ការអនុវត្តច្បាប់ និងផ្សព្វផ្សាយ ច្បាប់ជូនប្រជាពលរដ្ឋអាជ្ញាធរមានសមត្ថកិច្ចគ្រប់ប្រភេទដើម្បីលើកកំពស់ការយល់ដឹង ឱ្យកាន់ តែច្បាស់ក្នុងការអនុវត្តន៍ និងគោរពច្បាប់ ។ | | | | | | | | | |
| -ការគោរព និងអនុវត្តច្បាប់ | % | ៥០ | ៥៤ | ៥៨ | ៦២ | ៦៦ | ៧០ | ទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច | ទំនាក់ទំនងជាមួយរ ដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច |
| -ការដោះស្រាយពាក្យបណ្តឹង | % | ៥០ | ៥៤ | ៥៨ | ៦២ | ៦៦ | ៧០ | ទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច | ទំនាក់ទំនងជាមួយរ ដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច |
| -តាមដានការអនុវត្តន៍ច្បាប់ | % | ៦០ | ៦៣ | ៦៦ | ៦៩ | ៧២ | ៧៥ | ទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច | ទំនាក់ទំនងជាមួយរ ដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច |
| -ការធ្វើអធិការកិច្ច | % | ៦០ | ៦២ | ៦៤ | ៦៦ | ៦៨ | ៧០ | ទំនាក់ទំនងជាមួយ រដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច | ទំនាក់ទំនងជាមួយរ ដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច |

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២១៩ អនក.បក

ក្រសួងផែនការ
ចូល លេខ ... ថ្ងៃទី ២២ ខែ ១២ ឆ្នាំ ០៩
ម៉ោង បញ្ជូន ...

# អនុក្រឹត្យ

## ស្តីពី

## ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

មាត្រា ១._

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីគោលការណ៍ យន្តការ និងនីតិវិធីសម្រាប់ការពិគ្រោះយោបល់ ក្នុងការរៀបចំការគ្រប់គ្រងនិងការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដូចមានកំណត់ត្រង់មាត្រា៣៨និងមាត្រា៣៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

មាត្រា ២._

រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងអនុក្រឹត្យនេះ សំដៅត្រឹមតែរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

មាត្រា ៣._

អនុក្រឹត្យនេះមិនត្រូវអនុវត្តចំពោះការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ លើកលែងតែសកម្មភាពមួយចំនួនដែលទាក់ទងនឹងការចូលរួមរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍក្រុង ស្រុក ខណ្ឌ។

ផែនការអភិវឌ្ឍនិងកម្មវិនិយោគរបស់ខណ្ឌ សង្កាត់ ត្រូវដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់រាជធានីភ្នំពេញ។

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់សង្កាត់ក្នុងក្រុង ត្រូវដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ក្រុង។

មាត្រា ៤._

ផែនការអភិវឌ្ឍរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើប្រាស់ធ្វើជាមូលដ្ឋានយុទ្ធសាស្ត្រសម្រាប់ណែនាំរាល់ការធ្វើសេចក្តីសម្រេចក្នុងការងារអភិវឌ្ឍ ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលនឹងត្រូវទទួលហិរញ្ញប្បទានក្រោមក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងធនធាន ថវិកាពីប្រភពនានាតាមលទ្ធភាពជាក់ស្តែង។ ការរៀបចំក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមនីតិវិធីហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី២

## គោលការណ៍រួម

## នៃការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

## របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

មាត្រា ៥._

ការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រព្រឹត្តទៅតាមគោលការណ៍រួម ដូចខាងក្រោម ÷

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាពនិងសុខដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាពនិងសុក្រឹតភាពសេដ្ឋកិច្ចនិងសង្គម
- ការធានាចីរភាពធនធានធម្មជាតិនិងបរិស្ថាន
- ការធានាសមធម៌។

## ជំពូកទី៣
## យន្តការនិងភារកិច្ចក្នុងការកសាងនិងអនុវត្តផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

**មាត្រា ៦.-**

ក្រុមប្រឹក្សាទទួលខុសត្រូវ៖

- ណែនាំគោលនយោបាយទូទៅសម្រាប់រៀបចំខ្លឹមសារផែនការអភិវឌ្ឍ រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយរក្សាសង្គតិភាពជាមួយក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនិងថវិកាប្រចាំឆ្នាំនិងធនធានថវិកាពីប្រភពនានាតាមលទ្ធភាពជាក់ស្តែង
- ពិនិត្យនិងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យនិងអនុម័តផែនការអភិវឌ្ឍនៅឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន និងកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំ
- ពិនិត្យនិងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍក្នុងករណីចាំបាច់
- ផ្តល់សុពលភាពដល់លទ្ធផលត្រួតពិនិត្យនិងវាយតម្លៃអំពីការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលរាយការណ៍ដោយគណៈអភិបាល។

**មាត្រា ៧.-**

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សា ទទួលខុសត្រូវ៖

- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល

- ពិនិត្យនិងផ្តល់យោបល់ទៅក្រុមប្រឹក្សា មុនធ្វើការអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យនិងផ្តល់យោបល់ទៅក្រុមប្រឹក្សាលើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

មាត្រា ៨.-

គណៈអភិបាល ទទួលខុសត្រូវ÷

- ដឹកនាំការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំនៅថ្នាក់រដ្ឋបាលខ្លួន ស្របតាមការណែនាំពីក្រុមប្រឹក្សា ដូចបានកំណត់ក្នុងមាត្រា៦ខាងលើ ដោយធានាលក្ខណៈសង្គតិភាពរវាងខ្លឹមសាររបស់ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាមួយនឹងផែនការនិងគោលការណ៍ជាធរមាននានារបស់ជាតិ របស់រដ្ឋបាលថ្នាក់លើ និងផ្តោះទៅរកការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ
- ដឹកនាំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ចាត់ចែងអនុវត្តនិងតាមដានពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រាយការណ៍ជូនគ្រប់អង្គប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាមួយនឹងអនុសាសន៍ចាំបាច់ សម្រាប់លើកកម្ពស់ការអនុវត្តផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សារួមទាំងសមាសភាគនៃផែនការដែលស្ថិតក្រោមការគ្រប់គ្រងនិងការត្រួតពិនិត្យរបស់÷
  - ក្រុមប្រឹក្សារួមគ្នា
  - ប្រភេទក្រុមប្រឹក្សាផ្សេងៗ
  - ក្រសួង ស្ថាប័នឬអង្គភាពនានារបស់រាជរដ្ឋាភិបាល
  - ដៃគូពាក់ព័ន្ធនានា
- ធានាឱ្យមានអន្តរាគមន៍រហ័សក្នុងការដោះស្រាយការលំបាកឬបញ្ហានានាដែលកើតមានឡើងដោយចៃដន្យក្នុងអំឡុងពេលអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

មាត្រា ៩.-

តាមការឯកភាពពីក្រុមប្រឹក្សានិងដោយមានការគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលរាជធានី ខេត្ត ត្រូវបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ខ្លួន។ ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ ត្រូវមានសមាសភាពយ៉ាងតិច÷

- អភិបាលរាជធានី ខេត្ត ប្រធាន

- អភិបាលរងរាជធានី ខេត្ត០១រូប អនុប្រធាន
- នាយករដ្ឋបាលសាលារាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរផែនការរាជធានី ខេត្ត សមាជិកអចិន្ត្រៃយ៍
- ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត សមាជិក
- នាយកទីចាត់ការហិរញ្ញវត្ថុក្រុមប្រឹក្សារាជធានី ខេត្ត សមាជិក
- ប្រធានឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ សមាជិក
- ប្រធានឬតំណាងមន្ទីរនិងអង្គភាពជំនាញនានានៅរាជធានី ខេត្ត សមាជិក
- នាយកឬតំណាងទីចាត់ការចំណុះសាលារាជធានី ខេត្ត សមាជិក

មាត្រា ១០.-

តាមការឯកភាពពីក្រុមប្រឹក្សានិងដោយមានការគាំទ្រពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគរបស់ខ្លួន។ ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ ត្រូវមានសមាសភាពយ៉ាងតិច ÷

- អភិបាលក្រុង ស្រុក ខណ្ឌ ប្រធាន
- អភិបាលរងក្រុង ស្រុក ខណ្ឌ០១រូប អនុប្រធាន
- នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានការិយាល័យផែនការ ស្ថិតិក្រុង ស្រុក ខណ្ឌ សមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុសាលាក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានឬតំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ សមាជិក
- តំណាងអង្គភាពគាំទ្រឃុំ សង្កាត់ សមាជិក
- ប្រធានឬតំណាងការិយាល័យនិងអង្គភាពជំនាញនានានៅក្រុង ស្រុក ខណ្ឌ សមាជិក
- ប្រធានឬតំណាងការិយាល័យចំណុះសាលាក្រុង ស្រុក ខណ្ឌ សមាជិក

មាត្រា ១១.-

ក្រុមការងារកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគ មានភារកិច្ច ÷

- រៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលជូន គណៈអភិបាល
- ជួយគណៈអភិបាល ធ្វើការរៀបចំសិក្ខាសាលា វេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការ កសាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយផ្អែកលើលទ្ធផលរបស់ សិក្ខាសាលានិងកិច្ចប្រជុំពិគ្រោះយោបល់នានា។

# ជំពូកទី៤

## នីតិវិធី

## ការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

មាត្រា ១២._

ក្នុងឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន ក្រុមប្រឹក្សាត្រូវកសាងផែនការអភិវឌ្ឍដែលមានសុពលភាពរយៈពេលប្រាំឆ្នាំ និងរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលលើកទី១ សម្រាប់ថ្នាក់រដ្ឋបាលខ្លួន។ កម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

មាត្រា ១៣._

ក្នុងការរៀបចំនិងអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវមានការពិគ្រោះយោបល់ជាមួយនឹង ÷

- ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រភេទក្រុមប្រឹក្សាដទៃទៀតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- និងអ្នកពាក់ព័ន្ធនានា។

មាត្រា ១៤._

វិធីសាស្ត្រសម្រាប់ធ្វើការប្រជុំពិគ្រោះយោបល់អំពីការរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវកំណត់ដោយក្រុមប្រឹក្សា តាមតម្រូវការចាំបាច់។

រាល់សេចក្តីសម្រេចរបស់កិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ជាធាតុចូលសម្រាប់ក្រុមប្រឹក្សាធ្វើការពិនិត្យនិងអនុម័តលើសេចក្តីព្រាង។

មាត្រា ១៥._

ក្នុងកិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ត្រូវមានការចូលរួមពីប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ ពីក្រុង ស្រុក ខណ្ឌនៅក្នុងរាជធានី ខេត្ត។

មាត្រា ១៦._

ក្នុងកិច្ចប្រជុំរៀបចំផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុង ស្រុក ខណ្ឌ ត្រូវមានការចូលរួមពីមេឃុំ ចៅសង្កាត់ និងអ្នកទទួលបន្ទុកស្ត្រីនិងកុមារឃុំ សង្កាត់ ពីឃុំ សង្កាត់នីមួយៗនៅក្នុងក្រុង ស្រុក ខណ្ឌ។

# ជំពូកទី៥

## ការអនុម័ត ការចាត់ចែងអនុវត្ត
## ផែនការអភិវឌ្ឍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

មាត្រា ១៧._

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវអនុម័តដោយសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សា។

មាត្រា ១៨._

សេចក្តីស្នើកែសម្រួលលើផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវអនុម័តដោយសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សា។

មាត្រា ១៩._

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ត្រូវតម្កល់ទុកជាឯកសារមួយច្បាប់នៅសាលារាជធានី ខេត្ត មួយច្បាប់នៅមន្ទីរផែនការរាជធានី ខេត្ត មួយច្បាប់នៅក្រសួងមហាផ្ទៃ មួយច្បាប់នៅក្រសួងផែនការ។

មាត្រា ២០._

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ត្រូវតម្កល់ទុកជាឯកសារមួយច្បាប់នៅសាលារាជធានី ខេត្ត មួយច្បាប់នៅមន្ទីរផែនការរាជធានី ខេត្ត មួយច្បាប់នៅសាលាក្រុង ស្រុក ខណ្ឌ។

មាត្រា ២១._

ក្រុមប្រឹក្សាត្រូវផ្សព្វផ្សាយជាសាធារណៈនិងបន្ទាន់នូវផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលបន្ទាប់ពីអនុម័តរួច ជូនសាធារណជន និងភាគីពាក់ព័ន្ធបានដឹង។

មាត្រា ២២._

ក្រុមប្រឹក្សាត្រូវណែនាំឱ្យគណៈអភិបាលចាត់ចែងអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័ត ដោយមានតម្លាភាព មានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធភាព។

មាត្រា ២៣._

ករណីក្រុមប្រឹក្សាត្រូវបានរំលាយមុនអាណត្តិ ក្រុមប្រឹក្សាថ្មីដែលទទួលការងារបន្តអាចទទួលយកផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលមុនទាំងស្រុងឬអាចរៀបចំកែសម្រួលផែនការអភិវឌ្ឍសម្រាប់រយៈពេលដែលនៅសល់របស់អាណត្តិ។

មាត្រា ២៤._

ផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល មានសុពលភាពរហូតដល់មានផែនការអភិវឌ្ឍថ្មី និងកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្មីដែលបានអនុម័តដោយក្រុមប្រឹក្សាអាណត្តិបន្ទាប់។

## ជំពូកទី៦

## ការតាមដាន វាយតម្លៃ និងរបាយការណ៍

មាត្រា ២៥._

ក្រុមប្រឹក្សាត្រូវចាត់ចែងឱ្យមានការតាមដានពីវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល និងបណ្តាសកម្មភាពពាក់ព័ន្ធដែលអនុវត្តដោយស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិនានា និងផ្នែកឯកជននៅក្នុងដែនដីរដ្ឋបាលរបស់ខ្លួន។

មាត្រា ២៦._

នៅចុងឆ្នាំសារពើពន្ធនីមួយៗ គណៈអភិបាលត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ជូនក្រុមប្រឹក្សាពិនិត្យ។ របាយការណ៍ប្រចាំឆ្នាំត្រូវមាន ÷

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តក្នុងឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម។

មាត្រា ២៧._

ក្រុមប្រឹក្សាត្រូវអនុម័តនិងផ្ញើជូនទៅគ្រប់ថ្នាក់ពាក់ព័ន្ធមានសមត្ថកិច្ចនូវរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្នុងអំឡុងពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធនីមួយៗ។

មាត្រា ២៨._

សេចក្តីណែនាំលំអិតសម្រាប់អនុវត្តការកសាងនិងការអនុវត្តផែនការអភិវឌ្ឍនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្នុងអនុក្រឹត្យនេះ ត្រូវកំណត់និងអាចធ្វើបច្ចុប្បន្នភាពតាមតម្រូវការជាក់ស្តែង ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃនិងក្រសួងផែនការ។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

មាត្រា ២៩._

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ៣០._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សារាជធានី គណៈអភិបាលរាជធានី ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុង ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក ក្រុមប្រឹក្សាខណ្ឌ គណៈអភិបាលខណ្ឌ ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ៥ ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ និងក្រសួងផែនការ

លេខ ៤២.១៧... ប្រក

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកសាងផែនការអភិវឌ្ឍន៍

## និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

********

## រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- យោងអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- យោងអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងតាមការសម្រេចនៃកិច្ចប្រជុំ គ.ជ.អ.ប លើកទី៥ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះ មានគោលបំណងណែនាំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការកសាង អនុម័ត និងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលសម្រាប់រដ្ឋបាលរបស់ខ្លួន ដោយមានការចូលរួម និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមខ្លឹមសារនៃសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក្រោមសុពលភាពនៃប្រកាសអន្តរក្រសួង នេះ ។

**ប្រការ ២.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(០៥)ឆ្នាំ យ៉ាងយូរបំផុត នៅក្នុងឆ្នាំទី២នៃអាណត្តិរបស់ខ្លួន។ផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាឯកសារយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងជាមូលដ្ឋានសម្រាប់រៀបចំកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

**ប្រការ ៣.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធានាឱ្យបានថា ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ត្រូវបានដាក់បញ្ចូលនូវផែនការអភិវឌ្ឍន៍ និងថវិការបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងអ្នកពាក់ព័ន្ធនានា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

**ប្រការ ៤.-**

ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ត្រូវបញ្ចូលនូវផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខណ្ឌ និងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគសង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់រាជធានី។

ផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ត្រូវបញ្ចូលនូវផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគសង្កាត់នានាក្នុងដែនសមត្ថកិច្ចរបស់ក្រុង។

**ប្រការ ៥.-**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺជាឯកសារផ្លូវការ ហើយក្រុមប្រឹក្សានីមួយៗត្រូវរៀបចំចាត់ចែងផ្សព្វផ្សាយឯកសារនេះជាសាធារណៈ [illegible] ដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី២

## យន្តការ និងភារកិច្ចក្នុងការកសាងនិងអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

### ប្រការ ៦..

ដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ស្ថិតក្រោមការដឹកនាំ និងត្រួតពិនិត្យរួមរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ភារកិច្ចសំខាន់ៗរបស់ក្រុមប្រឹក្សារួមមាន :

- ត្រួតពិនិត្យ និងចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ណែនាំផ្នែកគោលនយោបាយសម្រាប់ដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងអនុម័តសំណើកែតម្រូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- តាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំលើការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

### ប្រការ ៧..

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សម្របសម្រួលការចូលរួមរបស់គ្រប់អ្នកពាក់ព័ន្ធក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ក្រៅពីភារកិច្ចខាងលើ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល មុននឹងក្រុមប្រឹក្សាធ្វើការពិនិត្យ និងអនុម័ត។

### ប្រការ ៨..

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ដឹកនាំ និងសម្របសម្រួលការងារកសាងសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ស្របតាមការណែនាំរបស់ក្រុមប្រឹក្សា ដោយសហការជាមួយភាគីពាក់ព័ន្ធនានា
- ដឹកនាំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់នានា ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ប្រការ ៩..

ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុមការងារកសាងផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្អែកគោលនយោបាយរបស់ក្រុមប្រឹក្សា
- រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដឹកនាំ និងសម្របសម្រួលដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសិក្ខាសាលា និងវេទិកាពិគ្រោះយោបល់នានាជាមួយភាគីពាក់ព័ន្ធនានា ក្នុងដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

ប្រការ ១០..

ក្នុងដំណើរការកសាងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ទីចាត់ការ និងការិយាល័យនានា នៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចសំខាន់ៗដូចខាងក្រោម :

- ជួយក្រុមប្រឹក្សា និងគណៈអភិបាលក្នុងការដឹកនាំ និងសម្របសម្រួលដំណើរការកសាង អនុម័ត តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សហការជាមួយក្រុមការងារកសាងផែនការក្នុងការដឹកនាំ និងសម្របសម្រួលការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ចូលរួមវិភាគស្ថានភាពនិងពិគ្រោះយោបល់ក្នុងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- សម្របសម្រួល និងចូលរួមការបណ្តុះបណ្តាលអំពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ។

## ជំពូកទី៣

## ដំណើរការកសាងផែនការអភិវឌ្ឍន៍

## និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ប្រការ ១១..

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន តាមរយៈដំណើរការដែលមានការចូលរួមនិងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប្រភេទក្រុមប្រឹក្សាផ្សេងទៀត សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ អង្គភាពពាក់ព័ន្ធ អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ដើម្បីរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រកបដោយគុណភាព និងស្របតាមគោលការណ៍ ដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យលេខ២១៩ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំគោលការណ៍ណែនាំផ្អែកគោលនយោបាយ និងប្រតិទិនស្តីពីដំណើរការកសាងផែនការឱ្យបានច្បាស់លាស់ ដោយផ្អែកលើតម្រូវការជាអាទិភាពរបស់មូលដ្ឋាន សក្តានុពលរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយរបស់ជាតិ ។

គោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា ត្រូវរៀបចំតាមរយៈដីកា ឬសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។

ការចំណាយនានាសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល គឺត្រូវរ៉ាប់រងដោយថវិការបស់ក្រុមប្រឹក្សានីមួយៗ។

## ប្រការ ១២..

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ខ្លួន ដោយបញ្ចូលនូវខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម :

- **ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច :** រៀបរាប់ដោយសង្ខេបអំពីព័ត៌មានក្នុងស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈមនានាដែលពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច សង្គមកិច្ច ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ និងស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល
- **ក្របខ័ណ្ឌអភិវឌ្ឍន៍ :** រៀបរាប់ពីចក្ខុវិស័យ គោលដៅ គោលបំណង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៃផែនការអភិវឌ្ឍន៍
- **ការតាមដាននិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ :** រៀបរាប់អំពីអ្នកទទួលខុសត្រូវនិងអ្នកចូលរួមក្នុងការវាយតម្លៃ វិធីសាស្ត្រវាយតម្លៃ និងការរៀបចំរបាយការណ៍។

## ប្រការ ១៣..

ក្នុងការកសាងផែនការអភិវឌ្ឍន៍ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកចិត្តទុកដាក់លើសកម្មភាពសំខាន់ៗមួយចំនួនដូចខាងក្រោម :

- ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍
- ការផ្សព្វផ្សាយពត៌មានអំពីដំណើរការ និងនីតិវិធីសម្រាប់ការកសាងផែនការអភិវឌ្ឍន៍
- ការកសាងផែនការអភិវឌ្ឍន៍ តាមរយៈការវិភាគស្ថានភាព និងការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ និង
- ការអនុម័តផែនការអភិវឌ្ឍន៍

## ប្រការ ១៤..

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដោយបញ្ចូលនូវខ្លឹមសារសំខាន់ៗមួយចំនួនដូចខាងក្រោម :

- **ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច :** រៀបរាប់ដោយសង្ខេបអំពីព័ត៌មានសេដ្ឋកិច្ច សង្គមកិច្ច ក្នុងស្ថានភាពបច្ចុប្បន្ន បញ្ហាប្រឈម និងតម្រូវការជាអាទិភាពរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- **គម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល :** រៀបរាប់អំពីគម្រោងវិនិយោគ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងផែនការសកម្មភាពសម្រាប់អនុវត្តគម្រោងឆ្នាំទី១នៃកម្មវិធីវិនិយោគបីឆ្នាំរំកិល។
- **ការតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគ :** រៀបរាប់អំពីអ្នកទទួលខុសត្រូវនិងអ្នកចូលរួមក្នុងការវាយតម្លៃ វិធីសាស្ត្រវាយតម្លៃ និងការរៀបចំរបាយការណ៍។

ប្រការ ១៥..

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួន ដោយផ្អែកលើផែនការអភិវឌ្ឍន៍។ កម្មវិធីវិនិយោគបីឆ្នាំរំកិល ត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។ សកម្មភាពសំខាន់ៗនៃដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលរួមមាន :

- ការវិភាគស្ថានភាព ដោយផ្តោតលើការកំណត់បញ្ហា និងតម្រូវការជាអាទិភាព
- ការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល

ប្រការ ១៦..

ក្រសួងផែនការត្រូវជួយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការរៀបចំព័ត៌មានស្តីពីវឌ្ឍនភាព នៃការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា កម្រងឯកសារស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យផ្សេងទៀតដែលពាក់ព័ន្ធនឹងការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ប្រការ ១៧..

ក្រោយពេលដែលក្រុមប្រឹក្សារាជធានី ខេត្ត បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្តរួចហើយ គណៈអភិបាលរាជធានី ខេត្តត្រូវធ្វើការកែសម្រួលដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ហើយដាក់ជូនអភិបាលរាជធានី ខេត្តនូវសេចក្តីព្រាងផែនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប។ លេខាធិការដ្ឋាន គ.ជ.អ.ប ត្រូវធ្វើការថតចម្លងសេចក្តីព្រាងនេះជូនក្រសួងមហាផ្ទៃ ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងត្រូវធ្វើការសម្របសម្រួល ពិនិត្យ ពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ជាមួយក្រសួងទាំងបីខាងលើនេះ ព្រមទាំងជាមួយស្ថាប័នពាក់ព័ន្ធនានា ដើម្បីពិនិត្យ និងផ្តល់យោបល់លើភាពស្របច្បាប់ និងសង្គតិភាពនៃផែនការនេះជាមួយគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។ ក្រោយពេលពិនិត្យ និងពិគ្រោះយោបល់រួចរាល់ហើយ លេខាធិការដ្ឋានត្រូវធ្វើកំណត់បង្ហាញសុំយោបល់មករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យ និងផ្តល់អនុលោមភាព។ ការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ត្រូវធ្វើឡើងក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់របស់អភិបាលរាជធានី ខេត្ត។ រយៈពេល៣០ថ្ងៃនេះ រួមមានពេលវេលាចំណាយសម្រាប់ការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា ការធ្វើទំនាក់ទំនងជាមួយអភិបាលរាជធានី ខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់ដែលផ្តល់ដោយក្រសួងមហាផ្ទៃលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលរាជធានី ខេត្ត និងក្រសួងមហាផ្ទៃអំពីខ្លឹមសារសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រសួងមហាផ្ទៃត្រូវរាយការណ៍ និងស្នើសុំ គ.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយលក្ខណ៍អក្សរពីក្រសួងមហាផ្ទៃផ្ញើទៅអភិបាលរាជធានី ខេត្តទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីក្រសួងមហាផ្ទៃ។

**ប្រការ ១៨..**

ក្រោយពេលដែលក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បានពិនិត្យ និងអនុម័តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌរួចហើយ គណៈអភិបាលក្រុង ស្រុក ខណ្ឌត្រូវធ្វើការកែសម្រួលដោយផ្អែកតាមការសម្រេចរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ហើយដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌនូវសេចក្តីព្រាងផែនការដែលបានកែសម្រួលនេះ ដើម្បីពិនិត្យ និងផ្ញើជូនអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងផ្តល់យោបល់លើភាពស្របច្បាប់ និងសង្គតិភាពនៃផែនការនេះជាមួយគោលនយោបាយជាតិ ច្បាប់ និងលិខិតបទដ្ឋាននានា។ អភិបាលរាជធានី ខេត្ត ត្រូវធ្វើការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្នុងរយៈពេល៣០ថ្ងៃ គិតពីថ្ងៃដែលទទួលបានការស្នើសុំពិនិត្យ និងផ្តល់យោបល់ដោយអភិបាលក្រុង ស្រុក ខណ្ឌ ដោយសហការយ៉ាងជិតស្និទ្ធជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធនានា។ រយៈពេល៣០ថ្ងៃនេះ រួមមានពេលវេលាចំណាយសម្រាប់ការធ្វើទំនាក់ទំនងរវាងអភិបាលក្រុង ស្រុក ខណ្ឌ ជាមួយនឹងអភិបាលរាជធានី ខេត្ត ដើម្បីស្រាយបំភ្លឺ និងឯកភាពលើយោបល់ដែលផ្តល់ដោយអភិបាលរាជធានី ខេត្ត លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ។

ក្នុងករណីមិនមានការឯកភាពគ្នារវាងអភិបាលក្រុង ស្រុក ខណ្ឌ និងអភិបាលរាជធានី ខេត្ត អំពីខ្លឹមសារនៃសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្តត្រូវរាយការណ៍ និងស្នើសុំមកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីធ្វើការសម្របសម្រួលដោះស្រាយ។

ក្នុងរយៈពេល៣០ថ្ងៃ បើគ្មានការឆ្លើយតបជាលាយលក្ខណ៍អក្សរពីអភិបាលរាជធានី ខេត្តទៅក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌទេ នោះសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ត្រូវចាត់ទុកថាទទួលបានអនុលោមភាពពីអភិបាលរាជធានី ខេត្ត។

ក្នុងការពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ក្រុង ស្រុក ខណ្ឌ អភិបាលរាជធានី ខេត្ត ត្រូវពិចារណាអំពីភាពស្របច្បាប់ និងសង្គតិភាពនៃខ្លឹមសារផែនការអភិវឌ្ឍន៍ទៅនឹងគោលនយោបាយជាតិ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

**ប្រការ ១៩..**

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំបោះពុម្ព បែងចែក ផ្សព្វផ្សាយជាសាធារណៈនូវផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានអនុម័តដោយក្រុមប្រឹក្សា និងតម្កល់ទុកទៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរផែនការរាជធានី ខេត្ត ការិយាល័យផែនការក្រុង ស្រុក ខណ្ឌ និងផ្ញើទៅក្រសួងផែនការ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអ្នកពាក់ព័ន្ធដទៃទៀត។

**ប្រការ ២០..**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងសំណើកែប្រែផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវតែអនុម័តដោយសម្លេងលើសពីពាក់កណ្តាលនៃសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងមូល។

ក្នុងករណីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានរំសាយមុនអាណត្តិ យោងតាមមាត្រា២៤ នៃច្បាប់

ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌថ្មី អាចទទួលយកផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលកំពុងមានទាំងស្រុង ឬអាចរៀបចំកែសម្រួលផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ សម្រាប់រយៈពេលអាណត្តិដែលនៅសល់។

## ជំពូកទី៤
## ការអនុវត្តផែនការអភិវឌ្ឍន៍
## និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ប្រការ ២១..

បន្ទាប់ពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវបានអនុម័ត ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាត់ចែងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយមានតម្លាភាព មានគណនេយ្យភាព មានការចូលរួម និងមានប្រសិទ្ធភាព។

ប្រការ ២២..

អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តគម្រោង និងសកម្មភាពនានានៃផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ ដូចជាការធ្វើលទ្ធកម្មការងារសាងសង់ សម្ភារៈ ឬទំនិញ និងសេវាកម្មជាដើម ។ល។

## ជំពូកទី៥
## ការតាមដាន ការវាយតម្លៃ និងរបាយការណ៍

ប្រការ ២៣..

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការណែនាំឱ្យអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ធ្វើការតាមដាននិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ដោយរួមទាំងគម្រោងនិង សកម្មភាពនានាដែលអនុវត្ត និងគ្រប់គ្រងក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដោយ :

- ប្រភេទក្រុមប្រឹក្សាដូចគ្នា
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀត
- មន្ទីរ អង្គភាពនានា
- អ្នកពាក់ព័ន្ធផ្សេងទៀតដូចជា អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។

ប្រការ ២៤..

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល និងសមិទ្ធផលនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលជារៀងរាល់ឆ្នាំ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា។

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើការវាយតម្លៃអំពីលទ្ធផល សមិទ្ធផល និងផលប៉ះពាល់នៃការអនុវត្តផែនការអភិវឌ្ឍន៍រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងរយៈពេល០៦ខែចុងក្រោយនៃអាណត្តិរបស់ក្រុមប្រឹក្សា ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមានការចូលរួមពីអ្នកពាក់ព័ន្ធនានា ។

នីតិវិធីនៃការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមសេចក្តីណែនាំរបស់ គ.ជ.អ.ប ។

**ប្រការ ២៥..**

នៅចុងឆ្នាំនីមួយៗ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត ។ ខ្លឹមសាររបាយការណ៍នេះរួមមាន :

- វឌ្ឍនភាពការងារអនុវត្តក្នុងឆ្នាំកន្លងមក
- ទិសដៅការងារសម្រាប់អនុវត្តឆ្នាំខាងមុខ
- សេចក្តីសន្និដ្ឋានរួម ។

ក្រៅពីរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំរបាយការណ៍ផ្សេងទៀត ដើម្បីរាយការណ៍ជូនក្រុមប្រឹក្សាជាប្រចាំ ។

**ប្រការ ២៦..**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុម័តរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល និងរបាយការណ៍ស្តីពីលទ្ធផលនៃការតាមដាន និងវាយតម្លៃ មិនឱ្យលើសពីសែសិបប្រាំ(៤៥)ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំនីមួយៗ ។

របាយការណ៍ប្រចាំឆ្នាំរបស់រាជធានី ខេត្ត ត្រូវផ្ញើជូនគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធនានា ។

របាយការណ៍ប្រចាំឆ្នាំរបស់ក្រុង ស្រុក ខណ្ឌ ត្រូវផ្ញើជូនអភិបាលរាជធានី ខេត្ត គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមហាផ្ទៃ ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធនានា ។

របាយការណ៍ប្រចាំឆ្នាំដែលបានអនុម័តដោយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវតម្កល់ទុកនៅសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មន្ទីរ ការិយាល័យផែនការរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

## ជំពូកទី៦

## ការរៀបចំ និងការផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

**ប្រការ ២៧..**

ក្រសួងផែនការ និងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំផ្សព្វផ្សាយ និងណែនាំឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនេះ ស្របតាមខ្លឹមសារនិងសកម្មភាពសំខាន់ៗដូចមានចែងក្នុងប្រការ១៣ ប្រការ១៤ ប្រការ១៥ និងប្រការ១៦នៃប្រកាសនេះ ។

**ប្រការ ២៨..**

ក្រសួងផែនការ និងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប អាចធ្វើការកែសម្រួលសេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមការចាំបាច់ បន្ទាប់ពីបានពិភាក្សាជាមួយក្រសួងមហាផ្ទៃ លេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធផ្សេងទៀត ។

**ប្រការ ២៩..**

ក្រសួងផែនការនិងជាប្រធានអនុគណៈកម្មាធិការផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប ត្រូវសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងអ្នកពាក់ព័ន្ធនានា ដើម្បីរៀបចំឯកសារ កម្មវិធីផ្សព្វផ្សាយ និងការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីនីតិវិធីកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចមានក្នុងសេចក្តីណែនាំបច្ចេកទេសនេះ ។

## ជំពូកទី៧

## អវសានបញ្ញត្តិ

**ប្រការ ៣០..**

ប្រកាសនេះ ពុំមានអធិកភាពលើប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ឡើយ ប៉ុន្តែប្រកាសទាំងពីរមានទំនាក់ទំនងជាមួយគ្នាយ៉ាងជិតស្និទ្ធ ជាពិសេសសម្រាប់សង្កាត់ដែលស្ថិតក្នុងដែនសមត្ថកិច្ចរាជធានី និងសង្កាត់ស្ថិតក្នុងដែនសមត្ថកិច្ចក្រុង ។

**ប្រការ ៣១..**

ប្រកាស និងសេចក្តីណែនាំទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣២..**

ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែ ធ្នូ ឆ្នាំ២០១០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងផែនការ**

<u>*កន្លែងទទួល*</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *សមាជិក "គ.ជ.អ.ប"*
- *ក្រសួង.ស្ថាប័នពាក់ព័ន្ធ*
  *"ដើម្បីជូនជ្រាប"*
- *សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់*
  *"ដើម្បីអនុវត្ត"*
- *ឯកសារ.កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្តព្រះវិហារ

លេខ: ០៣៩៤ -សសរ/តអ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

## ខេត្តព្រះវិហារ

## អភិបាលខេត្ត

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៩/៧៥២ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩ ស្ដីពីការតែងតាំងជាអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៤ ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៩ ស្ដីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តព្រះវិហារ អាណត្តិទី១ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ។
- បានឃើញអនុក្រឹត្យលេខ ២១៨ អ.ន ក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការបង្កើតការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈ-កម្មាធិការសម្របសម្រួលបច្ចេកទេស ក្រុមប្រឹក្សាក្រុង គណៈកម្មាធិការសម្របសម្រួលបច្ចេក-ទេសក្រុមប្រឹក្សាស្រុក ។

- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា ១២ នៃអនុក្រឹត្យលេខ ២១៩ ដោយកំណត់ឱ្យក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខ្លួនឱ្យបានយ៉ាងយូរត្រឹមឆ្នាំទី ២ នៃអាណត្តិរបស់ខ្លួន ។
- យោងប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ... 

- យោងប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការសាលាខេត្ត ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាក្រុង ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ។
- យោងប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- យោងលិខិតលេខ ០០៣ សណន/គ.ជ.អ.ប ចុះថ្ងៃទី ១០ ខែមករា ឆ្នាំ២០១១ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំ រំកិលប្រចាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- យោងលិខិតលេខ ០៣៤ សណន ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ ស្តីពីការបែងចែកតួនាទី ភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក ។
- យោងអង្គប្រជុំសាមញ្ញលើកទី ២៦ របស់ក្រុមប្រឹក្សាខេត្តព្រះវិហារ អាណត្តិទី ១ នាថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១១។

**សម្រេច :**

**ប្រការ ១ :** ត្រូវបានបង្កើត "**ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តព្រះវិហារ**" ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម **អ៊ុំ ម៉ារ៉ា** | អភិបាលខេត្ត | ប្រធាន |
| ២-លោក **ស៊ុយ សេរិទ្ធ** | អភិបាលរងខេត្ត | អនុប្រធាន |

៣-លោក **ខុយ យុនហ៊** នាយករដ្ឋបាលសាលាខេត្ត សមាជិក

៤-លោក **ចាន់ ស៊ន** ប្រធានមន្ទីរផែនការ សមាជិកអចិន្ត្រៃយ៍

៥-លោក **មាស វដ្ឋារឌុឡ្យ** ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៦-លោកឧត្តមសេនីយ៍ត្រី **ម៉ៅ តៅ** ស្នងការនគរបាលខេត្ត សមាជិក

៧-លោកឧត្តមសេនីយ៍ត្រី **សោម ប៊ុណ្ណរ័ត្ន** មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងព្រះវិហារ សមាជិក

៨-លោកឧត្តមសេនីយ៍ត្រី **យ៉ឺន គា** មេបញ្ជាការកងរាជអាវុធហត្ថខេត្ត សមាជិក

៩-លោក **ទិញ សត្ថា** តំណាងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី
និងកុមារ សមាជិក

១០-លោក **ផាន់ សំអាន** ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន សមាជិក

១១-លោក **នួន សុវណ្ណ** ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

១២-លោក **ទែន សារ៉ុម** ប្រធានមន្ទីរពាណិជ្ជកម្ម សមាជិក

១៣-លោក **សេខ សារី** ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ សមាជិក

១៤-លោកស្រី **ខ្វី សុខុម** ប្រធានមន្ទីរកិច្ចការនារី សមាជិក

១៥-លោក **ខុយ យុនចន្ទរ័ត្ន** ប្រធានមន្ទីរបរិស្ថាន សមាជិក

១៦-លោកស្រី **ខុយ ម៉ុនថាវី្ល** ប្រធានមន្ទីរសុខាភិបាល សមាជិក

១៧-លោក **រ៉ាត់ សោភា** ប្រធានមន្ទីរព័ត៌មាន សមាជិក

១៨-លោក **គង់ សោភ័ណ** ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់
និងសុរិយោដី សមាជិក

១៩-លោក **ហាន ឆន** ប្រធានមន្ទីរអប់រំយុវជន និងកីឡា សមាជិក

២០-លោក **ឆួន សេខគេខ** ប្រធានមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង
អធិការកិច្ច សមាជិក

២១-លោក **គង់ ទិបុល** ប្រធានមន្ទីរទេសចរណ៍ សមាជិក

២២-លោក **ពីង ទ្រីដា** ប្រធានមន្ទីរកសិកម្ម សមាជិក

២៣-លោក **មាស ណារិទ្ធ** ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក

២៤-លោក **ជា សុផល** ប្រធានសាខាពន្ធដារខេត្តព្រះវិហារ សមាជិក

២៥-លោក **ហួន គា** ប្រធានមន្ទីរធម្មការ និងសាសនា សមាជិក

២៦-លោក **នុ សំអឿន** នាយកធនាគារខេត្តព្រះវិហារ សមាជិក

២៧-លោក **មុយ ចាន់ពេញ** ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា សមាជិក

| | | | |
|---|---|---|---|
| ២៨-លោក **ចាប កុយ** | ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ២៩-លោក **នៅ សុគុណា** | ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៣០-លោក **អ៊ាង ចណ្ណថា** | ប្រធានរតនាគារ | សមាជិក |
| ៣១-លោក **ប៊ុល ខាំណារ៉ា** | នាយខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ | សមាជិក |
| ៣២-លោក **ប៉ែន ចាសនា** | នាយខណ្ឌរដ្ឋបាលជលផលព្រះវិហារ | សមាជិក |
| ៣៣-លោក **ជួន ម៉ិនឡើន** | ប្រធានក្រុមការងារផែនការសកម្មភាពកម្ចាត់មីនខេត្ត | សមាជិក |
| ៣៤-លោក **កែ សេងគីម** | នាយកទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត | សមាជិក |
| ៣៥-លោក **លី ឆៀនឡុក** | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ៣៦-លោក **លីម សៀ** | នាយកទីចាត់ការរដ្ឋបាល | សមាជិក |
| ៣៧-លោក **ខួន សៀង** | នាយកទីចាត់ការផែនការ និងវិនិយោគ | សមាជិក |
| ៣៨-លោក **ស៊្រុយ សារី** | នាយករងទទួលបន្ទុករួមទីចាត់ការអន្តរវិស័យ | សមាជិក |
| ៣៩-លោក **អ៊ួង គីមសាន** | ប្រធានការិយាល័យមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |

**ប្រការ ២ :** ក្រុមការងារនេះមានតួនាទី និងភារកិច្ចដូចខាងក្រោម:

+រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំផ្នែកគោលនយោបាយរបស់ក្រុមប្រឹក្សា។

+រៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខេត្ត។

+ប្រមូលសរុបបញ្ហា និងតម្រូវការនានាស្នើឡើងដោយក្រុង ស្រុក និងស្នើឡើងដោយមន្ទីរ អង្គភាពនានា ព្រមទាំងអង្គការ សង្គមស៊ីវិល និងវិស័យឯកជន នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត។

+រៀបចំផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខេត្ត។

+រៀបចំសិក្ខាសាលា វេទិកាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធនានាក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខេត្ត។

+រៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខេត្ត។

+រៀបចំឯកសារពាក់ព័ន្ធនានាសម្រាប់កិច្ចប្រជុំក្រុមប្រឹក្សាដើម្បីពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគខេត្ត។

+កែសម្រួល និងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្ត ។

**ប្រការ ៣ :** សេចក្តីសម្រេចលេខ ០២០-សសរ/គអ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១ របស់សាលាខេត្ត-ព្រះវិហារ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៤ :** នាយករដ្ឋបាល នាយកទីចាត់ការទាំង ៥ចំណុះរចនាសម្ព័ន្ធសាលាខេត្ត, អភិបាលក្រុង-ស្រុក ប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត និងឯកឧត្តម អស់លោក លោកស្រីដូចមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

ព្រះវិហារ ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១

**ជ.គណៈអភិបាលខេត្ត**

**អភិបាលខេត្ត**

អ៊ុំ ម៉ារ៉ា

<u>ចម្លងជូន</u> :

-ក្រសួងមហាផ្ទៃ

-ក្រសួងផែនការ

-លេខាធិការដ្ឋាន គ.ជ.អ.ប

-ក្រុមប្រឹក្សាខេត្ត

"ដើម្បីជូនជ្រាប"

-គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

-គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

-ដូចប្រការ ៣

"ដើម្បីជ្រាប និងមុខការ"

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តព្រះវិហារ
លេខ: ០១៥ -សសរ/ក្រប្រ/ទរ

# សេចក្តីសម្រេច
# ស្តីពី
# ការទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិក
# គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្តព្រះវិហារ

## ប្រធានក្រុមប្រឹក្សាខេត្តព្រះវិហារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ។
- បានឃើញអនុក្រឹត្យលេខ ២១៨ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក ។
- យោងតាមប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយនៃសាលាខេត្ត ការបង្កើតការិយាល័យច្រកចេញចូលតែមួយនៃសាលាក្រុង ការបង្កើតការិយាល័យច្រកចេញចូលតែមួយនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ។

- យោងតាមសេចក្តីណែនាំលេខ ០៣៦ សណន ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃ ។
- យោងតាមសេចក្តីជូនដំណឹងលេខ ២៨៩ សជណ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ របស់ក្រសួងមហាផ្ទៃ ។
- យោងតាមស្មារតីនៃកិច្ចប្រជុំសាមញ្ញលើកទី ២៦ក្រុមប្រឹក្សាខេត្តអាណត្តិទី១ នាថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ ។

## សម្រេច:

**ប្រការ១** : ត្រូវបានទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្តព្រះវិហារ ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ០១-ឯកឧត្តម | **អ៊ុំ ម៉ារ៉ា** | អភិបាលខេត្ត | ជាប្រធាន |
| ០២-លោក | **ស៊ុយ សេរិទ្ធ** | អភិបាលរងខេត្ត | អនុប្រធាន |
| ០៣-លោក | **ខុយ ឃុនហ៊ី** | នាយករដ្ឋបាលសាលាខេត្ត | សមាជិកអចិន្ត្រៃយ៍ |
| ០៤-លោកជំទាវ | **ចឹក ហេខ** | សមាជិកក្រុមប្រឹក្សាខេត្ត | សមាជិក |
| ០៥-ឯកឧត្តម | **នខ ចន** | សមាជិកក្រុមប្រឹក្សាខេត្ត | សមាជិក |
| ០៦-ឯកឧត្តម | **ស៊ាខ សួនធឿន** | សមាជិកក្រុមប្រឹក្សាខេត្ត | សមាជិក |
| ០៧-លោក | **មាស រដ្ឋាទុឌ្ឍ** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ០៨-លោក | **ផាន់ សំអាន** | ប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ០៩-លោក | **នួន សុវណ្ណ** | ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ១០-លោក | **ខែន សារ៉ុម** | ប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |
| ១១-លោក | **ចាន់ ស៊ីន** | ប្រធានមន្ទីរផែនការ | សមាជិក |
| ១២-លោក | **សេខ សារី** | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៣-លោកស្រី | **ឡិ សុខុម** | ប្រធានមន្ទីរកិច្ចការនារី និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុមប្រឹក្សាខេត្ត | សមាជិក |
| ១៤-លោក | **ខុយ ឃុនចន្ទរ័ត្ន** | ប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ១៥-លោកស្រី | **ខុយ ម៉ិនថាវ្លី** | ប្រធានមន្ទីរសុខាភិបាល | សមាជិក |
| ១៦-លោក | **រ៉ាត់ សោភា** | ប្រធានមន្ទីរព័ត៌មាន | សមាជិក |
| ១៧-លោក | **គង់ សោភ័ណ** | ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី | សមាជិក |
| ១៨-លោក | **ហាន ឆន** | ប្រធានមន្ទីរអប់រំយុវជន និងកីឡា | សមាជិក |

| | | | |
|---|---|---|---|
| ១៩-លោក | ឃួន សេងភេង | ប្រធានមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា - ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ២០-លោក | គង់ វិបុល | ប្រធានមន្ទីរទេសចរណ៍ | សមាជិក |
| ២១-លោក | មាស ណារិទ្ធ | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ២២-លោក | ពីង ឡើជា | ប្រធានមន្ទីរកសិកម្ម | សមាជិក |
| ២៣-លោក | ជា សុផល | ប្រធានសាខាពន្ធដារខេត្ត | សមាជិក |
| ២៤-លោក | ហួន គា | ប្រធានមន្ទីរធម្មការ និងសាសនា | សមាជិក |
| ២៥-លោក | នូ សំអឿន | ប្រធានធនាគារខេត្ត | សមាជិក |
| ២៦-លោក | មុយ ចាន់ពេញ | ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | សមាជិក |
| ២៧-លោក | ចាប កុយ | ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ២៨-លោក | ប៉ុល ខាំណារ៉េ | នាយខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ | សមាជិក |
| ២៩-លោក | អ៊ាង វណ្ណថា | ប្រធានរតនាគារខេត្ត | សមាជិក |
| ៣០-លោក | នៅ សុគុណា | ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៣១-លោក | គង់ មករា | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៣២-លោក | យុង គីមហ៊ាន | នាយកសាខាកាកបាទក្រហមកម្ពុជាខេត្ត | សមាជិក |
| ៣៣-លោក | តុច វឌ្ឍ | អភិបាលក្រុងព្រះវិហារ | សមាជិក |
| ៣៤-លោក | អ៊ុង វុទ្ធី | អភិបាលស្រុកឆែប | សមាជិក |
| ៣៥-លោក | ថោង សារគឿន | អភិបាលស្រុកជ័យសែន | សមាជិក |
| ៣៦-លោក | ឆាំង យឿត | អភិបាលស្រុកត្បែងមានជ័យ | សមាជិក |
| ៣៧-លោក | ង សារ៉ុ | អភិបាលស្រុករវៀង | សមាជិក |
| ៣៨-លោក | សំ ហេង | អភិបាលស្រុកសង្គមថ្មី | សមាជិក |
| ៣៩-លោក | ជុំ ពុយ | អភិបាលស្រុកគូលែន | សមាជិក |
| ៤០-លោក | សុក ហៃ | អភិបាលស្រុកជាំក្សាន្ត | សមាជិក |
| ៤១-លោក | លឹម សឿ | នាយកទីចាត់ការរដ្ឋបាលសាលាខេត្ត | សមាជិក |
| ៤២-លោក | ខួន សៀង | នាយកទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត | សមាជិក |
| ៤៣-លោក | កែ សេងគីម | នាយកទីចាត់ការហិរញ្ញវត្ថុសាលាខេត្ត | សមាជិក |

| | | | |
|---|---|---|---|
| ៤៤-លោក | **លី ឆៀវឆាន** | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្សសាលាខេត្ត | សមាជិក |
| ៤៥-លោក | **ស្រ៊ុយ សារិទ្ធ** | នាយករងទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ៤៦-លោក | **ឃុត ឃួត** | មេឃុំជាំក្សាន្ត និងជាប្រធានសមាគម ក្រុមប្រឹក្សាឃុំ-សង្កាត់ | សមាជិក |
| ៤៧-លោកស្រី | **សោម សុខុម** | មេឃុំចំរើន និងជាអនុប្រធានសមាគម ក្រុមប្រឹក្សាឃុំ-សង្កាត់ខេត្ត | សមាជិក |

**ប្រការ ២ :** "**គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្តព្រះវិហារ**" មានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត លើកិច្ចការសំខាន់ៗដូចខាងក្រោម :

-ផែនការអភិវឌ្ឍ និងថវិកា ។

-សម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាខេត្ត ជាមួយមន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ននានា ។

-កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពខេត្ត ។

-កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់នៅក្នុងខេត្ត ។

-កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាខេត្តជាមួយក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត ។

-ការងារទាក់ទងមុខងារ និងធនធាន ។

-កិច្ចការមួយចំនួនទៀត ដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាផ្សេងៗ ឬតាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សារបស់ខ្លួន ។

**ប្រការ៣ :** សេចក្តីសម្រេចលេខ ០០៦-សសរ/ក្រប្រ/ទវ ចុះថ្ងៃទី០៤ ខែមីនាឆ្នាំ២០១១ របស់រដ្ឋបាលខេត្តព្រះវិហារ ត្រូវលុបចោលទទួលស្គាល់ ។

**ប្រការ ៤ :** គណៈអភិបាលខេត្ត, នាយករដ្ឋបាល នាយកទីចាត់ការទាំង៥ ចំណុះរចនាសម្ព័ន្ធសាលាខេត្ត, លោក លោកស្រីប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត, លោកអភិបាលក្រុង-ស្រុក និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ ០១ខាងលើត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ព្រះវិហារ ថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១១

**ជ.ក្រុមប្រឹក្សាខេត្ត**

**ប្រធាន**

**ស៊ុន សុវណ្ណ**

**ចម្លងជូន :**

-ក្រសួងមហាផ្ទៃ

-លេខាធិការដ្ឋាន គ.ជ.អ.ប

"ដើម្បីជូនជ្រាប"

-ដូចក្នុងប្រការ ០៣

"ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តព្រះវិហារ**

លេខ : ០១៤ -សសរ/ក្រប្រ/ទរ

## សេចក្តីសម្រេច
## ស្តីពី
## ការទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិក
## គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុមប្រឹក្សាខេត្តព្រះវិហារ

## ប្រធានក្រុមប្រឹក្សាខេត្តព្រះវិហារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ។
- យោងតាមប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាក្រុង ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ ។
- យោងតាមប្រកាសលេខ ៤២៧៥ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

- យោងតាមសេចក្តីជូនដំណឹងលេខ ១៤៧ សជណ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ របស់ក្រសួងមហាផ្ទៃ ។
- យោងតាមស្មារតីនៃកិច្ចប្រជុំសាមញ្ញលើកទី ២៦ក្រុមប្រឹក្សាខេត្តអាណត្តិទី១ នាថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១ ។

**សម្រេច:**

**ប្រការ ១** : ត្រូវបានទទួលស្គាល់ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាខេត្តព្រះវិហារ ដូចមានរាយនាមខាងក្រោម :

| | | | |
|---|---|---|---|
| ០១-លោកជំទាវ | **មុយ ច័ន្ទថន** | សមាជិកក្រុមប្រឹក្សាខេត្ត | ជាប្រធាន |
| ០២-ឯកឧត្តម | **សុខ ម៉ិនលាង** | សមាជិកក្រុមប្រឹក្សាខេត្ត | អនុប្រធាន |
| ០៣-លោកស្រី | **ខូយ ម៉ិនថាន** | អភិបាលរងខេត្ត | អនុប្រធាន |
| ០៤-លោក | **មុយ ចាន់ពេញ** | ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ០៥-លោកស្រី | **ទ្វិ សុខុម** | ប្រធានមន្ទីរកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| ០៦-លោក | **មុត តិសិទ្ធនា** | នាយករងរដ្ឋបាលសាលាខេត្ត | សមាជិក |
| ០៧-លោក | **ជា សុផល** | ប្រធានសាខាពន្ធដារខេត្ត | សមាជិក |
| ០៨-លោក | **ហួន គា** | ប្រធានមន្ទីរធម្មការ និងសាសនា | សមាជិក |
| ០៩-លោក | **នូ សំអឿន** | ប្រធានធនាគារខេត្ត | សមាជិក |
| ១០-លោក | **ចាប កុយ** | ប្រធានមន្ទីរធនធានទឹក និងឧតុនិយម | សមាជិក |
| ១១-លោក | **គង់ មករា** | ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១២-លោក | **យុង គីមហ៊ាន** | នាយកសាខាកាកបាទក្រហមកម្ពុជាខេត្ត | សមាជិក |
| ១៣-លោកវរសេនីយ៍ឯក | **សំ ស៊ីផុល** | មេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងព្រះវិហារ | សមាជិក |
| ១៤- លោកវរសេនីយ៍ឯក | **ហែម ផល្លី** | មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត | សមាជិក |
| ១៥-លោកស្រីវរសេនីយ៍ទោ | **នៃ សំណាង** | ស្នងការរងនគរបាល | សមាជិក |
| ១៦-លោក | **សឿង សារិត** | អនុប្រធានមន្ទីរអប់រំយុវជន និងកីឡា | សមាជិក |
| ១៧-លោក | **នាយ សោរ៍មុនី** | អនុប្រធានមន្ទីរសុខាភិបាល | សមាជិក |
| ១៨-លោក | **ស្រ៊ុន បូរិន្ទ** | អនុប្រធានមន្ទីរកសិកម្ម | សមាជិក |
| ១៩-លោក | **ម៉ប់ ធីរ៉េត** | អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| ២០-លោក | **សុះ ស៊ីន** | អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២១-លោក | **ហោ គីមឡុង** | អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២២-លោក | **សរ គន្ធា** | អនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២៣-លោកស្រី | **ស្វាយ ច័ន្ទស៊ីសុផា** | អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ២៤-លោកស្រី | **ហែម សុគុណពិសី** | អនុប្រធានមន្ទីរព័ត៌មាន | សមាជិក |
| ២៥-លោក | **ទិញ សត្ថា** | អនុប្រធានមន្ទីរផែនការ | សមាជិក |

| | | | |
|---|---|---|---|
| ២៦-លោក | **ហេង សោភ័ណ្ឌ** | អនុប្រធានមន្ទីរពាណិជ្ជកម្ម | សមាជិក |
| ២៧-លោក | **អ៊ុំ សុបូរិន** | អនុប្រធានមន្ទីរបរិស្ថាន | សមាជិក |
| ២៨-លោក | **សំ សារឿន** | អនុប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី | សមាជិក |
| ២៩-លោក | **ណាយ សារិន** | អនុប្រធានមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា - ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៣០-លោក | **ម៉ៅ ញៀប** | អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៣១-លោក | **នុត សារុធ** | អនុប្រធានរតនាគារខេត្ត | សមាជិក |
| ៣២-លោក | **នុច ខេមរិន្ទ** | នាយរងខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារ | សមាជិក |
| ៣៣-លោក | **រស់ ចាន់ធី** | អនុប្រធានពន្ធនាគារខេត្ត | សមាជិក |
| ៣៤-លោក | **ហោ ប៊ុនឃួរ** | នាយករងទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ៣៥-លោកស្រី | **សោម សុខុម** | មេឃុំចំរើន និងជាអនុប្រធានសមាគម ក្រុមប្រឹក្សាឃុំ-សង្កាត់ខេត្ត | សមាជិក |
| ៣៦-លោក | **ឃូ សុខា** | មន្ត្រីការិយាល័យនៃមន្ទីរទេសចរណ៍ | សមាជិក |

**ប្រការ ២ :** " **គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុមប្រឹក្សាខេត្តព្រះវិហារ** " ដែលហៅកាត់ថា " គ.ក.ស.ក " ក្រុមប្រឹក្សាខេត្តព្រះវិហារ មានភារកិច្ចដូចខាងក្រោម :

-ចូលរួមក្នុងការកសាងចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងដើម្បីធ្វើឱ្យសម្រេចបាននូវសមភាពយេនឌ័រ និងការផ្តល់សេវាផ្សេងៗដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រស្ត្រី យុវវ័យ និងកុមារ ។

-ប្រមូល និងវិភាគព័ត៌មាន និងទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខេត្ត ។

-រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន ដើម្បីបញ្ចូលទៅក្នុងផែនការសកម្មភាព និងថវិការបស់ក្រុមប្រឹក្សាខេត្ត ។

-ចូលរួមក្នុងការរៀបចំតាក់តែង ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាខេត្ត ទាក់ទងនឹងការលើកកម្ពស់ និងការឆ្លើយតបលើបញ្ហាសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ ។

-ស្វែងរកការគាំទ្រពីក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងគណៈកម្មាធិការផ្សេងៗទៀតនៃក្រុម-ប្រឹក្សាខេត្ត ដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ។

-សហការ និងផ្តល់ការគាំទ្រដល់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងការដោះស្រាយបញ្ហា ឬសំណូមពរ ឬសំណើនានាដែលគណៈកម្មាធិការនៃក្រុម-ប្រឹក្សាប្រភេទផ្សេង នោះមិនអាចដោះស្រាយបានក្នុងការអនុវត្តមុខងាររបស់ខ្លួន ។

-លើកសំណើ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្ត ឬគណៈអភិបាលខេត្ត អំពីវិធានការសមស្របនានា ដើម្បីជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងពាក់ព័ន្ធនឹងកិច្ចការស្ត្រី យុវវ័យ និងកុមារ ។

-ស្វែងរក និងទទួលបានរាល់ព័ត៌មានដែលពាក់ព័ន្ធនឹងការងាររបស់គណៈកម្មាធិការ ។

-ជំរុញការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយនានាទាក់ទងនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ ដល់សហគមន៍នានានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ។

-ជំរុញឱ្យមានការប្រមូលព័ត៌មានរបស់សហគមន៍អំពីអ្វីដែលបានកើតមានជាប្រចាំពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ និងមានវិធានការដើម្បីឆ្លើយតប ។

-ស្វែងរកការគាំទ្រ ដើម្បីជំរុញឱ្យស្ត្រីចូលរួមនៅក្នុងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹងការងារអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ។

-លើកយោបល់ និងផ្តល់អនុសាសន៍អំពីការពង្រឹងទំនាក់ទំនង កិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាប្រភេទផ្សេងទៀត មន្ទីរ អង្គភាពពាក់ព័ន្ធនានា អ្នកផ្តល់សេវា អង្គការមិនមែនរដ្ឋាភិបាល ក្រុមអ្នកស្ម័គ្រចិត្ត និងសហគមន៍ ដើម្បីធានាថាសកម្មភាពទាំងឡាយត្រូវបានគាំទ្រដល់ស្ត្រី យុវវ័យ និងកុមារ ។

-ពិនិត្យមើលលើការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពរបស់ស្ត្រី យុវវ័យ និងកុមារ ជាពិសេសដើម្បីកំណត់រកគម្លាតផ្សេងៗនៅក្នុងការទទួលបានសេវានានា និងដើម្បីលើកអនុសាសន៍ក្នុងការដោះស្រាយបញ្ហាទាំងនេះ ។

-រាយការណ៍ជូនក្រុមប្រឹក្សាលើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រ ការបង្កើនសមត្ថភាពដល់ស្ត្រី និងបញ្ហារបស់យុវវ័យ និងកុមារ ។

-គាំទ្រគ្រប់កិច្ចខិតខំប្រឹងប្រែង ដើម្បីកៀរគរមូលនិធិសម្រាប់ការងារសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ។

-បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់ក្រុមប្រឹក្សាខេត្ត ។

**ប្រការ៣** : សេចក្តីសម្រេចលេខ ០០៤-សសរ/ក្រប្រ/ទរ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១១ របស់រដ្ឋបាលខេត្តព្រះវិហារ ត្រូវឈប់ទទួលស្គាល់ ។

**ប្រការ ៤** : គណៈអភិបាលខេត្ត, នាយករដ្ឋបាល នាយកទីចាត់ការទាំង៥ ចំណុះរចនាសម្ព័ន្ធសាលាខេត្ត, លោក លោកស្រីប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត, លោកអភិបាលក្រុង-ស្រុក និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ ០១ខាងលើត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ព្រះវិហារ ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១

**ជ.ក្រុមប្រឹក្សាខេត្ត**

**ប្រធាន**

**ឡុង សុវណ្ណ**

**<u>ចម្លងជូន :</u>**

-ក្រសួងមហាផ្ទៃ

-លេខាធិការដ្ឋាន គ.ជ.អ.ប

**"ដើម្បីជូនជ្រាប"**

-ដូចក្នុងប្រការ ០៣

**"ដើម្បីអនុវត្ត"**

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តព្រះវិហារ

លេខ: ០០១ លផ/ក្រ.ប្រ

ប្រតិទិនការងារសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ខេត្តប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត

I.ការកសាងផែនការអភិវឌ្ឍន៍ខេត្តប្រាំឆ្នាំ

| ល.រ | សកម្មភាព | ពេលវេលា | ទីតាំង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|
| **ដំណាក់កាលទី១: ការត្រៀមរៀបចំសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ខេត្ត** | | | | | | |
| ១.១ | កិច្ចប្រជុំណែនាំ | | | | | |
| | ១.ការរៀបចំប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ | ១៥ មិនា | សាលាខេត្ត | ក្រុមប្រឹក្សា/ក្រុមការងារ | | |
| | ២.ប្រជុំណែនាំស្តីពីការរៀបចំបំពេញតារាង បញ្ហានិងតម្រូវការរបស់អ្នកពាក់ព័ន្ធនានាក្នុងខេត្ត | ២១មិនា | សាលាខេត្ត | ក្រុមការងារ/អ្នកពាក់ព័ន្ធ | | |
| | ៣.ក្រុង ស្រុក មន្ទីរ អង្គភាព អង្គការ វិស័យឯកជន បំពេញតារាង១.១ ដល់ ១.៤ និងផ្ញើមកខេត្តវិញ | ២២.២៤មិនា | មន្ទីរអង្គភាព | ក្រុង ស្រុក មន្ទីរ អង្គភាព អង្គការ វិស័យឯកជន | | |
| | ៤.ចូកសរុបតារាង ១.៥ ដល់ ១.៨ | ២២.២៥ មិនា | មន្ទីរផែនការ | ក្រុមការងារកសាងផែនការ | | |
| ១.២ | រៀបចំគោលការណ៍ណែនាំផ្នែកគោលនយោបាយ | ២២.២៨ មិនា | សាលាខេត្ត | ក្រុមប្រឹក្សា/ក្រុមការងារ | | |
| ១.៣ | ការរៀបចំវឌ្ឍនភាពរបស់ខេត្តក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា | ២១.២៨មិនា | សាលាខេត្ត | មន្ទីរផែនការខេត្ត | | |
| ១.៤ | ការរៀបចំបញ្ជីឯកសារពាក់ព័ន្ធនានា | ២១.២៨មិនា | មន្ទីរផែនការ | ក្រុមការងារកសាងផែនការ | | |
| **ដំណាក់កាលទី២: ការផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍ខេត្ត** | | | | | | |
| | ១.ប្រជុំផ្សព្វផ្សាយព័ត៌មានអំពីការកសាងផែនការអភិវឌ្ឍន៍ខេត្ត | ២៨ មិនា | សាលាខេត្ត | គណៈអភិបាល/ក្រុមការងារ | | |
| **ដំណាក់កាលទី៣: ការកសាងផែនការអភិវឌ្ឍន៍ខេត្ត** | | | | | | |
| ៣.១ | ការវិភាគស្ថានភាពខេត្ត | | | | | |
| | ១.ប្រជុំណែនាំស្តីពីដំណើរការវិភាគស្ថានភាពខេត្ត | ២៩.៣០ មិនា | សាលាខេត្ត | ក្រុមការងារ/អ្នកពាក់ព័ន្ធ | | |

| ល.រ | សកម្មភាព | ពេលវេលា | ទីតាំង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៣.២ | ការរៀបចំក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត | ៣០មីនា.២មេសា | សាលាខេត្ត | ក្រុមការងារកសាងផែនការ | | |
| ៣.៣ | ការរៀបចំយុទ្ធសាស្ត្រតាមជាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ខេត្ត | ៣០មីនា.២មេសា | សាលាខេត្ត | ក្រុមការងារកសាងផែនការ | | |
| ៣.៤ | ការសរសេរសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្ត | ៣០មីនា.៣មេសា | មន្ទីរផែនការ | ក្រុមការងារកសាងផែនការ | | |
| ៣.៥ | កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងបឋមផែនការអភិវឌ្ឍន៍ខេត្ត | ០៤.០៥មេសា | សាលាខេត្ត | ក្រុមការងារ/អ្នកពាក់ព័ន្ធ | | |
| ៣.៦ | ការពិនិត្យ និងផ្តល់យោបល់របស់គណៈអភិបាលខេត្តលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្ត | ០៤.០៥មេសា | សាលាខេត្ត | គណៈអភិបាលខេត្ត | | |
| ៣.៧ | ការពិនិត្យ និងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ខេត្ត | ០៦.០៧មេសា | សាលាខេត្ត | គណៈកម្មាធិការសម្រប សម្រួលបច្ចេកទេស | | |
| **ជំហានទី៤: ការអនុម័តផែនការអភិវឌ្ឍន៍ខេត្ត** | | | | | | |
| ៤.១ | ការងារមុនសម័យប្រជុំក្រុមប្រឹក្សាខេត្ត | | | | | |
| | ១.រៀបចំរបៀបវារៈ សេចក្តីថ្លែងហេតុ លិខិតអញ្ជើញ និងបទបង្ហាញសេចក្តីព្រាងផែនការអភិវឌ្ឍន៍ | ០៦.០៧មេសា | មន្ទីរផែនការ | ក្រុមការងារកសាងផែនការ | | |
| ៤.២ | ការប្រជុំក្រុមប្រឹក្សាខេត្ត | | | | | |
| | ១.ប្រជុំពិនិត្យ ពិភាក្សា និង អនុម័តលើសេចក្តីព្រាងបញ្ចប់ផែនការអភិវឌ្ឍន៍ខេត្ត | ០៧.០៨មេសា | សាលាខេត្ត | ក្រុមប្រឹក្សាខេត្ត | | |
| ៤.៣ | ការងារក្រោយកិច្ចប្រជុំក្រុមប្រឹក្សាខេត្ត | | | | | |
| | ១.ធ្វើការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ និងផ្ញើជូនលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិនិត្យនិងផ្តល់អនុលោមភាព | ០៨.១៣មេសា | សាលាខេត្ត | គណៈអភិបាល/ក្រុមការងារ | | |
| | ២.ធ្វើការកែសម្រួលសេចក្តីព្រាងផែនការអភិវឌ្ឍន៍ តាមយោបល់ក្រសួងមហាផ្ទៃ ដាក់ជូនក្រុមប្រឹក្សា ខេត្តពិនិត្យ និងអនុម័តឡើងវិញ និងចេញសេចក្តីសម្រេចដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ខេត្ត និងដាក់ជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខា | ០៦.១៦ឧសភា | សាលាខេត្ត | គណៈអភិបាល/ក្រុមការងារ | | |
| | ៣.បោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍ ខេត្ត ដើម្បី និង ផ្សព្វផ្សាយជាសាធារណៈ | ១៧.២៥ឧសភា | សាលាខេត្ត | គណៈអភិបាល/ក្រុមការងារ | | |

| ល.រ | សកម្មភាព | ពេលវេលា | ទីតាំង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|
| II.ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | | |
| **ជំហានទី១: ការរៀបចំបញ្ជីគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត** | | | | | | |
| ១.១ | ការកំណត់ និងរៀបចំសំណើគម្រោង | | | | | |
| | ១.ប្រជុំណែនាំដល់ មន្ទីរ អង្គភាព ក្រុង ស្រុក និង ភ្នាក់ងារពាក់ព័ន្ធ ដើម្បីធ្វើការកំណត់គម្រោងដែលត្រូវស្នើឡើង | ១១.១២មេសា | សាលាខេត្ត | ក្រុមការងារកសាងផែនការ | | |
| ១.២ | ការពិនិត្យសំណើគម្រោង | ១៩.២២មេសា | សាលាខេត្ត | ក្រុមការងារកសាងផែនការ | | |
| ១.៣ | ការគណនាអត្ថប្រយោជន៍របស់គម្រោង | ១៩.២២មេសា | សាលាខេត្ត | ក្រុមការងារកសាងផែនការ | | |
| ១.៤ | រៀបចំសេចក្តីព្រាងបញ្ជីសំណើគម្រោងរបស់ខេត្ត | ១៩.២២មេសា | សាលាខេត្ត | ក្រុមការងារកសាងផែនការ | | |
| ១.៥ | កិច្ចប្រជុំពិនិត្យសេចក្តីព្រាងបញ្ជីសំណើគម្រោងខេត្ត | ២៥.២៦មេសា | សាលាខេត្ត | ក្រុមការងារ/អ្នកពាក់ព័ន្ធនានា | | |
| **ជំហានទី២: ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល** | | | | | | |
| ២.១ | ការរៀបចំខ្លឹមសារស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច | ២៥.២៨មេសា | សាលាខេត្ត | ក្រុមការងារ/អ្នកពាក់ព័ន្ធនានា | | |
| ២.២ | ការរៀបចំគម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | ២៥.២៨មេសា | សាលាខេត្ត | ក្រុមការងារកសាងផែនការ | | |
| ២.៣ | ការប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | ២៥.២៨មេសា | សាលាខេត្ត | ក្រុមការងារ/អ្នកពាក់ព័ន្ធនានា | | |
| ២.៤ | ការរៀបចំសិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគខេត្ត | ៣ ឧសភា | សាលាខេត្ត | ក្រុមការងារ/អ្នកពាក់ព័ន្ធនានា | | |
| ២.៥ | ការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគខេត្ត | ៤ ឧសភា | សាលាខេត្ត | ក្រុមការងារកសាងផែនការ | | |
| ២.៦ | ការរៀបចំបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | ៤ ឧសភា | សាលាខេត្ត | ក្រុមការងារកសាងផែនការ | | |
| ២.៧ | ការពិនិត្យនិងផ្តល់យោបល់របស់គណៈអភិបាលខេត្តលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | |
| | ១.រៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល | ៥ ឧសភា | សាលាខេត្ត | គណៈអភិបាលខេត្ត | | |
| ២.៨ | ការពិនិត្យនិងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្តលើសេចក្តីព្រាង កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | |
| | ១.រៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល | ៦ ឧសភា | សាលាខេត្ត | គណៈកម្មាធិការសម្រប | | |

| ល.រ | សកម្មភាព | ពេលវេលា | ទីតាំង | អ្នកទទួលខុសត្រូវ | ថវិកា | ផ្សេងៗ |
|---|---|---|---|---|---|---|
| **ជំហានទី៣: ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត** | | | | | | |
| ៣.១ | ការងាររៀបចំសម្រាប់ការប្រជុំអនុម័តសេចក្ដីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | |
| | ១.រៀបចំ សេចក្ដីថ្លែងហេតុ បង្ហាញអំពីមូលដ្ឋានគតិយុត្តដែលតម្រូវឱ្យមានសម្រាប់ការកសាងកម្មវិធីវិនិយោគ ទម្រង់កម្មវិធីវិនិយោគ ដំណើរការរៀបចំកម្មវិធីវិនិយោគ ចំនួនគម្រោង និង ថវិកានៃកម្មវិធីវិនិយោគតាមវិស័យនីមួយៗ ព្រមទាំងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ។ | ៣.៩ ឧសភា | សាលាខេត្ត | គណៈអភិបាល/ក្រុមការងារ | | |
| ៣.២ | ការងារក្នុងពេលប្រជុំអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | |
| | ១.ប្រជុំពិនិត្យ ពិភាក្សា និង អនុម័តលើសេចក្ដីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | ៩ ឧសភា | សាលាខេត្ត | ប្រធានក្រុមប្រឹក្សាខេត្ត | | |
| ៣.៣ | ការងារក្រោយពេលប្រជុំអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | | |
| | ១.ធ្វើការកែសម្រួល និងដាក់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តជូនប្រធានក្រុមប្រឹក្សាចុះហត្ថលេខានិងរៀបចំសេចក្ដីសម្រេចឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | ១០.១២ឧសភា | សាលាខេត្ត | គណៈអភិបាល/ក្រុមការងារ | | |
| | ២.បោះពុម្ព និង ផ្សព្វផ្សាយសៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | ១២.២៤ឧសភា | សាលាខេត្ត | គណៈអភិបាល/ក្រុមការងារ | | |

ប្រតិទិនការងារកសាងផែនការអភិវឌ្ឍន៍ខេត្តប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តខាងលើ ត្រូវបានក្រុមប្រឹក្សាខេត្តព្រះវិហារ អនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី២៣ នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១១។

ព្រះវិហារ.ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០១១

ជ.ក្រុមប្រឹក្សាខេត្ត

ប្រធាន

ហ៊ួ-សុវណ្ណ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តព្រះវិហារ
លេខ : ០០៩ -សសរ/ក្រប្រ

# សេចក្តីសម្រេច
## ស្តីពី
## គោលការណ៍ណែនាំផ្នែកគោលនយោបាយ សម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តព្រះវិហារ

## ប្រធានក្រុមប្រឹក្សា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៩/៧៥២ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៩ ស្តីពីការតែងតាំងជាអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៤ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តព្រះវិហារអាណត្តិទី ១ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក ។
- យោងតាមប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាក្រុង ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាស្រុក និងការកំណត់តួនាទីភារកិច្ចរបៀបរបបការងារនៃការិយាល័យទាំងនោះ។
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- យោងតាមស្មារតីនៃកិច្ចប្រជុំសាមញ្ញលើកទី២៤ ក្រុមប្រឹក្សាខេត្តអាណត្តិទី១ នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១។

## សម្រេច ៖

**ប្រការ ១..**

សេចក្តីសម្រេចនេះ មានគោលបំណងណែនាំផ្នែកគោលនយោបាយសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ។

**ប្រការ ២..**

ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ត្រូវអនុវត្តទៅតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ប្រការ ៣..**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ត្រូវរៀបចំឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗមួយចំនួនដូចជា ៖

១. ការចែករំលែកព័ត៌មាន
២. តម្លាភាព
៣. សង្គតិភាព និងសុខដុមនីយកម្ម
៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ
៥. ការឆ្លើយតបនឹងតម្រូវការ
៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
៧. ប្រសិទ្ធភាព និងសុក្រឹត្យភាពសេដ្ឋកិច្ច និងសង្គម
៨. ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
៩. ការធានាសមធម៌។

**ប្រការ ៤..**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្ត ត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយដែលគ្របដណ្តប់លើគ្រប់វិស័យអាទិភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងស្របតាមគោលនយោបាយអភិវឌ្ឍន៍ខេត្ត និងគោលនយោបាយអភិវឌ្ឍន៍ជាតិ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិត និងសុខុមាលភាពប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខេត្ត។

ប្រការ ៥..

ស្ថិតក្នុងអាណត្តិ៥ឆ្នាំ ក្រុមប្រឹក្សាខេត្តមានទស្សនៈវិស័យគោលដៅ បន្តអនុវត្តនូវយុទ្ធសាស្ត្រកាត់បន្ថយនូវភាពក្រីក្ររបស់រាជរដ្ឋាភិបាលស្របទៅតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា។ គោលនយោបាយខាងលើនេះ ផ្អែកទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋក្នុងពេលបច្ចុប្បន្ននេះដែលជាមតិយោបល់ពីគ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋ និងគ្រប់ស្ថាប័នដោយធ្វើការសំយោគចេញពីបញ្ហា និងតម្រូវការរបស់គ្រប់ស្ថាប័ននៅថ្នាក់ក្រោមជាតិដែលមានលក្ខណៈតាមបែបប្រជាធិបតេយ្យមានសង្គតិភាពសុខដុមនីយកម្ម និងតម្លាភាពដែលបម្រើឱ្យផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋនៅក្នុងខេត្ត និងប្រើប្រាស់ឱ្យសក្តានុពលធនធានដែលមាននៅក្នុងខេត្ត និងការជួយឧបត្ថម្ភគាំទ្រពីថ្នាក់ជាតិ។ ផែនការអភិវឌ្ឍន៍ខេត្តរយៈពេល៥ឆ្នាំចាប់ពីឆ្នាំ២០១១-២០១៥ មានគោលដៅកាត់បន្ថយនូវភាពក្រីក្រក្នុងខេត្ត។កត្តាចាំបាច់ត្រូវយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍ប្រព័ន្ធគមនាគមន៍ធនធានទឹក អគ្គិសនី ធនធានមនុស្សនិងយកចិត្តទុកដាក់ជា សំខាន់ទៅលើជនក្រីក្រដែលងាយរងគ្រោះឱ្យមានសមភាពសមធម៌ យេនឌ័រធ្វើឱ្យប្រជាពលរដ្ឋមានជីវភាពរស់នៅកាន់តែល្អប្រសើរឡើង កាត់បន្ថយនូវអតុល្យភាពរវាងជនបទ និងទីប្រជុំជន។ ដើម្បីសម្រេចឱ្យបាននូវទស្សនៈគោលនយោបាយដូចខាងលើនេះ គ្រប់ស្ថាប័នទាំងអស់ត្រូវយកចិត្តដាក់ខិតខំជម្រុញការអនុវត្តឱ្យបានទៅលើវិស័យសំខាន់ៗជាច្រើន ដូចខាងក្រោមនេះ :

## ១.ផ្នែកសេដ្ឋកិច្ច

### ១.១ វិស័យកសិកម្ម

ពង្រឹង និងពង្រីកវិស័យកសិកម្មឱ្យមានការរីកចម្រើនបន្ថែមទៀត ដោយពង្រីកផ្ទៃដីបង្កបង្កើនផលឱ្យបាន ៩០.០០០ហិកតា ទិន្នផលជាមធ្យមទូទៅ៣.២តោន/១ហិកតា ដោយបញ្ចូលបច្ចេកវិទ្យាកសិកម្មទំនើបកែប្រែប្រព័ន្ធធារាសាស្ត្រ បង្កើនផ្ទៃដីស្រោចស្រព ពង្រីកផ្ទៃដីដំណាំស្រូវតាមរយៈការធ្វើប្រពលវប្បកម្មដំណាំស្រូវ ដើម្បីបង្កើន ទិន្នផលផលិតកម្មដំណាំស្រូវឱ្យប្រជាពលរដ្ឋមាននិរន្តរភាពស្បៀងអាហារហូបចុកឱ្យបានគ្រប់គ្រាន់ និងកែច្នៃជាអង្ករ សម្រាប់ធ្វើការនាំចេញទៅក្រៅខេត្ត ស្របតាមគោលនយោបាយនាំអង្ករឱ្យបាន១លានតោននៅឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល។ ជាពិសេសក្រៅពីការងារផលិតកម្មដំណាំស្រូវ គឺការយកចិត្តទុកដាក់លើការចិញ្ចឹមសត្វគ្រប់ប្រភេទ សម្រាប់បម្រើជីវភាពរស់នៅ ធ្វើជាកម្លាំងអូសទាញ និងបង្កើនប្រាក់ចំណូលបន្ថែម។ ទន្ទឹមនឹងនេះ ការថែរក្សា ធនធានជលផល ពង្រីកវារីវប្បកម្ម លក្ខណៈគ្រួសារឱ្យធ្វើយ៉ាងណាបានគ្រប់ភូមិ ឃុំ ដើម្បីធានាឱ្យបាននូវនិរន្តរភាព ធនធានធម្មជាតិនៅក្នុងខេត្ត ជាពិសេសការពារព្រៃលិចទឹកតាមតំបន់ដងស្ទឹង និងតំបន់ស្រះជំរកត្រីធម្មជាតិតាមរយៈ ការបង្កើតជាសហគមន៍ការពារស្រះជំរកត្រី និងព្រៃឈើបម្រុងទុកជាសាធារណៈរបស់រដ្ឋ ធ្វើយ៉ាងណាឱ្យបាន៦០% ស្របតាមគោលនយោបាយថ្នាក់ជាតិ ។

### ១.២ ធនធានទឹក និងឧតុនិយម

ស្របតាមគោលនយោបាយថ្នាក់ជាតិ បន្តជម្រុញការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក និងការអនុវត្ត អនុត្តរភាពប្រព័ន្ធធារាសាស្ត្រតាមរយៈការកសាង និងស្តារប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ដើម្បីឆ្លើយតបទៅនិង តម្រូវការទឹកបន្ទាន់សម្រាប់ការងារកសិកម្ម គ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ។ ផ្តល់អាទិភាពដល់ ការងារស្តារ និងសាងសង់អាងតំកល់ទឹក ស្រះទឹក ប្រឡាយនាំទឹក និងប្រព័ន្ធដោះទឹក ដើម្បីធានាដល់ការផ្គត់ផ្គង់ទឹកដល់ផ្ទៃដីបង្កបង្កើនផល មច្ឆវប្បកម្ម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងសត្វពាហនៈ ។ ជម្រុញការរៀបចំច្បាប់បទប្បញ្ញត្តិ និងចីរភាពទឹក ។ គ្រប់គ្រងព័ត៌មាន និងផ្សព្វផ្សាយអំពីច្បាប់ស្តីពីធនធានទឹក និងឧតុនិយម ។ ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍធនធានមនុស្ស ។ បង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីជម្រុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រង ថែរក្សាប្រភពទឹក និងប្រព័ន្ធធារាសាស្ត្រឱ្យមាននិរន្តរភាព ដើម្បីចូលរួមចំណែកការបន្ថយភាពក្រីក្រនៅជនបទ ។ បន្តសហការ និងស្វែងរកដៃគូអភិវឌ្ឍន៍សង្គមស៊ីវិលដើម្បីជួយគាំទ្រលើវិស័យធនធានទឹក ។ ជម្រុញការអភិវឌ្ឍកសិកម្មតាមរយៈការបន្តតាមដានកំរិតទឹកភ្លៀង និងកំរិតទឹក ស្ទឹងប្រចាំឆ្នាំ ដើម្បីត្រៀមបង្ការគ្រោះមហន្តរាយធម្មជាតិ ។

### ១.៣ ឧស្សាហកម្មរ៉ែ និងថាមពល

យកចិត្តទុកដាក់ពង្រីក និងគ្រប់គ្រងឱ្យបានល្អនូវមូលដ្ឋានសិប្បកម្ម អាជីវកម្មនៅក្នុងខេត្ត ដើម្បីគាំទ្រដល់ការកែច្នៃ កសិផលសម្រាប់ហូបចុក នាំចេញ និងកែច្នៃ គ្រប់គ្រងធ្វើអាជីវកម្មធនធានរ៉ែសម្រាប់បង្កើនចំណូលក្នុងខេត្ត ។ ជម្រុញកិច្ចសហការជាមួយក្រុមហ៊ុន ឬវិស័យឯកជនលើការងារសិប្បកម្មដោយធ្វើការផ្សព្វផ្សាយ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រសហគ្រាសឧស្សាហកម្មសិប្បកម្មធុនតូចនិងមធ្យម ច្បាប់ស្តីពីការធ្វើអាជីវកម្ម ធនធានរ៉ែ និងច្បាប់ស្តីពីថាមពលអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបានទូលំទូលាយ ។ យកចិត្តទុកដាក់ និងពង្រីកការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋឱ្យបានជាអតិបរមាតាមរយៈការស្វែងរកដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ។ បង្កើនការផ្គត់ផ្គង់អគ្គិសនីឱ្យបានគ្រប់ទីប្រជុំជន និងជនបទដែលមានតម្លៃសមស្របទៅតាមជីវភាពរស់នៅបច្ចុប្បន្ន ។ ជម្រុញឱ្យមានការចូលរួមវិនិយោគពីផ្នែកឯកជនក្នុងវិស័យថាមពលរួមមានការផលិតការបញ្ជូននិងការចែកចាយជាដើម ។

### ១.៤ សាធារណការ និងដឹកជញ្ជូន

បន្តការអភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន តាមរយៈការផ្សព្វផ្សាយអំពីការប្រើប្រាស់ផ្លូវថ្នល់ និងច្បាប់ចរាចរផ្លូវគោក ការសាងសង់ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍ ជាពិសេសផ្លូវដែលតភ្ជាប់ពីទីប្រជុំជនទៅជនបទសម្រាប់ផ្សារភ្ជាប់សេដ្ឋកិច្ចជនបទនិងទីផ្សារ ដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋធ្វើជាផ្លូវយុទ្ធសាស្ត្រសម្រាប់ចរាចរសេដ្ឋកិច្ចអន្តរជាតិ ។

### ១.៥ គមនាគមន៍ និងទូរគមនាគមន៍

ផ្អែកតាមគោលនយោបាយថ្នាក់ជាតិ ពង្រីកសេវាកម្មប្រៃសណីយ៍ និងកាត់បន្ថយថ្លៃដោយធ្វើការអភិវឌ្ឍ

និងផ្តល់ព័ត៌មាន ស្តីពីកាលានុវត្តភាពនៃការវិនិយោគដល់វិនិយោគិន ទាក់ទងនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ ពង្រីកបណ្តាញទូរគមនាគមន៍គ្រប់ប្រភេទសម្រាប់ទំនាក់ទំនងពាណិជ្ជកម្ម ដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ចខេត្ត។

### ១.៦ ពាណិជ្ជកម្ម

បង្កើនការគ្រប់គ្រង និងអភិវឌ្ឍន៍ទីផ្សារ រៀបចំពិព័ណ៌ផលិតផលពាណិជ្ជកម្មប្រចាំឆ្នាំ ដើម្បីស្វែងរកទីផ្សារផលិតផល បង្កើនបរិមាណ គុណភាពផលិតផល កសិផល សិប្បកម្មកែច្នៃដើម្បីនាំចេញ ផ្សព្វផ្សាយច្បាប់ ផ្តល់ព័ត៌មានពាណិជ្ជកម្មតំលៃលើទីផ្សារតាមប្រព័ន្ធព័ត៌មានទីផ្សារអេឡិចត្រូនិច (EMCS) ផ្តល់គោលនយោបាយបើកទូលាយទីផ្សារដល់វិនិយោគ ធុរៈកិច្ចអនុញ្ញាតផ្តល់សេវាដល់មូលដ្ឋានការធ្វើអាជីវកម្មសេវាកម្ម ពង្រឹងប្រសិទ្ធិភាពនៃការត្រួតពិនិត្យទីផ្សារ ដើម្បីការពារសុខភាព និងសុខុមាលភាពអ្នកប្រើប្រាស់។

### ១.៧ ទេសចរណ៍

ពង្រីក និងពង្រឹងការអភិវឌ្ឍន៍ផលិតផលទេសចរណ៍នៅក្នុងខេត្ត តាមរយៈដៃគូអភិវឌ្ឍន៍នានា និងការរៀបចំសហគមន៍ទេសចរណ៍មូលដ្ឋាន ដើម្បីធ្វើឱ្យខេត្តក្លាយជាគោលដៅទាក់ទាញទេសចរ ។ ជម្រុញការផ្សព្វផ្សាយពីផលិតផលទេសចរណ៍ សិក្សាទីផ្សារទេសចរណ៍ ជម្រុញសកម្មភាពចលនាប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាតសេវាល្អ។ សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធដើម្បីធានាបានសន្តិសុខសុវត្ថិភាពជូនភ្ញៀវទេសចរ លើកស្ទួយតម្លៃនៃវប្បធម៌ប្រពៃណីជាតិ និងការគ្រប់គ្រងអភិវឌ្ឍន៍លើប្រភពធនធានប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយជាតិលើវិស័យទេសចរណ៍ ផ្តល់ឱកាសការងារធ្វើដល់ប្រជាពលរដ្ឋដោយផ្ទាល់ និងប្រយោល ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍ ។

### ១.៨ វិស័យឯកជន

យកចិត្តទុដាក់បង្កើនការទំនាក់ទំនង និងសហប្រតិបត្តិការជាមួយវិស័យឯកជន សង្គមស៊ីវិលដើម្បីលើកកម្ពស់ការវិនិយោគគ្រប់វិស័យក្នុងខេត្ត សំដៅរួមចំណែកក្នុងការអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយវឌ្ឍនភាព និងបង្កើតឱកាសការងារសម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ។

## ២.ផ្នែកសង្គមកិច្ច

### ២.១ អប់រំយុវជន និងកីឡា

ស្របតាមគោលនយោបាយជាយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រជាតិ រួមមានការបង្កើនសមធម៌នៃការចូលរៀន ដោយយកចិត្តទុកដាក់បង្កើនចំនួនសាលារៀន ចាប់ពីសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ និងជម្រុញកុមារគ្រប់អាយុឱ្យបានចូលរៀនគ្រប់ៗគ្នា ពិសេសកុមារតូច។ សារំកេលម្អគុណភាព និងប្រសិទ្ធភាពសេវាអប់រំដោយយកចិត្តទុកដាក់លើវឌ្ឍនភាពសំខាន់ៗលើកម្មវិធីមួយចំនួនដូចជាកម្មវិធីសាលាកុមារមេត្រី កម្មវិធីសិក្សា និងការវាយតម្លៃសិក្សា និងត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ជាពិសេសលើការអភិវឌ្ឍន៍កុមារតូចៗ ការកាត់បន្ថយអត្រាបោះបង់ការសិក្សា។ ទន្ទឹមនេះដែរខេត្ត ជម្រុញការយកចិត្តទុកដាក់ពង្រីកហេដ្ឋារចនាសម្ព័ន្ធឱ្យមានភាពងាយស្រួល អនុគ្រោះដល់សិស្សានុសិស្សក្រីក្រនៅ ជនបទ , ពង្រឹងគុណភាព

វិស័យអប់រំសម្រាប់យើងទាំងអស់គ្នា ផ្តល់សមធម៌ក្នុងការអប់រំធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋម្នាក់ៗអាចបញ្ចប់ការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំស្របទៅតាមគោលដៅទី៣នៃសហវត្សរ៍កម្ពុជា ផ្តល់បច្ចេកទេសវិជ្ជាជីវៈ និងលុបបំបាត់អនក្ខរភាព យកចិត្តទុកដាក់លើការអភិវឌ្ឍន៍ធនធានមនុស្ស។

## ២.២ សុខាភិបាល

ផ្អែកលើផែនការយុទ្ធសាស្ត្រជាតិក្នុងវិស័យសុខាភិបាល លើកកំពស់សុខភាពបន្តពូជ មាតា ទារក និងកុមារ យកចិត្តទុកដាក់បង្ការទប់ស្កាត់ជម្ងឺឆ្លង និងបញ្ហាសុខភាពដទៃទៀត។ លើសពីនេះទៀត លើកកំពស់ការគ្រប់គ្រងសីលធម៌វិជ្ជាជីវៈ ពង្រឹងគុណភាពសុខាភិបាល ផ្តល់សេវាសុខភាពប្រកបដោយសមធម៌ដល់ ប្រជាពលរដ្ឋទូទៅ ជាពិសេសជនងាយរងគ្រោះ ជនក្រីក្រ ស្ត្រី និងកុមារ។ កាត់បន្ថយអត្រាមរណៈភាពមាតាពេលសំរាលនិងអត្រាមរណៈភាពកុមារដោយជំរុញឱ្យទទួលយកសេវាសំរាលកូនដោយឆ្មបពេទ្យ ។បន្តការចាក់វ៉ាក់សាំងការពារជំងឺ៨មុខដល់កុមារ ការពារការរីករាលដាលនៃមេរោគអេដស៍ ជំងឺអេដស៍ ផ្សព្វផ្សាយពីសុខភាពអនាម័យ អប់រំណែនាំពីវិធានការការពារសុខភាព និងជំរុញប្រជាពលរដ្ឋ ដែលរស់នៅជនបទឱ្យមានទំលាប់ប្រើប្រាស់ទឹកស្អាត និងបង្គន់អនាម័យឱ្យបានគ្រប់គ្រួសារ។ ជាងនេះទៀត បន្តជម្រុញការអភិវឌ្ឍមណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព តាមបណ្តោយព្រំដែន ដើម្បីពង្រឹងសុវត្ថិភាពសុខភាពប្រជាពលរដ្ឋ។

## ២.៣ យេនឌ័រ

យកចិត្តទុកដាក់លើកកំពស់សមភាព សមធម៌យេនឌ័រ ដោយបង្កើនជីវភាពរស់នៅដល់ស្ត្រី ការថែទាំសុខភាព ផ្តល់ការអប់រំចំណេះដឹងជំនាញវិជ្ជាជីវៈដល់ស្ត្រី កាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ ទប់ស្កាត់ការចាប់រំលោភផ្លូវភេទ អប់រំពីការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ជួយការពារផ្តល់អនុសាសន៍ផ្នែកផ្លូវច្បាប់ដល់ស្ត្រី ជម្រុញលើកទឹកចិត្តឱ្យស្ត្រីមានសេចក្តីក្លាហាន និងមានសមត្ថភាពចូលរួមក្នុង ការងារអភិវឌ្ឍន៍សង្គម និង ធ្វើសេចក្តីសំរេចចិត្តឱ្យបានច្រើនថែមទៀតនៅគ្រប់ស្ថាប័ន និងគ្រប់មូលដ្ឋាននៅជនបទ។

## ២.៤ ភាពក្រីក្រ

ជម្រុញកាត់បន្ថយនូវភាពក្រីក្រឱ្យបានច្រើនជាអតិបរមាក្នុងមួយឆ្នាំៗ ដោយយកចិត្តទុកដាក់ដល់ជនងាយរងគ្រោះមាន ស្ត្រីមេម៉ាយ ជនពិការ កុមារកំព្រា ចាស់ជរាគ្មានទីពឹង និងអ្នកផ្ទុកមេរោគអេដស៍។ ផ្តល់ដីសម្បទានសង្គមកិច្ចដល់អ្នកគ្មានដីសំរាប់សាងសង់លំនៅដ្ឋាន និងកសិកម្ម ផ្តល់ផលប្រយោជន៍ពីការអភិវឌ្ឍន៍ដោយផ្តល់ប័ណ្ណសមធម៌ដើម្បីទទួលបានសេវាផ្សេងៗជាពិសេសសេវាថែទាំសុខភាព និងសេវាអប់រំសំរាប់គ្រួសារ។ ធ្វើការបណ្តុះ-បណ្តាលវិជ្ជាជីវៈ និងបង្កើតមុខរបរ ដល់ជនក្រីក្រ។

## ២.៥ សាសនា

លើកកម្ពស់ការគោរពជំនឿសាសនា គ្រប់ប្រភេទដោយស្ម័គ្រចិត្ត និងយកចិត្តទុកដាក់គ្រប់គ្រង និងអភិវឌ្ឍន៍ផ្តល់សេវាសាសនាប្រកបដោយសីលធម៌ និងគុណធម៌ខ្ពស់ ជាពិសេសព្រះពុទ្ធសាសនាដែលជាសាសនារបស់ជាតិ។

### ២.៦ ស្ថានភាពអន្តោប្រវេសន៍

បង្កើនភាពជាដៃគូរក្នុងការវិនិយោគនៅក្នុងខេត្តឱ្យបានច្រើនថែមទៀត ដើម្បីពង្រីកមុខរបរឱ្យប្រជាជនធ្វើឱ្យបានច្រើន កាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ។

## ៣.ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិបរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ៣.១ ការគ្រប់គ្រងដីធ្លី

ពង្រឹងការគ្រប់គ្រង និងបែងចែកការប្រើប្រាស់ដីធ្លី ដោយជំរុញការបោះព្រំប្រទល់ព្រៃបំរុងទុករបស់រដ្ឋ ការរៀបចំដែនទេសាទ ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជាប្រព័ន្ធដល់ប្រជាពលរដ្ឋឱ្យបានគ្រប់គ្រួសារ និងអប់រំផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុតិដល់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយទំនាស់ដីធ្លី សំដៅបង្កើតកំណើនសេដ្ឋកិច្ចគ្រួសារ និងសហគមន៍ ។

### ៣.២ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

ពង្រឹងការគ្រប់គ្រង និងថែរក្សា ការពារធនធានធម្មជាតិ ធនធានរ៉ែ ព្រៃឈើ សត្វព្រៃ ធនធានជលផល ព្រៃលិចទឹក ការស្តារបឹងធម្មជាតិឱ្យបានគង់វង្ស ធានានូវការប្រើប្រាស់ប្រកបដោយចីរភាព និងកាត់បន្ថយការបំផ្លិចបំផ្លាញធនធានធម្មជាតិ និងការបំពុលបរិស្ថានឱ្យបានជាអតិរមាតាមរយៈការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យជួយថែរក្សាព្រៃឈើ និងដាំដើមឈើឡើងវិញ។ គ្រប់គ្រង និងថែរក្សានិរន្តរភាព បរិស្ថាន តាមរយៈការផ្សព្វផ្សាយអំពីផលប៉ះពាល់បរិស្ថានដែលបណ្តាលមកពីការប្រើប្រាស់ថ្នាំពុលកសិកម្ម ការចោល សម្រាម ឬកាកសំណល់រឹងរាវដោយគ្មានសណ្តាប់ធ្នាប់ និងការប្រើប្រាស់បង្គន់អនាម័យ ។

### ៣.៣ គ្រោះមហន្តរាយ និងការប្រែប្រួលធាតុអាកាស

ធ្វើការតាមដាន និងសិក្សាអំពីស្ថានភាពនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ដើម្បីចាត់វិធានការធ្វើផែនការត្រៀមបង្ការ ត្រៀមបំរុងនូវទីទួលសុវត្ថិភាព ថវិកា សំភារៈ ស្បៀងអាហារ មធ្យោបាយដឹកជញ្ជូន ដើម្បីជួយសង្គ្រោះឱ្យបានទាន់ពេលវេលាដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ ។ គ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព ដើម្បីទប់ទល់នឹងគ្រោះធម្មជាតិពីការប្រែប្រួលអាកាសធាតុ ជាពិសេសគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលតែងតែកើតមាននៅតាមដងស្ទឹងនានា និងតំបន់ទំនាប ។ ធ្វើផែនការបញ្ចៀសទឹកជំនន់ កាត់បន្ថយការខូចខាតដល់ភោគផលដំណាំទ្រព្យសម្បត្តិ ផ្ទះសំបែងរបស់ប្រជាពលរដ្ឋ ។

## ៤.ការគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សង្គម

លើកកំពស់ការគ្រប់គ្រងរដ្ឋបាលតាមរយៈអភិបាលកិច្ចល្អនៅគ្រប់ថ្នាក់រដ្ឋបាលខេត្ត ដើម្បីកាត់បន្ថយពេលវេលាពិនិត្យឯកសារ និងចំណាយរត់ការក្រៅផ្លូវច្បាប់ ។ បង្កើនការគ្រប់គ្រងកំណត់ព្រំប្រទល់រដ្ឋបាល ឱ្យបានច្បាស់ កំណត់បង្កើតភូមិថ្មីស្របតាមផ្លូវច្បាប់ធ្វើការរៀបចំប្លង់គោលឱ្យបានត្រឹមត្រូវ និងជំរុញការចុះបញ្ជីអត្រានុកូលដ្ឋាន ធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋប្រើប្រាស់បានគ្រប់១គ្នា ។

លើកកំពស់ការអនុវត្តន៍គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដើម្បីលប់បំបាត់ការជួញដូរគ្រឿងញៀន អំពើចោរកម្ម អំពើហឹង្សា ការជួញដូរមនុស្ស ការចាប់រំលោភផ្លូវភេទ ល្បែងស៊ីសង ក្មេងទំនើង បទល្មើសផ្សេងៗ និងជំរុញការគោរពការអនុវត្តន៍ច្បាប់ចរាចរ ។

**ប្រការ ៦.-**

ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ត្រូវផ្តល់ឱកាសឱ្យបានពេញលេញដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីចូលរួមនៅក្នុងដំណើរការទាំងមូលរួមមាន គណៈអភិបាលខេត្ត មន្ទីរ អង្គភាពជំនាញជុំវិញខេត្ត, ទីចាត់ការចំណុះសាលាខេត្ត, សាលាក្រុង-ស្រុក, ក្រុមប្រឹក្សាឃុំ-សង្កាត់, អង្គការ សង្គមស៊ីវិល, វិស័យឯកជន ជាពិសេសក្រុមហ៊ុនឯកជននានា សហគ្រាសធុនតូច និងមធ្យម, ប្រជាពលរដ្ឋ, ក្រុមតំណាងផលប្រយោជន៍ , ក្រុមជនងាយរងគ្រោះ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។

**ប្រការ ៧.-**

គណៈអភិបាលខេត្ត, នាយករដ្ឋបាល នាយកទីចាត់ការទាំង ៥ ចំណុះរចនាសម្ព័ន្ធសាលាខេត្ត, លោកអភិបាលក្រុង-ស្រុក និងលោក លោកស្រីប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ព្រះវិហារ ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១១

ជ. ក្រុមប្រឹក្សាខេត្ត

ប្រធាន

ឡុង សុវណ្ណ

*ចម្លងជូន :*

- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- លេខាធិការដ្ឋាន (គ.ជ.អ.ប)

" **ដើម្បីជូនជ្រាប** "

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុមប្រឹក្សាខេត្ត
- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត
- ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដូចក្នុងប្រការ៧

" **ដើម្បីមុខការ និងអនុវត្ត** "

- ឯកសារ-កាលប្បវត្តិ

## តារាង ២.១៣ តារាងបញ្ហា និងតម្រូវការ ខេត្ត

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| **១. ផ្នែកសេដ្ឋកិច្ច** | | | | | | | |
| **ទេសចរណ៍** | | | | | | | |
| -ការអភិវឌ្ឍន៍ផលិតផល ទេសចរណ៍ | • មិនទាន់អភិវឌ្ឍនទាញយកផលប្រយោជន៍អោយអស់លទ្ធភាពនៅឡើយ ។ | • ខ្វះមធ្យោបាយនិងដៃគូរក្នុងការ អភិវឌ្ឍន៍ដើម្បីទាញយកផលប្រយោជន៍ ពីប្រភព ធនធាន។ | • ផ្តល់មធ្យោបាយ និងរកដៃគូរដើម្បីមានលទ្ធភាពក្នុងការអភិវឌ្ឍន៍ ។ | ✓ | | ខ | ខ |
| -ការពង្រឹងគុណភាព ផលិតផលទេសចរណ៍ | • គុណភាពមិនទាន់មានការទទួលស្គាល់ និងនៅមានកំរិត ។ | • អាស្រ័យលើស្ថានភាពទីតាំង | • ពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋាននានា ។ | ✓ | | ម | ម |
| | | • ការយល់ដឹងនៅមានកំរិត<br>• ផ្អែកលើប្រាក់ចំណូល | • ជម្រុញចលនាប្រឡង ប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ ។ | ✓ | | ទ | ទ |
| -ផ្សព្វផ្សាយពីផលិតផល ទេសចរណ៍ | -នៅមិនទាន់ផ្សព្វផ្សាយបានទូលំទូលាយ ចំពោះ ភ្ញៀវទេសចរ | -ការចងក្រងប្រមូលទិន្នន័យមិនទាន់គ្រប់ជ្រុងជ្រោយ។ | -ចូលរួមផ្សព្វផ្សាយ កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ ។ | | | ខ | ខ |
| | | -មធ្យាបាយផ្សព្វផ្សាយមានកំរិត | -បង្កើនការចងក្រងទិន្នន័យទេសចរណ៍ | | | ម | ម |
| -ការរៀចំកញ្ចប់ទស្សនៈកិច្ច | នៅមិនទាន់បានរៀបចំ | -សម្បទាសេវាកម្មនៅមានកំរិត | -លើកកម្ពស់គុណភាពសេវាកម្ម ទេសចរណ៍ | | | ខ | ខ |
| | | -មិនទាន់មានដៃគូរច្បាស់លាស់ | -ទាក់ទាញរកដៃគូរពិតប្រាកដ | | | ខ | ខ |
| -ការបណ្តុះបណ្តាលធនធាន មនុស្ស | -តម្រូវការចាំបាច់ក្នុងវិស័យទេសចរណ៍ | -ខ្វះធនធាននៅក្នុងការគ្រប់គ្រងវិស័យទេសចរណ៍ | -លើកទឹកចិត្តដល់អ្នកស្ម័គ្រចិត្ត និងបង្កើនការអភិវឌ្ឍន៍ សមត្ថភាព | ✓ | | ម | ម |
| ទេសចរណ៍ | | | -រៀបចំកែលំអបន្ថែម | | ខ | | ខ |
| | | | បណ្តុះបណ្តាលជំនាញបដិសណ្ឋារកិច្ចទទួលភ្ញៀវ | | ខ | | ខ |

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| | | | -រៀបចំកែលំអផ្លូវចូលឱ្យបានសមរម្យ | | ម | | ម |
| | | | -បង្កើតប្រព័ន្ធព័ត៌មានដាក់សញ្ញាជូនដំណឹង | | ម | | ម |
| | | | -អប់រំប្រជាពលរដ្ឋឱ្យយល់ពីសារៈសំខាន់ ពី | | ម | | ម |
| | | | -បង្កើតពង្រឹងគណៈកម្មការគ្រប់គ្រងតំបន់ ទេសចរណ៍ | | ម | | ម |
| | | | -រៀបចំរមណីយដ្ឋានទេសចរណ៍ | | ទ | | ទ |
| **កសិកម្ម** | | | | | | | |
| -ផលិតកម្មដំណាំបន្លែ | -ការដាំដុះមិនស្របតាមបច្ចេកទេស | -ខ្វះការបណ្តុះបណ្តាល | -បណ្តុះបណ្តាលពីបច្ចេកទេស ដាំដុះដំណាំបន្លែ | ✓ | ខ | ខ | **ខ** |
| | -ប្រភពទឹកនៅរដូវប្រាំងមិនគ្រប់គ្រាន់ | -ខ្វះការធ្វើបង្ហាញ | -គំរោងទំនប់ស្ទាក់ទឹកខ្នាត តូចសម្រាប់រដូវប្រាំង | ✓ | ខ | ខ | **ខ** |
| | -ពូជបន្លែផ្តល់ទិន្នផលទាប | -ខ្វះទឹកស្រោចស្រពនៅរដូវប្រាំង | -ជីអណ្តូង | ✓ | ខ | ម | **ខ** |
| | -តំលៃទីផ្សារមិនសមស្រប | -ទិន្នផលបន្លែទាប | -ជីកស្រះជាលក្ខណៈគ្រួសារ | ✓ | ខ | ទ | **ម** |
| -បង្កើនផលិតកម្មដំណាំស្រូវ | -មិនអនុវត្តតាមបច្ចេកទេស | -ពុំទទួលបានការបណ្តុះបណ្តាល បច្ចេកទេសដាំដុះដំណាំស្រូវ | -បណ្តុះបណ្តាលបច្ចេកទេស ដាំដុះដំណាំស្រូវ | ✓ | ខ | ខ | ខ |
| | -ប្រើប្រាស់ពូជពីបុរាណ | -ការផ្សព្វផ្សាយពូជផ្តល់ទិន្នផលខ្ពស់ នៅមានកំរិត | -រៀបចំធ្វើស្រែបង្ហាញពូជ | ✓ | ម | ខ | ខ |
| | -មិនបានប្រើប្រាស់ជីបំប៉ន( ជីគីមី) | -ខ្វះការផ្តល់ពូជសុទ្ធ | -រៀបចំទិវាស្រែបង្ហាញ | ✓ | | ម | ម |
| | -មិនបានសាងសង់រោងសន្សំជី | -ពុំមានការផលិតពូជសុទ្ធនៅតាមមូលដ្ឋាន | -ផ្តល់ពូជស្រូវទិន្នផលខ្ពស់ | ✓ | ខ | ម | ខ |
| | -ប្រើប្រាស់ពូជស្រូវកណ្តាល និងស្រូវធ្ងន់ដែលមិនសមស្របតាមល័កខ័ណ្ឌអាកាសធាតុ | | -រៀបចំឱ្យមានកន្លែងផលិតពូជនៅតាមមូលដ្ឋាន | ✓ | | ម | **ម** |

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| -បង្កើនផលិតកម្មសត្វ | -ការចាក់វ៉ាក់សាំងការពារជម្ងឺនៅមានកំរិតការចិញ្ចឹមមានការថយចុះ | -ពុំបានចាក់វ៉ាក់សាំងការពារ | -យុទ្ធនាការចាក់វ៉ាក់សាំង | ✓ | ខ | ខ | **ខ** |
| | -ការនាំចេញទៅកាន់ទីផ្សារមានតំលៃទាប | -ខ្វះការយល់ដឹងពីបច្ចេកទេសចិញ្ចឹមសត្វ | -ធ្វើការផ្សព្វផ្សាយពីវិធីសាស្ត្រ ការពារនិងថែទាំនៅមូលដ្ឋាន | ✓ | | ខ | **ខ** |
| | -ពុំមានប្រភពទឹកគ្រប់គ្រាន់នៅរដូវប្រាំងសំរាប់សត្វផឹក | -សមត្ថភាពភ្នាក់ងារសុខភាពភូមិ នៅមានកំរិត ពូជសត្វពុំសូវល្អតលាស់ល្អ | -ពង្រឹងសមត្ថភាពបន្ថែមដល់ ភ្នាក់ងារសុខភាពសត្វភូមិធ្វើបង្ហាញពូជគោល្អ | ✓ | ខ | ម | **ខ** |
| | | -ខ្វះចំណីសត្វនៅរដូវប្រាំង | -ផ្សព្វផ្សាយពីអត្ថប្រយោជន៍ នៃការចាក់វ៉ាក់សាំង | ✓ | ទ | ម | **ទ** |
| | | | -ផ្សព្វផ្សាយ និងធ្វើបង្ហាញពី ដំណាំស្មៅចំណីសត្វ | ✓ | | ខ | **ខ** |
| -ជំរុញផលិតផលកសិកម្មទៅកាន់ទីផ្សារ | -ពុំទាន់មានការវេចខ្ចប់ឱ្យបានត្រឹមត្រូវ | -ពុំទាន់មានការបង្កើតសហគមន៍ អភិវឌ្ឍន៍កសិកម្ម | -រៀបចំចងក្រងក្រុមកសិករ ក្លាយជាសហគមន៍ អភិវឌ្ឍន៍ កសិកម្ម | ✓ | ទ | ទ | **ទ** |
| | -ពុំទាន់មានការយល់ដឹងពីបច្ចេកទេសក្រោយប្រមូលផល | -ពុំទាន់មានជំនាញខាងទំនាក់ទំនងទីផ្សារ | -បណ្តុះបណ្តាលជំនាញទីផ្សារ ដល់ក្រុមកសិករ | ✓ | | ម | **ម** |
| | -តំលៃទីផ្សារមិនសម ស្រប | -ខ្វះខាតប្រព័ន្ធព័តមាន ទីផ្សារ | -រៀបចំឱ្យមានប្រព័ន្ធព័តមាន ទីផ្សារពីតំលៃផលិតផលដល់ មូលដ្ឋាន | ✓ | | ខ | **ខ** |
| -កាត់បន្ថយការបាត់បង់ក្រោយប្រមូលផល | -នៅអនុវត្តតាមទំលាប់បុរាណ | -ខ្វះការគ្រប់គ្រងក្នុងពេលប្រមូលផល | -ផ្សព្វផ្សាយពីការបាត់បង់ ក្រោយប្រមូផល | ✓ | | ម | **ម** |
| | | -ពុំមានការបណ្តុះបណ្តាលពីបច្ចេកទេសក្រោយប្រមូលផល | -ធ្វើបង្ហាញពីបច្ចេកទេស ក្រោយប្រមូលផល | ✓ | | ខ | **ខ** |

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| | | | -បណ្ដុះបណ្ដាលពីបច្ចេកទេស ក្រោយប្រមូលផល | ✓ | | ខ | ខ |
| កសិកម្ម | | | -ផ្ដល់បច្ចេកទេសកសិកម្ម | | ខ | | ខ |
| | | | -ផ្ដល់ម៉ាស៊ីនបូមទឹក | | ខ | | ខ |
| | | | -ធ្វើស្រែបង្កើនរដូវ | | ម | | ម |
| | | | -ផ្ដល់ដីសម្បទានដីកសិកម្ម | | ម | | ម |
| | | | -ផ្សព្វផ្សាយឱ្យគាត់យល់ពីការជ្រើសរើសមុខរបរ | | ម | | ម |
| | | | -វគ្គបច្ចេកទេសប្រើប្រាស់ជីគីមី និងថ្នាំសម្លាប់សត្វល្អិត | | ម | | ម |
| | | | -ពង្រីកដីស្រែកសិកម្ម | | ទ | | ទ |
| | | | -វគ្គបច្ចេកទេសកែប្រែគុណភាពដី | | ទ | | ទ |
| ដំណាំផ្សេងៗ | | | - សាងសង់ស្រះស្រោចស្រព | | ខ | | ខ |
| | | | -បណ្ដុះបណ្ដាលបច្ចេកទេសដីកំប៉ុស | | ខ | | ខ |
| | | | -បណ្ដុះបណ្ដាលបច្ចេកទេសដាំដុះដំណាំ | | ម | | ម |
| | | | -ផ្ដល់ពូជដំណាំចំការ | | ម | | ម |
| | | | -ផ្ដល់ពូជបន្លែ | | ម | | ម |
| | | | -ទីផ្សារកសិផល រុក្ខផល | | ម | | ម |
| | | | -ផ្ដល់ពូជឈើហូបផ្លែ | | ទ | | ទ |
| ការងារផលិតកម្ម និងបសុព្យាបាល | | | -បណ្ដុះបណ្ដាលបច្ចេកទេសចិញ្ចឹមសត្វ | | ខ | | ខ |
| | | | - ផ្ដល់ថ្នាំការពារនិងព្យាបាលជម្ងឺសត្វ | | ម | | ម |
| | | | -ផ្ដល់ពូជសត្វ | | ម | | ម |
| | | | -ផ្ដល់សេវាលក់វ៉ាក់សាំងដល់មូលដ្ឋាន | | ម | | ម |
| | | | -ត្រូវមានវិធានការថែទាំសត្វ | | ទ | | ទ |



អក្សរកាត់ : ខ (ខ្ពស់), ម ( មធ្យម ) , ទ (ទាប )

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| | | | -ទប់ស្កាត់ការដុតបំផ្លាញស្មៅនៅរដូវប្រាំង | | ទ | | ទ |
| | | | -បណ្តុះបណ្តាលចំណេះដឹងពីការបន្តពូជសត្វ | | ទ | | ទ |
| | | | -បណ្តុះបណ្តាលឱ្យកសិករយល់ពីស្ថានភាព ជម្ងឺសត្វ និងវិធានការការពារ | | ទ | | ទ |
| | | | -បណ្តុះបណ្តាលពីវិធានការការពារ និងធ្វើបង្ហាញពីការចិញ្ចឹមជ្រូក | | ទ | | ទ |
| ការចិញ្ចឹមត្រី | | | -សាងសង់ស្រះចិញ្ចឹមត្រី | | ខ | | ខ |
| | | | -ផ្តល់វគ្គបច្ចេកទេសចញ្ចឹមត្រី | | ខ | | ខ |
| | | | - ផ្តល់ពូជត្រី | | ម | | ម |
| | | | -បង្កើតសហគមន៍ចិញ្ចឹមត្រី | | ទ | | ទ |
| | | | -បង្កើតឱ្យមានមណ្ឌលពិសោធន៍ | | ទ | | ទ |
| ឥណទានស្រូវ | | | សាងសង់ជង្រុកស្រូវសហគមន៍ | | ម | | ម |
| | | | បង្កើនធនាគារស្រូវតាមសហគមន៍ | | ម | | ម |
| សន្តិសុខស្បៀង<br>-ស្បៀង និងប្រភពចំណូល | | | -បណ្តុះបណ្តាលមុខវិជ្ជាជីវៈ | | ខ | | ខ |
| | | | -ដោះស្រាយផ្តល់ដីគ្រួសារខ្វះខាត | | ម | | ម |
| | | | -បង្កើតមុខរបរបន្ថែម | | ទ | | ទ |
| **ឧស្សាហកម្មរ៉ែ និងថាមពល** | | | | | | | |
| -ផ្គត់ផ្គង់ទឹកស្អាត | -ផ្ទះនៅឃ្លាតឆ្ងាយពីគ្នា<br>-ការប្រើប្រាស់តាមគ្រួសារមានបរិមាណតិច<br>-ចំណាយទុយោច្រើន | -គ្មានក្រុមហ៊ុនមកវិនិយោគ | -ជំរុញការវិនិយោគ | | | ម | ម |
| | | | - រកដៃគូអភិវឌ្ឍន៍ | | | ខ | ខ |

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| -រ៉ែមាន២៥តំបន់ស្មើ១៦ក្រុមហ៊ុន ដែលមាន អាជ្ញាប័ណ្ណសិក្សា | -ក្រុមហ៊ុនមួយចំនួនធ្វើការសិក្សាយឺត | -ខ្វះដៃគូវិនិយោគ | -ធ្វើអាជីវកម្មដែក | | | ម | ម |
| | -លទ្ធផលសិក្សាទទួលបានក៏រិតទាប<br>-ក្រុមហ៊ុនខ្លះពុំដំណើរការ | -គ្មានទុនធ្វើការសិក្សា | -អនុវត្តច្បាប់ | | | ខ | ខ |
| -ថាមពលអគ្គិសនី | -ទីរួមស្រុក ៤ពុំទាន់ដំណើរការ (មានច្បាប់អនុញ្ញាតហើយ) | -ការកសាងបណ្តាញយឺតយ៉ាវ | -ជំរុញការកសាងបណ្តាញ | | ខ | ខ | ខ |
| | | | -ជំរុញការអនុវត្តច្បាប់ | | | ម | ម |
| | | | -រកដៃគូវិនិយោគថ្មី | | ខ | ខ | ខ |
| | | | -ផ្គត់ផ្គង់អគ្គីសនី | | **ម** | | **ម** |
| | | | -តបណ្តាញអគ្គីសនី ដាក់អំពូលភ្លើងសាធារណៈ | | **ទ** | | **ទ** |
| ថ្មភក់ | | | -បណ្តុះបណ្តាលជំនាញ | | **ខ** | | **ខ** |
| | | | -បង្កើសិប្បកម្មកែច្នៃនៅមូលដ្ឋាន | | **ម** | | **ម** |
| | | | -បង្កើតសហគមន៏ការពារថ្មភក់ | | **ទ** | | **ទ** |
| **ពាណិជ្ជកម្ម** | | | | | | | |
| -បន្តសាងសង់អាគាររដ្ឋបាលមន្ទីរពាណិជ្ជកម្មខេត្ត | -ជួលកន្លែងឯកជនធ្វើការបណ្តោះអាសន្ន | -ពុំទាន់មានថវិកាគ្រប់គ្រាន់សម្រាប់សាងសង់ | -ជួយថវិកាសាងសង់ឱ្យបានឆាប់ | | | ខ | ខ |
| -ការរៀបចំពិព័រណ៍ផលិតផលពាណិជ្ជកម្ម ប្រចាំឆ្នាំ | -ផលិតផលពុំទាន់មានទីផ្សារត្រឹមត្រូវ | -ផលិតករខ្វះពត៌មានទីផ្សារ | -ស្វែងរកព័តិមានទីផ្សារដល់ផលិតករ | | | ខ | ខ |
| | | -ផលិតករមិនអាចប្រគួតប្រជែងទីផ្សារបាន | -បញ្ជ្រៀតផលិតផលទៅក្នុងទីផ្សារ | | | ខ | ខ |
| | | -ផលិតរកគ្មានទីផ្សារមិនបានច្បាស់លាស់ | -ជួយស្វែងរកទីផ្សារច្បាស់លាស់ | ✓ | | ខ | ខ |
| | | -តម្លៃផលិតផលពុំមានលំនឹង | -បង្កើតជាសហគមន៏ប្រមូលទិញ | | | ម | ម |
| | | -ខ្វះបច្ចេកទេសក្នុងការផលិត | -បណ្តុះបណ្តាលបច្ចេកទេសក្នុងការផលិត | | | ម | ម |
| | | -ខ្វះសហគមន៏អ្នកផលិត | -បង្កើតសហគមន៏អ្នកផលិត | | | ម | ម |
| | | -ពុំទាន់មានព័តិមានទីផ្សារ | -ស្វែងរកព័តិមានទីផ្សារ | | | ម | ម |



អក្សរកាត់ : ខ (ខ្ពស់), ម ( មធ្យម ) , ទ (ទាប )

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| -សាងសង់មណ្ឌលពិព័រណ៍ដាក់តាំងផលិតផល | -ពុំទាន់មានកន្លែងបណ្ដុំព័ត៌មានទីផ្សារ | -មិនអាចដឹងតម្លៃទំនិញ | -ជួយផ្ដល់ប្រព័ន្ធព័ត៌មានទីផ្សារអេឡិចត្រូនិច | | | ទ | ទ |
| | | -ផលិតផលមានភាពប្រថុយប្រថាន | -ជួយកែលំអរផលិតផលមានភាពត្រឹមត្រូវ | | | ខ | ខ |
| | -ពុំទាន់មានវេទិការធុរៈកិច្ច | -មិនមានអ្នកទទួលខុសត្រូវលើអាជីវកម្ម | -មានត្រូវអ្នកវិនិយោគ | | | ខ | ខ |
| | | -មិនមានអ្នកពិគ្រោះយោបល់ | -ឱ្យមានវេទិការធុរៈកិច្ចពិគ្រោះយោបល់ | | | ម | ម |
| | | -មិនអាចស្វែងរកទីផ្សារបានរហ័ស | -ស្វែងយល់ទីផ្សារបានរហ័សពីប្រព័ន្ធ(EMCS) | | | ទ | ទ |
| -វគ្គបណ្ដុះបណ្ដាលដើម្បីពង្រឹងសមត្ថភាព មន្ត្រី បច្ចេកទេសថ្នាក់ខេត្ត ស្រុក ភ្នាក់ងារ ផ្សព្វផ្សាយផលិតផល និងព័ត៌មាន ទីផ្សារជំរុញផលិតផល នាំចេញ | -ចំណេះដឹងមន្ត្រីនៅមានកម្រិត | -មិនអាចជំរុញផលិតផលបាន | -ជំរុញផលិតផលចូលក្នុងទីផ្សារ | ✓ | | ម | ម |
| | | -មន្ត្រីមិនមានសមត្ថភាពក្នុងជំនាញ | -បណ្ដុះបណ្ដាលមន្ត្រីឱ្យមានសមត្ថភាពក្នុងជំនាញ | | | ខ | ខ |
| | | -មន្ត្រីមិនមានទំនួលខុសត្រូវ | -មន្ត្រីមានជំនាញច្បាស់លាស់ | | | ខ | ខ |
| -ពង្រឹងបច្ចេកទេសផលិត ស្វែងរកទីផ្សារ ដល់អ្នកផលិត ថ្នាក់ក្រុង ស្រុក | -ផលិតករមានចំណេះដឹងតាមកម្រិត | -បច្ចេកទេសផលិតនៅមានកម្រិត | -ផ្ដល់បច្ចេកទេសដល់អ្នកផលិត | ✓ | | ខ | ខ |
| | | -ផលិតករមិនមានទំនុកចិត្តក្នុងការផលិត | -ត្រូវមានទីផ្សារច្បាស់លាស់ | | | ម | ម |
| | | -មិនមានការសម្រេចចិត្តក្នុងការផលិត | -មានការសម្រេចចិត្តខ្ពស់ដល់អ្នកផលិត | | | ទ | ទ |
| -កម្មវិធីការវិភាគប្រព័ន្ធទីផ្សារ | -ផលិតផលមិនចំគោលដៅទីផ្សារ | -មិនដឹងពីតម្រូវការទីផ្សារបានច្បាស់លាស់ | -សិក្សាពីតម្រូវការទីផ្សារ | ✓ | | ខ | ខ |
| -បង្កើតសហគមន៍ទីផ្សារ ផលិតផល លក់រាយ-ដុំ | -មិនទាន់មានកន្លែងប្រមូលផ្ដុំផលិតផល | -មិនមានផលិតផលគ្រប់គ្រាន់ពេលមាន តម្រូវការទីផ្សារ | -បង្កើនការផលិតទៅតាមតម្រូវការទីផ្សារ | ✓ | | ខ | ខ |
| ទីផ្សារ និងការងារ | | | -សាងសង់ផ្សារថ្មី | | ខ | | ខ |
| | | | -ផ្ដល់ធុងសម្រាម | | ទ | | ទ |
| | | | -ពង្រឹងសមត្ថភាពដល់សហគមន៍ក្នុងការធ្វើជំនួញ | | ម | | ម |



អក្សរកាត់ : ខ ( ខ្ពស់ ), ម ( មធ្យម ) , ទ ( ទាប )

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| | | | -ដីបម្រុងទុកសម្រាប់សម្បទានសេដ្ឋកិច្ច ជាង២0.000ហិចតា) | | ម | | ម |
| | | | -សិក្សាការងារទីផ្សារ | | ម | | ម |
| | | | -សាងសង់ផ្សារសម្រាប់ប្រជាពលរដ្ឋលក់ដូរ (ដីបម្រុង ចំនួន ២១ហិចតា) | | ទ | | ទ |
| **ព័តិមាន** | | | | | | | |
| -រដ្ឋបាល | -អាគារទ្រុឌទ្រោម | -ខ្វះអគាររដ្ឋបាល | -សាងសង់អគារមន្ទីរព័ត៌មាន | ✓ | | ខ | ខ |
| -សោតទស្សន៍ | -ទូរទស្សន៍ខ្សែកាបឯកជនពុំមានគ្រប់ស្រុក | - គ្មានស្ថានីយ៍វិទ្យុខេត្ត | -សាងសង់ស្ថានីយ៍វិទ្យុខេត្ត | | | ខ | ខ |
| | | -គ្មានស្ថានីយ៍ទូរទស្សន៍ខេត្ត | -សាងសង់ស្ថានីយ៍ទូរទស្សន៍ខេត្ត | | | ម | ម |
| | | -ខ្វះឧបករណ៍វិទ្យុ និងទូរទស្សន៍ | -បំពាក់ឧបករណ៍វិទ្យុ និងទូរទស្សន៍ | | | ម | ម |
| | | -ស្ថានីយ៍វិទ្យុនិងទូរទស្សន៍ឯកជនមានចំនួនតិច | -ពង្រីកស្ថានីយ៍វិទ្យុនិង ទូរទស្សន៍ឯកជន/ ទូរទស្សន៍ខ្សែកាប | | | ម | ម |
| -បច្ចេកទេស | | -កំលាំងផ្សាយទាប | -បង្កើនកំលាំងផ្សាយអោយគ្របដណ្តប់ទូទាំងខេត្ត | ✓ | | ខ | ខ |
| | | -ខ្វះមន្ត្រីអចិន្ត្រៃយ៍នៅតាមស្រុក | -ដាក់មន្ត្រីអចិន្ត្រៃយ៍គ្រប់ស្រុក | ✓ | | ខ | ខ |
| | | -មន្ត្រីមានចំនួនតិច | -ជ្រើសរើស មន្ត្រីក្រខ័ណ្ឌបន្ថែម | ✓ | | ខ | ខ |
| | | -ពុំមានចំណេះដឹងគ្រប់គ្រាន់ក្នុងការបញ្ជូនព័ត៌មាន | -បណ្តុះបណ្តាល មន្ត្រីព័ត៌មាន និងបច្ចេកទេស | ✓ | | ខ | ខ |
| | | -ខ្វះបច្ចេកទេសក្នុងការរៀបចំព័ត៌មាន | -បង្កើតភ្នាក់ងារចុះយកព័ត៌មាន | ✓ | | ម | ម |

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| | -ពុំទាន់មានមន្ត្រីប្រចាំនៅគ្រប់ស្រុក | -ឧបករណ៍យកព័ត៌មានចាស់ និងមានចំនួនតិច | -ទស្សនកិច្ចសិក្សា | ✓ | | ម | ម |
| | | | -បណ្តុះបណ្តាល មន្ត្រីគ្រប់គ្រងឧបករណ៍ព័ត៌មាន | ✓ | | ខ | ខ |
| | | | -ផ្តល់ និងបន្ថែមម៉ាស៊ីនថតកាមេរ៉ា | ✓ | | ម | ម |
| | | | -បណ្តុះបណ្តាលមន្ត្រីលើការគ្រប់គ្រង សំភារៈបរិក្ខាព័ត៌មាន | ✓ | | ទ | ទ |
| | | | -ជំរុញការចុះយកព័ត៌មាន | ✓ | | ម | ម |
| | | | -ពង្រីកការផ្សព្វផ្សាយព័ត៌មាន | ✓ | | ម | ម |
| ព័ត៌មាន | -ការចុះយកព័ត៌មានពុះទាន់ពេលវេលា | -ខ្វះមធ្យោបាយចុះយកព័ត៌មាន<br>-ធ្វើដំណើរដោយសាររថយន្តគេ | -ផ្តល់មធ្យោបាយសម្រាប់ធ្វើដំណើរចុះយកព័ត៌មាន | | | ខ | ខ |
| **ទីចាត់ការអន្តរវិស័យ សាលាខេត្ត** | | | | | | | |
| ការគ្រប់គ្រងមូលដ្ឋានអាជីវកម្ម និងផលិតកម្មគ្រប់ប្រភេទ | -ការគ្រប់គ្រង មិនច្បាស់លាស់ | -ការបែងចែក ការ គ្រប់គ្រង មិនដាច់ ស្រឡះ | -រៀបចំការគ្រប់គ្រង ឱ្យបានដាច់ស្រឡះជៀសវាង ការជាន់ភារកិច្ចគ្នា | ✓ | | ម | ម |
| ការអភិវឌ្ឍន៍ វិស័យសេដ្ឋកិច្ច និងការប្រកបមុខរបរក្នុងខេត្ត | អ្នកវិនិយោគមិន បានអនុវត្ត ត្រឹមត្រូវតាម កិច្ចសន្យា | -ការអនុវត្តច្បាប់ មានភាពធូរលុង | -ពង្រឹងការអនុវត្តច្បាប់ឱ្យបាន តឹងរឹង | ✓ | | ខ | ខ |
| គោលការណ៍គ្រប់គ្រងទីផ្សារ និងសត្តឃាតដ្ឋាន | -ខ្វះទីតាំងសម្រាប់ ឱ្យអាជីវករលក់ដូរ | -អាជីវករមានការ កើនឡើង | -ពង្រីកទីតាំង និងសាងសង់តូប លក់ដូរបន្ថែម | ✓ | | ខ | ខ |
| | ផ្សារចាស់ទ្រុឌ ទ្រោមខ្វះសោភ័ន ភាព និងអនាម័យ | -គ្មានការស្តាបនា និងជួសជុល | -រៀបចំជួសជុល និងសាងសង់ថ្មី បន្ថែម | ✓ | | ខ | ខ |

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| | -ទីតាំងពិឃាតសត្វ តូចចង្អៀត គ្មានអនាម័យ | -ខ្វះការយកចិត្តទុក ដាក់ | -រៀបចំសាងសង់ ទីតាំងឱ្យបាន ល្អ | ✓ | | ខ | ខ |
| ជំរុញឱ្យមានការវិនិយោគ និងអភិវឌ្ឍន៏វិស័យឯកជននៅក្នុងខេត្ត | -ខ្វះការចាប់ អារម្មណ៍ពីអ្នក វិនិយោគ | -មិនបានធ្វើការ ផ្សព្វផ្សាយឱ្យបាន ទូលំទូលាយ ពី សក្តានុពលរបស់ ខេត្ត | -ធ្វើការផ្សព្វផ្សាយ អំពីសក្តានុពល ដែលខេត្តមាន ដើម្បីទាក់ទាញការវិនិយោគ | ✓ | | ខ | ខ |
| **ទីចាត់ការផែនការ និងវិនិយោគ** | | | | | | | |
| ការគាំទ្រឃុំ សង្កាត់ | - សមត្ថភាពការងាររបស់ក្រុមប្រឹក្សា ឃុំ សង្កាត់មានកំរិតទាប | - ការងារជាច្រើនគ្រប់វិស័យតំរង់ ឆ្ពោះទៅកាន់ឃុំ សង្កាត់ | - បន្ថយទំហំការងារដែលឃុំ សង្កាត់ត្រូវធ្វើតាមរយៈ ការផ្ទេរការងារទៅរកស្រុកក្រុង និង អ្នកពាក់ព័ន្ធ | | | ខ | ខ |
| | - ខ្វះមន្ត្រីមានជំនាញបច្ចេកទេស សិក្សា និងគ្រប់គ្រងគំរោង | - ស្ថានភាពសេដ្ឋកិច្ចសង្គម មានការវិវឌ្ឍន៍ជានិច្ច | - ជ្រើសរើសសមាជិកក្រុម ប្រឹក្សាឃុំសង្កាត់ ស្មៀន ដែល មានសមត្ថភាពសមរម្យ | | | ខ | ខ |
| | - សមាជិកក្រុមប្រឹក្សា ស្មៀនឃុំ សង្កាត់មានការផ្លាស់ប្តូរជាញឹកញាប់ | - លិខិតបទដ្ឋាននានាមានកែ សម្រួលថ្មី | - ផ្សព្វផ្សាយលិខិតបទដ្ឋាន នានាឱ្យបានដល់ឃុំ សង្កាត់ផ្ទាល់ | | | ម | ម |
| | | - ខ្វះការផ្សព្វផ្សាយ បណ្តុះណ្តាលឱ្យបានដល់ ពួកគាត់ | - បណ្តុះបណ្តាលពង្រឹង សមត្ថភាពដល់ក្រុមប្រឹក្សា នានា | | | ខ | ខ |
| ការគាំទ្រក្រុង ស្រុក | - សមត្ថភាពការងាររបសមន្ត្រីស្រុកមាន កំរិតទាប | - ការយល់ដឹងរបស់មន្ត្រីពាក់ព័ន្ធបរិបទ កំណែទំរង់ រដ្ឋបាលថ្នាក់ក្រោមជាតិ | - បណ្តុះបណ្តាលពង្រឹង សមត្ថភាពដល់មន្ត្រីស្រុកក្រុង | | | ខ | ខ |
| ការវិនិយោគខេត្ត | - ខ្វះមន្ត្រីដែលមានសមត្ថភាព ចំណេះដឹង សម្រាប់លើកកម្ពស់ និងជម្រុញការវិនិយោគ ខេត្ត | - លំបាកក្នុងការសហការ និងចុះសិក្សាលទ្ធភាព ជូនក្រុមហ៊ុនវិនិយោគនានា | - បណ្តុះបណ្តាលពង្រឹង សមត្ថភាពមន្ត្រីពាក់ព័ន្ធ ការវិនិយោគថ្នាក់ខេត្ត ក្រុង ស្រុក | | | ខ | ខ |

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការ យេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| | - ខ្វះផ្លូវគមនាគមន៍ដែលមាន សុវត្ថិភាព | - មានការវិនិយោគច្រើន តែសមត្ថភាព មន្ត្រីមានកំរិតទាប មិនទាន់ឆ្លើយតមទៅតាមស្ថានភាពជាក់ស្តែង | - ធ្វើទស្សនៈកិច្ចសិក្សាដក ស្រង់បទពិសោធន៍លើវិស័យ វិនិយោគនេះ ទាំងក្នុប្រទេស និងក្រៅប្រទេស | | | ម | ម |
| | - មិនមានធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រ | | - ផ្សព្វផ្សាយលិខិតបទដ្ឋាន ដែលពាក់ព័ន្ធការ វិនិយោគដល់អ្នកពាក់ព័ន្ធ | | | ម | ម |
| កិច្ចសហការរៀបចំផែនការ | - មិនមានធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រ | - មានការលំបាកក្នុការរៀបចំ ផែនការ | - ផ្សព្វផ្សាយលិខិតបទដ្ឋាន ដែលពាក់ព័ន្ធការ វិនិយោគដល់អ្នកពាក់ព័ន្ធ | | | ខ | ខ |
| | -មន្ត្រីខ្វះសមត្ថភាពចំណេះដឹង និងបទ ពិសោធន៍ផ្នែករៀបចំផែនការនានា | | - បណ្តុះបណ្តាលពង្រឹង សមត្ថភាពមន្ត្រីពាក់ព័ន្ធ ការរៀបចំផែនការ | | | ខ | ខ |
| | - មិនមានធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រ | - ខ្វះការគាំទ្រក្នុងការរៀបចំ ផែនការ | -បណ្តុះបណ្តាលពង្រឹងសមត្ថភាពលើការតាមដាន ត្រួតពិនត្យ និងវាយតម្លៃការអនុវត្ត ផែនការនានា | | | ខ | ខ |
| | | | - ការគាំទ្រទាំងស្មារតី និងហិរញ្ញវត្ថុដល់មន្ត្រី ផែនការ | | | ម | ម |
| -ការកសាងផែនការ | | | -ការសិក្សាគម្រោងអភិវឌ្ឍន៍ | | ខ | ខ | ខ |
| | | | -ពង្រឹងការរៀបចំគ្រប់គ្រងអនុវត្តគម្រោង | | ម | ខ | ខ |
| | | | -ពង្រឹងប្រព័ន្ធការរៀបចំកសាងផែនការមូលដ្ឋាន | | ទ | ខ | ខ |
| | | | -ផ្សព្វផ្សាយអំពីតួនាទីភូមិ ឃុំ | | ទ | | ទ |

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| **ធនធានទឹក និងឧតុនិយម** | | | | | | | |
| ( វិស័យធនធានទឹក ) មានប្រព័ន្ធស្រោចស្រព ល្អគ្រប់គ្រាន់ សម្រាប់ធ្វើការបង្កបង្កើនផល | -ខ្វះទឹកសម្រាប់ស្រោចស្រពក្នុងការបង្កបង្កើនផល | -ទំនប់អាងទឹកខូចធ្លាយមិនអាចស្តុកទឹកទុកបាន | -ជួសជុលទំនប់និងប្រព័ន្ធស្រោចស្រពឡើងវិញ | ✓ | ខ | ខ | ខ |
| | | -ប្រឡាយគោករាក់មិនអាចនាំទឹក ស្រោចស្រពក្នុងការបង្កបង្កើនផល | -ស្តារប្រឡាយ និងប្រព័ន្ធចែកចាយទឹកឡើងវិញ | | ខ | ខ | ខ |
| មានសហគមន៍កសិករ ប្រើប្រាស់ទឹក | -ខ្វះការគ្រប់គ្រង និងថែទាំ-ប្រព័ន្ធធារាសាស្ត្រ | -ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រមិនច្បាស់លាស់ | -បង្កើតសហគមន៍កសិករប្រើប្រាស់ទឹក | ✓ | | ខ | ខ |
| | | -ការស្រោចស្រពខ្វះខ្វាយមិនត្រូវតាមបច្ចេកទេស | -ណែនាំកសិករអោយដឹងរបៀបស្រោចស្រពនិងសន្សំសំចៃទឹក | | | ម | ម |
| មានអណ្តូងទឹកស្អាតសម្រាបប្រើប្រាស់ | -ប្រជាជនដាច់ស្រយាលនៅឆ្ងាយពីប្រភពទឹក | -ខ្វះទឹកស្អាតសម្រាប់ប្រើប្រាស់ | -រៀបចំអភិរក្សទឹកស្អាតដោយជីកស្រះ និងខួងអណ្តូងស្នប់ | ✓ | ខ | ខ | ខ |
| មានអាងស្តុកទឹកសម្រាប់ស្រោចស្រព | -ខ្វះទឹកជួយសង្គ្រោះសំណាបពេលជួបគ្រោះ រាំងស្ងួត | -បឹងត្រពាំង ឬ ស្រះទឹកបាក់ធ្លាយ និងគោគរាក់មិនអាចស្តុកទឹកបាន | -ស្តារបឹងត្រពាំង និងស្រះទឹកឡើងវិញ | ✓ | | ម | ម |
| | | -ដីស្រែកសិករមួយចំនួននៅឆ្ងាយពីប្រភពទឹកមិនអាចនាំទឹកទៅស្រោចស្រពបាន | -ត្រូវជីក រឺស្តារអាងទឹកសម្រាប់ស្តុកទឹក ជួយសង្គ្រោះពេលជួបគ្រោះរាំងស្ងួត | | | ខ | ខ |
| មានប៉ុស្តិ៍វាស់កម្ពស់ទឹកភ្លៀងគ្រប់ស្រុក ទូទាំងខេត្ត | -មិនមានរបាយការណ៍ទឹកភ្លៀងតាមបណ្តាស្រុ | -ប៉ុស្តិ៍តំរង់ទឹកភ្លៀងបានខូចអស់ | -ជួសជុលប៉ុស្តិ៍តំរង់ទឹកភ្លៀងឡើងវិញ | ✓ | | ម | ម |
| | -តាមបណ្តាលស្រុកមិនការទទួលខុសត្រូវច្បាសលាស់ | -ភ្នាក់ងារប៉ុស្តិ៍ពុំមានប្រាក់ឧបត្ថម្ភ | -រៀបចំភ្នាក់ងារប៉ុស្តិ៍ឡើងវិញ | | | ខ | ខ |

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| មានប៉ុស្តិ៍តាមដានកម្ពស់ទឹកជំនន់ តាម ដងស្ទឹងសែន | -មិនមានរបាយការណ៍តាមដានកម្ពស់ទឹក តាម ដងស្ទឹងសែន | -មិនមានប៉ុស្តិ៍វាស់កម្ពស់ទឹកជំនន់ នៅតាម ដងស្ទឹងសែន | -ដាក់ប៉ុស្តិ៍វាស់កម្ពស់ទឹកតាមដងស្ទឹងសែន | ✓ | | ខ | ខ |
| សំណង់ធារាសាស្ត្រ | | | - សាងសង់ទ្វារទឹក | | ម | | ម |
| | | | -សាងសង់ទំនប់បង្ហៀរ | | ម | | ម |
| **ប្រៃសនីយ និងទូរគមនាគមន៍** | | | | | | | |
| -សេវាទូរស័ព្ទគ្របដណ្តប់ ទូទាំងខេត្ត សេវាអ៊ីនធឺណេត | ជំនាញមានកំរិតទាប | -ដំបន់ដាច់ស្រយ៉ាលមានប្រជាជនតិច | -ជំរុញអោយក្រុមហ៊ុន ឯកជនចូលមកវិនិយោគ ដល់មូលដ្ឋាន | | | ម | ម |
| | ជំនាញមានកំរិតទាប | -ខ្វះការអប់រំផ្សព្វផ្សាយ | -អប់រំផ្សព្វផ្សាយតាមសាលារៀននានា | | | ម | ម |
| ប្រព័ន្ធកាប្លិអុបទិកនិងកាប្លិអាកាស | មិនទាន់បានស្ថាបនាដល់ជនបទ | -កំរិតជំនាញទាប | -ជំរុញអោយក្រុមហ៊ុនឯកជនស្ថាបនាដល់ជនបទ | | | ម | ម |
| -សេវាចែកចាយបញ្ញើ ទូទាំងខេត្ត | -ការចែកចាយ បញ្ញើ នៅមានកំរិតទាប | -ខ្វះបុគ្គលិក | -ផ្តល់បន្ថែមមន្ត្រី | | | ខ | ខ |
| | | -ខ្វះមធ្យោបាយ | -ផ្តល់មធ្យោបាយ | | | ម | ម |
| | | - ខ្វះទីតាំងសាខា | -ផ្តល់ទីតាំងបង្កើតសាខាតាមស្រុក និង ឃុំ | | | ខ | ខ |
| **ជលផល** | | | | | | | |
| វារីវប្បកម្ម (ចិញ្ចឹមត្រីជាលក្ខណៈ គ្រួសារ) | • ទឹកស្រះពុំមានគ្រប់គ្រាន់ពេញមួយឆ្នាំ | • រដូវកាលភ្លៀងពុំទៀងទាត់ | • ជីកស្រះឱ្យធំ និងជ្រៅ | | | ម | ម |
| | • ខ្វះប្រភពចំណីត្រី | • ទឹកស្រះពុំមានគ្រប់គ្រាន់ពេញមួយឆ្នាំ | • ស្វែងរកប្រភពជំនួយ (ថវិការ សំភារៈនិង បច្ចេកទេស) | | | ខ | ខ |

| វិស័យ និងសកម្មភាព | បញ្ហា | មូលហេតុ | ដំណោះស្រាយ | តម្រូវការយេនឌ័រ | អាទិភាព | | |
|---|---|---|---|---|---|---|---|
| | | | | | ស្រុក | ខេត្ត | មធ្យម |
| | • ខ្វះបច្ចេកទេសចិញ្ចឹម | • ខ្វះប្រភពចំណីត្រី | • គម្រោងគាំទ្រថវិការពី ឃុំ-ស្រុក,អង្គការ | ✓ | | ខ | ខ |
